**ផលលាបំផ្លាញការបង្កើតថ្មី ឈ្មោះថាបំផ្លាញខ្លួនឯង និងសង្គមជាតិ**

មត្រា ២៧ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស "មនុស្សគ្រប់រូបមានសិទ្ធិចូលរួមដោយសេរីក្នុងសកម្មភាពសិល្បៈ និងវិទ្យាសាស្ត្រ ហើយមានសិទ្ធិទទួលបាននូវគោភផលពីការរីកចំរើននៃផ្នែកទាំងនោះ ដែលខ្លួនបានបង្កើតឡើង ហើយមានសិទ្ធិទទួលកិច្ចការពារផលប្រយោជន៍ទាំងឡាយដែលកើតចេញពីផលិតកម្មខាងវិទ្យាសាស្ត្រ វប្បធមិ សិល្បៈ និងអក្សរសាស្ត្រ ដែលខ្លួនជាអ្នកបង្កើត"។

# សេចក្តីផ្តើមសិក្សាពីនីតិព្រហ្មទណ្ឌ

**នីតិព្រហ្មទណ្ឌ**ជាសាខាមួយនៃនីតិដែលសិក្សាពីការកំណត់បទល្មើស ការស្វែងរកជនល្មើស ការស្វែងរកពិរុទ្ធភាព ឬភាពស្លូតត្រង់របស់ជនល្មើស ការចោទប្រកាន់ ការជំនុំជម្រះ ការប្រកាសទោស និងការអនុវត្តទោស ជាដើម។ និយាយក្នុងន័យចង្អៀត នីតិព្រហ្មទណ្ឌជាសារវ័ន្តនៃវិធានគតិយុត្តដែលកំណត់ពីទណ្ឌកម្ម។ តែបើនិយាយក្នុងន័យទូលាយ នីតិព្រហ្មទណ្ឌបានដល់បណ្តុំនៃបទដ្ឋានគតិយុត្តដែលចែងពីការបង្ក្រាបបទល្មើសដោយរដ្ឋអំណាច។

យោងតាមស្មារតីនេះ គេសន្និដ្ឋានថា**នីតិព្រហ្មទណ្ឌ** ឬនិយាយឱ្យចំ*ច្បាប់ព្រហ្មទណ្ឌ* ជាសាខានៃនីតិដែលរឹត បន្តឹងសិទ្ធិសេរីភាពពលរដ្ឋ ឬសេរីភាពបុគ្គល រហូតពេលខ្លះឈានទៅដល់ការដកហូតសិទ្ធិសេរីភាពមួយចំនួន(ទោសដាក់ពន្ធនាគារ)ទៀតផង ព្រោះនីតិព្រហ្មទណ្ឌស្តែងឡើងជាព្រំដែននៃសិទ្ធិ។ នីតិព្រហ្មទណ្ឌមានចរិតបង្ក្រាប ហើយ ការដាក់ទោសនេះបង្ហាញពីប្រតិកម្មរបស់សង្គមចំពោះអំពើឈ្លានពានមិនសមហេតុផល និងគ្មានវិចារណញាណ។ ដូចនេះ នីតិព្រហ្មទណ្ឌបង្កើតបទល្មើស និងដាក់ទណ្ឌកម្មចំពោះអាកប្បកិរិយាទាំងឡាយណាដែលបង្កចលាចលដល់ការរស់នៅជាសង្គម និងប៉ះពាល់ដល់តំលៃសង្គមដែលត្រូវបានការពារ។ តាមន័យនេះ សង្គមបង្កើតបទល្មើសឡើង ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខ ផ្តន្ទាទោសដល់ជនល្មើស និងធ្វើការហាមឃាត់ជនដទៃ ដែលបំរុងនឹងបង្កការអុកឡុកសង្គម ឱ្យបញ្ឈប់ការសម្រេចចិត្តប្រព្រឹត្តបទល្មើសរបស់ខ្លួនជាបន្ទាន់។

មូលហេតុដែលនាំឱ្យគេបង្កើតនីតិនេះឡើង គឺ

**១**.*សកម្មភាពខ្លះរបស់មនុស្ស*ក្នុងការប្រើសេរីភាព ច្រើនតែហួស ព្រំដែន ហើយជួនកាលសកម្មភាពនេះធ្វើឡើងដោយបំពានទាំងកំរោល លើសិទ្ធិអ្នកដទៃដោយ ចេតនាដែលអំពើនេះ មិនត្រឹមតែធ្វើឱ្យខូចប្រយោជន៍អ្នកដទៃដែលជាជនរងគ្រោះនោះទេ តែថែមទាំងបង្កភាពចលាចល់ដល់សង្គមទៀតផង។

**២**.ការដកហូតធនធានមនុស្សចេញពីសង្គមធ្វើឱ្យសង្គមបាត់បង់ធនធាននោះក៏មែនពិតហើយ តែជាបដិភាគ វាផ្តល់មកវិញនូវភាពសុខស្ងប់ជូនសង្គម។ ការដកហូតសេរីបុគ្គលនេះ បណ្តាលពីការធ្វេសប្រហែសមួយពេលរបស់ជនល្មើស ប៉ុណ្ណោះ ទើបគេត្រូវដាក់គាត់ឱ្យថ្លឹងថ្លែងពីកំហុសនេះ នៅក្នុងពន្ធនាគារមួយរយៈទើបដោះលែងឱ្យមករួមរស់ក្នុងសង្គមវិញ។ យោងតាមការពិចារណា វិភាគ និងថ្លឹងថ្លែងនេះហើយ ទើបគេនាំគ្នាបង្កើតច្បាប់ព្រហ្មទណ្ឌ ដោយមតិភាគច្រើនយល់ ស្របគ្នាថាជាការគួរបំផុត។ ការបង្កើតបទល្មើស

ព្រហ្មទណ្ឌដោយច្បាប់នេះ ជាមធ្យោបាយដោះស្រាយតែមួយគត់ដើម្បី ធានារក្សាសន្តិសុខ និងរបៀបរៀបរយសាធារណៈជូនសង្គម។

**ប្រភេទនៃនីតិព្រហ្មទណ្ឌ**-ជាធម្មតា គេបែងចែកនីតិជាពីរប្រភេទ គឺនីតិសាធារណៈ និងនីតិឯក-ជន។ នីតិសាធារណៈនិយាយពីការរៀបចំរដ្ឋនិងស្ថាប័នផ្សេងៗរបស់រដ្ឋ ព្រមទាំងទំនាក់ទំនងរវាងស្ថាប័នរដ្ឋផងគ្នា និងជាមួយពលរដ្ឋ។ រីឯនីតិឯកជន និយាយពីការរៀបចំ និងគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលឯកជនផងគ្នា។ តើនីតិព្រហ្មទណ្ឌ ស្ថិតក្នុងផ្នែកណា? ពេលមានបទល្មើសកើតឡើង គេឃើញមានអន្តរាគមន៍ពីរដ្ឋដែលជាហេតុនាំឱ្យគេថានីតិព្រហ្មទណ្ឌ ស្ថិតក្នុងសាខានៃនីតិសាធារណៈ។ តែក្នុងរឿងព្រហ្មទណ្ឌ គេឃើញមានទំនាក់ទំនងមួយទៀត រវាងជនល្មើស និងជនរងគ្រោះដែលជនរងគ្រោះក៏មានប្រយោជន៍ឱ្យមានការផ្តន្ទាទោសជនល្មើស និងទាមទារឱ្យជួសជុលការខូតខាត ដែលកើតចេញពីបទល្មើស។ គេសង្កេតឃើញថានីតិព្រហ្មទណ្ឌជានីតិចម្រុះ។

**សាខានៃនីតិព្រហ្មទណ្ឌ** : នីតិព្រហ្មទណ្ឌត្រូវបានគេបែងចែកជា ៤ មុខវិជ្ជាធំៗ

-នីតិព្រហ្មទណ្ឌទូទៅៈ សិក្សាពីគោលការណ៍ យន្តការណ៍ និងវិធានទូទៅដែលអនុវត្តទៅលើគ្រប់ចង្កោមនៃនីតិព្រហ្មទណ្ឌ។ វាជាគ្រឹះនៃនីតិព្រហ្មទណ្ឌ ដែលជាកម្មវត្ថុដែលត្រូវលើកយកមកការសិក្សានៅទីនេះ។

-នីតិព្រហ្មទណ្ឌពិសេស : សិក្សាពីបទល្មើសនីមួយៗដោយឈ្វេចឱ្យឃើញពីធាតុផ្សំនៃបទល្មើសនីមួយៗ។ ធាតុផ្សំនេះត្រូវបានគេផ្តោត និងលំអិតជាពិសេស ព្រោះនីតិនេះមានកម្មវត្ថុសិក្សាតែបទល្មើសមួយៗប៉ុណ្ណោះ។

-នីតិវិធីព្រហ្មទណ្ឌ : សិក្សាពីវិធានទាំងឡាយដែលមានគោលដៅស្វែងរកការពិត និងការគោរពសេរីភាពបុគ្គល។ ការសិក្សាផ្តោតទៅលើ*ការស្វែងរកជនល្មើស ការចោទប្រកាន់ និងការជំនុំជម្រះ*។ នីតិវិធី-ព្រហ្មទណ្ឌជា ឧបករណ៍ សម្រាប់អនុវត្តច្បាប់ព្រហ្មទណ្ឌ(ច្បាប់សារធាតុ)ដែលកំណត់បទល្មើស ទោសអនុវត្ត និងការអនុវត្តទោស។

-នីតិព្រហ្មទណ្ឌអន្តរជាតិ ជាសាខាថ្មីមួយដែលគេកំណត់យក តែមិនទាន់ចាត់ជានីតិពេញលេញនៅឡើយ។ បទល្មើសឆ្លងដែន បទល្មើសមានលក្ខណៈជាអន្តរជាតិ កិច្ចសហការជាអន្តរជាតិដើម្បីបង្ការនិងទប់ស្កាត់ ព្រមទាំងការបង្ក្រាបអំពើភេរវកម្ម ការជួញដូរគ្រឿងញៀន ការរត់ពន្ធមនុស្ស ការធ្វើបត្យាប័នជាដើម ជាកម្មវត្ថុសិក្សានៃនីតិនេះ។ នៅសម័យសាកលភាវូបនីយកម្ម ប្រទេសនានាបានចងភ្ជាប់ខ្លួនទៅនឹងរដ្ឋដទៃផងគ្នា ក្នុងវត្ថុបំណងសហការគ្នាស្ទើរលើគ្រប់វិស័យ ដូចជាវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌នយោបាយ ជាដើម ដើម្បីពង្រឹងនិងពង្រីកការដោះដូរផ្នែកសេដ្ឋកិច្ច ដោយឈានទៅរដ្ឋការបើក ចំហជើងមេឃ តាមរយៈនយោបាយឆ្លងកាត់ព្រំដែនដោយគ្មានរបាំងពន្ធគយ(មិនយកពន្ធនាំចូល-នាំចេញ)។ សាកល-

ភាវូបនីយកម្មនេះ នាំឱ្យមានលំហូរទំនិញ លំហូមនុស្ស និងសិទ្ធិតាំងគ្រឹះស្ថានរបស់ក្រុមហ៊ុននៅប្រទេសដែលអនុគ្រោះដល់កត្តាផលិត ដោយតំលៃពលកម្មថោក និងកត្តាអនុគ្រោះផ្សេងៗទៀត។ ទន្ទឹមនឹងលំហូរមនុស្ស សាកលភាវូបនីយកម្ម ក៏បើកឱកាស និងជួយសម្រួលដល់ឧក្រិដ្ឋជនក្នុងការឆ្លងដែនពីប្រទេសមួយទៅប្រទេសមួយទៀត ដែលកត្តានេះនាំឱ្យមានការលំបាកក្នុងការបង្ការទប់ស្កាត់ បង្ក្រាបបទល្មើស ដោយសារតែអធិតេយ្យនៃរដ្ឋនីមួយៗ រារាំងការស្វែងរក ការតាមចាប់ខ្លួន និងបញ្ជូនខ្លួនមកទទួលការកាត់ទោស។ បើរដ្ឋនីមួយៗនៅតែបែបនេះ ការបង្ការ និងបង្ក្រាបបទល្មើសពិតជាមិនអាចប្រព្រឹត្តទៅបានទេ ហើយឧក្រិដ្ឋជននៅក្រៅច្បាប់ជានិច្ច ដែលជំរុញលើកទឹកចិត្តឱ្យមានឧក្រិដ្ឋឆ្លងដែន ដោយឧក្រិដ្ឋជនមិនខ្លាចនរណា។

នៅក្រោយថ្ងៃទី ១១ កញ្ញា ២០០១ (អំពើភេរវកម្ម ដោយយន្តហោះបុកកំទេចអគារពាណិជ្ជកម្មពិភពលោករបស់សហរដ្ឋអាមេរិក) ការពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បានក្លាយជាក្តីបារម្ភ សម្រាប់ពិភពលោកទាំងមូល ជាពិសេសកិច្ចសហប្រតិបត្តិជាអន្តរជាតិមួយត្រូវតែមាន ក្នុងការទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែន។ មហាសន្និអង្គការសហប្រជាជាតិ បានតម្រូវឱ្យប្រទេសនីមួយៗមានច្បាប់រៀងៗខ្លួន ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ហើយត្រូវសហការគ្នាក្នុងការបង្ក្រាបអំពើនេះ។ ជាលទ្ធផលប្រទេសនីមួយៗបានសម្រេចថាអំពើភេរវកម្ម ជាបទល្មើសដែលអាចធ្វើបត្យាប័នបានជានិច្ច។ ដោយឈរលើស្មារតីនេះផងដែរ រដ្ឋនីមួយៗបានស្រុះស្រួលគ្នាបង្កើតជាសន្ធិសញ្ញា លើវិស័យព្រហ្មទណ្ឌផ្សេងទៀត ដែលតម្រូវឱ្យរដ្ឋភាគីនីមួយៗនូវកាតព្វកិច្ចសហការក្នុងការស្វែងរក តាមចាប់ និងបញ្ជូនខ្លួនឧក្រិដ្ឋជនដែលបានរត់គេចខ្លួនចេញពីទីកន្លែងប្រព្រឹត្តបទល្មើស ហើយទៅជ្រកកោននៅឯបរទេស បញ្ជូនទៅកាន់ប្រទេសដែលបទល្មើស ត្រូវបានប្រព្រឹត្តវិញ។ សន្ធិសញ្ញាបែបនេះ ត្រូវបានគេស្គាល់ ថាជាសន្ធិសញ្ញា "បត្យាប័ន"។ បត្យាប័នមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

ក្រៅពីនេះ នីតិព្រហ្មទណ្ឌ មានមុខវិជ្ជាសំខាន់ៗជាសេនាធិការ ក៏ដូចជាជំនួយការចាំបាច់មិនអាចខ្វះបានក្នុង ដំណើរស្វែងរកជនល្មើស ការដាក់ឱ្យទណ្ឌកម្មបំពេញអានុភាពហាមឃាត់ការប្រព្រឹត្តបទល្មើសដែលគេគួរចេះដឹង :

-**ឧក្រិដ្ឋវិទ្យា** : វិទ្យាសាស្ត្រសិក្សាពីមូលហេតុ ឬកាលៈទេសៈដែលជាប្រភពជំរុញឱ្យមនុស្សប្រព្រឹត្តបទល្មើស និងស្វែងរកដំណោះស្រាយ ដើម្បីកាត់បន្ថយបទល្មើស និងដើម្បីជាមូលដ្ឋានក្នុងការអនុវត្តនយោបាយព្រហ្មទណ្ឌ

-**ទណ្ឌវិទ្យា** : សិក្សាពីវិធីសាស្ត្រដាក់ទណ្ឌកម្មឱ្យសមាមាត្រនឹងកំហុស ដើម្បីអប់រំកែប្រែ ជាពិសេសគឺសិក្សា ពីវិធានការនៃការអនុវត្តទោស ក្នុងទិសដៅកំណត់ជំរើស និងដំណោះស្រាយផ្នែកព្រហ្មទណ្ឌដែលមានប្រសិទ្ធភាពខ្ពស់ ជាងគេដើម្បីសម្រេចគោលដៅហាមឃាត់ ធ្វើឱ្យខ្លាចរអារ និងអប់រំកែប្រែ។

**-ឧក្រិដ្ឋវិទ្យា** : បណ្ដុំនៃវិទ្យាសាស្ត្រចូលរួមចំណែកស្វែងរកបទល្មើស កំណត់កាលៈទេសៈពិប្រាកដនៃបទល្មើស និងស្រាវជ្រាវរកមុខឧក្រិដ្ឋជន។

**-ចិត្តវិជ្ជា**: ការសិក្សាខាងចិត្តសាស្ត្រអាចផ្ដល់បទពិចារណា និងការយល់ដឹងបានល្អិតល្អន់លើចរិត និងបុគ្គលិកលក្ខណៈរបស់បុគ្គល ដើម្បីបង្កលក្ខណៈងាយស្រួលដល់ចៅក្រមក្នុងការវាយតំលៃលើការទទួលខុសត្រូវព្រហ្មទណ្ឌ និងការពិចារណាក្នុងការកំណត់ទណ្ឌកម្មសមស្របចំពោះជនល្មើស។ មុខវិជ្ជានេះ ក៏ត្រូវបានគេយកទៅអនុវត្តផងដែរ ក្នុងវត្ថុបំណងជួយសម្រួលផ្នែកផ្លូវចិត្តជនរងគ្រោះ(មាត្រា ៩៦ ក៏និយាយផងដែរអំពីការណ៍នេះ)។

**-សង្គមវិជ្ជា** : មុខវិជ្ជានេះ មានទំនាក់ទំនងយ៉ាងជិតស្និតបំផុតនឹងនីតិព្រហ្មទណ្ឌ ដោយហេតុ ថា មុខវិជ្ជានេះ មានកម្មវត្ថុសិក្សាអំពីមនុស្ស និងសង្គម ជាពិសេសបាតុភូតសង្គម ដែលនៅក្នុងបាតុភូតសង្គមខ្លះត្រូវបានច្បាប់កំណត់ ថាជាបទល្មើស។

**-នយោបាយព្រហ្មទណ្ឌ** ជាដើម : នយោបាយព្រហ្មទណ្ឌ បានដល់វិធីសាស្ត្រនានាដែលសង្គមរៀបចំដើម្បីឆ្លើយតបទៅនឹងបាតុភូតឧក្រិដ្ឋកម្ម។ ក្នុងន័យនេះ នីតិព្រហ្មទណ្ឌជារូបភាពមួយនៃនយោបាយព្រហ្មទណ្ឌ ហើយនយោបាយព្រហ្មទណ្ឌប្រើនីតិព្រហ្មទណ្ឌជាឧបករណ៍ តែមិនមែនកំណត់ពីបទល្មើសតាមផ្លូវច្បាប់ទេ តែដឹកនាំ និងចង្អុលបង្ហាញអំពីជម្រើសនៃនីតិកម្ម។ នយោបាយនេះ ក៏ត្រូវបាននីតិករខ្មែរយកមកប្រើប្រាស់ ក្នុងក្រមព្រហ្មទណ្ឌផងដែរ ត្រង់មាត្រា ៤៥៤ មាត្រា ៥០០ មាត្រា ៥៣៩ មាត្រា ៥៤៥ មាត្រា ៥៧៤ និង មាត្រា ៦៥២ ចំពោះជនល្មើសណាដែលទទួលសារភាព និងបញ្ឈប់ការប្រព្រឹត្តបទល្មើសនៅមុនពេលមានការចោទប្រកាន់ខ្លួន ហើយបែរមកសហការជាមួយសមត្ថកិច្ចក្នុងការបង្ក្រាប និងបង្ការបទល្មើសដែលសហចារី អ្នកសមគំនិត និងអ្នកផ្ដើមគំនិត ដទៃទៀតអាចប្រព្រឹត្តបទល្មើស ហើយឈានទៅរកការចាប់ខ្លួនជនល្មើសផ្សេងទៀត ត្រូវបានលើកលែងឱ្យរួចផុតពី ការផ្ដន្ទាទោស។ ករណីនេះ កើតមានចំពោះបទល្មើសសំខាន់ៗ និងពិបាកក្នុងការបង្ក្រាប ហើយក៏ជាក្ដីបារម្ភទាក់ទងនឹង ប្រសិទ្ធភាពក្នុងការស្វែងរកបង្ការ និងក្នុងការបង្ក្រាបបទល្មើស។ ជម្រើសនីតិកម្មនេះ ទទួលផលប្រយោជន៍ពីរយ៉ាង គឺលើកទឹកចិត្តឧក្រិដ្ឋជនឱ្យសម្រេចចិត្តបញ្ឈប់ការប្រព្រឹត្តបទល្មើស ហើយសហការជាមួយសមត្ថកិច្ច ក្នុងការបង្ក្រាប និងបង្ការបទល្មើស បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ហើយជូនកាលនៅមុនពេលមានបទល្មើសកើតឡើង។ នេះក៏ជាមធ្យោបាយមួយដ៏ល្អផងដែរ។

**ប្រភពនៃនីតិព្រហ្មទណ្ឌ** មានប្រភពជាតិ និងប្រភពអន្តរជាតិ។

-ប្រភពអន្តរជាតិ រួមមានជាអាទិ៍ កាតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ ១៩៦៦ និងសេចក្ដី ថ្លែងការណ៍ជាសាកលស្ដីពីសិទ្ធិមនុស្សជាដើម។

-ប្រភពជាតិ រួមមានរដ្ឋធម្មនុញ្ញ(មាត្រា ៣២ មាត្រា ៣៨ មាត្រា ៤០ មាត្រា ៤៤ និងមាត្រា ៤៦) ច្បាប់ព្រហ្មទណ្ឌ(ច្បាប់ព្រហ្មទណ្ឌនៅរាយប៉ាយ និងក្រមព្រហ្មទណ្ឌ) និងបទដ្ឋានក្រោមច្បាប់(នៅខ្សត់ខ្សោយ នៅឡើយ)។

យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ "... ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ជនណាម្នាក់នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់..."។ មាត្រា ៣១ ទទួលស្គាល់អនុសញ្ញាអន្តរជាតិទាក់ទងនឹង សិទ្ធិមនុស្ស ក្នុងនោះមានកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រង់មាត្រា ១៥(គោលការណ៍ នីត្យានុកូលនៃបទល្មើស និងនៃទោស) ចែងថា "គ្មានជនណាម្នាក់ត្រូវជាប់ទោសពីបទល្មើសព្រហ្មទណ្ឌឡើយ ចំពោះអំពើ ឬការធ្វេសប្រហែសណាមួយដែលពុំមែនជាបទល្មើសព្រហ្មទណ្ឌដែលមាននៅក្រោមច្បាប់ជាតិ ឬអន្តរជាតិ ខណៈពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត។ ហើយក៏មិនត្រូវមានការដាក់ទោសណាមួយឱ្យធ្ងន់ជាងទោសដែលផ្តន្ទាលនៅពេល ដែលពីបទល្មើសព្រហ្មទណ្ឌនោះត្រូវបានប្រព្រឹត្តឡើយ។ ប្រសិនបើក្រោយពីការប្រព្រឹត្តបទល្មើស ហើយច្បាប់បានបញ្ញត្តឱ្យមានការដាក់ទោសស្រាលជាងមុន ជនល្មើសត្រូវទទួលប្រយោជន៍នោះ"។ លើសពីនេះ រដ្ឋធម្មនុញ្ញបានដាក់កំហិតឱ្យសភាទទួលបន្ទុកបង្កើតបទល្មើស កំណត់ទោស និងការអនុវត្តទោស(ដោយគោរព និងសម្រេចឱ្យបាននូវគោលការណ៍ *គ្មានបទល្មើស ទោសគ្មានទោស ប្រសិនបើគ្មានច្បាប់ចែង*) គោរពគោលការណ៍អនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា តាក់តែងច្បាប់ព្រហ្មទណ្ឌឱ្យបានល្អិតល្អន់ និងពេញលេញ ដើម្បីជៀសវាងការប្រព្រឹត្តតាមទំនើងចិត្តចៅក្រម។ ឈរលើស្មារតីនេះ ក្រមព្រហ្មទណ្ឌ[9] ត្រូវបានតាក់តែង ហើយចាប់ពី ពេលចូលជាធរមាន និងចូលអនុវត្ត ក្រមព្រហ្មទណ្ឌក្លាយជាប្រភពដ៏សំខាន់នៃការបង្កើត និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ។ ក្រមនេះ អាចចាត់ទុកជាក្រមដ៏ទាន់សម័យ មួយ ដោយសារតែក្រមនេះទទួលស្គាល់ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ការកំណត់អំពីប្រភេទនៃទោស ដែលចៅក្រមអាចបត់បែនតាមកាលៈទេសៈ។ ក្រមនេះរួមមាន ៦ គន្ថី(គន្ថីទី ១ បទប្បញ្ញត្តិទូទៅ គន្ថីទី ២ បទល្មើស ប្រឆាំងនឹងមនុស្ស គន្ថីទី ៣ បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ គន្ថីទី ៤ បទល្មើសប្រឆាំងនឹងជាតិ គន្ថីទី ៥ អន្តរប្បញ្ញត្តិ និងគន្ថីទី ៦ អវសានប្បញ្ញត្តិ) និង ៦៧២មាត្រា ដែលជាការចងក្រងអត្ថបទដែលមានចរិតបង្ក្រាបឱ្យនៅមួយដុំ ក្នុងគោលដៅងាយស្រួយក្នុងការអនុវត្ត ការសិក្សាស្រាវជ្រាវ និងការស្វែងយល់ប្រព័ន្ធបង្ក្រាបរបស់កម្ពុជា។ លើសពីនេះ គេអាចរកឃើញក្នុងក្រមនេះនូវ អ្វីដែលមិនធ្លាប់មានពីមុនមកក្នុងប្រវត្តិសាស្ត្រច្បាប់ខ្មែរ :

-កំណត់គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ (បទល្មើសព្រហ្មទណ្ឌជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ស្ថានទម្ងន់ និងស្ថានសម្រាលទោស ....)

-កំណត់បញ្ជាក់ពីការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា និងក្នុងលំហ

-មូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

[9] ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ វិច្ឆិកា ២០០៩ ត្រូវបានគេស្គាល់ថា ជាក្រមព្រហ្មទណ្ឌឆ្នាំ ២០១០។

-ទោសបន្ថែម ទោសជំនួស ការស្តីបន្ទោស

-របបនៃការអនុវត្តទោស(ការព្យួរទោស របបពាក់កណ្តាលសេរីភាព ការបែងចែកទោសជាប្រភាគ ការបូកទោស ត្រួតទោស និងការស្រូបទោស)ដែលអនុញ្ញាតឱ្យចៅក្រមអាចបត់បែន និងអាចសម្របតាមស្ថានភាពជាក់ស្តែងនីមួយៗ

-(...)។

គួរកត់សំគាល់ផងដែរ ថាបើតាមការពិនិត្យ វិភាគ និងពិចារណាលើអត្ថបទច្បាប់ជាធរមាន និងលែងជាធរមានរបស់កម្ពុជា បង្ហាញឱ្យឃើញថានីតិករនិយមចូលចិត្តប្រើប្រាស់ទណ្ឌកម្មព្រហ្មទណ្ឌជាឧបករណ៍ធានាប្រសិទ្ធភាពអនុវត្តច្បាប់ទាំងនោះ ដោយហេតុនេះហើយ ទើបបានជាច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌនៅរាយប៉ាយស្ទើរតែគ្រប់ច្បាប់ទាំងអស់។ សំណួរគឺតើទណ្ឌកម្មផ្សេងទៀត ដូចជាទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មរដ្ឋប្បវេណី មិនគ្រប់គ្រាន់ទេឬ ?

នៅទីនេះ យើងលើកយកតែនីតិព្រហ្មទណ្ឌទូទៅមកសិក្សា។ នីតិព្រហ្មទណ្ឌទូទៅ ច្បាមយកការសិក្សាមួយដែល ផ្តោតលើការ*បង្កើតបទល្មើស ការចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងការកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ*។ ដូច្នេះ យើងនឹងសិក្សាពីការបង្កើត បទល្មើស (ជំពូកទី ១) ការទទួលខុសត្រូវព្រហ្មទណ្ឌ (ជំពូកទី ២) និងទោសដែលអនុវត្ត (ជំពូកទី ៣) ជាបន្តបន្ទាប់គ្នា ។

***<u>សំណួរត្រិះរិះ</u>*** តើច្បាប់ព្រហ្មទណ្ឌមានលក្ខណៈវិនិច្ឆ័យបែបណា ? តើសំអាងលើអ្វីបានជាហ៊ានថាក្រមព្រហ្មទណ្ឌឆ្នាំ ២០១០ ជាក្រមមួយដ៏ទំនើប ? ហេតុអ្វីត្រូវសិក្សានីតិព្រហ្មទណ្ឌ ? តើសង្គមមួយខ្វះច្បាប់ព្រហ្មទណ្ឌបានដែរឬទេ ? អ្វីទៅជាបត្យាប័ន ? បត្យាប័នមានប្រយោជន៍អ្វីខ្លះ ?

☼***<u>បញ្ជាក់</u>*** *: រាល់មាត្រាក្នុងអត្ថបទនិងក្នុងកំណត់យោងនៃអត្ថបទនេះទាំងមូលគឺជាមាត្រានៃក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ ២០១០ របស់កម្ពុជា លើកលែងតែមានការចង្អុលប្រាប់ផ្សេងពីនេះ ។*

“ព្រះធម៌មិនស្តាប់ច្បាប់មិនអាន ចេះចាំនឹងមានមកពីណា
ខ្លួនឯងមិនស្វែងជោគវាសនា សង្ឃឹមទេវតាណាគេអាណិត ។”

ដោយឧបាសក អ៊ឹង កាន



# ជំពូកទី ១ ច្បាប់ព្រហ្មទណ្ឌ និងការបង្កើតបទល្មើសព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវ បានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងបែបបទនៃការអនុវត្តទោសនេះ។ មានតែច្បាប់ទេដែលមានសមត្ថកិច្ចបង្កើតបទល្មើស តែក្នុងករណីចាំបាច់បទបញ្ញារដ្ឋាភិបាលអាចបង្កើតបទល្មើសបាន តែដែនសមត្ថកិច្ចត្រូវកម្រិតត្រឹមបទលហុ ដែលអាចពិន័យជាប្រាក់ប៉ុណ្ណោះ(មាត្រា ១)។ តាមន័យនេះ ច្បាប់ព្រហ្មទណ្ឌរាប់បញ្ចូលទាំងបទបញ្ញារដ្ឋាភិបាលដែលកំណត់បទលហុ(ទោសពិន័យជាប្រាក់)ផងដែរ។

ច្បាប់ព្រហ្មទណ្ឌមានចរិតជាប្រព័ន្ធបង្ក្រាប ហើយបើយើងក្រឡេកមើលក្នុងធម្មនិយាមមួយទៀតនៃប្រព័ន្ធនីតិ គឺការហាមឃាត់ជនដទៃកុំឱ្យឈានទៅប្រព្រឹត្តបទល្មើស តាមរយៈការដាក់ទណ្ឌកម្ម។ និយាយជារួម ច្បាប់ព្រហ្មទណ្ឌធ្វើការគ្រើនរំលឹកដោយភ្ជាប់ជាមួយទណ្ឌកម្មកុំឱ្យប្រព្រឹត្តអំពើបង្កចលាចលដល់សង្គម។ និយាយម្យ៉ាងទៀត ការបង្កើតបទល្មើសដោយច្បាប់ព្រហ្មទណ្ឌអាចជួយ និងអនុញ្ញាតឱ្យប្រជាជនយល់ដឹងរឹតតែច្បាស់អំពីសិទ្ធិ និងព្រំដែននៃការអនុវត្តសិទ្ធិរបស់ខ្លួន ជាពិសេសយល់ដឹងអំពីអំពើដែលត្រូវបានហាមឃាត់ និងផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏ការប្រព្រឹត្តបទល្មើសនៅតែបន្តកើតមានជាហូរហែរ ព្រោះតែការគិតខុស ឬធ្វេសប្រហែសមួយពេលដ៏ខ្លីប៉ុណ្ណោះ។ ប្រការនេះ ធ្វើឱ្យមានការតាំងសំណួរថាតើច្បាប់ព្រហ្មទណ្ឌ មានវត្តលុបបំបាត់បទល្មើស ឬយ៉ាងណា ? បទពិសោធបណ្តាប្រទេសជឿនលឿនហាក់ប្រាប់យើងថា បទល្មើសគ្រាន់តែថយចុះ មិនអាចសង្គមមួយគ្មានបទល្មើសទេ។

ការសម្របសម្រួលការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល និងក្នុងដែនដីក៏ជាចំណុចមួយដ៏សំខាន់ណាស់ដែរ។

គោលដៅនៃច្បាប់ព្រហ្មទណ្ឌ គឺរក្សាសណ្តាប់ធ្នាប់សាធារណៈ និងបង្ក្រាបការប៉ះពាល់ដល់សណ្តាប់ធ្នាប់នេះ។ និយាយក្នុងន័យទូលំទូលាយ ច្បាប់ព្រហ្មទណ្ឌមានចរិតនិងគោលដៅចម្បងបម្រើឱ្យប្រយោជន៍សាធារណៈ តាមរយៈការធានារក្សាការពារសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម សិទ្ធិនិងសេរីភាពបុគ្គល សេចក្តីថ្លៃថ្នូរ និងភាពសុខស្ងប់ ជូនប្រជាពលរដ្ឋ ដែលពេលខ្លះតម្រូវឱ្យដកហូតសេរីភាពខ្លះ និងសិទ្ធិខ្លះ។

***សំណួរត្រិះរិះ*** **:** ច្បាប់ព្រហ្មទណ្ឌ ត្រូវបានបង្កើតឡើងដើម្បីលុបបំបាត់បទល្មើស ? ហេតុអ្វីបានជាមានតែច្បាប់ទេទើបមានសមត្ថកិច្ចបង្កើតបទល្មើស ? ហេតុអ្វីបានជាបទបញ្ញារដ្ឋាភិបាលមិនអាចបង្កើតបទលហុខាងទោសដាក់ពន្ធនាគារ ? ហេតុអ្វីបានជាហ៊ានអះអាងថាច្បាប់ព្រហ្មទណ្ឌស្តែងឡើងក្រោមរូបភាពជាព្រំដែននៃសិទ្ធិ ?

# ផ្នែកទី ១ បទល្មើសព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌមានកម្មវត្ថុចម្បងបង្កើតបទល្មើស និងកំណត់ទោសដែលត្រូវវង។ ច្បាប់បញ្ញត្តថា **អំពើខ្លះ**របស់ *រូបវន្តបុគ្គល* ឬ*នីតិបុគ្គល*ដែលបង្កចលាចលដល់សង្គមជាបទល្មើស។ ពាក្យថា "អំពើខ្លះ" នេះ បញ្ជាក់ថា បើគ្មានច្បាប់ចែងជាមុនទេ នោះអំពើណាក៏ដោយទោះបានបង្កចលាចលដល់សង្គម ក៏មិនមែនជាបទល្មើសដែរ។ ដើម្បីឱ្យអំពើមួយជា បទល្មើស ដរាបណាមានការកំណត់ជាមុននូវអាកប្បកិរិយាណាខ្លះ ត្រូវចាត់ទុកជាអំពើល្មើសច្បាប់ដែលត្រូវទទួលរង ទណ្ឌកម្ម និងទោសដែលត្រូវអនុវត្ត "*គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង*"[២] (គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងនៃទោស)។ ធ្វើយ៉ាងនេះ ដើម្បីចៀសវាងការបង្ក្រាបនិងផ្តន្ទាទោសតាមអំពើចិត្ត(ការផ្តន្ទាទោសធ្វើ ឡើងតាមឆន្ទានុសិទ្ធិចៅក្រម) បណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិ និងសេរីភាពជាមូលដ្ឋាន ព្រមទាំងឈានទៅរកការបំបិទសេរីភាពទាំងស្រុង។ ហេតុនេះ ទើបតម្រូវឱ្យមានការកំណត់ជាមុន ឱ្យបានជាក់លាក់ និងច្បាស់លាស់ថា អំពើណាជាបទល្មើស(ត្រូវហាមឃាត់ការប្រព្រឹត្ត) អំពើណាមិនមែនជាបទល្មើស(មិនហាមឃាត់ការប្រព្រឹត្តដែលជា សេរីភាពក្នុងការប្រព្រឹត្ត)។ នៅពេលដែលអំពើមួយបានបង្កភាពចលាចលដល់សង្គម គេត្រូវពិនិត្យថាតើអំពើនោះជា បទល្មើសដែរ ឬទេ ដើម្បីចាត់ការបន្តតាមរយៈបណ្តឹងអាជ្ញាដែលធ្វើឡើងក្នុងគោលបំណងទាមទារ ឱ្យតុលាការព្រហ្មទណ្ឌអនុវត្តទោសដែលបានព្រាងទុកជាមុននោះប្រឆាំងនឹងជនល្មើស។

ដើម្បីឱ្យអំពើបង្កចលាចលដល់សង្គមជាបទល្មើស កាលណាអំពើនោះត្រូវបានច្បាប់ផ្តន្ទាទោស។ មានតែច្បាប់ចែង គឺមិនគ្រប់គ្រាន់ទេ ព្រោះពេលខ្លះជនល្មើសគ្មានចេតនាប្រព្រឹត្តបទល្មើសទេ។ ហេតុនេះ បានជាគេតម្រូវឱ្យមាន ធាតុផ្សំទាំងបីព្រមគ្នា បើបាត់តែណាមួយក៏មិនអាចបង្កើតបានជាបទល្មើសទេ។

**បទល្មើសព្រហ្មទណ្ឌ និងសញ្ញាណប្រហាក់ប្រហែល..**គេមិនត្រូវភ័ន្តច្រឡំបទល្មើសព្រហ្មទណ្ឌជាមួយនឹងអំពើអនីត្យានុកូលនោះទេ។ អំពើអនីត្យានុកូលក៏ជាអំពើខុសច្បាប់(បើពោលឱ្យចំគឺអំពើបំពានច្បាប់) ដែរ តែទោសដែលរងខុសគ្នា។ បទល្មើសព្រហ្មទណ្ឌ អាចរងទោសដកហូតសិទ្ធិ និងសេរីដើរហើរ ព្រមទាំងទ្រព្យសម្បត្តិ ក្នុងគោលដៅរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ និងភាពសុខស្ងប់ជូនសមាជិកសង្គមទាំងមូល ។ ការផ្តន្ទាទោសមានគោលដៅពីរយ៉ាង គឺទី ១ ការពារសង្គម និងជនរងគ្រោះពីគ្រោះថ្នាក់ ផ្នែកទ្រព្យសម្បត្តិ និងផ្នែកបូរណភាពរូបរាងកាយ ពេលនោះការផ្តន្ទាទោសគិតគូរពីសង្គម និងទី ២ ដាក់ឱ្យទណ្ឌកម្មបំពេញនាទីជាការអប់រំកែប្រែស្តានីតិសម្បទាជនល្មើសដើម្បីចូលមករួមរស់ក្នុងសង្គមវិញ ពេលនោះការផ្តន្ទាទោសគិតគូរពីជនល្មើស។

[២] ប្រែសម្រួលចេញពីភាសាឡាតាំង : *Nullem crimen, nulla poena, sine lege.*

ចំណែកអំពើអនីត្យានុកូលវិញអាចត្រូវបានដកហូតត្រឹមតែទ្រព្យសម្បត្តិប៉ុណ្ណោះ ក្នុងគោលដៅជួស-ជុលព្យសនកម្មដែល ជនរងគ្រោះបានទទួលរង(គិតគូរតែជនរងគ្រោះ)។

**សំណួរត្រិះរិះ:** ជាធម្មតា នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ តើធ្វើយ៉ាងណាទើបគេអាចញែកបទល្មើសព្រហ្មទណ្ឌ ចេញពីទោសកម្មរដ្ឋប្បវេណី និងសេរីភាពដទៃទៀត ? តើគេអាចនិយាយថាធាតុផ្សំនៃបទល្មើសមានតែពីរបានដែរឬ បើច្បាប់ព្រហ្មទណ្ឌមិនអាចក្លាយ ឬចូលរួមក្នុងនាមជាអ្នកប្រព្រឹត្តបទល្មើស? តើលោក Cesar Beccaria មានទស្សនៈយ៉ាងណាដែរ ចំពោះគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងនៃទោស ?

## កថាខណ្ឌទី ១ ធាតុផ្សំនីត្យានុកូលនៃបទល្មើស

ធាតុផ្សំនីត្យានុកូល សំដៅយកអត្ថបទច្បាប់ដែលបញ្ញត្តអំពើណាដែលចាត់ជាបទល្មើស និងកំណត់អំពីទោសដែលត្រូវទទួលរង។ ក្នុងស្មារតីនៃការកំណត់បទល្មើស ច្បាប់គ្រាន់តែជាធាតុបឋមតែប៉ុណ្ណោះ(ច្បាប់មិនបានចូលរួមប្រព្រឹត្តបទល្មើសជាមួយជនរងគ្រោះទេ)។ មានន័យថាបើគ្មានច្បាប់ នោះក៏គ្មានទោស ហើយការប្រព្រឹត្តអំពើផ្សេងៗ ទោះជាមានឆន្ទះក្តី ទោះដោយការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជារក្តី ក៏ពុំអាចទទួលរងទោសបានដែរ។ ធាតុផ្សំនីត្យានុកូលធ្វើឱ្យមាននីត្យានុកូលភាពនៃបទល្មើស និងនៃទោស ដូចមានចែងក្នុង មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ "មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន"។ មាត្រា ៣ នេះ កំណត់អំពីគោលការណ៍នីត្យានុកូលភាពនៃច្បាប់ព្រហ្មទណ្ឌ។ គោលការណ៍នីត្យានុកូលភាពនេះ បង្កើត វិបាកជាច្រើនដែលយើងនឹងលើកមកសិក្សានៅខាងក្រោមនេះ។

### ក.-គោលការណ៍នីត្យានុកូលនៃបទល្មើស និងនៃទោស

គេគួរតែយល់ដឹងអំពីអត្ថន័យ ក៏ដូចជាបច្ច័យនៃគោលការណ៍នេះ និងនីត្យានុកូលភាពនៃបទប្បញ្ញត្តិព្រហ្មទណ្ឌ។

១-អត្ថន័យនៃគោលការណ៍

គោលការណ៍នេះ ធានាសិទ្ធិ និងសេរីភាពពលរដ្ឋក្នុងសង្គមលទ្ធិប្រជាធិបតេយ្យ។ គោលការណ៍នេះមាន គោលដៅធានាការពារប្រជាពលរដ្ឋ ប្រឆាំងនឹងការរំលោភអំណាចពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ឬចៅក្រម។ យោងតាមគោលការណ៍នេះ អំពើរបស់ជនណាម្នាក់នឹងអាចចាត់ទុកជាបទល្មើសដែលត្រូវ

ផ្តន្ទាទោសបាន ដរាបណាអំពើនោះមានចែងកំណត់ និងផ្តន្ទាទោសទុកជាមុនក្នុងច្បាប់ព្រហ្មទណ្ឌ។ ដូចនេះ ចៅក្រមមិនអាចធ្វើការផ្តន្ទាទោស ផ្នែកព្រហ្មទណ្ឌចំពោះជនណាម្នាក់ ចំពោះអំពើណាមួយដែលជននោះបានប្រព្រឹត្តឡើយ ប្រសិនបើច្បាប់មិនបានចែង កំណត់ទុកជាមុនថាអំពើនោះ ជាអំពើល្មើសដែលត្រូវផ្តន្ទាទោស ដោយទោសណាមួយនោះទេ។

ករណីដូចជាបទប្បញ្ញត្តិនៃមាត្រា ៧៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩ មាត្រា ៦០ និងមាត្រា ៦៨ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ព្រមទាំងមាត្រា ៤៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ជាដើមដែលច្បាប់ ចែងកំណត់បទល្មើស តែច្បាប់នោះមិនបានកំណត់ទោសដែលទទួលរងទេ។ ដោយសារតែបទប្បញ្ញត្តិទាំងនេះ មានតែនីត្យានុកូលភាពនៃបទល្មើស គ្មាននីត្យានុកូលភាពនៃទោស ចៅក្រមមិនអាចផ្តន្ទាទោសជនល្មើស ដោយទោសណាមួយបានទេ។

ជាបច្ច័យនៃគោលការណ៍នេះគឺ ការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង។

### ២-បច្ច័យនៃគោលការណ៍ : ច្បាប់ព្រហ្មទណ្ឌត្រូវបកស្រាយយ៉ាងតឹងរ៉ឹង

យោងតាមមាត្រា ៥ "ច្បាប់ព្រហ្មទណ្ឌត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាច**ពង្រីកវិសាល-ភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាព**បានឡើយ"។

-ចៅក្រមមានតួនាទីត្រឹមតែជាអ្នកអនុវត្តច្បាប់[៣] មិនអាចបង្កើតបទល្មើស និងទោសដែលច្បាប់ មិនបានកំណត់។ ការបកស្រាយច្បាប់ព្រហ្មទណ្ឌតាមសទិសភាព និងការពង្រីកដែនអនុវត្តត្រូវហាមឃាត់។

-មិនមានន័យថាមិនឱ្យចៅក្រមបកស្រាយច្បាប់ទេ ចៅក្រមអាចបកស្រាយក្នុងគោលដៅ អនុវតច្បាប់ ដូចជា "អំពើលួចជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោល បំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន"(មាត្រា ៣៥៣)។ ភាពស្រពិចស្រពិលមួយអាចកើតមានចំពោះសញ្ញាណ "*ទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀត*" សំណួរសួរថាថាមពលអគ្គីសនី ប្រព័ន្ធទូរស័ព្ទ ប្រព័ន្ធខ្សែកាបទូរទស្សន៍ ... ជាទ្រព្យសម្បត្តិដែរ ឬទេ ? សេចក្តីបំភ្លឺលើសញ្ញាណ"ទ្រព្យសម្បត្តិ" ដែលមានចែងក្នុងមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ថ្ងៃទី ១០ កញ្ញា ១៩៩២ ត្រូវបានធ្វើដោយតុលាការកំពូល[៤] ថាទ្រព្យសម្បត្តិក្នុងន័យនៃមាត្រានេះ បានដល់ *ចលនវត្ថុ* ដែល*មានរូបរាង* និង*អាចផ្លាស់ទីបាន*។ ហេតុនេះ

[៣] លោក Montesquieu ជនជាតិ (Français, 1689-1755) បានលើកឡើងថា ចៅក្រមគ្រាន់តែជាមាត់មួយរបស់ច្បាប់ ហើយមិនអាចបន្ថែម ឬបន្ថយអំណាច ឬ តឹងរ៉ឹងជាងច្បាប់ទេ « Les juges ne sont que la bouche qui prononce les paroles de la loi, des êtres inaminés qui n'en peuvent modérer ni la force ni la rigueur ».

[៤] សាលដីកាតុលាការកំពូលលេខ ៧៨ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៥ "ប្រព័ន្ធទូរសព្ទពុំមែនជាចលនទ្រព្យមានរូបរាង អាចចាប់កាន់បាន ឬអាចផ្លាស់ទីកន្លែងបានដែលជាធាតុផ្សំនៃបទល្មើសចោរកម្មតាមមាត្រា ៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី ១០-០៩-១៩៩២ ឡើយ"។

ការប្រើប្រាស់ប្រព័ន្ធទូរសព្ទ័ដោយមិនបង់កំរៃ មិនមែនជាបទលួចទេ(មិនមែនពង្រីកដែនអនុវត្ត ចំពោះអំពើដែលច្បាប់មិនបានបញ្ញត្តិទេ តែគ្រាន់តែបកស្រាយអ្វីដែលស្ថិតក្នុង ដែនអនុវត្តប៉ុណ្ណោះ)។

ក្រៅពីនេះ ចៅក្រមត្រូវពិនិត្យមើលថាតើមាន ឬមិនមានអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។

**សំណួរត្រិះរិះ:** បើច្បាប់កំណត់តែបទល្មើស ហើយមិនបានកំណត់អំពីទោស ករណីដូចមានមាត្រា ៧៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩ តើចៅក្រមអាចផ្តន្ទាទោសបានដែរ ឬទេ ? ហេតុអ្វី ?

តើគេអាចនិយាយបែបណាចំពោះសាលដីការបស់តុលាការកំពូលលេខ ៧៨ ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៥ ពាក់ព័ន្ធនឹងការបកស្រាយច្បាប់ព្រហ្មទណ្ឌយ៉ាងតឹងរ៉ឹង ?

តើមាត្រា ៣៩៣ នៃក្រមព្រហ្មទណ្ឌ រាប់បញ្ចូលទាំងការលួចវត្ថុអរូបិយដែលគេអាចគ្រប់គ្រងដែរ ឬទេ ?

## ខ.-ការអនុវត្តច្បាប់ព្រហ្មទណ្ឌ

ការអនុវត្តច្បាប់ព្រហ្មទណ្ឌជាការសំដែងប្រតិកម្មរបស់សង្គមឆ្លើយតបទៅនឹងជនល្មើស និងអំពើល្មើសក្នុងគោលដៅធានាឱ្យបាននូវភាពសុខស្ងប់ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈជូនសង្គមទាំងមូល។

### ១-ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ដើម្បីអាចអនុវត្តច្បាប់ព្រហ្មទណ្ឌឱ្យបានត្រឹមត្រូវ ការបកស្រាយឱ្យបានសមស្របនិងត្រឹមត្រូវ ជាដំណាក់កាលមួយមិនអាចខ្វះបាន និងខានមិនបានមុននឹងឈានទៅរកការអនុវត្តច្បាប់ព្រហ្មទណ្ឌ ហេតុនេះចៅក្រមមានកាតព្វកិច្ចផ្ទៀងផ្ទាត់ផ្ទូវផ្ទង់ដោយប្រុងប្រយ័ត្ន និងហ្មតចត់នូវច្បាប់ដែលចង្អុលបទល្មើស អត្ថិភាពនៃទោស និងការត្រួតពិនិត្យរកមើលអានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។ ការដកហូតសិទ្ធិ សេរីភាពបុគ្គលទោះក្នុងរយៈពេលណាមួយជាកំណត់ តម្រូវឱ្យមានភាពច្បាស់លាស់អំពីនីត្យានុកូលភាពនៃបទល្មើស និងនៃទោសដែលត្រូវអនុវត្ត បើពុំនោះទេ ការដកហូតនេះនឹងធ្វើឡើងដោយរំលោភសិទ្ធិសេរីបុគ្គល។

**ការអនុវត្តច្បាប់ព្រហ្មទណ្ឌ.**-"ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង"(មាត្រា ៥)។ មាត្រា នេះចង្អុលប្រាប់ចៅក្រមអ្នកទទួលបន្ទុកអនុវត្តច្បាប់ឱ្យធ្វើការផ្ទៀងផ្ទាត់ និងផ្ទូវផ្ទង់ ដោយហ្មតចត់ និងដោយយកចិត្ត ទុកដាក់រវាងអង្គហេតុនិងអត្ថបទច្បាប់ព្រហ្មទណ្ឌ មុននឹងសម្រេចអនុវត្តច្បាប់ព្រហ្មទណ្ឌទៅនឹងអង្គហេតុ។ ចៅក្រមមិនត្រូវយកច្បាប់មកអនុវត្តទេ ប្រសិនបើច្បាប់ចែងមិនច្បាស់លាស់ (វិមតិសង្ស័យជាប្រយោជន៍ ដល់ជនជាប់ចោទ) ហើយ "ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាម**សទិសភាព**បានឡើយ"(មាត្រា ៥)។ សទិសភាព គឺការប្រដូចអំពើណាមួយដែលច្បាប់មិនបានកំណត់ថាជាបទល្មើស(ឧ.មាត្រា ៣៧៧ ទៅនឹងការអូសទាញឱ្យមាន ទំនាក់ទំនងផ្លូវភេទ-ប្រគល់ខ្លួនឱ្យគេ-ក្រោយមកគេ

បែកបែរ)។ ឯពង្រីកដែនអនុវត្ត សំដៅយកស្ថានភាពដែល ចៅក្រមពង្រីកដែនអនុវត្តច្បាប់ ករណីដូចជា មាត្រា ៣៨៤ *"ស៊ីមាំង"*។

២-ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា

២-១ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

ជាគោលការណ៍ ច្បាប់មួយមានអានុភាពអនុវត្តតែក្នុងពេលអនាគត ពោលគឺចាប់ពីថ្ងៃចូលជាធរ-មាន រហូតដល់ពេលនិរាករណ៍ កែប្រែ ឬជំនួសដោយច្បាប់ថ្មី។ យោងតាមមាត្រា ៩៣ ថ្មី នៃរដ្ឋធម្មនុញ្ញ "ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ។ ត្រូវបានព្រះមហាក្សត្រប្រកាសឱ្យប្រើ ត្រូវចូលជាធរមាន នៅភ្នំពេញរយៈពេល ១០ ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេស រយៈពេល ២០ ថ្ងៃគត់ ក្រោយ ប្រកាសឱ្យប្រើ។ ក៏ប៉ុន្តែ បើច្បាប់នេះបានចែងជាការប្រញាប់ ច្បាប់នេះ ត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ"។

ដូចនេះ ច្បាប់ក្នុងន័យទូទៅ និងច្បាប់ព្រហ្មទណ្ឌជាពិសេសអាចមានអានុភាពអនុវត្តតែទៅលើអំពើទាំងឡាយ ណាដែលកើតក្រោយថ្ងៃចូលជាធរមានរបស់ខ្លួនតែប៉ុណ្ណោះ។ គោលការណ៍នេះ គេឱ្យឈ្មោះថា "គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ"។ គោលការណ៍នេះ ក៏ជាផលវិបាកនៃគោលការណ៍នីត្យា-នុកូលភាពនៃបទល្មើស និងនៃទោសមួយផងដែរ ព្រោះថានៅពេលដែលមិនមានច្បាប់ចែងទេនោះ គឺពុំមានបទល្មើស ហើយក៏ពុំមានការផ្តន្ទាទោសដែរ។ គោលការណ៍នេះ មានគោលដៅដើម្បីការពារសេរីភាពបុគ្គល មានន័យថានៅពេលពុំទាន់មានច្បាប់ហាមឃាត់ទេនោះ បុគ្គលមានសេរីភាពពេញលេញដើម្បីធ្វើសកម្មភាពណាមួយ។ ក៏ប៉ុន្តែ គេក៏សង្កេតឃើញមានអញ្ញត្រកម្មមួយ ចំនួនផងដែរចំពោះគោលការណ៍នេះ។

២-១ អញ្ញត្រកម្ម

អញ្ញត្រកម្ម បានដល់សម្មតិកម្មទាំងឡាយណាដែលក្នុងនោះច្បាប់ព្រហ្មទណ្ឌមួយអាចមានអានុភាពអនុវត្តចំពោះអំពើទាំងឡាយណាដែលបានកើតមុនការចូលជាធរមានរបស់ខ្លួន ឬក្នុងករណីដែលច្បាប់ព្រហ្ម-ទណ្ឌ ត្រូវយកមក អនុវត្តភ្លាមៗ។ ភាពប្រតិសកម្ម ឬភាពត្រូវយកមកអនុវត្តភ្លាមៗនេះ អាស្រ័យទាំងស្រុងថា តើច្បាប់នោះជាច្បាប់សារធាតុ ឬច្បាប់នីតិវិធី។

តាមសេចក្តីសម្រេចលេខ ០៤០/០០២/២០០១ កបធ.ច ចុះថ្ងៃទី ១២ កុម្ភៈ ២០០២ ក្រុមប្រឹក្សាធម្មនុញ្ញ បានសម្រេចថា គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌពុំមានតំលៃស្មើនឹងរដ្ឋធម្មនុញ្ញទេ ព្រោះសភាធម្មនុញ្ញ ពុំបានបញ្ចូលគោលការណ៍នេះទៅក្នុងរដ្ឋធម្មនុញ្ញ ឬទៅក្នុងបុព្វបទនៃរដ្ឋធម្មនុញ្ញទេ។ តើគោលការណ៍ប្រតិសកម្មនេះ មានតំលៃគតិយុត្តជាអ្វី ?

## រ) ប្រតិសកម្មនៃច្បាប់សារធាតុ

-ប្រតិសកម្មនៃច្បាប់សារធាតុស្រាលជាង : គោលការណ៍មិនប្រតិសកម្មអនុវត្តតែក្នុងករណីដែលច្បាប់ថ្មី ផ្តន្ទាទោសធ្ងន់ជាងច្បាប់ចាស់។ តែបើច្បាប់ថ្មីស្រាលជាង ពេលនោះច្បាប់ថ្មីត្រូវយកទៅអនុវត្តភ្លាម។ គេអាចកត់សំគាល់ថាច្បាប់ថ្មីមានលក្ខណៈស្រាលជាងច្បាប់ចាស់ កាលណាច្បាប់ថ្មី:

-កែប្រែបទល្មើសពី បទឧក្រិដ្ឋ ទៅ បទមជ្ឈិម ឬពីបទមជ្ឈិម ទៅ បទលហុ ជាដើម

-ច្បាប់ថ្មីដាក់ទោសស្រាលជាង

-បន្ថយថិរវេលានៃការដាក់ទណ្ឌកម្ម ឬជំនួសទោសគុកដោយទោសពិន័យ

-បន្ថយឬលុបចោលទោសគុក ទោសពិន័យ ឬទោសបន្ថែក្រោមអំណាចច្បាប់ចាស់

-លុបចោលបទល្មើសដែលកំណត់ដោយច្បាប់ចាស់

-បន្ថែមធាតុផ្សំនៃបទល្មើស .....។

ការអនុវត្តភ្លាមនេះ("បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម") អាចធ្វើទៅបាន តែក្នុងករណីដែល ១-សំណុំរឿងនៃបទល្មើសត្រូវបានប្រព្រឹត្តមុនពេលច្បាប់ថ្មីចូលជាធរមាន ២-ពុំទាន់ត្រូវបានតុលាការ សម្រេចផ្តន្ទាទោសតាមអំណាចសាលក្រម ឬសាលដីកាស្ថាពរនៅឡើយ។ និយាយម្យ៉ាងទៀត "ការផ្តន្ទាទោសដែលជាស្ថាពរ ហើយនោះត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។ បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ"(មាត្រា១០)។ ក៏ប៉ុន្តែ "បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូល ជាធរមានមិនអាចត្រូវចោទប្រកាន់ទៀតឡើយ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះត្រូវបញ្ចប់។ ប្រសិនបើការផ្តន្ទាទោសជាស្ថាពរ ត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត" (មាត្រា ៩)។

-ប្រតិសកម្មនៃច្បាប់សារធាតុតាមការបញ្ញត្តិរបស់ច្បាប់ : ក្នុងករណីមួយចំនួន ច្បាប់បានកំណត់អំពីអានុភាព ប្រតិសកម្មនេះតែម្តង។ នេះជាករណីពិសេស កើតក្នុងកាលៈទេសៈពិសេស ហើយកំរកើតមានណាស់ ព្រោះវាប៉ះពាល់ដល់សេរីភាពពលរដ្ឋ។ ប្រការ ១១ នៃក្រឹត្យ-ច្បាប់លេខ ០២ ចុះថ្ងៃទី ១៥-០៥-១៩៨០ ចែងថា "អំពើប្រព្រឹត្តបទល្មើសទាំងឡាយ ដែលកើតមានក្រោយថ្ងៃ ៧ មករា ១៩៧៩ រហូតដល់ ថ្ងៃប្រកាស ក្រឹត្យ-ច្បាប់នេះ ហើយមិនទាន់បានជំនុំជម្រះ ត្រូវចោទប្តឹងទៅតុលាការ និងជំនុំជម្រះតាមក្រឹត្យនេះ" ។ ប្រការ ១២ នៃក្រឹត្យ-ច្បាប់ លេខ ០៤ ចុះថ្ងៃទី ១២-០៨-១៩៨១ ចែងថា "ក្រឹត្យ-ច្បាប់នេះ ត្រូវ អនុវត្តទៅលើបទល្មើសទាំងឡាយដែលបានកើតឡើងតាំងពីថ្ងៃ ៧ មករា ១៩៧៩ ហើយដែលពុំទាន់ដាក់ជំនុំជម្រះនៅឡើយ"។ ការប៉ុនប៉ងត្រូវបានលេច

រួបរាងតាមរយៈច្បាប់ឆ្នាំ ២០០១ ស្តីពី "ការបង្កើតឱ្យមានអង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីជំនុំជម្រះអំពើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ"។ អានុភាពប្រតិសកម្មនេះ ត្រូវកំណត់កំឡុងពេលមួយច្បាស់លាស់។

-ប្រតិសកម្មនៃច្បាប់សារធាតុក្នុងករណីផ្សេងទៀត : ដូចជាបទប្បញ្ញត្តិថ្មីធ្វើការបកស្រាយ បទប្បញ្ញត្តិចាស់ ដោយបទបញ្ញត្តិចាស់មានខ្លឹមសារមិនច្បាស់។ ករណីនេះ កម្រកើតមានណាស់។

ii) ការអនុវត្តភ្លាមៗនៃច្បាប់នីតិវិធី

នៅពេលមានច្បាប់នីតិវិធីថ្មីចូលជាធរមានដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តី ឬដំណើរការរឿងព្រហ្មទណ្ឌ ជាដើម ច្បាប់ប្រភេទនេះ ត្រូវមានអានុភាពអនុវត្តភ្លាម ចំពោះគ្រប់អំពើដែលកើតមុន ហើយមិនទាន់ត្រូវបាន ជំនុំជម្រះតាមអំណាចសេចក្តីសម្រេចស្ថាពរនៅឡើយ គិតចាប់ពីថ្ងៃចូលជាធរមាន។ ប្រការដែលអនុវត្តបែបនេះ ព្រោះច្បាប់ប្រភេទនេះពុំបានធ្វើឱ្យប៉ះពាល់ដល់អត្ថិភាពនៃបទល្មើសឡើយ ហើយជាទូទៅច្បាប់ប្រភេទនេះទៀតសោត គ្រាន់តែមានបំណងស្វែងរកជនល្មើស និងស្វែងរកការពិត ឱ្យបានកាន់តែឆាប់រហ័ស និងកាន់តែមានប្រសិទ្ធភាពប៉ុណ្ណោះ។ ហេតុនេះ ទើបវាមិនបានធ្វើឱ្យប៉ះពាល់ដល់សុពលភាពនៃកិច្ចនីតិវិធីដែលធ្វើឡើង ស្របតាមអំណាចច្បាប់ចាស់ទេ។ "ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មីគ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធី ដែលបានបំពេញស្រប តាមបទប្បញ្ញត្តិចាស់ឡើយ" (មាត្រា ១១)។

***សំណួរត្រិះរិះ*** : ហេតុអ្វីបានជាគេអនុញ្ញាតឱ្យច្បាប់ព្រហ្មទណ្ឌស្រាលជាងមានអានុភាពប្រតិសកម្ម ?
តើមាត្រា ៩ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ ខុសគ្នាយ៉ាងដូចម្តេចខ្លះ ?
ចូរលើកឧទាហរណ៍អំពីករណីច្បាប់ថ្មីដាក់ទោសស្រាលជាង ? តើគេធ្វើយ៉ាងណាទើបដឹងថាច្បាប់ ថ្មីស្រាល ឬធ្ងន់ជាងច្បាប់ចាស់ ?

៣-ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងដែនដី ឬក្នុងលំហ

**គោលការណ៍ដែនដីនៃច្បាប់ព្រហ្មទណ្ឌ**..ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា(មាត្រា ១២)។ បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះបានប្រព្រឹត្ត នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា(មាត្រា ១៣)។ មានន័យថា ច្បាប់ព្រហ្មទណ្ឌខ្មែរត្រូវអនុវត្តចំពោះជនគ្រប់រូប ទោះជាជននោះមានសញ្ជាតិជាអ្វី ឬគ្មានសញ្ជាតិដែលប្រព្រឹត្ត

បានបទល្មើសនៅលើទឹកដីខ្មែរ លើកលែងតែមានកិច្ចព្រមព្រៀងអន្តរជាតិកំណត់ផ្សេងពីនេះដែលកម្ពុជាជាសមាជិក ក្នុងនោះរួមមានសន្ធិសញ្ញាទីក្រុងវីយែន ចុះថ្ងៃទី ១៨_មេសា_១៩៦១ និងចុះថ្ងៃ ទី ២៤_មេសា_១៩៦៣ ស្តីពីទំនាក់ទំនងការទូត និងកុងស៊ុល និងករណីពិសេសមួយចំនួនទៀតដែលមានចែងក្នុងលក្ខន្តិកៈនៃទីក្រុងរ៉ូម ចុះថ្ងៃទី ១៧_កក្កដា_១៩៩៨ ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ[៥] (ផជ) ជាដើម ដែលអង្គទូតពុំស្ថិតនៅក្រោមយុត្តាធិការរបស់រដ្ឋម្ចាស់ផ្ទះទេ ជាដើម។ នេះជាគោលការណ៍ដែនដីនៃច្បាប់។

**បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា**..ច្បាប់កម្ពុជា ត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែល ប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជា បានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃ កិច្ចព្រមព្រៀងអន្តរជាតិ ។

**បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា**..ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតសនៅទីណាក៏ដោយ។

ច្បាប់កម្ពុជា ក៏ត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរដូចខាងក្រោមនេះ ត្រូវបានបំពេញ :

_បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង

_អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់ តុលាការបរទេស ។

**សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក**..ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១_បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា។

២_បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា។

៣_បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤_បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។

៥_បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។

**_អញ្ញត្រកម្មនៃគោលការណ៍ដែនដីនៃច្បាប់ព្រហ្មទណ្ឌ**

[៥] ច្បាប់ស្តីពីការអនុម័តយល់ព្រមលើលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ចុះថ្ងៃទី ៧-០១-២០០២ រាជកិច្ចខែមករា ២០០២ ទំព័រ ៧៥។

ច្បាប់កម្ពុជា ត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្នុង ប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។ បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ។

ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

## គ.-ការត្រួតពិនិត្យមើលនីត្យានុកូលភាពនៃច្បាប់ព្រហ្មទណ្ឌ

អត្ថបទច្បាប់ដែលបង្កើតបទល្មើសព្រហ្មទណ្ឌ និងកំណត់ទោសអនុវត្តចំពោះបទល្មើសនោះ ត្រូវតែស្របនឹងឋានានុក្រមថ្នាក់លើ បើពុំដូច្នោះទេ វានឹងត្រូវប្រកាសមោឃភាព មានន័យថាមិនត្រូវយកមកអនុវត្តទេ[៦]។ នេះគេយកតាមទ្រឹស្តីឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត បង្កើតឡើងដោយលោក Hans Kelsen ជនជាតិអូទ្រីស្ត[៧]។

នៅកម្ពុជា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ នៅមុនពេល និងក្រោយពេលប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ ហើយអត្ថបទច្បាប់ណា ឬបទប្បញ្ញត្តិនៃច្បាប់ណាដែលត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ ប្រកាសអធម្មនុញ្ញភាពគ្មានអានុភាពអនុវត្តទេ។ ចំណែកឯការប្រកាសពីភាពស្របច្បាប់នៃបទដ្ឋានគតិយុត្តក្រោមច្បាប់ ជាសមត្ថកិច្ចរបស់តុលាការ តាមការទាមទាររបស់ភាគីណាមួយដែលបាត់បង់ផលប្រយោជន៍ដោយសារអត្ថបទដែល ផ្ទុយនឹងច្បាប់នោះ។ ក៏ប៉ុន្តែករណីនេះកម្រកើតមានណាស់ បើកើតមានក៏ចៅក្រមក៏ហាក់មិនអើពើប៉ុន្មានដែរ[៨]។

**ស្ទឹងដែលស្ងប់បំផុត គឺស្ទឹងដែលជ្រៅបំផុត ។**

[៦] ចំពោះករណីនេះ សូមអាន សៀវភៅ *សេចក្តីផ្តើមនីតិកម្ពុជា* បោះពុម្ពដោយហ្វូណន ឆ្នាំ ២០០៥។

[៧] Hans Kelsen, *Théorie pure de droit*, LGDJ 1960.ទស្សនវិជ្ជានេះមានឥទ្ធិពលយ៉ាងសំខាន់នៅក្នុងទស្សនវិជ្ជាផ្នែកច្បាប់ និងក្នុងនីតិសាធារណៈ ហើយបានពង្រឹងបាតុភូតនៃលំដាប់ឋានានុក្រមគតិយុត្ត។

[៨] ចំពោះនីតិវិធីប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ : សៀវភៅវិធីសាស្ត្រគតិយុត្ត-នីតិកម្ពុជា រោងពុម្ពហ្វូណន ភ្នំពេញ ២០០៦ ទំ. ១០០ និងសៀវភៅសេចក្តីផ្តើមនីតិកម្ពុជា រោងពុម្ពហ្វូណន ភ្នំពេញ ២០០៥ ព្រមទាំងសៀវភៅ នីតិរដ្ឋធម្មនុញ្ញកម្ពុជា រោងពុម្ពហ្វូណន ភ្នំពេញ ២០០៥ ទំ. ២១៥។

## កថាខណ្ឌទី ២ ធាតុផ្សំសត្យានុម័ត ឬសម្ភារៈនៃបទល្មើស

ធាតុផ្សំសត្យានុម័តនៃបទល្មើស សំដៅយកអត្ថិភាពខាងក្រៅនៃបទល្មើសដែលគេអាចពិនិត្យឃើញជាក់ស្តែង តាមរយៈអំពើ ឬសកម្មភាពរបស់ជនល្មើស។ ដើម្បីឱ្យបទល្មើសមួយកើតឡើង អាប្បកិរិយាត្រូវស្តែងឡើងមកខាងក្រៅ។ ពោលគឺការដាក់ចេញនូវសេចក្តីសម្រេចចិត្តប្រព្រឹត្តបទល្មើស ឱ្យមានចលនាតាមរយៈសកម្មភាពផ្សេងៗ សំដៅធ្វើឱ្យសម្រេចគំនិតនេះ។ និយាយម្យ៉ាងទៀត អំពើសម្ភារៈជាការសំដែងចេញមកខាងក្រៅជាអំពើ ឬសកម្មភាព មួយឬច្រើន ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់សង្គម ធ្វើឱ្យប៉ះពាល់ ដល់សន្តិសុខ និងសេចក្តីសុខសាន្តក្នុងសង្គម ឬធ្វើឱ្យ ខូចសណ្តាប់ធ្នាប់សាធារណៈ។ ធាតុផ្សំសម្ភារៈនេះ ជាចំណងដែល ភ្ជាប់អំពើល្មើសទៅព្យសនកម្ម។ ជាទូទៅ គេចាត់ទុកអំពើសម្ភារៈនេះ **ជាអង្គនៃបទល្មើស** ហើយបើគ្មានអង្គសម្ភារៈ នេះទេ នោះក៏ពុំមានបទល្មើសដែរ។

ដើម្បីងាយយល់ យើងសូមធ្វើការសិក្សាធាតុផ្សំនេះនៅក្នុងបទល្មើស ០២ ផ្សេងគ្នា។

### ក.-ធាតុផ្សំសម្ភារៈនៅក្នុងបទល្មើសបានសម្រេច

អំពើសម្ភារៈអាចស្តែងឡើងក្រោមរូបភាពសកម្ម ឬអកម្ម។

១-បទល្មើសសកម្ម និងបញ្ហានៃបទល្មើសសកម្មប្រព្រឹត្តក្រោមរូបភាពអកម្ម

អំពើសម្ភារៈសកម្ម បានដល់ទំរង់នៃអំពើដែលស្តែងមកខាងក្រៅជាកាយវិការ ឬសកម្មភាពវិជ្ជមានមួយ ឬ ច្រើនដែលបង្កចលាចលដល់សង្គម។

ជាគោលការណ៍ដើម្បីឱ្យដឹងថាបទល្មើសមួយសកម្មឬអកម្ម អាស្រ័យលើច្បាប់បញ្ញត្ត។ ចំពោះបទល្មើសសម្ភារៈសកម្ម យើងត្រូវរកឱ្យឃើញនូវចំណងហេតុនិងផលរវាងអំពើនិងព្យសនកម្ម។ ពេលខ្លះព្យសនកម្មនេះដើរ តួនាទីសំខាន់ណាស់ក្នុងការកំណត់បទល្មើស។ ព្យសនកម្មត្រូវតែមាន (នៅក្នុងបទល្មើសបានសម្រេច) ប៉ុន្តែ ពេលខ្លះព្យសនកម្មមិនបានកើតមានពិតប្រាកដទេ ដោយហេតុថាមានកាលៈទេសៈខាងក្រៅដែលរំខាន ឬរារាំងជនល្មើស ក្នុងការសម្រេចគោលដៅ។

ក្នុងករណីខ្លះច្បាប់ផ្តន្ទាទោសអំពើមួយចំនួនដែលមិនបានបង្កព្យសនកម្មអ្វីទាំងអស់ តែត្រូវផ្តន្ទាទោសក្នុង ទិសដៅការពារសណ្តាប់ធ្នាប់សាធារណៈ និងបង្ការការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬគ្រោះថ្នាក់ដល់សង្គម។ ឧ.ការបើកបរបញ្ច្រាសទិស បើកបរមិនគោរពភ្លើងសញ្ញាចរាចរ ហួសល្បឿនកំណត់ឬការបើកបរដោយស្រវឹងស្រា....

លើសពីនេះ ចំណោទបញ្ហាស្ថិតត្រង់ សម្មតិកម្មនៃបទល្មើស "សកម្មប្រព្រឹត្តក្រោមទំរង់អកម្ម"។ និយាយម្យ៉ាងទៀតថា តើមានករណីបទល្មើសសកម្ម ប្រព្រឹត្តក្រោមទំរង់អកម្មដែរឬទេ ?

-លោក "ក" ឃើញ លោក"ខ" ដែលជាសត្រូវលង់ទឹក មិនបានជួយ ប៉ុន្តែគាត់ក៏មិនចង់ឱ្យគាត់ស្លាប់ដែរ។

-ជនម្នាក់ដោយការធ្វេសប្រហែស បានចោលកន្ទុយបារីនៅក្បែរគំនរស្លឹកឈើងាប់ជាប់ជញ្ជាំងផ្ទះលោក"ខ"។ លោក "ក" ដែលមិនចូលចិត្តម្ចាស់ផ្ទះនោះ ក៏មិនអើពើពន្លត់ភ្លើងដែលគាត់ពិតជាអាចធ្វើបាន។ តើក្នុងករណីនេះ លោក "ក" អាចត្រូវចាត់ទុកជាអ្នកបង្កអគ្គីភ័យដែរឬទេ?

-លោក "ក" រើសបានកាបូបប្រាក់នៅតុ ហើយបានប្រគល់វាឱ្យលោក "ខ" ដោយស្មានថាលោក "ខ" ជាម្ចាស់ ហើយលោក "ខ" ដែលមិនមែនជាម្ចាស់ក៏ទទួលទុកដោយមិនបានប្រាប់លោក "ក" ថាគាត់មិនមែនជាម្ចាស់កាបូប ប្រាក់ទេ។ តើលោក "ក" អាចត្រូវបានចាត់ទុកថាប្រព្រឹត្តអំពើចោរកម្មដែរ ឬទេ?

២-បទល្មើសអកម្ម

បទល្មើសកើតដោយច្បាប់ដាក់កាតព្វកិច្ចវិជ្ជមានឱ្យធ្វើ តែជនល្មើសខកខានមិនបានបំពេញ :

-ច្បាប់តម្រូវឱ្យធ្វើអ្វីមួយ =កាតព្វកិច្ចធ្វើ ឬកាតព្វកិច្ចវិជ្ជមាន

-ជនល្មើសមិនបានបំពេញកាតព្វកិច្ចខាងលើ=មិនបំពេញ(មិនព្រមទៅចុះសំបុត្រកំណើតកូន មិនប្តឹងបរិហារ បទល្មើស មិនព្រមជួយសង្គ្រោះមនុស្សដែលជួបប្រទះគ្រោះថ្នាក់ដល់អាយុជីវិត)។

## ខ.-ធាតុផ្សំសម្ភារៈនៅក្នុងបទល្មើសមិនបានសម្រេច

-ដំណាក់កាលប្រព្រឹត្តបទល្មើស រួមមាន :

*១-ការគិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស* : ការគិតជាសកម្មភាពមួយរបស់ចិត្ត ដែលមិនស្តែងចេញមកខាងក្រៅទេ។ ការគិតឬគំនិតក៏ពុំមានភាពជាក់លាក់ណាមួយទេ ពោលគឺមានការផ្លាស់ប្តូរមិនទៀងទាត់។ នៅពេលជនណាម្នាក់សម្រេចចិត្តប្រព្រឹត្តបទល្មើស ជននោះនៅតែអាចផ្លាស់ប្តូរវិញបានភ្លាមៗដែរ។ នេះជាមូលហេតុដែលគេ មិន អាចផ្តន្ទាទោសគំនិត ជាពិសេសការសម្រេចចិត្តប្រព្រឹត្តបទល្មើស។

*២-ការត្រៀមរៀបចំ ឬត្រៀមបំរុងប្រព្រឹត្តបទល្មើស* ស្ថិតនៅឆ្ងាយពីការបង្កចលាចលដល់សង្គម។ នៅក្នុងសកម្មភាពរៀបចំ ឬត្រៀមបំរុង ជនល្មើសនៅតែអាចបញ្ឈប់សកម្មភាពរៀបចំ ឬនិងការសម្រេចចិត្តប្រព្រឹត្តបទល្មើស។ ដំណាក់រៀបចំពុំត្រូវបានច្បាប់កំណត់ថាមានទោស លើកលែងតែមានបទល្មើសផ្សេងទៀតត្រូវបានប្រព្រឹត្ត ដូចជាការកាន់កាប់អាវុធខុសច្បាប់ ជាដើម។

*៣-ការចាប់ផ្ដើមប្រព្រឹត្ត ឬអនុវត្តបទល្មើស* : ជនល្មើសកំពុងតែធ្វើសកម្មភាពដឹកនាំឆ្ពោះទៅដោយផ្ទាល់ទៅរកព្យសនកម្ម មានន័យថាជនល្មើសកំពុងតែធ្វើសកម្មភាពដើម្បីធ្វើឱ្យសម្រេចនូវគោលបំណងរបស់ខ្លួន។ ហេតុនេះ ទើបច្បាប់ព្រហ្មទណ្ឌសម្រេចផ្ដន្ទាទោស ចាប់ពីដំណាក់កាលនៃការចាប់ផ្ដើមនេះ។ ក៏ប៉ុន្តែ ជនល្មើសមិនសុទ្ធតែអាចទទួលលទ្ធផលដូច ការរំពឹងទុករបស់ខ្លួននោះទេ។ បើសម្រេច វាជាបទល្មើសបានសម្រេច បើមិនទេ វាជាបទល្មើសមិនបានសម្រេច ដែល និយមហៅថា "ការប៉ុនប៉ងប្រព្រឹត្តបទល្មើស"។

*៤-ការសម្រេចបទល្មើស* : ជនល្មើសសម្រេចគោលដៅខ្លួន។

-ការប៉ុនប៉ង : ករណីពិសេសនៃបទល្មើសប៉ុនប៉ង ដូចជាបទល្មើសដែលមិនអាចសម្រេចបាន (Théorie de l'infraction impossible) និងបទល្មើសដែលខ្វះកម្មវត្ថុ(Théorie de l'infraction manquée)។ ក្នុងប្រភេទបទល្មើសប៉ុនប៉ងនេះ ធាតុផ្សំមានគ្រប់គ្រាន់ ព្រោះជនល្មើសបានអាក់ខានការសម្រេចបទល្មើស មកពីកត្តាខាងក្រៅ។

គួររំលឹកថាការប៉ុនប៉ងអាចផ្ដន្ទាទោសបាន លុះត្រាតែ មានការចាប់ផ្ដើមប្រព្រឹត្តបទល្មើស និងការបញ្ឈប់សកម្មភាពទៅវិញដោយអចេតនា(មាត្រា ២៧) ។ យោងតាមមាត្រា ២៧ នេះ ជាពិសេសសញ្ញាណនៃការអនុវត្តបទល្មើសត្រូវបានកំណត់ជាទូទៅថា រាល់អំពើទាំងឡាយណាដែលឆ្ពោះទៅដោយផ្ទាល់ ហើយអាចបង្កគ្រោះថ្នាក់ភ្លាមៗ ឬក្នុងរយៈពេលដ៏ខ្លី ដល់ទ្រព្យសម្បត្តិ មនុស្ស ឬមុខសញ្ញានៃបទល្មើសដ៏ទៀត។ ជាឧទាហរណ៍ បទល្មើសលួចលក់អចលវត្ថុរបស់អ្នកដទៃ(មាត្រា ២៥៥ ច្បាប់ភូមិបាល ឆ្នាំ ២០០១) បទល្មើសចាប់ផ្ដើមនៅពេល ដែលជនល្មើស និងអ្នកទិញបានយកកិច្ចសន្យាលក់-ទិញទៅកាត់ឈ្មោះនៅអង្គភាពសុរិយោដី(មាត្រា ៦៩ និងមាត្រា ៦៥ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ដូចគ្នា មាត្រា ១៣៥ នៃ រដ្ឋប្បវេណី ឆ្នាំ ២០០៧) ហើយបានសម្រេចនៅពេល កាត់ឈ្មោះរួចរាល់ក្នុងបញ្ជីសុរិយោដី ។

ការប៉ុនប៉ងប្រព្រឹត្តបទល្មើស ត្រូវផ្ដន្ទាទោសដូចបទល្មើសបានសម្រេចដែរ។ មានមតិខ្លះជំទាស់នឹងការផ្ដន្ទាទោសនេះ ដោយលើកឡើងថាគួរតែផ្ដន្ទាទោសត្រឹមទំហំព្យសនកម្ម មិនគួរដល់ទៅបទល្មើសបានសម្រេចទេ។ មតិមួយទៀតថា ដោយសារតែជនល្មើសមានចេតនា ហើយបានអនុវត្តបទល្មើស ការដែលមិនបានសម្រេចក៏ព្រោះតែកាលៈទេសៈខាងក្រៅចេតនាជនល្មើសប៉ុណ្ណោះ នោះមុខតែជនល្មើសបានទៅដល់គោលដៅ ហើយព្យសនកម្មធំកើតមាន។ ការផ្ដន្ទាទោសនេះ គឺយោងលើសភាពផ្លូវចិត្តរបស់ជនល្មើស និងគ្រោះថ្នាក់នៃអំពើដល់សង្គម។

**គ.-ហេតុបច្ច័យ**

**គោលការណ៍ទូទៅនៃការទទួលខុសត្រូវរួម**.-តាមពិត ច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណី គឺមានលក្ខខណ្ឌរួម ឬដូចគ្នា គឺថាមុននឹងដាក់ឱ្យជនណាម្នាក់ទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ឬបទល្មើស ចៅក្រមត្រូវរកឱ្យឃើញ នូវ :

-*កំហុស* : អំពើ ទោះកើតដោយចេតនា ឬអចេតនា ដែលបំពានកាតព្វកិច្ចអ្វីមួយ[9]។

-*ព្យសនកម្ម* : ការខូចខាតផ្នែកសម្ភារៈ ផ្នែកបូរណភាពរូបរាងកាយ និងផ្នែកផ្លូវចិត្ត(ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីព្រហ្មទណ្ឌ ចាត់បញ្ចូលក្នុងព្យសនកម្មដែលអាចជួសជុលបាន**ព្យសនកម្មផ្លូវចិត្ត**-Mental Harm or Moral damages)។ ព្យសនកម្ម ក្នុងរឿងព្រហ្មទណ្ឌ មានន័យទូលំទូលាយជាងនេះ ហើយត្រូវបានច្បាប់ព្រហ្មទណ្ឌកម្រិតយ៉ាងជាក់ច្បាស់ និងដោយលំអិតជាមុន ដើម្បីដែលជាមូលដ្ឋានក្នុងការកំណត់បទល្មើស។ ចំណែកក្នុងរឿងរដ្ឋប្បវេណី វាជាតួនាទីរបស់ចៅក្រម ព្រោះពុំមានកំណត់ជាលំអិតជាមុនក្នុងច្បាប់ទេ។

-*ហេតុបច្ច័យ* : ទំនាក់ទំនងគ្នារវាង កំហុសដែលជាបុព្វហេតុនាំឱ្យមានព្យសនកម្ម ។ មានន័យថាត្រូវមាន កំហុសជា"ហេតុ" ហើយ "ព្យសនកម្ម" ជាបច្ច័យ។ បើតាមបណ្ឌិត ហ៊ែល ចំរើន ច្បាប់ហេតុផល "គឺជាសំណុំវិធានដែលមានគោលបំណងកំណត់ផលរបស់ហេតុ ឬកំណត់ផលដែលត្រូវនឹងហេតុ ឬកំណត់ចំណងដែលចងភ្ជាប់ហេតុទៅនឹងផលដែលអាចហៅថា "ចំណងហេតុនិងផល" ឬ"ចំណងហេតុផល"[១០]។ ច្បាប់ហេតុផលនេះ មានគោលដៅស្វែងរក ផលដែលត្រូវគ្នានឹងហេតុ សមដូចសុភាសិតខ្មែរបុរាណ "*តម្កក់ទៅ ទើបញ្ញាវាជ្រុះ*" "*មានប្រឡាយ ទើបទឹកថាហូរ*" "*មានសំរាម ទើបផ្កៃវាដុះ*" "*មានភ្លើង ទើបមានផ្សែង*" ជាដើម។ ច្បាប់ហេតុផល ត្រូវបានគេយកមកអនុវត្តក្នុងរឿងព្រហ្មទណ្ឌ និងរឿងរដ្ឋប្បវេណី(ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល)។

**ព្យសនកម្ម និងអំពើនៃជនល្មើស**.-ដោយផ្អែកលើគោលការណ៍សច្ចធារណ៍នៃនិរទោស ឬនៃភាពគ្មានទោស (មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ) ព្រះរាជអាជ្ញាត្រូវបង្ហាញភស្តុតាងមិនត្រឹម តែបទល្មើសដែលច្បាប់កំណត់ប៉ុណ្ណោះទេ តែថែមទាំងត្រូវបង្ហាញចំណងហេតុផល រវាងអំពើទៅរកព្យសនកម្ម ហើយបញ្ចុះបញ្ចូលឱ្យចៅក្រមជឿលើអង្គហេតុ និងការបកស្រាយច្បាប់ ដើម្បីឱ្យមានការដាក់ទោសជនល្មើស។ ដើម្បីងាយយល់យើងសូមលើកជាឧទាហរណ៍ថា កសិករ "ក" បាន លីនង្គ័លតាំងពីព្រលឹងស្រាងៗទៅភ្ជួរស្រែ ដោយអាក់អន់ចិត្តនឹងគោខ្លួន គាត់ក៏បានយកកាំបិតផ្គាក់កាប់គោគាត់ចំនួនមួយកាំបិត ហើយក៏ដើរសំដៅទៅផ្ទះវិញ។ ចៃដន្យដើរកាត់ទីកន្លែងដែលមានមនុស្សទើបតែស្លាប់ប៉ុន្មាននាទី ដោយ ឈាមមិនទាន់កកស្រួលបួល

[9] Maurice Planiol(អ្នកប្រាជ្ញជាតិបារាំង) បានលើកឡើងថា កំហុសជាការបំពានកាតព្វកិច្ចណាមួយ : la faute est un manquement à une obligation pré-existante.

[១០] បណ្ឌិត ហ៊ែល ចំរើន ***មាគ៌ាយុត្តិធម៌ខ្មែរ*** បោះពុម្ពដោយរោងពុម្ពភ្នំពេញ ឆ្នាំ ២០០៩-២០១០ ទំព័រ ៣១៤-៣១៥ ។

ផង។ នគរបាយុត្តិធមីដែលដើរកាត់ផ្លូវនោះ បន្ទាប់ឃើញសាកសព ក៏ឃើញកសិករ "ក" លីកាំបិតដែលមានឈាមមិនទាន់កកស្រួលបួល ក៏ចាប់ខ្លួនយកទៅ។ ទង្វើលីកាំបិតជាប់ឈាម ស៊ីសង្វាក់ទៅនឹងការស្លាប់របស់ជនរងគ្រោះណាស់ នាំឱ្យនគរបាលយុត្តិធមីសន្និដ្ឋានថាពិតជាមានចំណងហេតុផល គឺការកាប់ជនរងគ្រោះនឹងកាំបិត ហើយជនរងគ្រោះស្លាប់នឹងផ្លែកាំបិត។ ប្រសិនបើអ្នកជាមេធាវីការពាររឿងក្តីនេះ តើអ្នកគួរការពារកូនក្តីរបស់អ្នកដោយរបៀបណា បើតាមអង្គហេតុខាងលើ គឺពិតជាគ្មានចំណងហេតុផលទេ គឺគ្មានការកាប់មនុស្សទេ តែពិតជាមានការកាប់ ដោយសារតែមានឈាមជាប់នឹងកាំបិត។

**ការទទួលខុសត្រូវដោយផ្អែកលើទំហំព្យសនកម្ម.**-ជនល្មើសត្រូវបានចាប់បង្ខំឱ្យទទួលខុសត្រូវ ថ្វីបើព្យសនកម្មកើតឡើង ដោយជនល្មើសមិនបានដឹងក៏ដោយ។ ករណីនេះ កើតដោយសារតែស្ថានភាពរបស់ជនរងគ្រោះ។ "ក" បានវាយ "ខ" មួយដៃ ធ្វើឱ្យលោក "ខ" បានស្លាប់ ដោយសារជំងឺ បេះដូង។

**ចេះពីរៀន មានពីរក**

**សៀវភៅជាកាដនឹ់ផ្ទុកនូវខួរក្បាលអ្នកប្រាជ្ញ ដូច្នេះការអានសៀវភៅ**
**មានន័យស្មើនឹងការបញ្ចូលខួរក្បាលអ្នកប្រាជ្ញ មកក្នុងខួរក្បាលយើងដែរ**[១១]។

[១១] ធម្មាចារ្យ **ប៊ុត សាវង្ស** បានពន្យល់យ៉ាងដូច្នេះថា មានតែសៀវភៅទេដែលជាមិត្តដ៏ល្អរបស់យើងតែមួយគ្មានពីរ។ ទោះជាយើងសំដែងអាប្បកិរិយា ឬកពារបែបណាៗក៏មិនដែលចេះខឹង អាក់អន់ចិត្តមករកយើង តែបែរជាផ្តល់ការប្រឹក្សាដ៏ប្រសើរ ហើយផ្តល់នូវដំណោះស្រាយដែលកំពុងស្វែងរកបានទៀតផង។

# កថាខណ្ឌទី ៣ ធាតុផ្សំអន្តោម័តនៃបទល្មើស[១២]

បទល្មើសជាផ្លែផ្ការ ឬលទ្ធផលនៃអំពើសម្ភារៈដែលបានសិក្សារួចមកហើយ។ នៅទីនេះ យើងនឹងសិក្សាពីសភាពផ្លូវចិត្តរបស់ជនល្មើសដែលជាប្រភពនៃការបង្កព្យសនកម្មដល់ជនរងគ្រោះ និងការបង្កចលាចលដល់សង្គមទាំងមូល។ ជាការឆ្លើយតប សង្គមបានសម្រេចដាក់ទណ្ឌកម្ម។ ទណ្ឌកម្មនេះ ឈរលើទិដ្ឋភាពពីរយ៉ាង **១.ទិដ្ឋភាពសង្គម** ពិនិត្យតែពីព្យសនកម្ម(បានកើតឡើង)ដែលជាលទ្ធផលនៃអំពើប៉ុណ្ណោះ ដោយពុំបានលើកយកមក ពិចារណាសភាព ផ្លូវចិត្តរបស់ជនល្មើសទេ។ **២.ទិដ្ឋភាពបុគ្គល** អំពើសម្ភារៈជាការសំដែងចេញមកខាងក្រៅនូវវិថីចិត្តរបស់ជនល្មើស។ ទិដ្ឋភាពនេះ បានលើកយកមកពិចារណាសភាពផ្លូវចិត្តរបស់ជនល្មើស ក្នុងគោលដៅឱ្យការផ្តន្ទាទោសសមាមាត្រទៅនឹងកំហុស និងឱ្យទណ្ឌកម្មនេះអាចបំពេញតួនាទីក្នុងការអប់រំ ដាស់តឿន ក៏ដូចជាការបង្ការទប់ស្កាត់បទល្មើសផ្សេងទៀត។ ការរួមបញ្ចូលទិដ្ឋភាពទាំងពីរនេះ បង្កើតបានជាធាតុផ្សំអន្តោម័តនៃបទល្មើស។

ក្រមព្រហ្មទណ្ឌ មានសម្រេចអនុម័តយកសភាពផ្លូវចិត្តរបស់ជនល្មើសជាមូលដ្ឋានគ្រឹះ ក្នុងការកំណត់ទណ្ឌកម្ម។ និយាយក្នុងន័យមួយទៀត ច្បាប់ធ្វើការផ្តន្ទាទោសទៅតាមចេតនាប្រព្រឹត្តបទល្មើស។ ជាឧ. ការផ្តន្ទាទោសពីអំពើឃាតកម្មស្តែងឱ្យដឹងនូវជំហរនេះ។ មនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លាន៛ ទៅ ៦ លាន ៛ (មាត្រា ២០៧) ចំណែកឯឃាតកម្ម(មនុស្សឃាតដោយចេតនា)វិញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ(មាត្រា ១៩៩) ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ក្នុងករណីឃាតកម្មគិតទុកជាមុន(មាត្រា ២០០) ឃាតកម្មដោយមានទារុណកម្ម អំពើឃោឃៅ ឬរំលោភសេពសន្ថៈ ក្នុងពេល ឬក្រោយពេលប្រព្រឹត្ត បទល្មើស (មាត្រា ២០៥) ជាដើម។

ជារួម អំពើសម្ភារៈកើតចេញពីចេតនាប្រព្រឹត្តបទល្មើសដែលជនល្មើសបានជ្រើសរើស ក្រោយពីមានគំនិត និងការសម្រេចចិត្តប្រព្រឹត្តបទល្មើស។

ជាធម្មតាចេតនានេះ អាចកើតឡើងភ្លាមៗ និងជាញឹកញយគឺកើតចេញពីការពិចារណាជុំវិញចំណង់ចង់ឱ្យវិបាកណាមួយកើតឡើង។ ក្នុងករណីចុងក្រោយនេះ ចេតនានេះនឹងមានកំលាំងនៅក្រោយពេលជនល្មើសបានសម្រេច ចិត្តថានឹងប្រព្រឹត្តបទល្មើស ហើយក៏ចាប់ផ្តើមត្រៀមរៀបចំប្រព្រឹត្តបទល្មើស។

---

[១២] ការីន កូបាំង *ធាតុផ្សំអត្តនោម័តនៃបទល្មើសព្រហ្មទណ្ឌ* ក្នុងសៀវភៅ **វិធីសាស្ត្រគតិយុត្ត -នីតិកម្ពុជា -** ២០០៦ ទំ. ២២៥។

ជាគោលការណ៍ បទល្មើសកើតចេញពីឆន្ទៈ ឬចេតនាប្រព្រឹត្តបទល្មើស តែក្នុងករណីមួយចំនួន បទល្មើសក៏អាចកើតឡើងដោយអចេតនាផងដែរ។ ហេតុអ្វីក៏ច្បាប់ធ្វើការផ្តន្ទាទោសបទល្មើសដោយអចេតនា? ការផ្តន្ទាទោសចំពោះកំហុសដោយអចេតនានេះជាការក្រើនរំលឹក ក៏ដូចជាការដាក់កំហិតឱ្យមានការប្រុងស្មារតីបង្ការ ឬញៀសសង្គមពីគ្រោះថ្នាក់។

### ក.‿បទល្មើសប្រព្រឹត្តដោយចេតនា

**ចេតនាប្រព្រឹត្តបទល្មើស.‿**ជាគោលការណ៍ ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត (មាត្រា ៤)។ នេះជាការធ្វើនីត្យានុកូលកម្មនៃធាតុផ្សំអន្តោម័តនៃបទល្មើស។

**ការវាយតំលៃចេតនាប្រព្រឹត្តបទល្មើស.‿**ចេតនា ឬឆន្ទៈប្រព្រឹត្តបទល្មើសតែងស្ថិតក្នុងសភាពអរូបី ដែលគេពុំអាចស្មានដឹង និងអាចវាយតំលៃបានទេ។ តែចេតនានេះ ស្តែងចេញមកខាងក្រៅដែលជាអំពើសម្ភារៈ។ តាមរយៈ អំពើសម្ភារៈនេះ(អំពើសម្ភារៈនៃបទល្មើស កាលៈទេសៈប្រព្រឹត្តបទល្មើស ឬហេតុការណ៍នានាជុំវិញការប្រព្រឹត្ត បទល្មើស) គេអាចសំគាល់ កំណត់ និងវាយតំលៃវាបាន។

ចេតនាប្រព្រឹត្តបទល្មើសនេះ កើតភ្លាមក្រោយចេតនាទុច្ចរិតនៃការសម្រេចចិត្តប្រព្រឹត្តបទល្មើស។ ចេតនា ទុច្ចរិតនេះមានពីរប្រភេទគឺចេតនាទុច្ចរិតទូទៅ និងចេតនាទុច្ចរិតពិសេស។ ចេតនាទុច្ចរិទូទៅ (មានដូចៗគ្នាចំពោះ គ្រប់បទល្មើសទាំងអស់) មានន័យថាចារីមានឆន្ទៈបំពានច្បាប់ (ចារីដឹងថាអំពើដែលខ្លួនប្រព្រឹត្តជាអំពើដែលច្បាប់ហាមឃាត់[១៣] ហើយនៅតែផ្តោងចិត្តបន្តអំពើល្មើសនេះ) ហើយធ្វើសកម្មភាពក្នុងគោលដៅធ្វើឱ្យសម្រេចនូវអំពើដែលបង្កើតបានជាបទល្មើស។ ចេតនាក្នុងការប្រព្រឹត្តបទល្មើសនេះ ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសនីមួយៗ ទៅតាមបុគ្គលម្នាក់ៗ (មូលហេតុនៃបទល្មើស[១៤])កាលៈទេសៈ និងស្ថានភាពជុំវិញនាពេលប្រព្រឹត្តបទល្មើស។

ជួនកាល អ្នកនីតិប្បញ្ញត្តិយកចិត្តទុកដាក់ជាពិសេសលើចេតនាទុច្ចរិតរបស់ចារី។ ក្នុងន័យនេះ ការប្រព្រឹត្តបទល្មើសសន្មត មិនត្រឹមតែចេតនាប្រព្រឹត្តទេ តែចេតនាយ៉ាងច្បាស់ដែលច្បាប់បានកំណត់ទុក។ ចេតនានេះ ជាចេតនាទុច្ចរិតពិសេស។ ចេតនានេះសំដៅយក "ឆន្ទៈក្នុងបំណងរំខានដល់តំលៃសង្គមណាមួយជាកំណត់ ឬក៏អាកប្បកិរិយារបស់ចារីបង្ហាញពីប្រតិកម្មយ៉ាងឃោរឃៅខុសពីឆន្ទៈប្រព្រឹត្តដទៃទៀត"។ និយាយម្យ៉ាងទៀត ចារីមានឆន្ទៈចង់សម្រេចឱ្យបាននូវលទ្ធផលណាមួយ ហើយលទ្ធផលនោះៗត្រូវបានច្បាប់ហាមឃាត់។ ជាឧ. អំពើបទឃាតកម្ម ក្រៅពីឆន្ទៈបំពានច្បាប់ដោយបានដឹងជាមុន ជនល្មើសមានបំណង

---

[១៣] ជាគោលការណ៍ គេសន្មតថាគ្រប់ពលរដ្ឋទាំងអស់សុទ្ធតែបានដឹង និងចេះច្បាប់ « Nul n'est censé ignorer la loi » ។

[១៤] មូលហេតុមិនមែនជាធាតុផ្សំនៃបទល្មើសទេ ហើយចៅក្រមក៏ពុំអាចលើកយកមូលហេតុដើម្បីលើកលែងការចោទប្រកាន់ទេ ទោះជាមូលហេតុនោះត្រឹមត្រូវ ក៏ដោយក៏អំពើសម្ភារៈនៅតែជាបទល្មើសដដែល លើកលែងតែមានច្បាប់ចែង។

ឱ្យជនរងគ្រោះស្លាប់។ ការឃុំឃាំង ឬបង្ខាំងមនុស្សក្នុងគោលដៅ "ជំរិតយកទ្រព្យសម្បត្តិ ឬទាមទារឱ្យបំពេញលក្ខខណ្ឌអ្វីមួយ"។ "អំពើភេរវកម្ម ជាអំពើហឹង្សា ទាំងឡាយដែលប្រព្រឹត្តដោយជន មួយនាក់ ឬច្រើននាក់ ឬជនមួយក្រុម ឬច្រើនក្រុម *បង្កើតការភិតភ័យតក់ស្លុតក្នុងចំណោមប្រជាជន ក្នុងគោលដៅធ្វើឱ្យជ្រួលច្របល់យ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ និងឱ្យប៉ះពាល់ស្ថិរភាពនយោបាយ*"[១៥]។ ច្បាប់ប្រឆាំងនឹងភេរវកម្មចុះថ្ងៃទី ២០ កក្កដា ២០០៧ ត្រូវបានរៀបចំឡើង ក្នុងគោលដៅអនុញ្ញាតឱ្យកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទប់ស្កាត់អំពើភេរវកម្ម ដែលអាចនឹងគំរាមកំហែងដល់សន្តិភាព ស្ថិរភាព សន្តិសុខ និងភាពរុងរឿងខាងសេដ្ឋកិច្ចរបស់ខ្លួន។ លើសពីនេះ "ការគំរាមកំហែងក្រោមទម្រង់ណាក៏ដោយ ថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ប្រឆាំងនឹងបុគ្គល ប្រសិនបើការគំរាមកំហែងនេះត្រូវបានធ្វើឡើង ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ៦ ខែ ទៅ ២ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លាន រៀល ទៅ ៤ លាន រៀល " (មាត្រា ២៣២)។

ជាទូទៅ ចេតនាទុច្ចរិតពិសេសនេះ ចូលរួម និងដើរនាទីសំខាន់ណាស់ក្នុងការកំណត់ប្រភេទនៃបទល្មើស។ ដូច្នេះ ការយកកាំបិតចាក់លើជនរងគ្រោះជាច្រើនដង បង្ហាញឱ្យដឹងតាមការវិភាគលើចេតនាទុច្ចរិតពិសេសថាតើ ជនល្មើសគ្រាន់តែចង់បង្ករបួសស្នាម ឬជាការប៉ុនប៉ងធ្វើមនុស្សឃាត ដោយចេតនា។

ចរន្តគំនិតថ្មីបានលេចឡើងពាក់ព័ន្ធនឹងចេតនាទុច្ចរិតពិសេសនេះ។ ទស្សនៈថ្មីមួយចំនួន យល់ឃើញថាគេពុំអាច ធ្វើការញែកចេតនាទុច្ចរិតពិសេសចេញពីចេតនាទុច្ចរិតទូទៅទេ ដោយហេតុថាចេតនាទី ២ គ្រាន់តែជាផ្នែកមួយនៃចេតនាទី ១ ប៉ុណ្ណោះ។ ទស្សនៈនេះ សន្និដ្ឋានថាគ្រប់បទល្មើសប្រព្រឹត្តដោយចេតនាទាំងអស់ ត្រូវមានចេតនាទុច្ចរិត ពិសេសនៅក្នុងបទល្មើសទាំងនោះ មានន័យថាជនល្មើសតែងមានឆន្ទៈចង់បាន ឬចង់សម្រេចផលណាមួយជាកំណត់ ពោលគឺចេតនាទុច្ចរិតនេះមានលក្ខណៈដូចគ្នាទៅនឹងបទល្មើស (ចំពោះមនុស្សឃាតដោយចេតនាទាំងអស់ចេតនាទុច្ចរិត ដូចៗគ្នាទាំងអស់គឺចង់ឱ្យជនរងគ្រោះស្លាប់)។

ក្រៅពីនេះចេតនាទុច្ចរិតអាចមានលក្ខណៈជា ចេតនាទុច្ចរិតសាមញ្ញ និងចេតនាទុច្ចរិតធ្ងន់ធ្ងរ ចេតនាទុច្ចរិត ច្បាស់លាស់ និងចេតនាទុច្ចរិតមិនច្បាស់លាស់។

**ចេតនាទុច្ចរិតសាមញ្ញ និងចេតនាទុច្ចរិតធ្ងន់ធ្ងរ.**-ចំពោះចេតនាទុច្ចរិតប្រភេទទី ១ វាកើតឡើងភ្លាមៗ ឬដោយឯកឯង តែចំពោះចេតនាទុច្ចរិតប្រភេទទី ២វិញ កើតចេញពីការគិតទុកជាមុន ឬដោយការពួនស្ទាក់ដើម្បី សម្រេចលទ្ធផលក្នុងការប្រព្រឹត្តបៀតបៀនណាមួយលើជនរងគ្រោះ។ យោងតាមក្រមព្រហ្មទណ្ឌ ឃាតកម្មគិតទុក ជាមុន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ធ្ងន់ជាងឃាតកម្មធម្មតា។

**ចេតនាទុច្ចរិតច្បាស់លាស់ និងចេតនាទុច្ចរិតមិនច្បាស់លាស់.**-ចេតនាទុច្ចរិតច្បាស់លាស់ កាលណាលទ្ធផលដែលជាបច្ច័យនៃអំពើល្មើស ត្រូវនឹងអ្វីដែលជនល្មើសរំពឹងទុក និងផ្ទុយមកវិញចំពោះចេតនាទុច្ចរិត

[១៥] មាត្រា ១ នៃច្បាប់ស្តីពីផ្តន្ទាទោសអំពើភេរវកម្ម ចុះថ្ងៃទី ៧ កុម្ភៈ ១៩៩២។

មិនច្បាស់លាស់ មានន័យថា ជនល្មើសមិនបានកំណត់ឱ្យច្បាស់លាស់ ឬជាមុននូវអ្វីដែលនឹងកើតក្រោយពេលអនុវត្តបទល្មើស។

### ខ.-បទល្មើសដោយអចេតនា

"ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ ប៉ុន្តែ ក្នុងករណីដែលច្បាប់បានចែងទុកជាមុន[១៦] បទល្មើស មួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ច ដោយឡែកណាមួយ" (មាត្រា ៤ កថាខណ្ឌទី ២)។ និយាយដោយខ្លីគឺ បុគ្គលត្រូវមានកំហុសក្នុងការបង្កឱ្យមានព្យសនកម្ម។ ពោលគឺជនល្មើស មានកំហុសក្នុងការញុាំងឱ្យព្យសនកម្មកើតឡើង។

ក្រមរដ្ឋប្បវេណី បានអនុម័តយកលក្ខណៈវិនិច្ឆ័យមួយក្នុងការកំណត់ថាតើអំពើអនីត្យានុកូលមួយជាអំពើដោយចេតនា ឬដោយអចេតនា គឺជា "អំពើបំពាន(ដែលអាច)ព្យាករណ៍ទុកជាមុនអំពីការកើតឡើងនៃលទ្ធផល"[១៧] ហើយ "ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា និងការធ្វេសប្រហែស" បង្ហាញពីអវត្តមាននៃចេតនា។ ហេតុនេះ បទល្មើសដោយ អចេតនាកើតឡើងដោយមិនមានឆន្ទៈឱ្យកើតទេ តែដោយការមិន ប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយបណ្តាលឱ្យបទល្មើសមួយបានកើតឡើង។

ដូច្នេះ មនុស្សឃាតដោយអចេតនា គឺជា**អំពើបណ្តាលឱ្យអ្នកដទៃស្លាប់ដោយគ្មានចេតនាសំលាប់។**

មានន័យថាការផ្តាច់អាយុជីវិតកើតចេញពីអំពើមួយក្រៅឆន្ទៈរបស់ចារី(ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬការមិនគោរពកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័្តដែលច្បាប់តម្រូវ បណ្តាលឱ្យបទល្មើសមួយកើតឡើង)។ ជាពិសេសភាពអាចផ្តាច់អាយុជីវិត ឬការបង្ករបួសស្នាម[១៨] ដោយគ្រោះថ្នាក់ចរាចរ គ្រោះថ្នាក់ការងារ ជាដើម។ មនុស្សឃាតដោយអចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ ឆ្នាំ

---

[១៦] មាត្រា ៦៦៦.-ករណីយកិច្ចយកចិត្តទុកដាក់ ដល់សុវត្ថិភាព **នៃក្រមរដ្ឋប្បវេណី** "និយោជកមានករណីយកិច្ចយកចិត្តទុកដាក់ ដល់ការរក្សារូបរាងកាយ សុខភាព ជាអាទិ៍ របស់កម្មករនិយោជិត ពីគ្រោះថ្នាក់ នៅទីកន្លែងដែលកម្មករនិយោជិតត្រូវធ្វើពលកម្ម សិល្បៈការ្យ នៅក្នុងការធ្វើឧបករណ៍"។

[១៧] "ធ្វើអំពើដែល បើតាមប្រក្រតី បុគ្គលដែលមានឋានៈនៃការងារ ឬបទពិសោធន៍ស្មើគ្នានឹងអ្នកធ្វើអំពើនោះ អាចព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផល ក៏ដោយ ក៏អ្នកធ្វើអំពើនោះនៅតែពុំបានព្យាករទុកជាមុនអំពីការកើតឡើងនៃលទ្ធផលនោះ ដោយសារការធ្វេសប្រហែស មិនប្រុងប្រយ័ត្ន ហើយទោះជាមាន ករណីយកិច្ចជៀសវាង នូវលទ្ធផលនោះ ក៏ដោយក៏នៅតែប្រព្រឹត្តផ្ទុយនឹងករណីយកិច្ចនោះ" (មាត្រា ៧៤២)។ នេះជាការប្រើសញ្ញាណ Resonable person នៃពិភពច្បាប់ Common law.

[១៨] "បទល្មើសបង្កឱ្យមានរបួសដោយអចេតនា គឺជាអំពើដែលបណ្តាលឱ្យមានរបួសដល់អ្នកដទៃដោយ : ១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ដែលបង្កឱ្យមានអសមត្ថភាពក្នុងការធ្វើការងារស្មើ ឬលើសពី ៨ ថ្ងៃ ។ ២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ។"

ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរ ទៅ ៦ លាន រ (មាត្រា ២០៧ ) ឯការ "បង្កឱ្យមានរបួស ដោយអចេតនា ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ៦ ខែ ទៅ ២ ឆ្នាំ និងពិន័យជាប្រាក់ពី ១ លាន រៀល ទៅ ៤ លាន រៀល"(មាត្រា ២៣៦)។

នៅពេលអំពើមួយបង្កើតបានជាបទល្មើស បណ្តឹងមួយត្រូវបានដឹកនាំប្រឆាំងនឹងជនល្មើស ដើម្បីទាមទារឱ្យតុលាការអនុវត្តទោសដែលបានកំណត់។

## កថាខណ្ឌទី ៤ បណ្តឹងអាជ្ញា

"បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមផ្លូវច្បាប់កំណត់"(មាត្រា ២ ម្រនីតិវិធីព្រហ្មទណ្ឌ)។ ជាគោលការណ៍បណ្តឹងអាជ្ញា ជាសិទ្ធិផ្តាច់មុខរបស់អយ្យការ(មាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញ : "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា") អញ្ចឹងក្រមនីតិវិធីព្រហ្មទណ្ឌ(មាត្រា ៥ និងពីមាត្រា ១៣៨ ដល់មាត្រា ១៤២) ដែលផ្តល់លទ្ធភាពឱ្យជនរងគ្រោះ អាចធ្វើបណ្តឹងអាជ្ញា ជាបទប្បញ្ញត្តិមួយដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ?

**អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា**..ចិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា[១៩] មានរយៈពេល ១៥ ឆ្នាំ ចំពោះ បទឧក្រិដ្ឋ ៥ ឆ្នាំ ចំពោះបទមជ្ឈិម និង ១ ឆ្នាំ ចំពោះបទលហុ។ ចំពោះ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋសង្គ្រាម បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងអំពើភេរវកម្ម សុទ្ធតែជាបទល្មើសមិនចេះផុតអាជ្ញាយុកាល។ អាជ្ញាយុកាលនៃបទល្មើស មិនមែនជាបទប្បញ្ញត្តិអាជ្ញាបញ្ញាទេ ច្បាប់អាចកំណត់អាជ្ញាយុកាលផ្សេងពីនេះ ករណីដូចជាមាត្រា ៣១២ កំណត់យកអាជ្ញាយុកាល ១ ឆ្នាំ ចំពោះបទបរិហារបង្កាច់កេរ្តិ៍ ជាដើម។

ចិរវេលានៃអាជ្ញាយុកាលត្រូវ ចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស លើកលែងតែបទល្មើសមួយចំនួន ដូចជា ការទទួលផលចោរកម្ម បទល្មើសទំលាប់ ជាដើម ។

[១៩] ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២0ឆ្នាំ ពីបទមជ្ឈិមមានអាជ្ញាយុកាល ៥ឆ្នាំ និងពីបទលហុមានអាជ្ញាយុកាល ១ឆ្នាំ (ម. ១៤៤) ហើយ "ចិរវេលា ២0 ឆ្នាំ ៥ឆ្នាំ និង ១ឆ្នាំ ដែលមានចែងនៅក្នុងមាត្រា ១៤៤ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសបានក្លាយទៅជាស្ថាពរ។ (ម. ១៤៥ )។" នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។" (ម .១៤២ )។

អាជ្ញាយុកាលសំដៅយកកំឡុងពេលមួយកាលបើហួសកំឡុងពេលនោះហើយ អានុភាពមួយបានកើតឡើង ដោយរំលត់សិទ្ធិ ឬបង្កើតសិទ្ធិ។ ក្នុងរឿងព្រហ្មទណ្ឌ អាជ្ញាយុកាលមានពីរយ៉ាងគឺ អាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា និងអាជ្ញាយុកាលនៃទោស ដែលសុទ្ធតែជាអាជ្ញាយុកាលរំលត់សិទ្ធិរបស់ព្រះរាជអាជ្ញា ក្នុងការធ្វើបណ្ដឹងអាជ្ញា( ចោទប្រកាន់ដើម្បីឱ្យទាមទារឱ្យមានការអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ) និងក្នុងការស្វែងរកចាប់ខ្លួនទណ្ឌិតយកមកអនុវត្តទោស(ដែលចៅក្រមប្រកាសក្នុងសេចក្ដីសម្រេចស្ថាពរ)។

**ឧប្បទេវហេតុនៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា** សំដៅយកករណីនៃការផ្ដាច់អាជ្ញាយុកាល និងការព្យួរអាជ្ញាយុកាល។ អាជ្ញាយុកាលត្រូវផ្ដាច់ ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ។ ការបញ្ចប់កិច្ចចោទប្រកាន់ ឬកិច្ចស៊ើបសួរនីមួយៗ នាំឱ្យចាប់ផ្ដើមគិតចិរវេលាថ្មីនៃអាជ្ញាយុកាល។ ចិរវេលាថ្មីអាចយកទៅជំទាស់បានចំពោះជន គ្រប់រូបដែលទាក់ទងនៅក្នុងរឿងនេះ។ ចំណែកឯការព្យួរអាជ្ញាយុកាលវិញមានមូលហេតុបណ្ដាលមកពីឧបសគ្គដែលមិនអាចឱ្យព្រះរាជអាជ្ញាធ្វើបណ្ដឹងអាជ្ញាបាន(ករណីជនល្មើស បានឆ្លតបន្ទាប់ពីប្រព្រឹត្តបទល្មើស)។ ការព្យួរអាជ្ញាយុកាល មិននាំឱ្យចាប់ផ្ដើចិរវេលានៃអាជ្ញាយុកាលទេ ពោលគឺអាជ្ញាយុកាលគ្រាន់តែឈប់រាប់ក្នុងអំឡុងពេលដែល ព្រះរាជអាជ្ញាមិនអាចធ្វើបណ្ដឹងអាជ្ញាប៉ុណ្ណោះ ហើយបានជាប្រយោជន៍ដល់តែជននោះប៉ុណ្ណោះ។

***ការរលត់បណ្ដឹងអាជ្ញា***._បណ្ដឹងអាជ្ញារលត់ដោយ( មាត្រា ៧ ក្រមនីតិវិធីព្រហ្មទណ្ឌ)

១._មរណភាពនៃជនល្មើស

២._ការផុតអាជ្ញាយុកាល

៣._ការលើកលែងទោសជាទូទៅ

៤._និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៥._អាជ្ញាអស់ជំនុំ

ហើយកាលណា ច្បាប់ដោយឡែកចែងជាក់លាក់ ( មាត្រា ៨ ក្រមនីតិវិធីព្រហ្មទណ្ឌ)

៦._ការសម្របសម្រួលជាមួយរដ្ឋ

៧._ការដកពាក្យប្ដឹងនៅក្នុងករណីដែលពាក្យប្ដឹងនោះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់[២០]

[២០] "(...) ពាក្យបណ្ដឹងរបស់សាមីខ្លួន ឬប្រធានស្ថាប័នសាមី ដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ គឺជាលក្ខខណ្ឌចាំបាច់ នៃការចោទប្រកាន់ពី បទព្រហ្មទណ្ឌដោយអយ្យការ កាលបើ ការបរិហាកេរ្តិ៍ ហើយការដកពាក្យប្ដឹងវិញ របស់អ្នកប្ដឹងនាំឱ្យបណ្ដឹងអាជ្ញារលត់។ (...)" (មាត្រា ៣០៥)។

មាត្រា ៨ នៃច្បាប់ស្ដីពីឯកពន្ធភាពឆ្នាំ២០០៦ : ក្នុងករណីដែលមានអំពើផិតកើតឡើង "ព្រះរាជអាជ្ញា**អាច**សម្រេចមិនធ្វើបណ្ដឹងអាជ្ញាបាន ប្រសិនបើមានបណ្ដឹងរបស់ សហពទ្ធណាមួយស្នើសុំកុំឱ្យចោទប្រកាន់"។

៨_ការបង់ពិន័យសរុបឬប្រាក់ពិន័យសម្របសម្រួល។

ជារួម បណ្តឹងអាជ្ញាមានគោលដៅទាមទារឱ្យសាលាជម្រះក្តីព្រហ្មទណ្ឌអនុវត្តច្បាប់ព្រហ្មទណ្ឌដាក់ទោស និងអនុវត្តទោសប្រឆាំងនឹងការប្រព្រឹត្តបទល្មើសសំដៅជម្រុញឱ្យជនល្មើសឈប់និងបញ្ឈប់ការ សម្រេចចិត្តប្រព្រឹត្តបទល្មើ។

**ចេះមិនដល់ ឆ្ងល់មិនកើត បើចេះឆ្លក់ឆ្លើត កុំរិះគន់គេ។**

**ការសិក្សាជាការវិនិយោគដ៏ធំមួយ។**

# ផ្នែកទី ២ ការចាត់ថ្នាក់បទល្មើស

បទល្មើសអាចត្រូវបានចាត់ថ្នាក់ជាច្រើនរបៀបទៅតាមការយល់ឃើញរបស់បុគ្គលម្នាក់ៗ[២១]។ តែនៅទីនេះ យើងសូមជ្រើសរើសយកវិធីចាត់ថ្នាក់បទល្មើសមួយមកបង្ហាញ : បទល្មើសអាចត្រូវបានចាត់ថ្នាក់ ស្រប តាមចរិតគ្រោះថ្នាក់នៃអំពើ តាមការស្តែងឡើងនៃអំពើសម្ភារៈ និងតាមរបបគតិយុត្តគ្រប់គ្រងប្រភេទបទល្មើសនោះៗ។ ជម្រើសនេះ ត្រូវបានអនុម័តដោយយោងលើផលប្រយោជន៍ដែលត្រូវស្វែងរក។

## កថាខណ្ឌទី ១ ចំណាត់ថ្នាក់តាមចរិតគ្រោះថ្នាក់នៃអំពើ

បទល្មើសត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ (មាត្រា ២)។

១-បទលហុ

នៅព្រះរាជាណាចក្រកម្ពុជា ច្បាប់ទុកលទ្ធមួយចំនួនឱ្យអំណាចនីតិប្រតិបត្តិធ្វើការកំណត់បទលហុ តែមិនមែន ជាសមត្ថកិច្ចផ្តាច់មុខនោះទេ ដូចមានចែងក្នុងមាត្រា ១ កថាខណ្ឌទី២ ក្រមព្រហ្មទណ្ឌ ថា "នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្ត ដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ"។

"បទល្មើសជាបទលហុ នៅក្នុងករណីដែល : ១.អតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈ ពេលក្រោម ឬស្មើនឹង ៦ថ្ងៃ។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ ២.បទល្មើសត្រូវ ផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ"(មាត្រា ៤៨) ចាប់ពី មួយពាន់ រៀល ទៅ មួយសែន រៀល[២២] និងទោស. បន្ថែម មួយ ឬច្រើន។

---

[២១] ជាទូទៅ គេចាត់ថ្នាក់បទល្មើសដោយយោងទៅតាមធាតុផ្សំនៃបទល្មើស (ធាតុផ្សំនីត្យានុកូល សត្យានុម័ត និងអត្តនោម័តនៃបទល្មើស)។

[២២] "អំពើប្រព្រឹត្តដោយចេតនាដោយបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬធ្វើឱ្យខូចខាត បណ្ណប្រកាស ឬសេចក្តីជូនដំណឹងជាផ្លូវការរបស់រដ្ឋបាល ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារ ពី ១ថ្ងៃ ទៅ ៦ថ្ងៃ និងពិន័យជាប្រាក់ពី ១ ០០០ រៀល ទៅ ១០០ ០០០រៀល" (មាត្រា ៤២២)។

យោងតាមច្បាប់ចរាចរផ្លូវគោក[២៣] បទលហុ ពិន័យជាប្រាក់មាន ៤ ថ្នាក់ (មាត្រា ៨៨) គឺ បទលហុថ្នាក់លេខ :

-១ ពិន័យជាប្រាក់ចំនួន ៣ ០០០៛ (ទោច ឬត្រីចក្រយាន) ៤ ០០០៛ (យានយន្តធន់ស្រាល) និង ១០ ០០០៛ (យានយន្តធន់ធ្ងន់)

-២ ពិន័យជាប្រាក់ចំនួន ៤ ០០០៛ (ទោច ឬត្រីចក្រយាន) ៨ ០០០៛ (យានយន្តធន់ស្រាល) និង ១៥ ០០០៛ (យានយន្តធន់ធ្ងន់)

-៣ ពិន័យជាប្រាក់ចំនួន ៥ ០០០៛ (ទោច ឬត្រីចក្រយាន) ១០ ០០០៛ (យានយន្តធន់ស្រាល) និង ២០ ០០០៛ (យានយន្តធន់ធ្ងន់)

-៤ ពិន័យជាប្រាក់ចំនួន ៦ ០០០៛ (ទោច ឬត្រីចក្រយាន) ១២ ០០០៛ (យានយន្តធន់ស្រាល) និង ២៥ ០០០៛ (យានយន្តធន់ធ្ងន់)

ហើយក្នុងករណីដែលជនល្មើសមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល ៣០ថ្ងៃ គិតពីថ្ងៃទទួលបណ្ណ-ពិន័យ ចំនួនប្រាក់ពិន័យនឹងឡើងដល់ ២ដង នៃប្រាក់ពិន័យ ៣ដង បើហួសរយៈពេល ៦០ថ្ងៃ។ បើហួសរយៈពេល ៩០ថ្ងៃ មន្ត្រី- នគរបាលចរាចរត្រូវរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ។

បទលហុមានអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា និងនៃទោស ចំនួនមួយឆ្នាំ។

## ២.-បទមជ្ឈិម

ចំពោះបទមជ្ឈិម សភាមានសមត្ថកិច្ចផ្ដាច់មុខក្នុងការបង្កើតបទល្មើស។

"បទល្មើសជាបទមជ្ឈិម ក្នុងករណីអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវវងនោះមានរយៈពេលលើសពី ៦ថ្ងៃ និងក្រោម ឬស្មើនឹង ៥ឆ្នាំ។ ទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ"(មាត្រា ៤៧)។

បទមជ្ឈិមមានអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា និងនៃទោសចំនួន ០៥ ឆ្នាំ។

## ៣-បទឧក្រិដ្ឋ

ចំពោះបទឧក្រិដ្ឋ សភាមានសមត្ថកិច្ចផ្ដាច់មុខក្នុងការបង្កើតបទល្មើស។

"បទល្មើសជាបទឧក្រិដ្ឋ ក្នុងករណីអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវវងនោះ :

១-ជាទោស ដាក់ពន្ធនាគារអស់មួយជីវិត។

២-ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ឆ្នាំ និងក្រោម ឬស្មើនឹង ៣០ ឆ្នាំ ។ ទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ"(មាត្រា ៤៦) ព្រមទាំងទោសបន្ថែម។

បណ្ដឹងអាជ្ញាត្រូវផុតរលត់ក្នុងរយៈពេល ១៥ ឆ្នាំ ហើយទោសដែលតុលាការប្រកាសប្រឆាំង នឹងទណ្ឌិត ត្រូវផុតរលត់ក្នុងរយៈពេល ២០ ឆ្នាំ។

[២៣] ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ៨-០២-២០០៧ រាជកិច្ច ខែកុម្ភៈ ឆ្នាំ ២០០៧ ទំ ១៨៣២។

ក្នុងចំណាត់ថ្នាក់នេះ ក៏អាចរាប់បញ្ចូលចំណាត់ថ្នាក់ដោយយោងលើចេតនាផងដែរ គឺបទល្មើសប្រព្រឹត្តដោយចេតនានិងបទល្មើសប្រព្រឹត្តដោយអចេតនា។ ព្រោះក្រមព្រហ្មទណ្ឌ បានកំណត់យកចេតនា (ដែលឆ្លុះបញ្ចាំងពីទម្ងន់នៃអំពើ) ប្រព្រឹត្តបទល្មើសជាស្នូលក្នុងការកំណត់ទោស។

ផលប្រយោជន៍នៃចំណាត់ថ្នាក់នេះរួមមាន :

១-សមត្ថកិច្ចក្នុងការបង្កើតបទល្មើស(មាត្រា ១)

២-អាជ្ញាយុកាលនៃបណ្តឹងអាជ្ញា និងនៃទោស(មាត្រា ៩ ដល់មាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ១៤៤-១៤៥ នៃក្រមព្រហ្មទណ្ឌ)

៣-ការផ្តន្ទាទោសចំពោះការសមគំនិត អ្នកផ្តើមគំនិត និងការប៉ុនប៉ង។

៤-ការទទួលបានស្ថានសម្រាលទោស និងប្រយោជន៍នីត្យានុកូល(ការផ្អាកការប្រកាសទោស ការព្យួរទោស ទោសជំនួស របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ ការប្រកាសទោសជំនួស ជាដើម) អនុញ្ញាតចំពោះតែបទមជ្ឈិមប៉ុណ្ណោះ ហើយក្នុងករណីដែលច្បាប់ចែង ចំពោះបទលហុ។

៥-ភាពចាំបាច់ក្នុងការបើកការស៊ើបសួរដើម្បីស្វែងរកការពិត និងការអនុវត្តនយោបាយព្រហ្មទណ្ឌក្នុងនោះ ចំពោះបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវបើការស៊ើបសួរ ឯបទមជ្ឈិមអាចបើក និងមិនចាំបាច់ក្នុងពីរករណី[២៤] គឺការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់(មាត្រា ៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ) និងការបង្ហាញខ្លួនភ្លាម (មាត្រា ៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ)។ ចំពោះបទលហុមិនចាំបាច់បើកការស៊ើបសួរអ្វីទេ ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឱ្យចូលខ្លួន ទៅចំពោះមុខតុលាការជំនុំជម្រះផ្ទាល់(មាត្រា ៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌ) តាមនីតិវិធីនៃការកោះហៅទៅជំនុំជម្រះផ្ទាល់)។

៦-ការឃុំខ្លួនបណ្តោះអាសន្ន។

៧-បត្យាប័ន។

៨-ករណីមិនរាងចាល។

៩-ការឃាត់ខ្លួន ។

**ពាក្យពិតដែងស្លែងពាក្យបញ្ចើចបញ្ចើរដែងផ្អែមដូចទឹកឃ្មុំ ។**

[២៤] មាត្រា ១២២ ក្រមនីតិវិធីព្រហ្មទណ្ឌ "ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន"។

## កថាខណ្ឌទី ២ ចំណាត់ថ្នាក់ទៅតាមការស្តែងឡើងនៃអំពើសម្ភារៈ

បទល្មើសមួយកើតមានតាមរយៈអំពើដែលចារីអនុវត្ត ហើយបង្កឱ្យព្យសនកម្មកើតឡើង។ ជាគោល-ការណ៍ បទល្មើសអាចកើតចេញពីអំពើសកម្ម និងអំពើអកម្មរបស់ចារី ហើយអាចជាប្រភេទ បទល្មើសជាក់ស្តែង ឬបទល្មើសមិនជាក់ស្តែង។ម្យ៉ាងវិញទៀត ការអនុវត្តបទល្មើសអាចដល់គោលដៅ ឬមិនដល់គោលដៅ។ បទល្មើសមួយអាច ប្រព្រឹត្តក្នុងរយៈពេលមួយ ជួនកាលអ្នកនីតិប្បញ្ញត្តិមិនតម្រូវឱ្យសម្រេចលទ្ធផល ឬឱ្យមានព្យសនកម្មទេ ដើម្បីអាច ត្រូវផ្តន្ទាទោសទេ។

### ក.-ចំណាត់ថ្នាក់ដោយយោងលើសភាពនៃអំពើ

១-បទល្មើសសកម្ម និងបទល្មើសអកម្ម

បទល្មើសសកម្ម កាលណាចារីប្រព្រឹត្តអំពើសម្ភារៈចារីធ្វើសកម្មភាពដើម្បីញ៉ាំងព្យសនកម្មដែលច្បាប់ទាមទារឱ្យកើត។ ចំណែកឯបទល្មើសអកម្មវិញកើតចេញពីការមិនគោរពកាតព្វកិច្ចដែលច្បាប់តម្រូវ។ ជាឧ. ការមិនប្តឹងបរិហារពី បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលបុគ្គលបានដឹងដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត។

មូលហេតុនៃការបង្កើតបទល្មើសអកម្ម មានពីរយ៉ាងគឺ

-បង្កើតការសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចនានា ដើម្បីស្វែងរក និងបង្ក្រាបបទល្មើស

- បង្កើតសាមគ្គីភាពក្នុងសង្គម ក្នុងគោលដៅរួមចំណែករក្សាសន្តិសុខ ភាពសុខស្ងប់ ....

២-បទល្មើសជាក់ស្តែង និងបទល្មើសមិនជាក់ស្តែង

បទល្មើសជាក់ស្តែងមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌពីមាត្រា ៨៦ និងបន្តបន្ទាប់។ មាត្រា ៨៦ ចែងថា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង កាលណា

"-បទល្មើសកំពុងតែប្រព្រឹត្ត

-បទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាម

ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសបន្តិចមក :

-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រភឹង

-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្តបទល្មើស ឬបានចូលរួមប្រព្រឹត្តបទល្មើស។" និងមាត្រា ៨៨ បន្តទៀតថា "ត្រូវចាត់ទុកដូចជាបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែងផងដែរ (....) គ្រប់បទឧក្រិដ្ឋ ឬមជ្ឈិមទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តនៅ ទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះសុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក្នុង ករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីនោះ។" នេះជាករណីលើកលែង ហើយទោះជាបទល្មើសបានកើតឡើង និងចប់សព្វគ្រប់(គំលាតក្នុងពេលនៃការប្រព្រឹត្តបទល្មើស និងការចូលពិនិត្យកន្លែង កើតហេតុ) ក្រោយមកមានការពិនិត្យកន្លែងនោះ បទល្មើសនៅតែជាបទល្មើសជាក់ស្តែង។

***<u>សំណួរត្រិះរិះ</u>*** : តើចំណាត់ថ្នាក់នេះ ផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

## ខ.-ចំណាត់ថ្នាក់ដោយយោងលើលទ្ធផលនៃអំពើ

១-បទល្មើសសម្ភារៈ និងបទល្មើសទម្រង់

បទល្មើសសម្ភារៈ សំដៅយកអំពើជាសម្ភារៈដែលស្តែងឡើងក្រោមសកម្មភាពផ្សេងៗបង្កឱ្យមានព្យសនកម្ម ពោលគឺលទ្ធផលសម្ភារៈដែលច្បាប់ទាមទារ។ បទល្មើសសម្ភារៈអាចចែកចេញជាបទល្មើសសាមញ្ញ និងបទល្មើសស្មុគស្មាញ។ បទល្មើសមួយជាបទល្មើសស្មុគស្មាញ កាលណាមានអំពើសម្ភារៈច្រើនខុសៗគ្នារួមគ្នាជាបន្តបន្ទាប់ក្នុង គោលដៅធ្វើឱ្យបទល្មើសមួយកើតឡើង ឬបានសម្រេច។ បទល្មើសសាមញ្ញកើតឡើងដោយអំពើសម្ភារៈតែមួយ។ ការបែងចែកបទល្មើសសាមញ្ញ និងស្មុគស្មាញ គឺចំពោះបទល្មើសស្មុគស្មាញទីកន្លែងប្រព្រឹត្តបទល្មើស[២៥] និងការចាប់ គតិអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា (នៅពេលគ្រប់អំពើសម្ភារៈត្រូវបានបំពេញ)។

ចំណែកឯបទល្មើសទម្រង់វិញ សំដៅយកទម្រង់ណាមួយនៃអំពើសម្ភារៈដែលស្ថិតនៅក្នុងដំណាក់កាលត្រៀមបំរុង ឬចាប់ផ្តើមប្រព្រឹត្តបទល្មើស តែព្យសនកម្ម ឬការអន្តរាយមិនទាន់កើតមាននៅឡើយ។ ការកំណត់ត្រឹមតែ**ទម្រង់** ដោយមិនទាមទារឱ្យមានព្យសនកម្ម ព្រោះបទល្មើសប្រភេទនេះមានផលប៉ះពាល់ជាអវិជ្ជមាន ដល់សន្តិសុខជាតិ សេដ្ឋកិច្ចជាតិ និងចរិតគ្រោះថ្នាក់ជាក់ស្តែងនៃអំពើ។ ការដាក់ថ្នាំពុលក្នុងម្ហូបអាហារ និងទឹកបរិភោគរបស់ ជនរងគ្រោះត្រូវចាត់ទុកថាបទឃាតកម្ម ឬបទប្រើហឹង្សាបានសម្រេច ដោយមិនចាំបាច់ ឬតម្រូវឱ្យជនរងគ្រោះ បរិភោគឡើយ។ ទង្វើនៃការដាក់ថ្នាំពុល តែឯកឯងគឺគ្រប់គ្រាន់

[២៥] មាត្រា ១៣ "បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើផែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា"។

ដើម្បីបង្កើតបានជាបទល្មើស។ ការក្លែងរូបិយវត្ថុ និងរូបិយបណ្ណ ត្រូវចាត់ទុកថាបានសម្រេច កាលបើជនល្មើសមាននៅនឹងខ្លួននូវពុម្ព និងសម្ភារៈ ដើម្បីក្លែងក្រដាសប្រាក់ ពោលគឺពុំចាំបាច់មានដំណើរការ បោះពុម្ពក្រដាសក្លែង និងចរាចរណ៍ក្រដាសប្រាក់ក្លែង នោះទេ។ ល។

២-បទល្មើសបានសម្រេច និងបទល្មើសប៉ុនប៉ង

បទល្មើសមួយចាត់ថា បានសម្រេចកាលណាចរិបានធ្វើឱ្យអំពើសម្ភារៈបានបង្កព្យសនកម្មរំពឹងទុក។ ប្រសិនបើអំពើនោះមិនបានបង្កព្យសនកម្ម ឬពុំសម្រេចគោលដៅរំពឹងទុកទេ អំពើសម្ភារៈនោះស្ថិតក្នុងដំណាក់កាលមួយ ហៅថាប៉ុនប៉ងប្រព្រឹត្តបទល្មើស។ កាលណានិយាយពីការប៉ុនប៉ង គេនិយាយពីដំណាក់កាលនៃការប្រព្រឹត្តបទល្មើស។ ការកំណត់ពីដំណាក់កាលនៃការប្រព្រឹត្តបទល្មើសនេះ គឺក្នុងគោលដៅកំណត់ថាចាប់ពីពេលណាទើបអំពើនេះអាចផ្តន្ទាទោសបាន។ ការប៉ុនប៉ងអាចត្រូវផ្តន្ទាទោស កាលណាលក្ខខណ្ឌពីរយ៉ាងត្រូវបំពេញ :

**១**-ចាប់ពីពេលដែលចរិបានចាប់ផ្តើម អនុវត្តសេចក្តីសម្រេចចិត្តប្រព្រឹត្តបទល្មើស ឬបើយោងតាមក្រមព្រហ្មទណ្ឌ ថា"ចរិចាប់ផ្តើមអនុវត្តបទល្មើស"(អំពើដែលមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស) និង

**២**-កាលបើចរិចូលក្នុងដំណាក់កាលចាប់ផ្តើមហើយ និងមិនបានបញ្ឈប់សកម្មភាពរបស់ខ្លួន ដោយស្ម័គ្រចិត្ត តែអាក់ខានដោយសារកាលៈទេសៈខាងក្រៅឆន្ទះរបស់ចរិ(មាត្រា ២៧)។ តាមន័យនេះ អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជា ការចាប់ផ្តើមអនុវត្តបទល្មើសទេ ។

***<u>សំណួរត្រិះរិះ</u>*** តើចំណាត់ថ្នាក់នេះ ផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

## គ.-ចំណាត់ថ្នាក់ដោយយោងលើរយៈពេលនៃការប្រព្រឹត្តបទល្មើស

បទល្មើសអាចប្រព្រឹត្តឡើងតែមួយខណៈពេល ឬអាចអូសបន្លាយ ឬសារចុះឡើងក្នុងពេលវេលាដែលជាតំណាវនៃគំនិតទុច្ចរិត។

-**បទល្មើសភ្លាមៗ និងបទល្មើសនិរន្តរ៍**: ចំពោះបទល្មើសប្រភេទទី ១ បទល្មើសសម្រេចលទ្ធផលក្នុងរយៈពេលមួយប៉ព្រិចភ្នែក ឬខ្លី ដោយអំពើសកម្ម ឬអំពើអកម្ម ដូចជាឃាតកម្ម អំពើលួច។ ចំពោះបទល្មើសភ្លាមៗមួយចំនួន ផលនៃបទល្មើសអាចអូសបន្លាយក្នុងរយៈពេលណាមួយ ដូចជាទ្វេពន្ធភាព ជាដើម ហើយបទល្មើសប្រភេទនេះត្រូវបានអ្នកខ្លះ ចាត់ទុកថាជាបទល្មើសអចិន្ត្រៃយ៍(Permanent offenses) ឬ

ជនល្មើសប្រព្រឹត្តច្រើនដងនូវបទល្មើសប្រភេទដដែល ក្នុងពេលវេលាខុសគ្នា ត្រូវបានច្បាប់បារាំងដាក់ឈ្មោះថាជាបទល្មើសបន្តបន្ទាប់(Infractions continuées)។ ចំណែកឯ បទល្មើសប្រភេទទី ២ ទាមទារឱ្យមានការអូសបន្លាយក្នុងពេលវេលានូវ ចេតនាទុច្ចរិត ដើម្បីអាចឱ្យបទល្មើសមួយបាន សម្រេចនៅពេលផុតរយៈពេលណាមួយជាកំណត់ដែលជាទូទៅ គឺផុតរយៈពេលនៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ករណីដូចជា "អំពើទទួលផលចោរកម្មគឺជាអំពើទទួល លាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថាវត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិម។

ត្រូវចាត់ទុកជាអំពើទទួលផលចោរ កម្មផងដែរ:

១.អំពើធ្វើជាអន្តរការីដើម្បីបញ្ជូនវត្ថុអ្វីមួយដោយដឹងថារបស់នោះបានមកពីបទ ឧក្រិដ្ឋ ឬបទមជ្ឈិម។

២.អំពើដែលបានទទួលផលពីផលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយបានដឹងហេតុការណ៍ច្បាស់។"

***<u>សំណួរត្រិះរិះ</u>*** : តើចំណាត់ថ្នាក់នេះ ផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

**-បទល្មើសសាមញ្ញ និងបទល្មើសទំលាប់** : បទល្មើសសាមញ្ញកើតឡើងដោយអំពើតែមួយ។ អំពើនេះគ្រប់គ្រាន់ ដើម្បីបង្កើតបានជាបទល្មើស។ ខុសពីបទល្មើសសាមញ្ញ បទល្មើសទំលាប់កើតឡើង ដោយអំពើច្រើនរួមគ្នា ហើយបើបំបែកអំពើទាំងនេះមួយៗ អំពើនេះមិនមែនជាបទល្មើសទេ។ មានន័យថា បទល្មើសទំលាប់នឹងជាបទល្មើសចាប់ពីអំពើទី ២ : "អំពើគំរាមកំហែងថានឹងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមប្រឆាំងនឹងបុគ្គល កាលបើការ គំរាមកំហែងនេះធ្វើឡើងម្តងហើយម្តងទៀត (...) ត្រូវផ្តន្ទាទោសពី ១ ខែ ទៅ ៦ ខែ និងពិន័យជាប្រាក់ពី ១ សែន ៛ ទៅ ១ លាន ៛ " ។

*<u>សំណួរត្រិះរិះ</u>* : តើចំណាត់ថ្នាក់នេះ ផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

**-បទល្មើសសាមញ្ញ និងបទល្មើសស្មុគស្មាញ.**-បទល្មើសសាមញ្ញសម្រេចដោយអំពើសម្ភារៈតែមួយ អាច កើតឡើងភ្លាមៗ ឬអូសបន្លាសក្នុងពេលវេលា ចំណែកបទល្មើសស្មុគស្មាញតម្រូវឱ្យមានអំពើច្រើនរួមគ្នា ហើយអំពើទាំងអស់រួមគ្នា និងមានគោលដៅតែមួយ ព្រមទាំងកើតចេញពីចារីតែម្នាក់ ទើបបង្កើតជាបទល្មើស ។

*<u>សំណួរត្រិះរិះ</u>* : តើចំណាត់ថ្នាក់នេះ ផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

**មានគំនិតល្អ មិនទាន់គ្រប់គ្រាន់ទេ**

**លុះត្រាតែចេះយកគំនិតល្អនោះទៅប្រើឱ្យបានត្រឹមត្រូវ**

## កថាខណ្ឌទី ៣ ចំណាត់ថ្នាក់ទៅតាមរបបគតិយុត្តអនុវត្តចំពោះបទល្មើស ជាបទល្មើសនៃនីតិរូម និងបទល្មើសនយោបាយ បទល្មើសយោធា និងអំពើភេរវកម្ម

បទល្មើសអាចត្រូវបានចាត់ថ្នាក់ជាបទល្មើសនៃនីតិរូម និងបទល្មើសពិសេសដែលលក្ខណៈពិសេសនេះ ស្ថិតត្រង់នីតិករបានបង្កើតរបបពិសេសសំរាប់ប្រភេទនីមួយៗនៃបទល្មើសនោះៗ។ បទល្មើសទាំងនោះមានបទល្មើសនយោបាយ បទល្មើសយោធា និងអំពើភេរវកម្ម។ របបពិសេសនេះ មានមូលដ្ឋានឈរលើលក្ខណៈពិសេសដែលជាធម្មតា វាជាបទល្មើសនៃនីតិរូម តែដោយចរិតណាមួយនៃបទល្មើសទាំងនោះហើយចរិតនេះនាំឱ្យបទល្មើស នោះខុសពីបទល្មើសធម្មតា (ឧ. ឱ្យតែមានការផ្តាច់អាយុជីវិត ក្នុងនីតិរូមគេថាវាជាបទល្មើសនៃនីតិរូម "ឃាតកម្ម" តែបើជនរងគ្រោះជាប្រមុខរដ្ឋ ពេលនោះវាប្រែក្លាយពីបទឃាតកម្មទៅជាបទល្មើសនយោបាយ)។ ចំណែកបទល្មើសនៃនីតិរូមស្ថិតត្រង់ វាមានរបបគតិយុត្តរួមមួយអនុវត្តចំពោះគ្រប់បទល្មើសទាំងអស់ ក្រៅពីបទល្មើសដែលមានរបបគតិយុត្តដោយឡែក។

### ១.-បទល្មើសនយោបាយ

តាមពិត គ្មានបទល្មើសនយោបាយទេ មានតែបទល្មើសមានចរិតជានយោបាយ។

បទល្មើសនយោបាយដូចឈ្មោះរបស់វាប្រាប់ស្រាប់ គឺកម្មវត្ថុនៃបទល្មើសទាក់ទងនឹងបញ្ហានយោបាយពោលគឺ បទល្មើសធ្វើឱ្យប៉ះពាល់ដល់ការរៀបចំ និងការប្រព្រឹត្តទៅជាប្រក្រតីនៃអំណាចសាធារណៈ។ និយាយឱ្យខ្លី បទល្មើសកើតឡើងដោយហេតុផលនយោបាយ។ ក្រមព្រហ្មទណ្ឌពុំបានចែងពីបទល្មើសនយោបាយទេ។ ឈរលើមូលដ្ឋាននេះ គេអាចសន្និដ្ឋានថានៅកម្ពុជាយើងពុំមានការបែងចែក រវាងបទល្មើស នៃនីតិរូមនិងបទល្មើសនយោបាយទេ។ បទល្មើសនយោបាយត្រូវស្ថិតក្រោមសមត្ថកិច្ចតុលាការនៃនីតិរូម ហើយឃាតកម្មលើប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ឬ ឥស្សរជនសំខាន់ក្នុងរដ្ឋាភិបាល ជាបទល្មើសដែលមាន ទោសដូចជាឃាតកម្មលើពលរដ្ឋទូទៅដែរ។ តែបើពិនិត្យមើល លើចេតនាទុច្ចរិតវិញ ឃើញថាមានសភាពធ្ងន់ ធ្ងរណាស់។ តាមពិត វាជាបទមនុស្សឃាត តែបើគេយកឋានៈជនរងគ្រោះជាមូលដ្ឋាន បទល្មើសនៃនីតិរូម(បទឃាតកម្ម) អាចក្លាយជាបទល្មើសនយោបាយ។

ក្រមព្រហ្មទណ្ឌពុំបានចែងពីបទល្មើសនយោបាយទេ។ ក្រមនីតិវិធីព្រហ្មទណ្ឌ ធ្វើការបែងចែកបទល្មើសនៃនីតិរូម ចេញពីបទល្មើសនយោបាយ ហើយការកំណត់នេះ ក្នុងវត្ថុបំណងតែមួយប៉ុណ្ណោះ គឺបត្យាប័នត្រូវបានបដិសេធ(មាត្រា ៥៧៣): "កាលណាអំពើចោទប្រកាន់មានលក្ខណៈនយោបាយ។ ប៉ុន្តែ

មិនត្រូវចាត់ទុកថាជាបទល្មើសនយោបាយទេ អំពើហិង្សាដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ជីវិត ដល់បូរណភាពខាងរូបកាយ ឬដល់សេរីភាពបុគ្គល"។ មាត្រានេះ មិនអនុញ្ញាតឱ្យគេកំណត់ថាតើអ្វីទៅជាបទល្មើសនយោបាយឱ្យបានច្បាស់លាស់នៅ ឡើយ។ ដូចគ្នាផងដែរ ច្បាប់ស្តីពីការប្រឆាំងនឹងអំពើភេរវកម្ម ប្រកាសឱ្យប្រើនាថ្ងៃទី ៣០ កក្កដា ២០០៧ ត្រង់ មាត្រា ៩៣ បដិសេធការផ្តល់បត្យាប័នចំពោះបទល្មើសនយោបាយ និងបទល្មើសសារពើពន្ធ។ តែច្បាប់ចុងក្រោយនេះ បានពន្លេចឱ្យគេអាចកំណត់ពីលក្ខណៈវិនិច្ឆ័យខ្លះពីបទ-ល្មើសនយោបាយ : "បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ និងបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេសនឹងពុំត្រូវបានចាត់ទុកជាបទល្មើសនយោបាយឡើយ ចំពោះបទល្មើស ពាក់ព័ន្ធនឹងបទល្មើសនយោបាយ ឬបទល្មើសដែលកើតឡើងដោយ*ហេតុផលនយោបាយ* ឬជាបទល្មើសសារពើពន្ធឡើយ សម្រាប់គោលបំណងបត្យាប័ន និងជំនួយទៅវិញទៅមក"។

២.-បទល្មើសយោធា

បទល្មើសយោធា "ជាបទល្មើសដែលទាក់ទិនដល់យោធិន ទាំងយោធិនជាប់កិច្ចសន្យា ទាំងយោធិនកំណែន ហើយដែលពាក់ព័ន្ធដល់បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា"(មាត្រា ១១ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០-៩-១៩៩២)។ បទល្មើស យោធាស្ថិតក្រោមសមត្ថកិច្ចតុលាការយោធា ហើយបទល្មើសដែលប្រព្រឹត្តដោយ យោធិន ក្រៅពី "*បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា*"។

កាលបើក្រមព្រហ្មទណ្ឌមិនបានបញ្ជាក់ថាប្រភេទបទល្មើសដូចមានចែងក្នុងជំពូកទី ២ខាងលើនេះ ប្រព្រឹត្ត ដោយយោធិនទាក់ទងនឹង "បទវិន័យយោធា ឬការខូចខាតទ្រព្យសម្បត្តិយោធា" ស្ថិតក្រោមសមត្ថកិច្ចនៃតុលាការនៃនីតិរូម(តុលាការធម្មតា)។

សួរថាតើតុលាការយោធាដែលមានសមត្ថកិច្ចផ្តាច់មុខក្នុងការជំនុំជម្រះបទល្មើសយោធា នឹងត្រូវដកហូតដែរឬទេ ? ថ្វីបើក្រមនេះ ពុំបានយកចិត្តទុកដាក់ពីបញ្ហានេះក៏ដោយ ក៏គេឃើញសេចក្តីព្រាងច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ ត្រង់ជំពូកទី ៥ បានចែងអំពីតុលាការយោធា : "តុលាការយោធាមាន ទីតាំងនៅរាជធានីភ្នំពេញ និងមានសមត្ថកិច្ចលាតសន្ធឹងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា ១១៦) ... មានសមត្ថកិច្ចជំនុំជំរះបទល្មើសយោធា ដោយបើកផ្លូវឧទ្ធរណ៍នៅចំពោះមុខសភាព្រហ្ម-ទណ្ឌនៃសាលាឧទ្ធរណ៍។ បណ្តឹងសារទុក្ខ ត្រូវជំនុំជម្រះនៅចំពោះមុខសភាព្រហ្មទណ្ឌនៃតុលាការកំពូល (មាត្រា ១១៧)។ វិធានស្តីពីសមត្ថកិច្ច ការចាត់តាំង និងដំណើរការ នៃតុលាការយោធា ត្រូវកំណត់ដោយច្បាប់ស្តីពីតុលាការយោធា (មាត្រា ១១៨)"។ ជាវិបាក នៅក្រោយពេល ដែលក្រមខាងលើចូលជាធរមាន និងចូលអនុវត្ត នោះតុលាការយោធានឹងបាត់បង់នូវសមត្ថកិច្ចរបស់ខ្លួន។

៣.-អំពើភេរវកម្ម

អំពើភេរវកម្មជាប្រភេទបទល្មើសថ្មីនាសតវត្សទី ២១ នេះ ហើយក៏ជាប្រភេទនៃបទល្មើសដែលមតិភាគច្រើន បានយល់ស្របគ្នាថាជាបទល្មើសដ៏សែនគ្រោះថ្នាក់បំផុតចំពោះមនុស្សជាតិ មិនត្រឹមតែសំរាប់ជាតិណាមួយនោះទេ តែចំពោះសហគមន៍អន្តរជាតិទាំងមូល។ ហេតុនេះ បទល្មើសភេរវកម្មត្រូវបានរៀបចំជាពិសេសដោយអ្នកនីតិប្បញ្ញត្តិ។ ច្បាប់ចុះថ្ងៃទី ៧ កុម្ភៈ ១៩៩២ បានឱ្យនិយមន័យថា "អំពើភេរវកម្ម ជាអំពើហិង្សាទាំងឡាយ ដែលប្រព្រឹត្តដោយ ជនមួយនាក់ ឬច្រើននាក់ ឬជនមួយក្រុម ឬច្រើនក្រុម *បង្កើតការភិតភ័យតក់ស្លុតក្នុងចំណោមប្រជាជន ក្នុងគោលដៅធ្វើឱ្យជ្រួលច្របល់យ៉ាងខ្លាំងដល់ សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ និងឱ្យប៉ះពាល់ស្ថិរភាពនយោបាយ*"[២៦]។ ច្បាប់នេះមានតែ ៤ មាត្រា។ ច្បាប់នេះអនុវត្តលើអំពើភេរវកម្ម ការចាប់ជំរិត និងបង្ខាំងមនុស្សដោយខុសច្បាប់ ក្នុងគោលដៅធ្វើវិច្ឆេទកម្ម ទារប្រាក់ សងសឹក ធ្វើជាចំណាត់ខ្មាំង យកទៅលក់.... ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ ឆ្នាំ ទៅ ២០ ឆ្នាំ ឬអស់មួយជីវិត ក្នុងករណី :

១-អនីតិភាពនៃជនរងគ្រោះ

២-មរណៈភាពនៃជនរងគ្រោះ និង

៣-ការគិតទុកជាមុន។

ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ចុះថ្ងៃទី ២២ កក្កដា ២០០៧ ត្រូវបានរៀបចំឡើង ដើម្បីឱ្យកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទប់ស្កាត់អំពើភេរវកម្ម។ ជាពិសេស សក្តានុពលនៃអំពើភេរវកម្ម អាចកើតឡើង នៅគ្រប់ទីន្លែង និងគ្រប់ពេលវេលា។ ច្បាប់នេះកំណត់បទល្មើសទាំងឡាយចាំបាច់ និងចែងពីលទ្ធភាពក្នុងការបង្កកប្រាក់ និងការរឹបអូសទ្រព្យបំរើឱ្យភេរវកម្ម ព្រមទាំងបត្យាប័ន និងការជួយគ្នាទៅវិញទៅមកជាអន្តរជាតិ។ ច្បាប់ថ្មីនេះ ផ្តន្ទាទោសចាប់ពី ១០ ឆ្នាំឡើងទៅ។

បន្ទាប់ពីសិក្សាអំពីចំណាត់ថ្នាក់នៃបទល្មើសរួចមក យើងទាញបានសេចក្តីសន្និដ្ឋានបានថា បទល្មើសទោះមានប្រភេទជាអ្វី និងមានលក្ខណៈនៃការសម្រេចផលយ៉ាងណា ក៏បទល្មើសនោះដោយយោងទៅលើទណ្ឌកម្មដាក់ ពន្ធនាធាគារ និងពិន័យជាប្រាក់ដែលត្រូវរង គ្រប់បទល្មើសត្រូវបានបែងចែកជា បីប្រភេទធំៗ គឺបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ដូចក្រមព្រហ្មទណ្ឌបានទទួលស្គាល់តែចំណាត់ថ្នាក់នេះ។

[២៦] មាត្រា ១ នៃច្បាប់ស្តីពីផ្តន្ទាទោសអំពើភេរវកម្ម ចុះថ្ងៃទី ៧ កុម្ភៈ ១៩៩២។

# ជំពូកទី ២ ការទទួលខុសត្រូវព្រហ្មទណ្ឌ

**សញ្ញាណនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**..ការទទួលខុសត្រូវព្រហ្មទណ្ឌ ជាកាតព្វកិច្ចរបស់ជន-ល្មើសក្នុងការ ទទួលយកវិបាកព្រហ្មទណ្ឌ ដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។ ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវផ្អែកលើ "ពិរុទ្ធភាព" ហើយត្រូវតែជាពិរុទ្ធភាពផ្ទាល់ខ្លួន ពោលគឺកើតចេញពីកំហុស(ទោះដោយចេតនា ឬដោយអចេតនា) របស់ជនល្មើសផ្ទាល់។ មាត្រា ២៤ ចែងពីការទទួលខុសត្រូវផ្ទាល់ខ្លួន "បុគ្គលម្នាក់ទទួលខុសត្រូវចំពោះអំពើផ្ទាល់ខ្លួន តែប៉ុណ្ណោះ"។ គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ បដិសេធការទទួលខុស ត្រូវព្រហ្មទណ្ឌចំពោះ អំពើអ្នកដទៃ និងជាសមូហភាព។

យោងតាមក្រមព្រហ្មទណ្ឌ នៅពេលជនណាម្នាក់ប្រព្រឹត្តបទល្មើស មិនទាន់ប្រាកដថាជននោះ ត្រូវទទួលខុស ត្រូវព្រហ្មទណ្ឌនៅឡើយទេ(ក្រមព្រហ្មទណ្ឌ ពីមាត្រា ៣១ ដល់មាត្រា ៣៧)។

**បទល្មើស និងការទទួលខុសត្រូវព្រហ្មទណ្ឌ : ការទទួលខុសត្រូវដោយស្វ័យប្រវត្ត ?**..អំណានបទប្បញ្ញត្តិ ព្រហ្មទណ្ឌហាក់ស្តែងឱ្យគេសន្និដ្ឋានថា នៅពេលមានបទល្មើស គឺមានការទទួលខុសត្រូវព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ វាមិនដូច្នេះទេ។ នៅពេលអំពើសម្ភារៈណាមួយបានបង្កព្យសនកម្ម ហើយសម្រេចបានជាបទល្មើសព្រហ្មទណ្ឌនឹងអាចដាក់ជនល្មើសឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ កាលណាអំពើនោះអាចទំលាក់កំហុសលើចារីនៃ**អំពើបាន** បើពុំនោះទេ ទោះបីជាមាន បទល្មើស ក៏ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌដែរ។ ផ្តើមចេញពីគោលការណ៍នេះ គេសង្កេតឃើញថា ក្នុងករណីខ្លះ បុគ្គលម្នាក់**ប្រព្រឹត្តអំពើដែលអាចចាត់ ជាបទល្មើស** ដោយសារតែកាលៈទេសៈ ឬស្ថានភាពខាងក្រៅ ឬខាងក្នុងខ្លួនតម្រូវ(និយាយម្យ៉ាងទៀតថាបុគ្គលគ្មានជម្រើសអ្វីផ្សេងក្រៅពីប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសខ្លួនឱ្យផុតពីហេតុការណ៍ ដ៏អាក្រក់ ដែលខ្លួនកំពុងពើប្រទះ) គេបានចោទសួរថាតើគួរ ឬមិនគួរឱ្យទទួលខុសត្រូវព្រហ្មទណ្ឌ ? និយាយម្យ៉ាងទៀត ថាតើការប្រព្រឹត្តបទល្មើសក្នុងស្ថានភាពបែបនេះ អាចចាត់ទុកថាជាកំហុសដែរ ឬទេ បើចារីគ្មានចេតនាទុច្ចរិតទេនោះ ?

លទ្ធផលនៃអំពើសម្ភារៈត្រូវតែកើតចេញពីឆន្ទៈរបស់ចារី មានន័យថាទោះមានព្យសនកម្មបង្កឡើងដោយអំពើ សម្ភារៈក៏ដោយ ក៏ចារីនឹងមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើសម្ភារៈនោះមិនកើតចេញពីឆន្ទៈ និង សកម្មភាពសម្ភារៈរបស់ខ្លួនទេ (ភាពអាចទំលាក់កំហុសបាននៃ អំពើ=ចំណងហេតុផលពីអំពើទៅរកព្យសនសកម្ម)។ ជាបន្ត ប្រសិនបើជនល្មើសមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ តើមិនមានន័យថាអំពើអនីត្យានុកូលដែលបង្កព្យសនកម្ម ខាងទ្រព្យសម្បត្តិ ឬព្យសនកម្មខាងបូរណភាពរូបរាងកាយ ដែលជនរងគ្រោះទទួលរងនឹងត្រូវបដិសេធ ?

ផ្តើមចេញពីការសង្កេតខាងលើនេះ គេត្រូវស្វែងរកអ្នកដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ លក្ខខណ្ឌដែលអាចឱ្យមានការទទួលខុសត្រូវ និងសិទ្ធិជនរងគ្រោះក្នុងការទាមទារសំណងខូចខាតដែលកើត ចេញពីអំពើអនីត្យានុកូលដែលអាចជា ឬមិនអាចជាបទល្មើស។

**ការទទួលខុសត្រូវព្រហ្មទណ្ឌសមូហភាព ?**..ការលើកឡើងខាងលើនេះ សុទ្ធតែងាយស្រួល មិនមានការលំបាកអ្វីសូម្បីតែបន្តិច ក៏ប៉ុន្តែ ការស្វែងរកបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ វាជារឿងមួយពិបាក ប្រសិនបើមានបុគ្គល ច្រើន ចូលរួមញ៉ាំងឱ្យព្យសនកម្មមួយ(បទល្មើស) កើតឡើង ករណីដូចជាមានអ្នកបរបាញ់ចំនួន ៨ នាក់ បានបាញ់ ព្រួញទៅ កាន់ទិសតែមួយក្នុងល្បឿនប្រហាក់ប្រហែលគ្នា ហើយបានដកហូតអាយុជីវិតជនរងគ្រោះដោយគ្រប់ព្រួញ តែមួយផ្លែប៉ុណ្ណោះ(គេមិនអាចបែងចែកគ្រប់ព្រួញទេ) ឬក៏ករណីដែលប្រជាពលរដ្ឋមួយក្រុមបាននាំគ្នាវាយជនល្មើស (ចោរឆក់បួន់) ម្នាក់មួយដៃ មួយជើង បណ្តាលឱ្យជនល្មើសស្លាប់ ដែលតាមការសិក្សាបង្ហាញថា បើបំបែកចេញពីគ្នា ទម្ងន់មួយដៃ មួយជើងមិនអាចសំលាប់ជនល្មើសបានទេ ...។

ក្នុងរឿងព្រហ្មទណ្ឌ គ្មានការទទួលខុសត្រូវព្រហ្មទណ្ឌជាសមូហភាព ដូចករណីការទទួលខុសត្រូវរួមគ្នាក្នុងរឿងរដ្ឋប្បវេណី ឬពាណិជ្ជកម្មទេ ....។

**ភ្លើងជាអ្នកបម្រើដ៏ល្អ តែជាចៅហ្វាយដ៏អាក្រក់ យ៉ាងណាមិញ គំនិតក៏យ៉ាងនោះដែរ។**

# ផ្នែកទី ១ ភ្នាក់ងារនៃបទល្មើស

នៅទីនេះ គេត្រូវកំណត់ថានរណាខ្លះអាចជាជនល្មើស ហើយជនល្មើសមានប៉ុន្មានប្រភេទ? អ្វីខ្លះ ?

## កថាខណ្ឌទី ១ បុគ្គលដែលអាចជាជនល្មើស

ដើមឡើយ នីតិព្រហ្មទណ្ឌមានកម្មវត្ថុតែលើរូបវន្តបុគ្គលដែលមានរូបរាង និងអាចពាល់បាន។ ប៉ុន្តែនៅសម័យទំនើបគេបានគិតគូរពីការដាក់ទណ្ឌកម្មចំពោះនីតិបុគ្គល ថ្វីបើអំពើនេះគឺរូបវន្តបុគ្គលជាអ្នកប្រព្រឹត្ត។ ព្រះរាជាណាចក្រកម្ពុជាយើងក៏បានគិតគូរពីបញ្ហានេះផងដែរ។ ច្បាប់បញ្ញត្តថា **អំពើខ្លះ**របស់ *រូបវន្តបុគ្គល* ឬ *នីតិបុគ្គល* ដែលបង្កចលាចលដល់សង្គមជាបទល្មើស(មាត្រា ២)។ ព្រះរាជាណាចក្រកម្ពុជាយើងទទួលស្គាល់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។

### ក. រូបវន្តបុគ្គល

ច្បាប់ព្រហ្មទណ្ឌតម្រង់ទិសដៅឆ្ពោះចំរូបវន្តបុគ្គលដែលជាសមាជិកសង្គមម្នាក់ ដែលធ្វើសកម្មភាពក្នុងជីវភាពប្រចាំថ្ងៃ។ អ្នកដែលអាចបង្កឱ្យមានភាពចលាចល និងភាពរីករវដល់សង្គម គឺមានតែរូបវន្តបុគ្គល។ ហេតុនេះ ការសិក្សាពីប្រធានបទល្មើសរូបវន្តបុគ្គល ផ្តោតលើរូបវន្តបុគ្គលដែលមានសម្បទាគ្រប់គ្រាន់ក្នុងការទទួលយកវិបាកដែលកើតចេញពីអំពើរបស់ខ្លួន។ មានន័យថាមិនមែនគ្រប់រូបវន្តបុគ្គលទាំងអស់សុទ្ធតែអាចមានលក្ខណៈសម្បត្តិ និងសមត្ថភាពទទួលយកវិបាកនៃអំពើរបស់ខ្លួនទេ។ ជាគោលការណ៍ នីតិជនមានសម្បទាគ្រប់គ្រាន់ក្នុងការទទួលយកវិបាកនៃអំពើ ក្នុងនោះច្បាប់ព្រហ្មទណ្ឌធ្វើការបែងចែកនីតិជនជាពីរប្រភេទ : នីតិជនដែលមានសតិគ្រប់គ្រាន់ ដឹងខុសត្រូវ និងអាចវិនិច្ឆ័យផលវិបាកដែលកើតចេញពីអំពើរបស់ខ្លួន និងនីតិជនដែលបាត់បង់សតិ ហើយបាត់បង់សមត្ថភាព យល់ដឹងពីសភាពគ្រោះថ្នាក់នៃអំពើរបស់ខ្លួនបាន(បន្ថយ ឬលប់បំបាត់ការទទួលខុសត្រូវព្រហ្មទណ្ឌ)។ ចំណែក អនីតិជន ត្រូវបានសន្មត ថាមិនមានសម្បទាគ្រប់គ្រាន់ ក្នុងការយល់ដឹងពីសភាពគ្រោះថ្នាក់នៃអំពើរបស់ខ្លួនទេ ជាហេតុឱ្យមិនមានការទទួលខុសត្រូវព្រហ្មទណ្ឌ ហើយបើមានក៏កើតចេញពីហេតុផលផ្សេង ដូចជាការគិតគូរអំពីការប្រើអនីតិជនជា

ចរិវផ្ទាល់ក្នុងការប្រព្រឹត្ត ក៏ដូចជាការដាក់ឱ្យបទល្មើសបានសម្រេចផល ឬការលើកទឹកចិត្ត និងជំរុញឱ្យអនីតិជនប្រព្រឹត្តបទល្មើស។ ក្រមព្រហ្មទណ្ឌបានគិតគូរពីបញ្ហានេះ ដោយបង្កើតគោលការណ៍មួយគឺការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ហើយបានទុកលទ្ធភាពឱ្យចៅក្រមគិតគូរ និងពិចារណាពីភាពចាំបាច់ក្នុងការដាក់ឱ្យ អនីតិជនទទួលខុសត្រូវព្រហ្មទណ្ឌ។

ចំពោះជនល្មើសជាអនីតិជន

-គោលការណ៍: អនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ហើយ "អនីតិជនដែលប្រព្រឹត្តបទល្មើសជាកម្មវត្ថុ នៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ" ដែល "មានដូចតទៅ :

១-ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។

២-ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣-ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

៤-ការប្រគល់អនីតិជនឱ្យ ទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥-ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ"។ "ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះផ្ញើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ" (មាត្រា ៤១)។ គោលដៅនៃវិធានការណ៍ទាំងនេះ គឺធានានិងទុកលទ្ធភាពឱ្យមានការកែប្រែដើម្បីអាចមករួមរស់ក្នុងសង្គមឡើងវិញ។

-អញ្ញត្រកម្ម "តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ"(កថាខណ្ឌទី ២ នៃ មាត្រា ៣៩)។ ជាគោលការណ៍ អនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ លើកលែងតែចៅក្រមយល់ឃើញថាដោយយោងលើ "កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ" ហើយប្រែក្លាយការដាក់ពន្ធនាគារជាការអប់រំ និងកែប្រែក្នុងទិសដៅស្តារនីតិសម្បទាឡើងវិញ ក្នុងការចូលមករួមរស់ក្នុងសង្គមវិញ ហើយវិធានការផ្សេងពីនេះពិតជា មិនមានប្រសិទ្ធភាពកែប្រែអនីតិជននោះទេ។ ដូចគោលការណ៍ដែលក្រមនេះកំណត់យកទណ្ឌកម្មដកហូតសេរីភាព ដើរហើរអាចប្រើបានក្នុងគោលដៅកែប្រែដែលវិធីអប់រំ

ធម្មតាក្រៅពីដាក់ក្នុងពន្ធនាគារពុំអាចប្រព្រឹត្តទៅបាន។ និយាយឱ្យខ្លី អនីតិជនដែលជាជនល្មើសស្ថិតក្នុងក្របខណ្ឌនៃការកែប្រែ និងអប់រំ។

## ខ.-នីតិបុគ្គល

**ប្រវត្តិនិងមូលដ្ឋាននៃការបដិសេធ.-**ការដាក់ឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានបដិសេធដោយឈរលើមូលដ្ឋានបីយ៉ាង

១-នីតិបុគ្គលគ្រាន់តែជាសេចក្ដីសន្មត(fiction Juridique) ដែលគ្មានឆន្ទៈផ្ទាល់ខ្លួនទេ មានតែរូបវន្ត-បុគ្គលទេ ទើបជាម្ចាស់នៃឆន្ទៈដែលជាលក្ខខណ្ឌមួយនាំឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ

២-នីតិបុគ្គលចូល រួមក្នុងសកម្មភាព និងជីវភាពសង្គម តាមរយៈគោលបំណង (objet social) ដែលពិតជាមិនមានគោលដៅប្រព្រឹត្ត បទល្មើសទេ និង

៣-មានវិសមិត្តភាពរវាងទណ្ឌកម្ម និងនីតិបុគ្គល ដោយហេតុថាគោលគំនិតនៃការដាក់ទណ្ឌកម្ម គេសំដៅតែលើរូបវន្តបុគ្គលប៉ុណ្ណោះ។ លើសពីនេះ លទ្ធិបានលើកឡើងពីភាពអយុត្តិធម៌ជុំវិញទស្សនៈ ដែលគាំទ្រការអនុញ្ញាតឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល : "តាមរយៈការផ្ដន្ទាទោសនីតិបុគ្គល ការផ្ដន្ទាទោសនេះ ពិតជាធ្វើឡើងដោយមិនរើសមុខរវាងអ្នកដែលប្រព្រឹត្តបទល្មើស និងអ្នកដែលមិនបានប្រព្រឹត្ត ហើយការណ៍នេះជា ការដើរថយក្រោយមិនមែនជាការរីកចំរើននោះទេ"។

**មូលដ្ឋាននៃការដាក់ឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ.-**ចរន្តគំនិតថ្មីបានមកដល់ ហើយតាមការសង្កេតបានឱ្យដឹងថាជាញឹកញាប់បទល្មើសត្រូវបានប្រព្រឹត្តក្នុងក្របខណ្ឌសហគ្រាស ដែលជាហេតុនាំឱ្យមានការគិតគូរឡើងវិញ នូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។ ទឡ្ហីករណ៍បីយ៉ាងត្រូវ បានលើកឡើងជាមូលដ្ឋានពិចារណា :

១-ប្រឈមនឹងគំនិតនៃសេចក្ដីសន្មត គេលើកឡើងថានីតិបុគ្គលបានក្លាយជាការពិតទៅហើយ ហើយក្នុងជីវភាពប្រចាំថ្ងៃ បទល្មើសប្រព្រឹត្តដោយនីតិបុគ្គលជាបាតុភូតឧក្រិដ្ឋមួយដ៏ពិតប្រាកដ បើទោះជារូបវន្តបុគ្គលជាអ្នកប្រព្រឹត្ត

២-ថ្វីបើ នីតិបុគ្គលចូលរួមក្នុងជីវភាពសង្គមតាមរយៈគោលបំណង ក៏មាននីតិបុគ្គលខ្លះធ្វើសកម្មភាពក្រៅពីក្របខណ្ឌនៃគោលបំណងនេះដែរ ដែលសកម្មភាពនេះអាចជាការបំបិទដាននៃការប្រព្រឹត្តបទល្មើស

៣-ការពន្យល់ទាក់ទងនឹងវិសមិត្តភាពនៃទោស គឺទោសដកហូតសេរីភាពមិនអាចអនុវត្ត ចំពោះនីតិបុគ្គលទេ ឯទោសពិន័យជាប្រាក់ ការរឹបអូស ការបិទគ្រឹះស្ថាន ការហាមឃាត់ការប្រកបអាជីវកម្មណាមួយ ឬការរំលាយអាចប្រព្រឹត្តទៅបាន។ តាមទស្សនៈ និងតួនាទីរបស់ទណ្ឌកម្ម គឺការគំរាមកំហែង

និងការបង្ការ ដែលទណ្ឌកម្មប្រភេទនេះពិតជា អាចឆ្លើយតបបានយ៉ាង សមស្របជាមួយនឹងលក្ខណៈពិសេសមួយៗនៃនីតិបុគ្គល និងជាចុងក្រោយការផ្តន្ទាទោសដោយមិនរើសមុខ។

យោងតាមក្រមព្រហ្មទណ្ឌ(មាត្រា ៤២)៖ នីតិបុគ្គលនឹងអាចត្រូវបានប្រកាស ថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ដរាបណាបទប្បញ្ញត្តិច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀតចែងជាក់លាក់ ហើយការទទួល ខុសត្រូវនេះជាការទទួលខុសត្រូវចំពោះអំពើដែលជាបទល្មើសប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដែលធ្វើសកម្មភាព ដើម្បីនិងជា ប្រយោជន៍របស់នីតិបុគ្គលនេះ។ គ្រប់នីតិបុគ្គលសុទ្ធតែត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ លើកលែង តែរដ្ឋចេញ។ លើសពីនេះ មាត្រាដដែលត្រង់កថាខណ្ឌទី ២ គូសបញ្ជាក់យ៉ាងដូច្នេះ ថា "ការទទួលខុសត្រូវព្រហ្មទណ្ឌ របស់នីតិបុគ្គលមិនលើកលែង នូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ"។

## កថាខណ្ឌទី ២ អំពីរបៀបនៃការប្រព្រឹត្តបទល្មើស ឬឋានៈរបស់ជនល្មើស

ដោយហេតុថា រូបវ័ន្តជាអ្នកមានសមត្ថភាពអាចឱ្យបទល្មើសមួយកើតឡើង ចំណែកនីតិបុគ្គលប្រព្រឹត្តបទល្មើសតាមរយៈតំណាងរបស់ខ្លួនដែលសុទ្ធតែជារូបវន្តបុគ្គល ទើបយើងលើកយកតែ រូបវន្តបុគ្គលមកសិក្សាប៉ុណ្ណោះ នៅទីនេះ។

ប្រធាននៃបទល្មើសរូបវន្តបុគ្គលនៃអំពើសម្ភារៈអាចជាចារី សហចារី អ្នកផ្តើមគំនិត និងជាអ្នកសមគំនិត។ ផ្តើមចេញពីការអង្កេតមួយបានបង្ហាញឱ្យឃើញថា មានរូបភាពពីរយ៉ាងនៃការប្រព្រឹត្តបទល្មើស គឺការប្រព្រឹត្តបទល្មើសដោយបញ្ចេញសកម្មភាព និងដោយមិនបញ្ចេញសកម្មភាពសម្ភារៈ។ ម្យ៉ាងទៀត គឺការចូលរួមធ្វើ សកម្មភាពសម្ភារៈក្នុងគោលដៅញ៉ាំងឱ្យបទល្មើសមួយបានសម្រេច និងមួយទៀតមិនមានវត្តមាននៅពេលដែល បទល្មើសត្រូវបានប្រព្រឹត្តទេ បើមានក៏មិនបានចូលរួមធ្វើសកម្មភាពដោយផ្ទាល់ដែរ ដោយគ្រាន់តែជួយជំរុញឱ្យ បទល្មើសងាយសម្រេចផលប៉ុណ្ណោះ។

ដោយឈរលើមូលដ្ឋាននៃសភាពគ្រោះថ្នាក់នៃអំពើ អ្នកនីតិប្បញ្ញត្តិបានលើកយកបញ្ហានេះ មកគិតគូរ ហើយ កំណត់យកវិធានមួយដើម្បីដាក់ទោសការប្រព្រឹត្តបទល្មើសដោយមិនផ្ទាល់ គឺជនល្មើសដោយមិនផ្ទាល់ ត្រូវទទួលរងទោសព្រហ្មទណ្ឌដូចជាបានប្រព្រឹត្តបទល្មើសដោយខ្លួនឯងផ្ទាល់។ នេះជាគោលការណ៍ខ្ទឹពិរុទ្ធភាពនៃអំពើ។

### ក.-ជនល្មើសផ្ទាល់

ជនល្មើសផ្ទាល់ សំដៅយកបុគ្គលដែលញ៉ាំងឱ្យបទល្មើសមួយបានសម្រេចដោយស្នាដៃរបស់ខ្លួនផ្ទាល់។

១-ចារី

ពាក្យចារីនេះ សំដៅលើតួនាទីជាប្រធាន ជាធំ និងជាហេតុសំខាន់ក្នុងការញ៉ាំងបទល្មើស ឱ្យសម្រេចផល។ ចារីជាបុគ្គលដែល*ប្រព្រឹត្តបទល្មើស*ដែលត្រូវចោទប្រកាន់(មាត្រា ២៥)។ នឹងអាចជាចារីបាន លុះណាតែបានប្រព្រឹត្តបទល្មើសតាមរយៈការប្រតិបត្តិអំពើសម្ភារៈដោយខ្លួនឯងក្នុងគោលដៅអនុវត្តគំរោង។ ម្យ៉ាងទៀត បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ(មាត្រា ២៤)។ តាមគោលការណ៍នេះ បដិសេធការទទួលខុស ត្រូវព្រហ្មទណ្ឌ ជាសមូហភាព ឬការទទួលខុសត្រូវ ចំពោះអំពើរបស់អ្នកដទៃ។ *ចារីនៃអំពើ*ជាលក្ខខណ្ឌ មូលដ្ឋានក្នុងការ ស្វែងរកទទួលខុសត្រូវព្រហ្មទណ្ឌ។ ដូចនេះ ចារីសំដៅយកបុគ្គលដែលបាន *ប្រព្រឹត្តអំពើសម្ភារៈ* ហើយជាអ្នកធ្វើឱ្យ *បទល្មើសបានសម្រេចដោយផ្ទាល់*។

២-សហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់*បានព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់*(មាត្រា ២៥): បុគ្គលដែលចូលរួមដោយសកម្មភាពជាចម្បង និងបន្ទាប់បន្សំដែលបានញ៉ាំងបទល្មើសឱ្យសម្រេចផល ដោយស្នាដៃខ្លួន។ សហចារីចូលរួមក្នុងនាមជាសហសេវិកម្នាក់ ក្នុងការជំរុញឱ្យការសម្រេចចិត្តប្រព្រឹត្តបទល្មើសបាន ដល់គោលដៅគ្រោងទុក។ តាមន័យនេះ ចារីចម្បងក៏ជាសហចារីផងដែរ។

### ខ.-ជនល្មើសមិនផ្ទាល់

ជនល្មើសមិនផ្ទាល់ សំដៅយកបុគ្គលដែលមិនបានញ៉ាំងឱ្យបទល្មើសមួយបានសម្រេចផល ដោយស្នាដៃរបស់ខ្លួនផ្ទាល់ទេ តែបានចូលរួមដោយប្រយោលក្នុងការញ៉ាំងបទល្មើសមួយឱ្យសម្រេច(ជំនួយស្មារតី សម្ភារៈ និងគំនិត)។ បទល្មើសកើតដោយស្នាដៃបុគ្គលដទៃ។ នេះជាហេតុធ្វើឱ្យមានការពិនិត្យឡើងវិញនូវគោល-ការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ : តើមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើអ្នកដទៃដែរ ឬទេ ?

**គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ**.-"បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌ តែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ"(មាត្រា ២៤)។ មានន័យថាបើខ្លួនមិនបានប្រព្រឹត្តអំពើទេ ខ្លួននឹងមិនត្រូវរងទោសទណ្ឌអ្វីដែរ តើ មិនមានន័យថាគ្មានការទទួលខុសត្រូវព្រហ្មទណ្ឌរួមគ្នា ឬការទទួលខុសត្រូវព្រហ្មទណ្ឌ

ចំពោះអំពើរបស់អ្នកដទៃ។ ចំលើយចំពោះបញ្ហានេះ ស្ថិតលើការបកស្រាយសញ្ញាណ "អំពើផ្ទាល់ខ្លួន" តើអំពើបែបណាខ្លះត្រូវចាត់ជាអំពើផ្ទាល់ខ្លួន ? អំពើដែលមានប្រភពចេញពីខ្លួនបុគ្គលដែលគេសំដៅ ទោះបីអំពើនោះជា "ជំនួយផ្នែកស្មារតី សម្ភារៈ និងគំនិត" ក៏ដោយ ឱ្យតែអំពើនោះជាហេតុ ឬជាដើមហេតុនាំឱ្យមានការប្រព្រឹត្តបទល្មើសមួយបានសម្រេច ឬបានប៉ុនប៉ង។ ប្រភពនៃលទ្ធផលកើតចេញពីអំពើខ្លួនមួយផ្នែកដែរ។ ហេតុនេះ ខ្លួនក៏បានចូលរួមញ៉ាំងឱ្យបទល្មើសមួយកើតឡើង វាពិតជាមានចំណងហេតុផលនៃភាពអាចទំលាក់កំហុសបានលើជនល្មើសមិនផ្ទាល់[២៧]។

១-អ្នកផ្តើមគំនិត

យោងតាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម បុគ្គលណា :

១. *ជំរុញ*ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម តាមការណែនាំ ឬការបញ្ជា និង

២. *បង្កឱ្យមាន*បទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយការផ្តល់អំណោយ ការសន្យា ឬការគំរាមកំហែង **ការញុះញង់** ការលួងលោម ឬក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន។ អ្នកផ្តើមគំនិតពុំមានវត្តនៅពេលបទល្មើសត្រូវបានប្រព្រឹត្ត តែជាដើមហេតុជំរុញ ឬបង្កឱ្យមាន ការប្រព្រឹត្តបទល្មើស ជាមេគំនិតជាកំសួលបាញ់ឆ្ពោះទៅរកលទ្ធផលដែលខ្លួនគ្រោងទុក។ និយាយម្យ៉ាងទៀត ចារីដែលទៅប្រព្រឹត្តបទល្មើសពុំមានគំនិតប្រព្រឹត្តទេ ហើយបែរជាប្រព្រឹត្តវិញ ដោយសារអ្នកផ្តើមគំនិត។ "ត្រូវចាត់ទុកថា ជាអ្នកផ្តើមគំនិតបុគ្គលណាដែលចាត់ចែង បញ្ជា ឬញុះញង់ ឱ្យបុគ្គលដទៃប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើស"[២៨]។

អ្នកផ្តើមគំនិតអាចមានទោស កាលណាបទល្មើសបានសម្រេច ឬបានប៉ុនប៉ង ហើយត្រូវផ្តន្ទាទោសដូចចារីដែរ។

២-អ្នកសមគំនិត

អ្នកសមគំនិតមានន័យថាចង់ឱ្យកើតមានបទល្មើសដែលចារីផ្ទាល់បានគ្រោងទុកកើតឡើង និងឈានទៅរកផល គឺបានសម្រេច(គំនិតត្រូវគ្នា និងស្របគ្នាដើម្បីឱ្យបទល្មើសមួយកើតឡើង) សមដូចពាក្យពេជន៍របស់ក្រមព្រហ្មទណ្ឌថា *ជួយសម្រួលដោយចេតនា*។ អ្នកសមគំនិត មិនបានប្រព្រឹត្តបទល្មើសដោយខ្លួនឯងទេ។ ដូចនេះ ធាតុចិត្តសាស្ត្រ ឬ ធាតុអត្តនោម័តជាលក្ខខណ្ឌចាំបាច់។ បុគ្គលណាដែល *ជួយសម្រួលដោយចេតនា* **ដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិម** *ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន*(ម.២៩)។

---

[២៧] លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ : អំពើអាចត្រូវផ្តន្ទាទោសបាន=បទល្មើសបានសម្រេច ឬប៉ុនប៉ង (ម. ២៨ និង ២៩)។

[២៨] មាត្រា ៥-១ ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ចុះថ្ងៃទី ២០ កក្កដា ២០០៧។

**-លក្ខខណ្ឌបឋមនៃការសមគំនិត** : ការសមគំនិតកើតមានកាលណាមានការប្រព្រឹត្តបទល្មើស។ បទល្មើសដែលប្រព្រឹត្តដោយចារី ត្រូវតែឈានដល់ដំណាក់ការប៉ុនប៉ងយ៉ាងហោចណាស់ ឬបទល្មើសបានសម្រេច ទើបអាចផ្តន្ទាទោសអ្នកសមគំនិតបាន។ និយាយឱ្យចំ ដរាបណាអំពើចម្បងត្រូវផ្តន្ទាទោស ទើបការសមគំនិតត្រូវផ្តន្ទាទោស។ នេះជាគោលការណ៍នៃការខ្ចីពិរុទ្ធភាពនៃអំពើមិនមែនខ្ចីទោសរបស់ជនដៃដល់ទេ។ អ្នកសមគំនិតខ្ចីពិរុទ្ធភាពនៃអំពើ ហាក់ដូចជា អ្នកសមគំនិតបានប្រព្រឹត្តបទល្មើសដោយដៃខ្លួន។ ការផ្តន្ទាទោសឈរលើអំពើនេះ មិនអនុញ្ញាតឱ្យ អ្នកសមគំនិតរួចផុតពីការទទួលខុសត្រូវដែលជាលក្ខណៈផ្ទាល់របស់ចារីទេ ឧ. ផ្តល់កំបិតឱ្យក្មេងអាយុក្រោម ១៤ ឆ្នាំ ប្រព្រឹត្តបទល្មើស។

**-លក្ខខណ្ឌមូលដ្ឋាន(អំពើសម្ភារៈ និងចិត្តសាស្ត្រនៃការសមគំនិត)..**ត្រូវចាត់ទុកជាអ្នកសមគំនិតបុគ្គលដែល បំពេញកិច្ចដូចមានចែងក្នុងមាត្រា ២៩ ខាងលើ ពោលគឺបាន*ជួយសម្រួល*ដោយចេតនា។ តើបញ្ជីនៃអំពើសម្ភារៈក្នុងមាត្រានេះ មានការកំណត់តែប៉ុណ្ណឹង ឬក៏អាចមានផ្សេងពីនេះទៀត ? ការសមគំនិតដោយការផ្តល់ជំនួយ ឬការឧបត្ថម្ភ =ជួយសម្រួលដោយចេតនា។ ការផ្តល់មធ្យោបាយឱ្យរៀបចំ (ឱ្យខ្ចីកាំភ្លើង ឬកាំបិត...) ឱ្យប្រព្រឹត្តបទល្មើស(ផ្តល់កន្លែងធ្វើពេស្យាចារ) ឬពន្លឿនការសម្រេចបទល្មើស (ឧបករណ៍ដឹកជញ្ជូន)។ នេះជាកិច្ចវិជ្ជមាន។ តើមានការ សមគំនិតដោយអកម្ម ឬទេ ? ការជួយសម្រួលដោយចេតនា ! គ្មានការសមគំនិតដោយអកម្មទេ។

**រូបភាពនៃការផ្តល់ជំនួយ ឬការឧបត្ថម្ភ..**ការផ្តល់ជំនួយ ឬការឧបត្ថម្ភ ជាការជួយសម្រួលក្នុងគោលដៅបង្កភាពងាយស្រួលក្នុងការរៀបចំប្រព្រឹត្តបទល្មើស ឬឱ្យបទល្មើសមួយបានសម្រេច។ តាមន័យនេះ ការផ្តល់ជំនួយ ឬការឧបត្ថម្ភត្រូវតែកើតពីអំពើវិជ្ជមាន និងមុនពេល ឬពេលដំណាលគ្នានៃការប្រព្រឹត្តបទល្មើសដោយចារី។ តាមការ វិភាគលើការផ្តល់ជំនួយ ឬការឧបត្ថម្ភ ចារីផ្ទាល់មិនតម្រូវថាត្រូវតែប្រើជំនួយ និងការឧបត្ថម្ភ ជាឧបករណ៍ សម្ភារៈ ឬ មធ្យោបាយដែលផ្តល់ឱ្យទៅប្រព្រឹត្តបទល្មើសទេ។

**<u>សំណួរត្រិះរិះ</u>** : តើបំណែងចែករវាងចារី សហចារី និងអ្នកសមគំនិត ផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

តើបំណែងចែករវាងចារី សហចារី និងអ្នកផ្តើមគំនិត ផ្តល់ផលប្រយោជន៍អ្វីខ្លះ ?

**ចេះឯងឱ្យក្រែងចេះគេ កុំនៅធំនេរ ស្វែងរកទ្រព្យធុកនៅ**

# ផ្នែកទី ២ លក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

ក្រមព្រហទណ្ឌ បានដាក់លក្ខខណ្ឌពីរយ៉ាងដើម្បីឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ : បទល្មើសព្រហ្មទណ្ឌ និងភាពអាចទំលាក់កំហុសបាន។ អំណានបញ្ចូលគ្នារវាងមាត្រា ៣ ៣១ ៣២ ៣៣ ៣៥ ៣៦ ៣៧ ៣៨ និង មាត្រា ១៦០ បានឱ្យឃើញគោលការណ៍មួយដែលក្រមព្រហ្មទណ្ឌអនុម័តយក : បើបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើស បុគ្គលនោះ នឹងទទួលខុសត្រូវព្រហ្មទណ្ឌ ដរាបណាអំពើនោះអាចទំលាក់កំហុសលើគាត់បាន ដូចមានការគូសបញ្ជាក់យ៉ាងនេះ "បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌឡើយ"[២៩]។ ចំណោទបញ្ហាស្ថិត ត្រង់លទ្ធភាពរបស់ជនរងគ្រោះនៃអំពើដែលជាបទល្មើស ឬមិនមែនអាចទទួលការជួសជុលព្យសនកម្មដែលខ្លួនបាន ទទួលរង។

ចារីនៃការប្រព្រឹត្តទល្មើស បានឈានដល់ដំណាក់កាលនៃការប្រព្រឹត្តបទល្មើសមិនមែនដោយសារតែខ្លួនចង់បាននោះទេ តែគាត់ស្ថិតក្នុងស្ថានភាពមួយដែលគ្មានជម្រើសអ្វីក្រៅពីប្រព្រឹត្តបទល្មើស។ ផ្តើមចេញពីមូលដ្ឋានដ៏រឹងមាំ នេះជំរុញឱ្យធ្វើការពិនិត្យឡើងវិញលើការកំណត់អំពើបែបនេះថាជាបទល្មើស និងគិតគូរផងដែរក្នុងករណីដែលវានៅតែ ជាបទល្មើសអំពីទោសដែលអនុវត្ត។ អ្នកប្រាជ្ញខាងទណ្ឌវិទ្យាបានយល់ស្របគ្នាថាក្នុងស្ថានភាពបែបនេះ គេមិនគួរចាត់ទុកអំពើដែលគ្មានជម្រើសក្នុងការមិនប្រព្រឹត្តបទល្មើសថា ជាបទល្មើសទេ ហើយប្រសិនបើវានៅតែជាបទល្មើស គេគួរផ្តល់ ស្ថានសម្រាលទោសដល់ចារី។ នេះជាគោលការណ៍នៃភាពអាចទំលាក់កំហុសបាននៃអំពើ។

ជាលទ្ធផលនីតិនិពន្ធខ្មែរ ដែលជំពាក់ចិត្តជាមួយនឹងការពន្យល់គូសបញ្ជាក់ហេតុផលនេះ បានទទួលយកទ្រឹស្តីនេះ ហើយកំណត់យករបបនៃការមិនទទួលខុសត្រូវ និងផ្តល់ស្ថានសម្រាលទោស : មូលហេតុពីរយ៉ាងដែលអនុញ្ញាតឱ្យរួច ផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយមូលហេតុខាងក្នុងខ្លួនជនល្មើស និងមូលហេតុខាងក្រៅខ្លួនជនល្មើស។

[២៩] តើអត្ថិភាពនៃបទល្មើសព្រហទណ្ឌ ភ្ជាប់ដោយស្វ័យប្រវត្តនូវពិរុទ្ធភាព ? សូមមើលមាត្រា ២៣ កនព និងជាឧ.មាត្រា ៣៣ ក្រមព្រហ្មទណ្ឌ។

## កថាខណ្ឌទី ១ ភាពអាចទំលាក់កំហុសបាន

ចំណងដែលចងភ្ជាប់ពីអំពើទៅលទ្ធផលនៃអំពើមិនទាន់គ្រប់គ្រាន់ទេ សកម្មភាពប្រឆាំងសង្គមត្រូវតែអាចបន្ទោសជនល្មើសបាន។ តាមន័យនេះ គេសង្កេតឃើញថា ចិត្តសាស្ត្រ ឬសភាពផ្លូវចិត្តរបស់ជនល្មើសដែលធាតុចិត្តសាស្ត្រ នេះជាសភាគមួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ និយាយម្យ៉ាងទៀត គឺកំហុសហើយកំហុស នេះត្រូវតែអាច ទំលាក់លើជនល្មើសបាន។

មានពេលខ្លះ គេមានការពិបាកក្នុងការកំណត់ពីភាពអាចទំលាក់កំហុសបាន :

-ជនរងគ្រោះត្រូវរបួសដោយកាំបិតកំពុងត្រូវបានដឹកជញ្ជូនតាមរថយន្តសង្គ្រោះបន្ទាន់ តែត្រូវស្លាប់ដោយ គ្រោះថ្នាក់ចរាចរ(អ្នកបើកបរម្ខាងទៀតរំលោភច្បាប់ចរាចរ ឬបុព្វសិទ្ធិ) ឬមកដល់មន្ទីរពេទ្យ តែពេទ្យដាក់ថ្នាំច្រឡំ ឬ ធ្វេសប្រហែសមិនពិនិត្យ និងព្យាបាលឱ្យទាន់ពេល។ ចំណោទសួរថាតើកំហុសនរណា ទើបជនរងគ្រោះស្លាប់ ដោយសារមុខរបួសកាំបិត ? ដោយគ្រោះថ្នាក់ចរាចរបង្កឡើង ដោយអ្នកបើកបរខុសច្បាប់ ? ដោយសារលោកគ្រូពេទ្យ? តើនរណាទទួលខុសត្រូវចំពោះបទមនុស្សឃាត ? តាមការពិនិត្យឃើញថាបើគ្មានគ្រោះថ្នាក់ចរាចរទេ លោកគ្រូពេទ្យ មានការប្រុងប្រយ័ត្ន និងគោរពតួនាទីខ្លួន របួសមុខកាំបិតតែមួយមុខមិនអាចផ្តាច់អាយុជីវិតរបស់ជនរងគ្រោះ បានទេ។ និងផ្ទុយមកវិញ បើគ្មានការបង្ករបួសស្នាមទេ នោះជនរងគ្រោះក៏មិនមានគ្រោះថ្នាក់ដល់អាយុជីវិតដែរ។ មានន័យថា គ្រោះថ្នាក់ចរាចរ មិនមានការដាក់ថ្នាំដោយភ័ន្តច្រឡំ(ស្លាប់ដោយប្រតិកម្មថ្នាំ) និងការខ្ជីខ្ជា មិនអើពើនឹង អ្នកជំងឺមិនមែនជាហេតុជិតនៃការទទួលមរណភាពទេ។ តែហេតុទាំងពីរជាបច្ច័យទៅវិញទៅមកដែលជាហេតុនាំឱ្យ បទល្មើសមួយបានសម្រេចផល។

ច្បាប់ធរមានខ្មែរមិនបានគិតគូរពីបញ្ហានេះទេ។ ក្រមព្រហ្មទណ្ឌបានជ្រើសរើស យកដំណោះស្រាយមួយ គឺមនុស្សឃាតដោយអចេតនា ("បទមនុស្សឃាតដោយអចេតនា គឺជាអំពើបណ្តាលឱ្យស្លាប់អ្នកដទៃដោយ : ១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា។ ២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែល ច្បាប់តម្រូវ" មាត្រា ២០៧) ឬការបង្ករបួសដោយអចេតនា ("បទល្មើសបង្កឱ្យមានរបួសដោយអចេតនា ជាអំពើបណ្តាលឱ្យមានរបួសអ្នកដទៃដោយ: ១-ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ដែលបង្កឱ្យមានអសមត្ថភាពក្នុង ការធ្វើការងារស្មើ ឬលើសពី ៨ថ្ងៃ។ ២-ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ" មាត្រា ២៣៦)ត្រូវទទួលទោសព្រហ្មទណ្ឌ ឱ្យតែបង្ហាញថាដោយការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការបំពានលើកាតព្វកិច្ចសន្តិសុខ ឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ បុគ្គលម្នាក់បានបណ្តាលឱ្យអ្នកដទៃស្លាប់ ឬមានរបួស។

## កថាខណ្ឌទី ២ ភាពមិនអាចទំលាក់កំហុសបាន

ភាពអាចទំលាក់កំហុសបានជាលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជាទូទៅ គេតែងលើកយកភាពមិនអាចទំលាក់កំហុសបានយកមកសិក្សា ដែលភាពមិនអាចទំលាក់កំហុសបាននេះ មានដូចជា អនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ការប្រតិបត្តិតាមបញ្ជាអាជ្ញាធរធម្មានុរូប ឬអាជ្ញាធរស្របច្បាប់ ការប្រព្រឹត្តអំពើដែលច្បាប់អនុញ្ញាត ឬអំពើយុត្តិការ។ ច្បាប់ខ្មែរបូរាណ[៣០] បានកំណត់យកគោលការណ៍ ហេតុចៃដន្យផលកម្មពីបូរាណ ពោលគឺបុគ្គលម្នាក់ បង្កការខូចខាតដល់អ្នកដទៃ ក្រោមការបង្គាប់បញ្ជារបស់អ្នកដទៃ មិនបណ្តាលឱ្យមានកាតព្វកិច្ចជួសជុលការខូចខាត ព្រោះអំពើបែបនោះមិនត្រូវបានចាត់ទុកជាកំហុស។ លើសពីនេះ កាលបើផលនៃអំពើនេះពុំមែនជាបំណងប្រាថ្នារបស់ ចារី ឬពុំមែនបង្កឡើងដោយផ្ទាល់ ដោយអំពើរបស់ចារី គេចាត់ទុកថានេះជាហេតុចៃដន្យ ឬជាផលកម្មពីបូរាណរបស់ ជនរងគ្រោះ ដោយចារីពុំទទួលខុសត្រូវឡើយ។ ករណីដូចជា បុរសម្នាក់លោតពីចុងត្នោតដើម្បីសម្លាប់ខ្លួន តែធ្លាក់ចំ លើបុរសម្នាក់ទៀតនៅពីក្រោមបណ្តាលឱ្យស្លាប់ បុរសអ្នកលោតនេះមិនទទួលខុសត្រូវចំពោះការស្លាប់នេះទេ។

### អនុកថាខណ្ឌទី ១ អនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

**សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ**.-ការកំណត់អំពីសមត្ថភាពរបស់ជនល្មើសក្នុងការ ទទួលយកផលវិបាកដែលខ្លួនបានបង្កឡើង។ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពី អាយុ ១៨ ឆ្នាំឡើងទៅ (មាត្រា ៣៨)។ តាមន័យនេះ អនីតិជនត្រូវបានសន្មតពីភាពមិនអាចទំលាក់កំហុសបាននៃអំពើ។ តែបើមើល មាត្រា ៣៩ និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ អនីតិជនចាប់ពីអាយុ ១៤ ឆ្នាំឡើងទៅ អាចត្រូវបាន ប្រកាសថាទទួលខុសត្រូវព្រហ្មទណ្ឌ តែទទួលបាននូវស្ថានសម្រាលទោសៈ

"កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ មូលទោស លើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១.អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

២.ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមក ដាក់ពន្ធនាគារ ២០ ឆ្នាំ។

[៣០] បណ្ឌិត **ហ៊ែល ចំរើន** *មរតកយុត្តិធម៌ខ្មែរ* ឆ្នាំ ២០០៩-២០១០ ទំ. ៣២៤-៣២៥។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ ថ្ងៃ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល"។

## អនុកថាខណ្ឌទី ២ បញ្ជាពីអាជ្ញាធរធម្មានុរូប ឬច្បាប់អនុញ្ញាត

ចរិបានប្រព្រឹត្តអំពើដែលច្បាប់អនុញ្ញាត ជាហេតុបណ្តាលឱ្យធាតុផ្សំនៃបទល្មើសបានបាត់ និងជាវិបាកពុំមាន ការទទួលខុសត្រូវព្រហ្មទណ្ឌណាមួយអាចត្រូវបានប្រកាសប្រឆាំងនឹងបុគ្គលនេះទេ។ ការពិភាក្សាបន្តលើលទ្ធភាពទទួល បានការជួសជុលព្យនកម្មបង្កលើជនរងគ្រោះ ព្រោះយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា ២ បទល្មើសមួយបង្កើតបានជាបណ្តឹងពីរផ្សេងពីគ្នាដែល "បណ្តឹងអាជ្ញាមានបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធ និងផ្តន្ទាទោសជនល្មើសតាមច្បាប់កំណត់" ចំណែកឯបណ្តឹងរដ្ឋប្បវេណីមានបំណងជួសជុលការខូចខាតដែលជនរងគ្រោះ ទទួលរងនូវសំណងជំងឺចិត្ត "ធនល្មមនឹងព្យសនកម្ម"។ ភាពចំរូងចំរាស់មួយអាចកើតមាន ប្រសិនបើគេយកមកផ្ទឹមគ្នា បណ្តាមាត្រា ២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌប្រកាសថា**ពិរុទ្ធភាព**ដែលប្រកាសដោយតុលាការព្រហ្មទណ្ឌ ប្រកាសជា លក្ខខណ្ឌនៃ ជួសជុលព្យសនកម្ម ចំណែកឯបណ្តាមាត្រា ៣៣ (ការការពារស្របច្បាប់) ៣៥ (ស្ថានភាពចាំបាច់) និងមាត្រា ៣៦ (ការបង្ខំ) នៃក្រមព្រហ្មទណ្ឌប្រកាសថាអំពើទាំងនេះជា*បទល្មើស* តែមិនមានការទទួលខុសត្រូវ ព្រហ្មទណ្ឌទេ ហើយមាត្រា ៧៥៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី អ្នកប្រព្រឹត្តអំពើដូចមានចែងក្នុងក្រមព្រហ្មទណ្ឌមិនទទួលខុសត្រូវរដ្ឋប្បវេណីទេ។

១.-បញ្ជាអាជ្ញាធរធម្មានុរូប

បញ្ជាអាជ្ញាធរធម្មានុរូប ឬបើតាមក្រមព្រហ្មទណ្ឌ បញ្ជាអាជ្ញាធរស្របច្បាប់ ត្រូវពិនិត្យមើលថាតើអាជ្ញាធរដែលដាក់ចេញបញ្ជាជាអាជ្ញាធរស្របច្បាប់ដែរឬទេហើយ តើអ្នកក្រោមបង្គាប់មានកាតព្វកិច្ចត្រូវតែគោរពតាមបញ្ជា ដោយគ្មានសិទ្ធិតវ៉ា ឬក៏អាចមិនព្រមគោរពតាមដែរឬទេ ?

-**សញ្ញាណអាជ្ញាធរធម្មានុរូប** : អាជ្ញាធរធម្មានុរូប ឬស្របច្បាប់ នៅក្នុងពីរករណី :

១-អាជ្ញាធរធម្មានុរូបជាអាជ្ញាធរសាធារណៈ ទោះជាយោធា ឬស៊ីវិល។ ក្នុងន័យនេះ ត្រូវបានបដិសេធ អាជ្ញាធរឯកជន ដូចជាឪពុក ឬម្តាយ ឬទាំងពីរដែលមានអំណាច អាណាព្យាបាល និយោជក

ជាដើមចេញបញ្ជាឱ្យអ្នកក្រោមឱវាទបំពេញកិច្ចអ្វីមួយ(បទល្មើស)ទាំងអ្នកប្រតិបត្តិ ទាំងអ្នកចេញបញ្ជា(អំពើនោះ បង្កើតជាបទល្មើសព្រហ្មទណ្ឌ)ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

២.អាជ្ញាធរសាធារណៈ ចេញបញ្ជាដែលបញ្ជា នោះត្រូវស្ថិតក្នុងដែនសមត្ថកិច្ចខ្លួន បើពុំនោះទេ បញ្ជានោះនិងមិនមែនជាបញ្ជាធម្មានុរូបទេ។ វាហាក់មានការលំបាក ក្នុងការអនុវត្តជាក់ស្តែង ព្រោះតែការ ដឹងអំពី ដែនសមត្ថកិច្ចនេះឯង។

**-បញ្ជាដែលជាក់ចេញមក** : យើងនឹងពិនិត្យទៅលើទិដ្ឋភាពទ្រឹស្តី និងច្បាប់បច្ចុប្បន្ន។

១.របកគំហើញ : តាមការវិភាគ គេឃើញមានបីករណី **ទី ១** កាតព្វកិច្ច គោរពបញ្ជាដែលបាន ដាក់ចេញមក។ ការមិនគោរពត្រូវរងទណ្ឌកម្ម ហើយបើប្រព្រឹត្តរួចផុត ពេលនោះជនក្រោមឱវាទ អនុវត្តបញ្ជា ពេលនោះអំពើនេះនឹងជាអំពើស្របច្បាប់ហើយគ្មានទោសទេ(ធម្មានុរូបកម្មនៃអំពើដោយបញ្ជា)។ **ទី ២** ការ អនុវត្តបែបនេះ បើឃើញថាអំពើនោះល្មើសច្បាប់ វាជាការងងឹតងងល់មួយ។ ហេតុនេះទើបគេបង្កើតទ្រឹស្តីទី ២ គឺការអនុវត្តបញ្ជាដោយមានហេតុផល ឬដោយការវវាសវវៃ។ ជនក្រោមឱវាទមិនត្រូវអនុវត្តបញ្ជា ដែលខុសច្បាប់ទេ ហើយការព្រងើយនឹងបញ្ជាមិនត្រូវរងទណ្ឌកម្មថានានុក្រមទេ។ **ទី ៣** បញ្ជាត្រូវតែគោរព តែមិនមែនចេះតែគោរពទេ។ ទ្រឹស្តីទី ៣ នេះ អនុញ្ញាតឱ្យជនក្រោមឱវាទធ្វើការផ្ទៀងផ្ទាត់ពីភាពស្របច្បាប់ នៃបញ្ជា។ លទ្ធភាពមិនត្រូវអនុវត្តបញ្ជាណាដែល "ខុសច្បាប់យ៉ាងជាក់ច្បាស់"។ ឃើញបែបនេះ ហើយ នៅតែបដិបត្តិ វាជាបទល្មើស ព្រោះអំពើនោះមិនត្រូវបានធ្វើធម្មានុរូបកម្មដោយបញ្ជាមិនស្របច្បាប់ ឡើយ។

២.ច្បាប់វិជ្ជមាន : មិនទាន់ឃើញមានចែងនៅឡើយ។ ក្រមព្រហ្មទណ្ឌ "បុគ្គលណាដែលប្រព្រឹត្ត អមពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនេះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើ ខុសច្បាប់យ៉ាងជាក់ច្បាស់"(មាត្រា ៣២ កថាខណ្ឌទី ២)។ លើសពីនេះ ក្រមព្រហ្មទណ្ឌបានគូសបញ្ជាក់ ត្រង់កថាខណ្ឌទី ៣ ទៀតថា "ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទឧក្រិដ្ឋប្រល័យ ពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹង មនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យរួចផុតពីការទទួល ខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុង ករណី មានមូលហេតុដូចខាងក្រោមក៏ដោយ :

១.ជនល្មើសនេះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២.បុគ្គលនេះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់"។

គេមិនអនុញ្ញាតឱ្យមានការធ្វើធម្មានុរូបកម្ម ការគោរពបញ្ជាឱ្យប្រព្រឹត្ត " អំពើប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម" ទេ។

ផ្តើមចេញពីកថាខណ្ឌទាំងពីរនេះ គេឃើញថាពុំមានបទប្បញ្ញត្តិទូទៅទាក់ទងនឹងធម្មានុរូបកម្មនៃ ការគោរព បញ្ជា ឬការអនុវត្តបញ្ជាអាជ្ញាធរស្របច្បាប់ទេ។

**<u>សំណួរត្រិះរិះ :</u>**

តើក្រមព្រហ្មទណ្ឌមានគោលជំហរយ៉ាងណាដែរចំពោះបញ្ហារបស់អាជ្ញាធរធម្មានុរូប ?

២.-ការអនុញ្ញាតដោយច្បាប់

ច្បាប់អនុញ្ញាតឱ្យប្រព្រឹត្តអំពើណា បណ្ដាលឱ្យបាត់បង់នីត្យានុកូលភាពនៃអំពើនោះ។ អំពើនោះ ត្រូវបានធ្វើយុត្តិកម្មដោយបទប្បញ្ញត្តិនីត្យានុកូល។ ការអនុញ្ញាតដោយច្បាប់ មានន័យជារួមថា ច្បាប់អនុញ្ញាតឱ្យប្រព្រឹត្ត តែច្បាប់មិនឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការអនុញ្ញាតដោយច្បាប់រួមមាន ការការ-ពារស្របច្បាប់ ស្ថានភាពចាំបាច់ និងអានុភាពនៃកំលាំងបង្ខំ ឬការបង្ខំ បញ្ជាពីអាជ្ញាធរធម្មានុរូប ឬវិបត្តិស្មារតី ការភ័នច្រឡំ ....

## អនុកថាខណ្ឌទី ៣ យុត្តិកម្មនៃអំពើ

បុគ្គលប្រព្រឹត្តបទល្មើស តែច្បាប់មិនឱ្យបុគ្គលនោះទទួលយកវិបាក ដែលកើតចេញពីបទល្មើសនោះទេ ពោលគឺច្បាប់អនុញ្ញាតឱ្យប្រព្រឹត្តបទល្មើស ករណីបែបនេះ គេហៅថា "យុត្តិកម្មនៃអំពើ" ឬ "អំពើយុត្តិការ"។ យុត្តិកម្មនៃអំពើ សំដៅយកស្ថានភាពដែលច្បាប់កំណត់ថាអំពើប្រព្រឹត្តជាបទល្មើស តែច្បាប់ពុំតម្រូវឱ្យមានការទទួលខុស ត្រូវព្រហ្មទណ្ឌទេ ពោលគឺពុំទទួលទោសព្រហ្មទណ្ឌទេ។

យោងតាមក្រមព្រហ្មទណ្ឌ គេឃើញថាយុត្តិកម្មនៃអំពើអាចជាមូលហេតុខាងក្នុងខ្លួន និងជាមូលហេតុខាងក្រៅខ្លួនរបស់ជនអ្នកប្រព្រឹត្តអំពើយុត្តិការ។

### ក.-អំពើយុត្តិការ : មូលហេតុខាងក្នុងបុគ្គល

អំពើយុត្តិការដែលមានមូលហេតុខាងក្នុងបុគ្គល មានពីរគឺ វិបល្លាសស្មារតី និងការភ័ន្តច្រឡំ។

១-វិបល្លាសស្មារតី

វិបត្តស្មារតី ឬវិបល្លាសស្មារតីត្រូវបានចែងក្នុងក្រមព្រហ្មទណ្ឌ ត្រង់មាត្រា ៣១។

វិបល្លាសស្មារតី សំដៅយកសមត្ថភាពមិនដឹងខុសត្រូវ ជាពិសេសការមិនអាចវិនិច្ឆ័យ និងយល់ដឹងអំពីសភាពគ្រោះថ្នាក់នៃអំពើដែលកើតចេញពីសកម្មភាពរបស់ខ្លួនបាន នៅពេលប្រព្រឹត្តអំពើនោះ។ បញ្ញា-ស្មារតីរបស់ជននេះ បានបាត់បង់ទាំងស្រុងដែលជាហេតុ "ធ្វើឱ្យបាត់បង់ការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ"។

ការទទួលខុសត្រូវព្រហ្មទណ្ឌអនុឡោមទៅតាមកម្រិតនៃការបាត់បង់សមត្ថភាពយល់ដឹង "កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននេះកើតវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុស ត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែតុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស"។ តាមន័យនេះ ការបាត់បង់ស្មារតីដោយភាគ ឬមួយផ្នែក ចារីទទួលបានស្ថានសម្រាលទោសទៅតាមកម្រិតនោះៗ។

ជួនកាលអ្នកនីតិប្បញ្ញត្តិ បានគិតគូរពីមូលហេតុនៃការបាត់បង់សមត្ថភាពយល់ដឹងពីអំពើរបស់ចារី។ "កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននេះកើតវិបល្លាសស្មារតីដោយសារ ការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់មិនអាចរួចផុតពីការទទួលខុស ត្រូវព្រហ្មទណ្ឌឡើយ"។

**<u>សំណួរត្រិះរិះ</u>**

តើកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ៣១ ខុសគ្នាយ៉ាងដូចម្តេចខ្លះ ?

តើកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ៣១ ខុសពីកថាខណ្ឌទី ៣ នៃមាត្រា ៣១ យ៉ាងដូចម្តេច ខ្លះ ?

២-ការភ័ន្តច្រឡំ

ការភ័ន្តច្រឡំដែលសំដៅយកការមិនដឹងការពិត មានពីរប្រភេទៈការភ័ន្តច្រឡំលើអង្គហេតុ និងលើអង្គច្បាប់។

-ការភ័ន្តច្រឡំលើអង្គហេតុ : នៅពេលប្រតិបត្តិការបរបាញ់សត្វព្រៃនៅពេលយប់មើលមិនសូវច្បាស់ អ្នកបរបាញ់ម្នាក់បានបាញ់ត្រូវអ្នកបរបាញ់ម្នាក់ផ្សេងទៀតបណ្តាលឱ្យរបួស ឬស្លាប់។ ក្រមព្រហ្មទណ្ឌ ដាក់ទោសពីបទបង្ករបួសស្នាមដោយអចេតនា ឬមនុស្សឃាតដោយអចេតនា។ ដូចគ្នាដែរ ការភ័ន្តច្រឡំលើអាយុនៃជនរងគ្រោះ(អនីតិជន)ដែលបានព្រមព្រៀងក្នុងការរួមភេទ[៣១]។ ការរួមភេទរវាងអនីតិជន និងនីតិជន ជាបទរំលោភសេពន្ទវៈ ទោះបីជនរងគ្រោះជាអនីតិជនអាយុក្រោម ១៥ឆ្នាំ បានព្រមព្រៀងក៏ដោយ។ ជាពិសេសការភ័ន្តច្រឡំ ក្នុងប្រភេទ បទល្មើសទម្រង់ដែល កម្មវត្ថុនៃបទល្មើសបានអវត្តមាន ក៏នៅតែជាបទល្មើសដដែល។ ដូចនេះ ឃើញថាការភ័ន្តច្រឡំ លើអង្គហេតុមិនមែន ជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ចុះការភ័ន្តច្រឡំលើអង្គច្បាប់ ?

[៣១] មាត្រា ៤២ ច្បា. ការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨ "ជនណា**រួមភេទជាមួយអ្នកដទៃ** *អាយុតិចជាង ១៥ ឆ្នាំ* ត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ"។ ជំនឿអំពីនីតិជនដែលជនល្មើសមានលើអនីតិជន អាចជាមូលហេតុនៃការរួចផុតពីទោសនៃមាត្រានេះ ។ ជំនឿនេះ អាចកើតពីសភាពខាងក្រៅនៃជនរងគ្រោះ ឬក៏កើតចេញពីការអះអាងរបស់ជនរងគ្រោះដោយផ្ទាល់តែម្តង ។

-ការភ័ន្តច្រឡំលើអង្គច្បាប់ : ជាគោលការណ៍ គេសន្មតថាគ្រប់ពលរដ្ឋទាំងអស់សុទ្ធតែបានដឹង និងចេះដឹង ច្បាប់ "Nul n'est censé ignorer la loi"។ នៅប្រទេសបារាំង ជាពិសេសក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ ១៩៩៤ បានអនុញ្ញាតឱ្យមានការលើកជាសំអាងថាខ្លួនមិនដឹងអំពីច្បាប់ ជាអាទិ៍ ការផ្តល់ព័ត៌មាន ដោយភ័ន្តច្រឡំដោយអាជ្ញាធររដ្ឋបាល។ មាត្រា ១១២-៣ នៃក្រមព្រហ្មទណ្ឌបារាំងបញ្ញត្តថា "មិនត្រូវទទួលទោសព្រហ្មទណ្ឌ បុគ្គលដែលមានការភ័ន្តច្រឡំដែលខ្លួនពុំអាចជៀសវាងបាន ដោយជឿថាខ្លួនប្រព្រឹត្តអំពើមួយស្របច្បាប់"[៣២]។ យុត្តិសាស្ត្របារាំង បានគូសបញ្ជាក់ថា ការភ័ន្តច្រឡំដែលមានចែងក្នុងមាត្រាខាងលើនេះ មានតែមួយគត់គឺ ការភ័ន្តច្រឡំត្រូវមានប្រភពចេញ ពីការផ្តល់ព័ត៌មានដោយភ័ន្តច្រឡំ ឬមិនពិតពីសំណាក់អាជ្ញាធររដ្ឋបាល ហើយវិនិច្ឆ័យនីយគិតថាអំពើរបស់ខ្លួនស្របច្បាប់ និងអំពើនេះត្រូវបានធ្វើធម្មានុរូបកម្មដោយសេចក្តីសម្រេចរដ្ឋបាលនេះ។

ក្រមព្រហ្មទណ្ឌ ហាក់ពុំបានគិតគូរអំពីបញ្ហានេះទេ។ ជាសន្និដ្ឋាន ច្បាប់ព្រហ្មទណ្ឌខ្មែរមិនទទួលស្គាល់ការភ័ន្តច្រឡំជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ(គួរតាមដានយុត្តិសាស្ត្របន្ត)។

## ខ.-អំពើយុត្តិការ : មូលហេតុខាងក្រៅបុគ្គល

អំពើយុត្តិការដែលជាមូលហេតុខាងក្រៅបុគ្គល រួមមាន ការការពារស្របច្បាប់ ស្ថានភាពចាំបាច់ ការបង្ខំ ការបញ្ឈប់សកម្មភាពមុនពេលមានព្យសនកម្ម និងការព្រមព្រៀងរបស់ជនរងគ្រោះ។

### ១-ការការពារស្របច្បាប់

ការការពារស្របច្បាប់ ជាប្រតិកម្មតបតមួយដែលច្បាប់អនុញ្ញាតឱ្យជនរងគ្រោះនៃអំពើឈ្លានពានមិនត្រឹមត្រូវ ធ្វើការតបតដើម្បីការពារអាយុជីវិត និងទ្រព្យសម្បត្តិ។ ច្បាប់អនុញ្ញាតឱ្យមានការការពារបូរណភាពរូបរាងកាយ និងទ្រព្យសម្បត្តិពីការទទួលរងគ្រោះផ្សេងដែលកើតចេញពីការឈ្លានពានមួយ។ ការអនុញ្ញាតនេះចាំបាច់ណាស់ ទោះបីជាប្រតិកម្មនេះស្តែងឡើងតាមរូបភាពហិង្សាក៏ដោយ ជាពិសេសគេយល់ឃើញថាក្នុងករណីបែបនេះ អំណាចសាធារណៈពុំអាចជួយទាន់ពេល ឬបើមិនឱ្យមានកិច្ចការពារទេ ជនរងគ្រោះ និង/ឬទ្រព្យសម្បត្តិខ្លួន នឹងត្រូវបាត់បង់ ហើយមិនអាចជួសជុលឱ្យមករកស្ថានភាពដូចដើមវិញបានទេ។ ឈរលើការពន្យល់នេះ គេក៏អនុញ្ញាតឱ្យមានកិច្ចនេះ។

យោងតាមក្រមព្រហ្មទណ្ឌ "ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-**បទល្មើស**ត្រូវចាត់ទុកថាត្រឹមត្រូវ*ដោយការចាំបាច់*ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

[32] « N'est pas pénalement responsable la personne qui jusitifie avoir cru, par une erreur sur le droit qu'elle n'était pas en mesure d'éviter, pouvoir légitimement accomplir l'acte ».

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន"។

យោងតាមបទប្បញ្ញត្តិនៃមាត្រា ៣៣ អំពើតបតមួយជាការការពារស្របច្បាប់ ឬការការពារជាធម្មានុរូប កាលណាលក្ខខណ្ឌចំនួនពីរត្រូវបានបំពេញ : ការឈ្លានពានមិនត្រឹមត្រូវ និងការតបតដែលត្រូវធ្វើក្នុងអំឡុងពេលឈ្លាន(ការតបត) និងត្រូវតែសមាមាត្រ ។

**ទី១-ការឈ្លានពានមិនត្រឹមត្រូវ** : អំពើខុសច្បាប់។ នៅពេលមានអំពើឈ្លានខុសច្បាប់ កិច្ចតបតអាចត្រូវបានធ្វើមិនត្រឹមតែជនរងគ្រោះរងខ្លួន តែក៏អាចធ្វើក្នុងក្របខណ្ឌនៃការ ការពារអ្នកដទៃផងដែរ ហើយក៏អាចធ្វើប្រឆាំងនឹងបទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិខ្លួនឯង និងអ្នកដទៃ។

**ទី២-លក្ខខណ្ឌនៃការតបត** : ការតបតត្រូវធ្វើក្នុងអំឡុងពេលឈ្លាន និងមានសមាមាត្រាមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។

*-បទល្មើស(អំពើតបត) និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា* : លក្ខខណ្ឌនេះងាយយល់ទេ ព្រោះការតបតក្រោយពេលបទល្មើសត្រូវបានបញ្ចប់ មិនមែនជាកិច្ចការការពារទេ តែជា ការសងសឹក ហើយក៏មិនអាចធ្វើមុនពេលមានអំពើឈ្លានពានដែរ បើពុំនោះវាក្លាយជាការប្រព្រឹត្តបទល្មើស។ ហេតុអ្វី ? ព្រោះមុនពេលមានការឈ្លានពាន និងក្រោយពេលការឈ្លានពាន គ្មានគ្រោះថ្នាក់ *គ្មានភាពចាំបាច់* ឬភាពបន្ទាន់បង្ខំ ដើម្បីការពារអ្វីដែរ "**បទល្មើស**ត្រូវចាត់ទុកថាត្រឹមត្រូវ*ដោយការចាំបាច់*ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារ ទ្រព្យសម្បត្តិ ប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ"។

*-សមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន* ឬតុល្យការ : ជាវិបាកដោយផ្ទាល់នៃភាពចាំបាច់នៃកិច្ចការពារ។ គេថ្លឹងមធ្យោបាយត្រូវបានប្រើប្រាស់មិនមែនលទ្ធផល នៃអំពើតបតទេ។ មួយវិញទៀត គឺក្រមព្រហ្មទណ្ឌពុំបានធ្វើការបែងចែកលក្ខខណ្ឌសមាមាត្រនេះ ចំពោះទ្រព្យសម្បត្តិទេ គួរកត់សំគាល់ថាទ្រព្យសម្បត្តិ មិនអាចប្រៀបជាមួយមនុស្សបានទេ។ ក្នុងន័យនេះ ការការពារទ្រព្យសម្បត្តិ គួរតែមានលក្ខខណ្ឌតឹងរ៉ឹងជាងការការពារមនុស្ស។

១-១-ការការពារមនុស្ស

*-ជនរងគ្រោះកំពុងទទួលរងគ្រោះអ្វី* :គ្រោះថ្នាក់ដល់អាយុជីវិត ឬដល់បូរណភាពរូបរាងកាយ។

**-ការការពារខ្លួននៃជនរងគ្រោះ :**

ឧ.-ចោរីកាន់កាំបិតប្រុងនឹងចាក់ ឬកាប់សំដៅជនរងគ្រោះ តែជនរងគ្រោះបានប្រើកាំភ្លើងសំលាប់ចោរីទៅ។

-ក្មេងស្ទាវមួយក្រុមបានកំពុងវាយជនរងគ្រោះនឹងដំបង ក្នុងបំណងនឹងសំលាប់ តែដោយជនរងគ្រោះ ជាអ្នកចេះ ក្បាច់គុណ ក៏ប្រើក្បាច់គុណនោះតតាំង បណ្តាលឱ្យក្រុមក្មេងស្ទាវស្លាប់ និងរបួស។

-ជនល្មើសប្រើថ្នាំសន្លប់ ហើយនាំជនរងគ្រោះទៅកន្លែងមួយដើម្បីរំលោភសេពសន្ថវៈ ពេលនោះ ជនរងគ្រោះ ក៏ទាញបានអំបែងដបមួយចាក់ជនល្មើសក្នុងបំណងការពារខ្លួន តែជាអកុសលជនល្មើស ក៏បាន ស្លាប់ដោយរបួសទៅ

-ក្នុងបំណងសម្រេចអំពើភេរវកម្ម ជនល្មើសក៏បានផ្ដាច់ប្រាំងឡាន អ្នកបើកបរក៏មើលទៅ ឃើញ ថាខាងមុខ មានជ្រោះ មួយដ៏ជ្រៅ ហើយនៅចំងាយប្រហែល ១០ ម៉ែត្រមានគូរស្នេហ៍កំពុងស្ថិតនៅ ហើយអ្នក បើកបរគិត និងដឹងថាប្រសិនបើគាត់ ប្រើសមត្ថភាពរបស់គាត់ឱ្យរថយន្តបុកដើមឈើ និងសំលាប់អ្នកទាំងពីរ រថយន្តនឹងមិនធ្លាក់ជ្រោះទេ គិតដូចនេះហើយ ក៏ធ្វើតាម គំរោង។ ទីបំផុត អ្នកដំណើរចំនួន ៦០ នាក់ រងតែ របួសប៉ុណ្ណោះមិនមានស្លាប់ទេ។

**-ការការពារអ្នកដទៃ**

ឧ.-បុគ្គលម្នាក់ឃើញចោរីកំពុងតែយកកាំបិតចាក់ជាច្រើនកាំបិតហៀបនឹងស្លាប់ ឃើញដូចនេះ លោក "ក" ដែលមាន ក្បាច់គុណពូកែ ក៏វាយចោរីនោះ តែដោយចារីតដៃ គាត់ក៏ជ្រុលបណ្ដាលឱ្យចោរីបាត់បង់ ជីវិតភ្លាមទៅ។

-ដោយឃើញជនរងគ្រោះ "ក" កំពុងត្រូវជនល្មើសដឹកតាមរថយន្ត ឈ្មោះ "ខ" ក៏បានប្រើមធ្យោ-បាយ ដើម្បីរំដោះជនរងគ្រោះ។ ក្នុងប្រតិបត្តិការនេះ អ្នកបើកបររថយន្តដែលជាអ្នកសមគំនិតបានស្លាប់។

-ក្នុងការវាយតប់គ្នារវាងក្មេងស្ទាវមួយក្រុម បងប្រុសរបស់ក្មេងម្នាក់ក៏ចូលក្នុងហ្វូងនេះ ដោយមិន បានប្រយ័ត្នក៏ បណ្ដាលឱ្យក្មេងស្ទាវស្លាប់។

១-២-ការពារទ្រព្យសម្បត្តិ

បញ្ហាស្ថិតត្រង់ការវាយតំលៃទ្រព្យសម្បត្តិ ហើយជាញឹកញយដើម្បីការពារទ្រព្យសម្បត្តិ បណ្ដាលឱ្យ មានការប៉ះពាល់ ដល់បូរណភាពរូបរាងកាយ ហើយពេលខ្លះបណ្ដាលឱ្យបាត់បង់អាយុជីវិត ដែលមិនអាច វាយ តំលៃជាសាច់ប្រាក់បាន ដូចអ្វីដែលគេធ្វើ ចំពោះទ្រព្យសម្បត្តិ និងបញ្ហាមួយទៀត គឺកិច្ចតបតជាមួយ និង តំលៃ នៃទ្រព្យសម្បត្តិ។ តែបញ្ហាមិនចោទជាបញ្ហាទេ ព្រោះក្រម ព្រហ្មទណ្ឌទាមទារឱ្យមានសមាមាត្រ រវាង មធ្យោបាយប្រើប្រាស់ទៅនិងទម្ងន់នៃការឈ្លានពាន។ អំណានច្បាប់បារាំងបានឱ្យដឹងថាៈ

-សកម្មភាពការពារត្រូវតែមានគោលដៅបញ្ឈប់បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ។ ប្រតិកម្មតប ត្រូវធ្វើឡើង ក្រោយ ពីមានការដកហូត ឬប៉ុនប៉ងដកហូត។

-សមាមាត្រនៃការការពារស្ថិតត្រង់មិនបណ្តាលឱ្យជនល្មើសស្លាប់ដោយចេតនា។ តាមន័យនេះ ច្បាប់បារាំងអនុញ្ញាតឱ្យ មានមុនស្សឃាតដោយអចេតនា ព្រោះគោលដៅគឺ បញ្ឈប់កិរិយាកាន់យកវត្ថុអ្នកដទៃ តែមធ្យោបាយដែលប្រើដើម្បីបញ្ឈប់ អាចឈានទៅដកយកអាយុជីវិតជនល្មើសដោយអចេតនា[៣៣]។

-កិច្ចការពារត្រូវតែចាំបាច់បំផុត។ វាមានការពិបាកថាតើស្ថិតក្នុងស្ថានភាពបែបណា ទើបអាចចាត់ទុកថាកិច្ចការពារចាំបាច់បំផុត ? ប្រសិនបើមានជម្រើសច្រើនយ៉ាង ត្រូវជ្រើសរើសយកជម្រើសណាដែលសមស្របបំផុត គឺជម្រើសនោះ ជាមធ្យោបាយតែមួយគត់ គ្មានពីរ ក្នុងការបញ្ឈប់បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ។

ឧ១.បុរសម្នាក់ខឹងសម្បានិងការប្រើឧបករណ៍ឆក់ត្រីក្នុងស្រះ គាត់ក៏សម្រេចចិត្តពង្រាយខ្សែលួសការពារ។ បុរសដដែល បានពង្រាយខ្សែភ្លើងការពារត្រីជៀតពីការលួច តែពេលចោរចូលមកក៏ត្រូវឆក់ស្លាប់ដោយខ្សែភ្លើងនោះ។

ឧ២. ចោរកំពុងតែគំរាមនឹងកាំបិត ដើម្បីយកឡាន ឬសម្ភារៈក្នុងឡាន ពេលនោះអ្នកបើកបរឡាន ក៏ប្រើកំលាំងខ្លួនវាយ បកវិញ ហើយជាអកុសលចោរនោះក៏បានបាត់បង់ជីវិត។

**បន្ទុកភស្តុតាង.**-បញ្ហាមួយផ្សេងទៀត គឺភស្តុតាងនៃការការពារស្របច្បាប់។ យោងតាមស្មារតីនៃការបក ស្រាយមាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌដែលផ្តល់អត្ថប្រយោជន៍ដល់រងគ្រោះ នូវសច្ចធារណ៍នៃការការពារស្របច្បាប់។ ក្នុងន័យនេះ ជនរងគ្រោះត្រូវបង្ហាញភស្តុតាង ថាខ្លួនតបតក្នុងក្របខណ្ឌនៃការការពារស្របច្បាប់។ ដើម្បីបង្វែរបញ្ហាបន្ទុកនៃភស្តុតាងនេះ ច្បាប់បានសន្មត់ពីការការពារស្របច្បាប់ ក្នុងករណីមួយចំនួនជាអត្ថប្រយោជន៍ដល់ជនរងគ្រោះ : "ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយដោយ ហិង្សា ឬដោយកលល្បិចនៅក្នុងកន្លែងដែលមានមនុស្សនៅ។

២-បទល្មើសបានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ**ការប្លន់**ដែលអនុវត្តដោយហិង្សា ។

សច្ចធារណ៍នៃការការពារស្របច្បាប់ពុំមានលក្ខណៈដាច់ខាតទេ។ សច្ចធារណ៍នេះ អាចត្រូវរំលាយដោយ ភស្តុតាងផ្ទុយ"(មាត្រា ៣៤)។ ព្រះរាជអាជ្ញាដែលជាភាគីមួយដ៏សំខាន់ ក្នុងរឿងក្តីព្រហ្មទណ្ឌមាន

---

[៣៣] មាត្រា ១២២-៥ កថាខណ្ឌទី ២ នៃក្រមព្រហ្មទណ្ឌបារាំងឆ្នាំ ១៩៩៤ "មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌទេ បុគ្គលដែលបញ្ឈប់ការឈ្លានពានមកលើទ្រព្យសម្បត្តិ ដោយអំពើចាំបាច់នៃការការពារទ្រព្យសម្បត្តិនោះ បណ្តាលឱ្យមានមនុស្សឃាតដោយអចេតនា កាលណាអំពើនោះចាំបាច់ជាទីបំផុត និងគ្មានវិសមាមាត្ររវាង មធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន"។ Art. 122-5, al. 2, NCP Fr. « N'est pas pénalement responsable la personne qui, pour interrompre l'exécution d'un crime ou d'un délit contre un bien, accomplit un acte de défense, autre qu'un homocide volontaire, lorsque cet acte est strictement nécessaire au but poursuivi dès lors que les moyens sont proportionnés à la gravité de l'infraction ».

បន្ទុកបង្ហាញពីវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។ ការវាយតំលៃភាពសមាមាត្រធ្វើឡើង តាមស្ថានភាព និងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស។

២-ស្ថានភាពចាំបាច់

ខុសពីការការពារស្របច្បាប់ ស្ថានភាពចាំបាចកើតមាន កាលណាបុគ្គលម្នាក់ស្ថិតក្នុងស្ថានភាពមួយ ដែលគ្មាន ជម្រើសអ្វីក្រៅពីប្រព្រឹត្តអំពើមួយ ឬច្រើនដើម្បីការពារខ្លួនឯង អ្នកដទៃ ឬទ្រព្យសម្បត្តិ ទោះបើដឹងថាអំពើនោះជា ការហាមឃាត់ក៏ដោយ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ(មាត្រា ៣៥) :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន ។ គ្រោះថ្នាក់ អាចកើតពីអំពើរបស់មនុស្ស ឬដោយសារអក្ខុហេតុធម្មជាតិ ។

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់។

ឧ. ប្រាំងឡានបានដាច់ចំពេលដែលត្រូវឆ្លងកាត់ជ្រោះ តែអ្នកបើកបរសម្រេចចិត្តបុកសំលាប់បុរសម្នាក់ក្រោមដើមឈើដ៏ធំនោះ ដើម្បីរំដោះអ្នកដំណើរចំនួន ៥០ នាក់ ឱ្យរួចផុតពីមរណៈ។

ឧ. ពេលមានអគ្គីភ័យកើតឡើង រថយន្តពន្លត់អគ្គីភ័យមួយបានមកដល់។ អ្នកបើកបរមើលឃើញថា ប្រសិនបើគាត់បរ កាត់សួនច្បារ គាត់ពិតជាអាចពន្លត់ភ្លើងបានទាន់ពេល ឬបើគាត់បរកិនលើយាយចាស់ម្នាក់ គាត់អាចពន្លត់ភ្លើងទាន់ពេល ហើយអាច ជួយសង្គ្រោះកុមារពីរនាក់ក្នុងផ្ទះកំពុងឆេះ។

ឧ.បុរសម្នាក់ស្ថិតក្នុងផ្ទះកំពុងឆេះភ្លើង ហើយពេលបានមកដល់រថយន្ត ក៏បើកសំដៅចាកចេញដោយប្រញាប់ពេក រថយន្តនោះបានសំលាប់ក្មេងប្រុសដែលកំពុងដើរនៅមិនឆ្ងាយប៉ុន្មានពីផ្ទះនោះ។

ឧ.បុគ្គលិកក្រុមហ៊ុន "ក" បានដឹងតាមចំណេះខ្លួនថា ម៉ាស៊ីនភ្លើងដែលដាក់ឱ្យដំណើរការ អាចផ្ទុះ ហើយអាចបង្កឱ្យទ្រព្យ សម្បត្តិក្រុមហ៊ុនវិនាសទាំងស្រុងដោយអគ្គីភ័យ ក៏សម្រេចចិត្តយកម៉ាស៊ីនចេញទាន់ពេល (ដោយមិនបានពិគ្រោះជាមួយប្រធាន ក្រុមហ៊ុនជាមុនទេ ដោយបន្ទាន់បង្ខំ) ជាហេតុធ្វើឱ្យចរន្តអគ្គិសនីត្រូវបានកាត់ផ្តាច់ បង្កឱ្យមានការខូចខាតដល់ដំណើរ ផលិតផល ហើយជាវិបាកក្រុមហ៊ុនមិនអាចប្រគល់ទំនិញតាមកាលកំណត់ និងត្រូវ បង់ប្រាក់ពិន័យក្នុងកិច្ចសន្យាដោយការយឺតយ៉ាវទៀតផង។

៣-អានុភាពនៃកំលាំងបង្ខំ ឬការបង្ខំ

ខុសពីស្ថានភាពចាំបាច់ដែលគ្រោះថ្នាក់អាចកើតពីអំពើរបស់មនុស្ស ឬអក្ខុហេតុធម្មជាតិ កំលាំងបង្ខំ ឬការបង្ខំ អាចកើតចេញពីអក្ខុហេតុធម្មជាតិប៉ុណ្ណោះ។

"បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬនៃការបង្ខំដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំង និងការបង្ខំនេះ ត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន"(មាត្រា ៣៦)។

**<u>សំណួរត្រិះរិះ</u>**

ចូរលើកឧទាហរណ៍ករណី ២ ដែលបង្ហាញឱ្យឃើញពីអានុភាពនៃកំលាំង ឬការបង្ខំ។

តើគេអាចថា អានុភាពនៃកំលាំង ឬការបង្ខំ ជាករណីប្រធានសក្តិបានដែរ ឬទេ ?

៤-ការបញ្ឈប់សកម្មភាពទៅវិញមុនពេលមានព្យសនកម្មកើតឡើង

ចំពោះការប៉ុនប៉ងប្រព្រឹត្តបទល្មើស សូមអានចំណាត់ថ្នាក់នៃបទល្មើសខាងលើ។

-បញ្ឈប់មុនពេលចាប់ផ្តើមសកម្មភាព (désistement volontaire)

-ហៀបធ្វើសកម្មភាព តែព្យសនកម្មនៅមិនទាន់កើតមាននៅឡើយ

ការបពឈ្សប់សកម្មភាពនេះ ត្រូវកើតចេញពីឆន្ទៈជនល្មើស មិនមែនដោយសារកាលៈទេសៈខាងក្រៅទេ។

ចំពោះការបញ្ឈប់ក្រោយពេលចាប់ផ្តើម មិនមែនកើតចេញពីការភ្ញាក់រលឹករបស់ចារី សូមមើលការប៉ុនប៉ង

<u>សំណួរត្រិះរិះ</u>

តើក្រមព្រហ្មទណ្ឌមានបញ្ញត្តអំពីករណីនេះដែរ ឬទេ ?

៥-ការព្រមព្រៀងពីសំណាក់ជនរងគ្រោះ

ច្បាប់វិជ្ជមានហាក់ពុំបានបញ្ញត្តអំពីបញ្ហានេះទេ។ ការមិនបញ្ញត្តបែបនេះ អាចឱ្យគេបកស្រាយបានថា ទោះជាជនរងគ្រោះអនុញ្ញាតក៏ដោយ អំពើនោះនៅតែជាបទល្មើសព្រហ្មទណ្ឌ ប្រសិនបើច្បាប់បញ្ញត្ត និងដាក់ទោសអំពើនោះ។ ចុះកីឡាប្រដាល់ កីឡា Judo Rugby និងកីឡាគ្រោះថ្នាក់ដទៃទៀត ដែលបង្កឱ្យមានរបួសស្នាម ឬផ្តាច់ អាយុជីវិត ឬដោយវេជ្ជបណ្ឌិតវះកាត់ តើមិនកើតចេញពីការព្រមព្រៀងរបស់ជនរងគ្រោះ ? ហេតុអ្វីគ្មានការផ្តន្ទាទោស ? អំណះអំណាង និងការលើកឡើងនេះ គឺភ្លេចថាវាជាការអនុញ្ញាតរបស់ច្បាប់ ឬដោយទំនៀមទំលាប់។

**ក្រមព្រហ្មទណ្ឌ**ក៏មិនបានចែងពីករណីនេះផងទេ។ ផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណីបានកំណត់ពីបញ្ហានេះ "អ្នកប្រព្រឹត្តអំពើបំពាន ត្រូវរួចផុតពីការទទួលខុសត្រូវក្នុងករណីដែលមានការយល់ព្រម ឬការទទួល

យកគ្រោះថ្នាក់ពីសំណាក់អ្នករងគ្រោះ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលការយល់ព្រម ឬការទទួលយកគ្រោះថ្នាក់នោះ មិនត្រូវបានសង្គមទទួលស្គាល់ថាសមហេតុផល" (មាត្រា ៧៥៦ កថាខណ្ឌទី ១)។

នោះជាយ៉ាងនេះក្តី ក៏គេអាចស្វែងរក និងទាញជាសេចក្តីអង្កេតជាទូទៅពីក្រមព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌ និងបទដ្ឋានព្រហ្មទណ្ឌដទៃទៀត លើបីករណី គឺទី ១ ទោះបីជាបទល្មើសត្រូវបានប្រព្រឹត្ត តែបើគ្មានឆន្ទៈធ្វើបណ្តឹងពី ជនរងគ្រោះទេ នោះព្រះរាជអាជ្ញា ក៏មិនអាចធ្វើបណ្តឹងអាជ្ញាបានដែរ។ ទី ២ អវត្តមាននៃឆន្ទៈព្រមព្រៀងរបស់ជនរង គ្រោះ អំពើប្រព្រឹត្តនឹងជាបទល្មើស និងជាចុងក្រោយគឺ បញ្ហាសុមរណៈ។

**បណ្តឹងបរិហារ : លក្ខខណ្ឌចាំបាច់ក្នុងការធ្វើបណ្តឹងអាជ្ញា**..ករណីទូទៅគឺមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា ៨ កថាខណ្ឌទី ២ ដែលបណ្តឹងអាជ្ញាតម្រូវជាចាំបាច់នូវពាក្យបរិហាររបស់ជនរង-គ្រោះ។ ករណីនេះមាន ចែងក្នុងមាត្រា ២១ ថា នៅក្នុងករណី បទឧក្រិដ្ឋ ឬបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅឯបរទេស(មាត្រា ១៩) ឬបទឧក្រិដ្ឋដែលជនរងគ្រោះជាជនជាតិខ្មែរប្រព្រឹត្តលើទឹកដីបរទេស "ការចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត ឬបណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត"។ ករណីដូចគ្នានេះក៏មានចែងផងដែរក្នុងមាត្រា ៣០៩ ចំពោះបទបរិហារកេរ្តិ៍ និងជេរប្រមាថជាសាធារណៈ ថា "ពាក្យប្តឹងរបស់សាមីខ្លួន ឬប្រធានស្ថាប័ន (...) គឺជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌដោយ អយ្យការ ហើយការដកពាក្យប្តឹងវិញរបស់អ្នកប្តឹង នាំឱ្យបណ្តឹងអាជ្ញារលត់"។ ករណីប្រហាក់ប្រហែលគ្នានេះដែរ មានចែងក្នុងមាត្រា ៨ នៃច្បាប់ស្តីពីឯកពន្ធភាព ថាក្នុងករណីបទផិត បើមានពាក្យរបស់សហពទ្ធម្ខាងទៀតមិនឱ្យប្តឹងអាជ្ញា ព្រះរាជអាជ្ញាអាចពិចារណាមិនប្តឹងអាជ្ញាបាន។

**អវត្តមាននៃឆន្ទៈព្រមព្រៀងរបស់ជនរងគ្រោះ នាំឱ្យមានបទល្មើស**..ចំពោះបទល្មើសមួយចំនួន កាលណាជនរងគ្រោះមិនយល់ព្រម នោះវានឹងបង្កើតបានជាបទល្មើស។ ករណីបទរំលោភ សេពសន្ថវៈ (មាត្រា ២៣៩) ក៏ប៉ុន្តែ ជនរងគ្រោះនោះត្រូវតែមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ទើបឆន្ទៈដែលសំដែងចេញដោយគ្មានវិការៈ មានសុពល។ ករណីនេះ ក៏តម្រូវដោយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ក្នុងទំនាក់ទំនងផ្លូវភេទរវាង សហព័ទ្ធ។ បទល្មើសទាក់ទងនឹងសិទ្ធិបុគ្គលភាព(មាត្រា ៣០១ និងមាត្រា ៣០២) ជាដើម។

លើសពីនេះ ការអនុញ្ញាតឱ្យមានការប្រព្រឹត្តលើបូរណភាពរូបរាងកាយ : កាត់ដៃ ជើង .... ព្រោះតែរឿងព្យាបាល(ហេតុផលវេជ្ជសាស្ត្រ) អាចប្រព្រឹត្តទៅបាន ទោះច្បាប់វិជ្ជមានហាក់ពុំបានគិតគូរក៏ដោយ

តែការអនុវត្តបានធ្វើនីត្យានុកូលភាពរួចហើយ។ ចុះឆន្ទះព្រមព្រៀងក្នុងទំនាក់ទំនងផ្លូវភេទ ? មិននាំឱ្យមានការផ្តន្ទាទោសទេ។ ការរំលូតកូន[៣៤] ។

**សិទ្ធិទទួលបានមរណភាពប្រព្រឹត្តដោយអ្នកដទៃ(សុមរណៈ)**..ការអនុញ្ញាតឱ្យសំលាប់ដែលអ្នកជំងឺផ្តល់ឱ្យលោកគ្រូពេទ្យ[៣៥]។ ព្រោះមានការឈឺចាប់ដែលមិនអាចអត់ទ្រាំតទៅទៀតបាន ឬអ្នកជំងឺព្យាបាលមិនជាសះស្បើយ។

សុមរណៈអាចប្រព្រឹត្តទៅក្រោមទម្រង់សកម្ម (ចាក់បញ្ចូលទៅក្នុងខ្លួនអ្នកជំងឺនូវសារធាតុគីមីដែលអាចដកហូតអាយុជីវិតរបស់អ្នកជំងឺ) និងអកម្ម(ទុកអ្នកជំងឺចោល ដោយមិនបន្តការព្យាបាល រហូតដល់ស្លាប់)។ ច្បាប់កម្ពុជាយើងមិនបានចែងពីករណីនេះទេ ថាតើអនុញ្ញាត ឬក៏ត្រូវហាមឃាត់នោះទេ។ ករណីដូចជាក្រុមគ្រួសារអ្នកជំងឺដែលអស់សង្ឃឹម បានសម្រេចចិត្តឱ្យវេជ្ជបណ្ឌិតបញ្ឈប់ការព្យាបាល ដោយទុកឱ្យអ្នកជំងឺស្លាប់ មិនដែលឃើញមានការចោទប្រកាន់ ឬការផ្តន្ទាទោសពីបទឃាតកម្ម ទេ។ សំណួរសួរថាតើតាមទំនៀមទំលាប់ យើងពិតជាទទួលស្គាល់សុមរណៈឬ។

គួររំលឹកថា នៅប្រទេសវៀតណាម វេជ្ជបណ្ឌិតចាក់បញ្ចូលទៅក្នុងអ្នកជំងឺអេដស៍នូវសារធាតុគីមីដែលអាចដកហូតអាយុជីវិតរបស់អ្នកជំងឺ ក្នុងរយៈពេលណាមួយជាកំណត់។

**កំណត់សំគាល់លើជនរងគ្រោះ** : ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ក្នុងមាត្រា ២២ ថាបណ្តឹងរដ្ឋប្បវេណី អាចធ្វើនៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌក៏បាន ឬសាលាជម្រះក្តីរដ្ឋប្បវេណីក៏បាន។ សាលាជម្រះក្តីចុងក្រោយនេះអាច ចាត់ការបណ្តឹងរដ្ឋប្បវេណី ដរាបណាសាលាជម្រះក្តីព្រហ្មទណ្ឌ សេចក្តីសម្រេចជាស្ថាពរ លើបណ្តឹងអាជ្ញា។ មាត្រា ២៣ បន្តទៀតថា "តុលាការព្រហ្មទណ្ឌនឹងអាចសម្រេចការជួសជុលព្យនសកម្មបាន លុះណាតែបានពិនិត្យជាមុន អំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថាជនជាប់ចោទត្រូវមានពិរុទ្ធភាពជាមុនសិន"។ សំណួរដំបូង សួរថាតើសេចក្តីសម្រេចរបស់សាលាជម្រះក្តីព្រហ្មទណ្ឌ មានអំណាចចាប់បង្ខំសាលាជម្រះក្តីរដ្ឋប្បវេណីដែរ ឬទេ ?

[៣៤] មាត្រា ៨ ច្បាប់ស្តីពីការរំលូតកូន "ការរំលូតកូនអាចធ្វើទៅបាន ចំពោះតែគភិណាដែលមានអាយុតិចជាង **១២សប្តាហ៍** លើសពី ១២ សប្តាហ៍នៃអាយុគភ៌ ការរំលូតកូន អាចទទួលការអនុញ្ញាតបាន លុះណាតែក្នុងពេលធ្វើ**រោគវិនិច្ឆ័យ**ឃើញថា -គភ៌នោះមាន**ភវនីយភាព**មិនលូតលាស់ដូចប្រក្រតី ឬបង្កគ្រោះថ្នាក់ដល់ **ជីវិតម្តាយ** -កូនដែលនឹងកើតមកអាចមាន**ជម្ងឺធ្ងន់ធ្ងរព្យាបាលពុំជា** -ក្នុងករណីដែលត្រូវគេ**រំលោភ** បណ្តាលឱ្យមានគភ៌ ការរំលូតកូនអាចប្រព្រឹត្តទៅបានដោយ មិនគិតពីលក្ខខណ្ឌដូចមានចែងខាងលើ តែត្រូវមានការស្នើសុំពីសាមីខ្លួន បើស្ត្រីនោះមានអាយុ ១៨ឆ្នាំ ឡើងទៅ ឬការស្នើសុំដោយទទួចពីឪពុកម្តាយ ឬ អាណាព្យាបាល និងសាមីខ្លួន បើស្ត្រីមានគភ៌អាយុតិចជាង ១៨ឆ្នាំ។ ការសម្រេចនៃបញ្ហានេះ ត្រូវមានការឯកភាពពីក្រុមគ្រូពេទ្យ ២ ឬ៣រូប រួមទាំងសាមីខ្លួន។ លក្ខខណ្ឌបច្ចេកទេសសម្រាប់ ការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល"។

[៣៥] ករណីសិក្សា និងឧទាហរណ៍ជាក់ស្តែង **សេង នាង** *នីតិព្រហ្មទណ្ឌទូទៅ* បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យបៀលប្រាយ ទំ.៨៧-៨៨ ។

ការមិនពិតប្រាកដនៃបញ្ញត្តិច្បាប់ ជាហេតុបង្កការលំបាកជាពិសេសរារាំង ឬជាឧបសគ្គមួយដ៏ធំ ក្នុងការរឹតត្បិតសិទ្ធិទទួលបានសំណងពីសំណាក់ជនរងគ្រោះ។ បញ្ហាស្ថិតត្រង់ពេលធ្វើក្រមព្រហ្មទណ្ឌ គេហាក់ពុំបានពិនិត្យ និងសិក្សាលើអ្វីដែលក្រមនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានសភាជាតិអនុម័តរួចហើយជាមូលដ្ឋានដែលជាហេតុធ្វើឱ្យលេចចេញបាតុភាព ក៏ដូចជាឧបសគ្គ។ មាត្រា ២៣ ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់ថាតុលាការព្រហ្មទណ្ឌនឹងអាចជួសជុលព្យសនកម្មរដ្ឋប្បវេណីបាន ដរាបណាមានការប្រកាសពីពិរុទ្ធភាពនៃជនល្មើសជាមុន ហើយក្នុងអត្ថន័យនេះបទល្មើសមិនមែនជាលក្ខខណ្ឌចាំបាច់ និងមិនអាចប្រកែក បាននៃពិរុទ្ធភាពទេ (អត្ថិភាពនៃបទល្មើសតែមួយមុខមិនទាន់អាចកំណត់ពីពិរុទ្ធភាពបានទេ ទាល់តែមើលពីភាពអាចទំលាក់បាន ដែលជាធាតុនីត្យានុកូលនៃបទល្មើស)។ ក្នុងករណីមួយចំនួន ក្រមព្រហ្មទណ្ឌកំណត់ថាអំពើមួយជាបទល្មើស តែ មិនមានការទទួល ខុសត្រូវព្រហ្មទណ្ឌទេ នោះវាបញ្ជាក់គ្មានពិរុទ្ធភាពទេ ពេលនោះតុលាការព្រហ្មទណ្ឌក៏ពុំអាចជួសជុលព្យសនកម្មបានដែរ។ ការបកស្រាយនេះស្របតាមស្មារតីនៃក្រមដេប្បវេណីដែលក្នុងករណីដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។ ជាគោលការណ៍ ចំពោះរឿងរដ្ឋប្បវេណី វាស្ថិតក្នុងក្របខណ្ឌនៃច្បាប់រដ្ឋប្បវេណី។ ដូចនេះ ចៅក្រមព្រហ្មទណ្ឌត្រូវមើលផងដែរ ក្រមរដ្ឋប្បវេណី។ ចំពោះការទទួលខុសត្រូវក្រៅកិច្ចសន្យាឬចំពោះអំពើអនីត្យានុកូល អនុម័តយកគោលការណ៍សមធម៌ ដ៏ទូលំទូលាយ និងដ៏គ្រោះថ្នាក់ និងគំរាមកំហែងដល់ សិទ្ធិទទួលបានសំណងរបស់ជនរងគ្រោះ។ "ចំពោះការខូចខាត ដោយសារអំពើដែលត្រូវសង្គមទទួល ស្គាល់ថាសមហេតុផល អ្នកប្រព្រឹត្តអំពើបំពានមិនត្រូវទទួលខុសត្រូវឡើយ"(ម.៧៥៦-៣)។

តាមពិត បទប្បញ្ញត្តិនៃមាត្រា ២២ និងមាត្រា ២៣ មែងជាឧបសគ្គក្នុងការទទួលបានសំណងរដ្ឋប្បវេណីទេ តែគ្រាន់តែ ជាបទប្បញ្ញត្តិមួយកម្រិតសម្ថកិច្ចសាលាជម្រះក្តីព្រហ្មទណ្ឌ ហើយបើសាលាជម្រះក្តីព្រហ្មទណ្ឌពុំអាចចាត់ការលើបណ្តឹងរដ្ឋប្បវេណីបានទេ ជនរងគ្រោះអាចដាក់បណ្តឹងទៅសាលាជម្រះក្តីរដ្ឋប្បវេណី ដើម្បីទាមទារសំណងការខូចខាត ដោយផ្អែកតាមច្បាប់រដ្ឋប្បវេណី។

**អ្នកដែលបើកទ្វារសាលារៀន គឺជាអ្នកបិទទ្វារពន្ធនាគារ ។**

**អ្នកដែលបង្កើតការងារជូនពលរដ្ឋ ជាអ្នកបិទទ្វារពន្ធនាគារ។**

# ជំពូកទី ៣ អំពីទោស

នៅក្នុងជំពូកនេះ យើងនឹងសិក្សាពីវិបាកដែលកើតចេញពីបទល្មើស។ វិបាកនៃបទល្មើស គឺទណ្ឌកម្មព្រហ្មទណ្ឌ(ទោស)។

**ទណ្ឌកម្ម.**-ពាក្យ"ទណ្ឌកម្ម"នេះ មានន័យទូលំទូលាយ។ យោងតាមវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ទណ្ឌកម្មជាការធ្វើទោសផ្ទាលតាមដំណើរដែលធ្វើខុសនឹងវិន័យបញ្ញត្តិ។ ការធ្វើទោសនឹងអាចប្រព្រឹត្តទៅបាន កាលណាមានបញ្ញត្តិ ហើយបុគ្គលណាម្នាក់បានធ្វើខុសនឹងបញ្ញត្តិនេះ ហើយទោសនោះទៀតសោតពិតត្រូវកំណត់ជាមុនដោយបញ្ញត្តិនោះ។ យ៉ាងណាមិញ ការដាក់ទណ្ឌកម្មក្នុងវិស័យច្បាប់ ក៏ដូចគ្នាដែរ ពោលគឺត្រូវគោរពតាមគោលការណ៍នីត្យានុកូលភាព។

ក្នុងវិស័យច្បាប់ទណ្ឌកម្ម ទណ្ឌកម្មមានបីប្រភេទ គឺ ១-ទណ្ឌកម្មរដ្ឋបាល ២-ទណ្ឌកម្មរដ្ឋប្បវេណី និង ៣-ទណ្ឌកម្មព្រហ្មទណ្ឌ។ នៅទីនេះ យើងលើកយកតែទណ្ឌកម្មចុងក្រោយមកសិក្សា ប៉ុណ្ណោះ។

ក្នុងន័យទូលាយ ទណ្ឌកម្មបានដល់វិធានការទាំងឡាយ ដែលមានលក្ខណៈបង្ខំឱ្យការបំពេញកិច្ចអ្វីមួយរួមទាំង ការជួសជុលព្យសនកម្មផង។ ក្នុងន័យចង្អៀត ទណ្ឌកម្មសំដៅ យកទោសដែលចៅក្រមព្រហ្មទណ្ឌប្រកាសប្រឆាំងនឹងទណ្ឌិត ហើយទោសនេះមានមូលដ្ឋាន គឺអំពើអនីត្យានុកូលដែលចាត់ជាបទល្មើស។

ដើមឡើយ ទោសក្នុងរឿងព្រហ្មទណ្ឌ ធ្វើឡើងក្រោមរូបភាពដាក់ពន្ធនាគារ។ ការវិវត្តបានជំរុញឱ្យមានប្រភេទវិធានការថ្មីទៀត ក្នុងនោះមានវិធានការមួយដែលក្រមនីតិវិធីព្រហ្មទណ្ឌប្រសិតនាមថា "វិធានការនិរន្តរាយ"(ពីមាត្រា ១៨៥ ដល់មាត្រា ២៣០ រួមមាន : ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួនការឃុំខ្លួនបណ្ដោះអាសន្ន និងការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ)។ គោលគំនិតនៃវិធានការនិរន្តរាយនេះ ក៏ជាកត្តាមួយជួយបង្ការការប្រព្រឹត្តបទល្មើសថ្មីទៀត ឬការមិនរាងចាល(គោលដៅបង្ការ ដោយធ្វើអព្យាក្រឹត្យភាពនៃស្ថានភាពគ្រោះថ្នាក់) ដើម្បីធានាប្រសិទ្ធភាពក្នុងការស៊ើបអង្កេត ការស៊ើបសួរ និងការស្វែងរកការពិត។ លើសពីនេះ មានប្រភេទទោសមួយចំនួនអាចត្រូវបានប្រកាស ដោយអាជ្ញាធររដ្ឋបាលផង អាជ្ញាធរតុលាការផង។ អំណានក្រមព្រហ្មទណ្ឌបានឱ្យដឹងថា ទោសបន្ថែម ក្នុងមាត្រា ៥៣ ដូចជា ការព្យួរលិខិតបើកបរ ការបិទគ្រឹះស្ថានអាជីវកម្ម... អាចត្រូវបានដាក់ដោយអាជ្ញាធររដ្ឋបាល ផង អាជ្ញាធរតុលាការផង។

**មុខងារនៃទោសព្រហ្មទណ្ឌ.**-ទោសព្រហ្មទណ្ឌមានមុខងារបីយ៉ាង ដែលក្នុងនោះ មុខងារទី ៣ (មុខងារអប់រំកែប្រែស្ដារនីតិសម្បទា) ទើបតែត្រូវបានគេរកឃើញនៅដើមសតវត្សទី ២០ :

*ទី ១-មុខងារបង្រ្កាប ឬសងសឹក* : មុខងារបង្ក្រាបនេះ ជាមុខងារចម្បង។ នៅសម័យបូរាណ ទោសព្រហ្មទណ្ឌ រមែងប្រព្រឹត្តទៅក្រោមរូបភាពជាការសងសឹក (ឈាមសងដោយឈាម ភ្នែកសងដោយភ្នែក...)។ តាមពិតច្បាប់ ព្រហ្មទណ្ឌត្រូវបានគេបង្កើតឡើងដើម្បីជាឧបករណ៍ក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសដែលជាប្រតិកម្មសង្គមទៅនឹង ជនល្មើស ហើយមានគោលដៅរក្សាសណ្តាប់ធ្នាប់ សន្តិសុខជូនពលរដ្ឋទូទៅ។ រហូតដល់មានទ្រឹស្តី "ឧក្រិដ្ឋជនពីកំណើត"[៣៦] ហើយចរន្តគំនិតនៃការបំបាត់ជនទុច្ចរិតពី សង្គមបានឈានទៅរកការបំបាត់សូម្បីតែជនណាដែលគេយល់ថា ជាឧក្រិដ្ឋជន ទោះពីកំណើត ហើយបើទោះបីជាជននោះ មិនទាន់បានប្រព្រឹត្តបទល្មើសក៏ដោយ។ នៅសម័យបុច្ចុប្បន្ន មុខងារ សងសឹកត្រូវបានជំនួសដោយមុខងារបង្ក្រាបដែលមានភាពចាំបាច់ ខ្វះមិនបានក្នុងការបង្ការ និងរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខជូនសង្គម។

*ទី ២-មុខបង្ការ ឬធ្វើឱ្យខ្លាចរអា* : ជនល្មើសក្រោយពីអនុវត្តទោសក្នុងពន្ធធនាគាររួច ហើយគឺធ្វើឱ្យខ្លាចរអា លែងហ៊ានប្រព្រឹត្តបទល្មើសតែម្តង។ អានុភាពរបស់វាគឺចង្អុលប្រាប់ជនដទៃក្រៅពីជនល្មើស ឱ្យមានសេចក្តីខ្លាចរអា នឹងទណ្ឌកម្មដែលដាក់លើជនល្មើស។

*ទី ៣-មុខងារអប់រំកែប្រែ* : ចាប់ពីសតវត្សទី ២០ មក ជាពិសេសដោយឥទ្ធិពលនៃទ្រឹស្តីមួយដែលថាមនុស្សតែងមានកំហុសជៀសពុំរួចឡើយ គួរតែទុកពេលឱ្យកែប្រែកំហុស(ត្រូវតែដកហូតសេរីភាពដើរហើរ និងសេរីភាពផ្លូវភេទ)។ គំនិតនេះត្រូវបានគេទទួលយក ហើយទោសព្រហ្មទណ្ឌប្រព្រឹត្តទៅ ដោយទុកលទ្ធភាពឱ្យជនល្មើសកែប្រែកំហុសក្នុងពន្ធនាគារក្នុងរយៈពេលមួយសមស្រប ហើយទោសដែលអនុវត្តចំពោះទណ្ឌិតមាននាទីសំខាន់ក្នុងការស្តារនីតិសម្បទាទណ្ឌិត(អប់រំកែប្រែឱ្យក្លាយជាពលរដ្ឋល្អក្នុងសង្គម) ក្នុងគោលដៅអនុញ្ញាតឱ្យចូលមករួមរស់ក្នុងសង្គមវិញ។ ឯគំនិតសងសឹក និងការលុបបំបាត់ឧក្រិដ្ឋជនចេញពីសង្គម ក៏ហួសសម័យ ហើយបានលិចទៅក្នុងស្រមោលគំនិតនៃការកែប្រែអប់រំនេះឯង។ គំនិតនេះ បន្តរហូតមកដល់បច្ចុប្បន្ន(លើកលែងតែបណ្តាប្រទេសមួយចំនួនដែលគេយល់ថាជនល្មើសមិនអាចកែប្រែបាន ទើបគេអនុវត្តទោសប្រហារជីវិត) ជាពិសេសប្រទេសកម្ពុជាយើង បានលុបចោលទោប្រហារជីវិត ដែលជាសញ្ញាមួយនៃការទុកលទ្ធភាពឱ្យជនល្មើសអាចកែប្រែកំហុស។ នៅពេលដំណាលគ្នានេះផងដែរ គេក៏ចាប់ផ្តើមពិចារណាភ្លាមថាតើការឃុំឃាំងដកហូតសេរីភាពក្នុងរយៈពេលប៉ុន្មាន ទើបអាចអប់រំកែប្រែជនល្មើសនោះបាន។ ហេតុនេះ ទើបមានការកំណត់ទោសដែលប្រែប្រួលទៅតាមកំហុស និងលទ្ធភាពស្តារនីតិសម្បទាទណ្ឌិត។

ដូចនេះ ក្រៅពីចរិតបង្ការការប្រព្រឹត្តបទល្មើសដោយបុគ្គលដទៃ(ជាលក្ខណៈសមូហភាព) និងជនល្មើសខ្លួនឯង(ជាលក្ខណៈបុគ្គល) ព្រមទាំងផ្តន្ទាទោសកំហុស ទោសដែលច្បាប់កំណត់ ក៏ដូចជាទោសដែលតុលាការប្រកាសប្រឆាំងនឹងទណ្ឌិតណាម្នាក់តែងប្រព្រឹត្តទៅ ដោយគិតគូរលើប្រយោជន៍ពីរយ៉ាង **១**-ប្រយោជន៍សង្គម(ភាពសុខសាន្តនៃសង្គមតម្រូវឱ្យដកហូតជនល្មើសចេញពីសង្គមទៅរក្សាទុកនៅកន្លែងមួយ ដើម្បីឱ្យ

[36] Le crimimel né.

ពិចារណាកំហុសកែខ្លួន)ដែលជាប្រយោជន៍រួម និង **២**-ប្រយោជន៍ផ្ទាល់របស់ទណ្ឌិត(លទ្ធភាពក្លាយជាពលរដ្ឋល្អរបស់សង្គម)។ តុល្យការនៃប្រយោជន៍ទាំងពីរឈរលើមូលដ្ឋានមួយ គឺការកំណត់ និងការដាក់ទោសត្រូវតែមានភាពសមហេតុសមផល មិនហួសហេតុពេក ពោលគឺធន់ល្មមនឹងចរិតគ្រោះថ្នាក់នៃបទល្មើស។

**ក្រមព្រហ្មទណ្ឌ**-គោលការណ៍ទាក់ទងនឹងទោសព្រហ្មទណ្ឌ ត្រូវបានចងក្រងបង្កើតបានជារបបគតិយុត្តមួយច្បាស់លាស់ដែលអាចអនុញ្ញាតឱ្យចៅក្រមយកទៅអនុវត្តបានសមស្របតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែងចំពោះមុខនីមួយៗ ដើម្បីជាប្រយោជន៍ដល់សង្គមជាតិទាំងមូល។ មានន័យថាក្រមព្រហ្មទណ្ឌបានគិតគូរពីប្រយោជន៍ ទាំងពីរខាងលើ ជាពិសេសរបបនៃការប្រកាសទោស និងការអនុវត្តទោស។

**ពេលវេលាជាមាសប្រាក់ ឯពេលសិក្សាជាការត្រងយកមាសប្រាក់មិនចេះរីងស្ងួត។**

# ផ្នែកទី ១ ទោសដែលកំណត់ដោយច្បាប់

រហូតមកដល់ក្រមព្រហ្មទណ្ឌ ទោសដែលច្បាប់កំណត់មានពីរប្រភេទ គឺទោសដាក់ពន្ធធនាគារ និងទោសពិន័យជាប្រាក់(មូលទោស)។ តែក្រមព្រហ្មទណ្ឌបានបង្កើតទោសពីរប្រភេទទៀត គឺទោសបន្ថែម និងទោសជំនួស។

ក្រមព្រហ្មទណ្ឌ បានអនុម័តបន្តប្រពៃណីច្បាប់ខ្មែរ "កាលបើបទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃទោសដាក់ពន្ធនាគារ។ កាលបើបទល្មើសត្រូវផ្តន្ទាទោសពិន័យ ច្បាប់កំណត់អំពីអប្បបរមា និងអតិបរមានៃចំនួនទឹកប្រាក់ពិន័យដែលត្រូវទទួល"(មាត្រា ៤៤)។

ទោសដែលច្បាប់កំណត់មានគោលដៅប្រឆាំងនឹងបុគ្គល ដកហូតទ្រព្យសម្បត្តិ និងរឹតបន្តឹងសេរីភាពបុគ្គល និងសិទ្ធិមួយចំនួន ព្រមទាំងដកហូតសេរីភាព និងសិទ្ធិមួយចំនួនទៀតផង។

ទោសដកហូតសេរីភាពក្នុងរយៈពេល ឬអស់មួយជីវិត និងដកហូតទ្រព្យសម្បត្តិ ត្រូវបានក្រមព្រហ្មទណ្ឌប្រសិទ្ធនាមថាមូលទោស ដែលអាចត្រូវបានជំនួសដោយទោសបន្ថែម មួយ ឬច្រើន និងទោសផ្សេងពីនេះជាទោសបន្ថែម។

## កថាខណ្ឌទី ១ ចំណាត់ថ្នាក់នៃទោស

**ចំណាត់ថ្នាក់ពីរប្រភេទនៃទោស.-**ចំណាត់ថ្នាក់ប្រភេទទី ១ ពិពណ៌នាអំពីប្រភេទផ្សេងៗ ដោយយោងទៅតាមកម្មវត្ថុនៃការដាក់ទោស និងប្រភេទទី ២ ពិពណ៌នាថាតើច្បាប់កំណត់ប្រភេទនៃទោសនោះយ៉ាងណាដែរ។ ចំណាត់ថ្នាក់ប្រភេទទី ១ គោងយកកម្មវត្ថុនៃទោស ចំណែកប្រភេទទី ២ វិញ ផ្តោតលើលក្ខខន្តិកៈនៃទោស។ តាមពិត ទោសត្រូវបានចាត់ថ្នាក់ជាបីប្រភេទ គឺមូលទោស ទោសបន្ថែម និងទោសបន្ថែមដែល ចំណាត់នេះ ត្រូវបានក្រមព្រហ្មទណ្ឌអនុម័តយក។

## អនុកថាខណ្ឌទី ១ ចំណាត់ទៅតាមកម្មវត្ថុនៃទោស

ទោសដែលអនុវត្តមានរូបភាពជាការដកហូតសេរីភាព ការរឹតបន្តឹងសេរីភាព ការដកហូត ឬការរឹតបន្តឹងប្រភេទសិទ្ធិមួយចំនួន និងការផ្សព្វផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស។

**ក..ទោសដកហូតសេរីភាព** ការដកហូតសេរីភាពនេះ ក៏អាចកើតមាននៅក្នុងអំឡុងពេលនៃនីតិវិធីតុលាការដែរ(ការឃុំខ្លួនបណ្ដោះអាសន្ន) បើទោះជាវាមានអានុភាពគំរាម និងធ្វើអព្យាក្រិត្យភាពជនសង្ស័យ តែវាមិនមែនជាទោសទេ ព្រោះជនប្រភេទនេះ ជាជនគ្មានកំហុស ហើយការឃុំនេះទៀតសោត ដោយហេតុផលនៃការស៊ើបសួរ ឬការឃាត់ខ្លួន។

នៅទីនេះ ទោសប្រភេទនេះដែលមានសេចក្ដីសម្រេចតុលាការស្ថាពរ អាចប្រព្រឹត្តទៅក្នុងរយៈពេល ឬអស់មួយជីវិត។ ការបំបិទសេរីភាពនេះ ឈរលើស្មារតីនៃភាពពុំអាចទុកឱ្យជនល្មើសនៅក្រៅឃុំបាន ក្នុងគោលបំណងបង្ការបទល្មើស និងអប់រំស្ដារនីតិសម្បទាចូលរួមរស់ក្នុងសង្គមឡើងវិញ។ តែការសិក្សាបែបវិទ្យាសាស្ត្របានបង្ហាញឱ្យឃើញថាការដកហូតសេរីភាពក្នុងន័យមនុស្សធម៌នេះ តែងប្រែសភាពដើមដូចពោះចិកកន្ទុយ : ពន្ធនាគារក្លាយជា សាលារៀននៃភាពមិនរាងចាល ! ការស្ដារនីតិសម្បទាជនល្មើសមិនបានជោគជ័យទេ ហេតុនេះ គេក៏ស្វែងរកវិធីសាស្ត្រផ្សេង។ គេត្រូវជួយសង្គ្រោះជនល្មើសណាដែលគេយល់ថាអាចជួយបាន ហើយរក្សាទុកនូវអំណាចហាម និងគំរាមកំហែងនៃទោសដល់ប្រភេទជនល្មើសមួយចំនួនដែលបុគ្គលិកលក្ខណៈមិនអាចទទួលយកការកែប្រែនេះបាន។

ទោសប្រភេទនេះ ត្រូវបានធ្វើប្រឆាំងនឹងបុគ្គល រួមមាន ការប៉ះពាល់អត្ថិភាពនៃបុគ្គល ដល់បូរណភាពរូប រាងកាយរបស់ជនល្មើស ដល់សេរីភាពបុគ្គល និងវិធានការនិរន្តរាយ ព្រមទាំងការដកហូត ឬការរឹតបន្តឹងសេរីភាព ពាណិជ្ជកម្ម និងឧស្សាហកម្ម។

**ខ..ទោសរឹតបន្តឹងសេរីភាព** ទោសប្រភេទនេះ មិនឈានរហូតដកហូតសេរីទាំងស្រុងទេមានតែសេរីមួយចំនួនប៉ុណ្ណោះដែលត្រូវបានដកហូត រឹតបន្តឹង ឬរឹតត្បិត។ ទោសនេះ ស្ដែងឡើងក្រោមរូបភាពផ្សេងៗ ដូចជាការហាមឃាតទណ្ឌិតមិនឱ្យចាកចេញពី ចំពោះការចូល និងស្នាក់នៅលើដែនដីកម្ពុជា ការហាមឃាត់មិនឱ្យមានមុខ នៅកន្លែងខ្លះ ទោសការងារសហគមន៍ ការបណ្ដេញចេញពីលទ្ធកម្មសាធារណៈជាដើម។

**គ..ទោសដកហូតសិទ្ធិ** ការដកហូតសិទ្ធិពលរដ្ឋសម្រាប់រយៈពេល ០៥ ឆ្នាំ ឬជាស្ថាពរ(មាត្រា ៥៥) ដែលរួមមាន :

១.សិទ្ធិបោះឆ្នោត

២.សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត

៣.សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ

៤.សិទ្ធិ ទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជាអាណត្តិគាហករបស់តុលាការ

៥.សិទ្ធិទទួល និងពាក់គ្រឿង ឥស្សរិយយសទាំងអស់

៦.សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការ។

**ឃ..ទោសដកហូតទ្រព្យសម្បត្តិ** រួមមានទោសពិន័យជាប្រាក់ ទោសរឹបអូសអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលបំរើឱ្យ ឬមានគោលដៅប្រព្រឹត្តបទល្មើស និងទោសបិទគ្រឹះស្ថាន ឬការដកហូតសេរីភាពពាណិជ្ជកម្មមួយរយៈ ឬជារឿងរហូត ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផល កើតចេញពីបទល្មើស ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុដែលលំអទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត ។

**ង..ទោសផ្សព្វផ្សាយសេចក្តីសម្រេចផ្តន្ទាទោស** រួមមានការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន និងការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយ ទូរគមនាគមន៍សោតទស្សន៍ ក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ។ ការផ្សាយអាចធ្វើទាំងស្រុង ឬតាមសម្រង់ ឬ តាមនិទ្ទេសធម្មតា។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។

-ទោសបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅកន្លែងដែលចង្អុលបង្ហាញ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ។ ការបិទផ្សាយមិនអាចលើសពី ២ខែ ទេ។

-ទោសផ្សាយសេចក្តីសម្រេចរបស់តុលាការ ត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងចិរវេលាដែលកំណត់ដោយតុលាការ។ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត។ ក្នុងករណីមិនគោរពតាម ទណ្ឌិតអាចត្រូវបង្ខំដល់រូបកាយ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាច បដិសេធការផ្សព្វផ្សាយនេះបានទេ។

-ទោសផ្សាយជាសាធារណៈនូវសេចក្តីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ដោយតុលាការ។ ការផ្សាយនេះ មិនអាចលើសពី ៨ថ្ងៃ ទេ។

## អនុកថាខណ្ឌទី ២ ចំណាត់ទៅតាមលក្ខខន្តិកៈនៃទោស

នេះជាប្រភេទនៃទោសតាមធម្មនិយាមគតិយុត្ត។

**ក..ទោសនៃនីតិរូម និងទោសផ្សេងទៀត** ការបែងចែកនេះ មានមូលដ្ឋានលើប្រភេទបទល្មើសដូចជាបទល្មើសនយោបាយ និងបទល្មើសដែលស្ថិតក្រោមរបបគតិយុត្តរួមមួយ។ តែការបែងចែកពុំត្រូវបានក្រមព្រហ្មទណ្ឌទទួលស្គាល់ទេ។

**ខ..មូលទោស ទោសជំនួស និងទោសបន្ថែម** មូលទោសជាទោសដ៏សំខាន់ក្នុងការផ្តន្ទាទោស ចំណែកឯទោស បន្ថែមគ្រាន់តែមានលក្ខណៈបន្ទាប់បន្សំ ហើយអាចប្រកាសបន្ថែមទៅនឹងមូលទោស និង ទោសជំនួស។ ទោសជំនួស ដូចឈ្មោះរបស់វាបញ្ជាក់ស្រាប់ "ជំនួសឱ្យមូលទោស" ហើយមូលទោសនោះ នឹងលែងអនុវត្ត(មាត្រា ៩៨)។ យោងតាមក្រមព្រហ្មទណ្ឌ ច្បាប់ទុកទល្ហភាពឱ្យចៅក្រមក្នុងការសម្រេច ប្រកាស ឬមិនប្រកាសទោសជំនួស(មាត្រា ៧២ និងមាត្រា ៧៦)។ សេចក្តីលំអិតនៅខាងក្រោម។

**គ..ទោសឧក្រិដ្ឋ មជ្ឈិម និងទោសលហុ** ទោសនេះ កើតឡើងដោយលទ្ធផលនៃការបែងចែក បទល្មើសជា បទឧក្រិដ្ឋ បទលជ្ឈិម និងបទលហុ។ ចំណាត់នេះ បង្ហាញពីការដាក់ដោយយោងលើចរិត គ្រោះថ្នាក់នៃអំពើ។

**ឃ..ទោសអនុវត្តចំពោះរូបវន្តបុគ្គល នីតិបុគ្គល និងអនីតិជន** នេះជាការបែងចែកមួយដែលមាន មូលដ្ឋាននៃការគិតគូរពីការប្រភេទបុគ្គល។

## កថាខណ្ឌទី ២ ប្រភេទនៃទោសក្នុងក្រមព្រហ្មទណ្ឌ

**ប្រភេទនៃទោស..**ក្រមព្រហ្មទណ្ឌបង្កើតទោសបីប្រភេទ គឺមូលទោស ទោសជំនួស និង ទោសបន្ថែម។ មានន័យថា ក្រមព្រហ្មទណ្ឌអនុម័តយកប្រភេទមួយនៃទ្រឹស្តីនៃទោសតាមលក្ខន្តិកៈ។

### អនុកថាខណ្ឌទី ១ មូលទោស

រហូតមកដល់សម័យកាលនៃក្រមព្រហ្មទណ្ឌ ច្បាប់ខ្មែរហាក់មិនទាន់បានគិតគូរដាក់ទោសនីតិបុគ្គល ទេ។ តែក្រមនេះ និងច្បាប់ពិសេសដូចជាច្បាប់ស្តីពីការបង្រ្កាបអំពើភេរវកម្មបានសម្រេចដាក់ទោសនីតិបុគ្គល។

យោងតាមក្រមព្រហ្មទណ្ឌ មូលទោសដែលអនុវត្តមានការប្រែប្រួលទៅតាមប្រភេទនៃជនល្មើសជា រូបវន្តបុគ្គល ឬនីតិបុគ្គល។ "មូលទោសរួមមានទោសដាក់ពន្ធនាគារ និងទោសពិន័យ។ ការពិន័យត្រូវគិតជា ប្រាក់រៀល" (មាត្រា ៤៣)។ "ប្រាក់ពិន័យដែលទទួលបាន ត្រូវបង់ចូលថវិការដ្ឋ"(មាត្រា ៥២)។

#### ក..មូលទោសអនុវត្តចំពោះរូបវន្តបុគ្គល

មូលទោសអនុវត្តចំពោះរូបវន្តបុគ្គល គឺទោសដកហូតសេរីភាព និងទោសដកហូតទ្រព្យសម្បត្តិ។

**ទម្ងន់នៃទោសប្រភេទនេះ មានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើសជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ ក្រៅពីមូលទោសនេះ អាចមានទោសបន្ថែមដែលចៅក្រមអាចប្រកាសបន្ថែមលើមូលទោសក្នុងលក្ខខណ្ឌដែលមានច្បាប់ចែងយ៉ាងជាក់លាក់ (ចំពោះបទល្មើសនីមួយៗ)។**

-ចំពោះបទឧក្រិដ្ឋ ទោសដែលអនុវត្តគឺ ទោសដាក់ពន្ធនាគារដែលមានដូចតទៅ :

-ទោសប្រហារជីវិតត្រូវបានលុបចោលដោយរដ្ឋធម្មនុញ្ញ ( ម. ៣២)

-ទោសដាក់ពន្ធនាគារអស់មួយជីវិត

-ទោសដាក់ពន្ធនាគារចាប់ពី ២០ ឆ្នាំ ទៅ ៣០ ឆ្នាំ

-ទោសដាក់ពន្ធនាគារចាប់ពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ

-ទោសដាក់ពន្ធនាគារចាប់ពី ១០ ឆ្នាំ ទៅ ២០ ឆ្នាំ

-ទោសដាក់ពន្ធនាគារចាប់ពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ

-ទោសដាក់ពន្ធនាគារចាប់ពី ៧ ឆ្នាំ ទៅ ១៥ ឆ្នាំ

-ទោសដាក់ពន្ធនាគារចាប់ពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ

-ទោសដាក់ពន្ធនាគារចាប់ពី ៣ ឆ្នាំ ទៅ ១០ ឆ្នាំ ( លួចដោយប្រើហិង្សា)

-ចំពោះបទមជ្ឈិម ទោសដែលអនុវត្ត គឺទោសដាក់ពន្ធនាគារ ពិន័យជាប្រាក់

-ទោសដាក់ពន្ធនាគារចាប់ពី ៣ ឆ្នាំ ទៅ ៥ ឆ្នាំ ( ម.២៥៣-២)

-ទោសដាក់ពន្ធនាគារចាប់ពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យពី ៤ លាន ៛ ទៅស្មើនឹងតំលៃមូនិធិ ឬតម្លៃទ្រព្យ ដែលជាកម្មវត្ថុនៃការសំអាតប្រាក់ ( ម.៤០៥)

-ទោសដាក់ពន្ធនាគារចាប់ពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យពី ៤ លាន ៛ ទៅ ១០ លាន ៛

-ទោសដាក់ពន្ធនាគារចាប់ពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ ( ម. ៣៧៩-៣៨០ បទឆបោកដោយមានស្ថានទម្ងន់ទោស)

-ទោសដាក់ពន្ធនាគារចាប់ពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យពី ៥ លាន ៛ ទៅ ២០ លាន ៛ ( ម. ៦៥៧)

-ទោសដាក់ពន្ធនាគារចាប់ពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យពី ២ លាន ៛ ទៅ ១០ លាន ៛

-ទោសដាក់ពន្ធនាគារចាប់ពី ១ ឆ្នាំ ទៅ ៣ ឆ្នាំ និងពិន័យពី ២ លាន ៛ ទៅ ៦ លាន ៛

-ទោសដាក់ពន្ធនាគារចាប់ពី ១ ឆ្នាំ ទៅ ២ ឆ្នាំ និងពិន័យពី ២ លាន ៛ ទៅ ៤ លាន ៛

-ទោសដាក់ពន្ធនាគារចាប់ពី ៦ ខែ ទៅ ៣ ឆ្នាំ និងពិន័យពី ១ លាន ៛ ទៅ ៦ លាន ៛

-ទោសដាក់ពន្ធនាគារចាប់ពី ៦ ខែ ទៅ ២ ឆ្នាំ និងពិន័យពី ១ លាន ៛ ទៅ ៤ លាន ៛

-ទោសដាក់ពន្ធនាគារចាប់ពី ៦ ខែ ទៅ ១ ឆ្នាំ និងពិន័យពី ១ លាន ៛ ទៅ ២ លាន ៛

-ទោសដាក់ពន្ធនាគារចាប់ពី ១ ខែ ទៅ ១ ឆ្នាំ និងពិន័យពី ១ លាន ៛ ទៅ ៥ លាន ៛ ( ម.៦៥៨)

-ទោសដាក់ពន្ធនាគារចាប់ពី ១ ខែ ទៅ ១ ឆ្នាំ និងពិន័យពី ១ សែន រ ទៅ ២ លាន រ

-ទោសដាក់ពន្ធនាគារចាប់ពី ១ ខែ ទៅ ៦ ខែ និងពិន័យពី ១ សែន រ ទៅ ១ លាន រ

-ទោសដាក់ពន្ធនាគារចាប់ពី ១ ខែ ទៅ ៣ ខែ និងពិន័យពី ១ សែន រ ទៅ ៥ សែន រ

-ទោសដាក់ពន្ធនាគារចាប់ពី ៦ ថ្ងៃ ទៅ ៣ ខែ និងពិន័យពី ១ សែន រ ទៅ ៥ សែន រ

-ទោសដាក់ពន្ធនាគារចាប់ពី ៦ ថ្ងៃ ទៅ ៣ ខែ និងពិន័យពី ១ សែន រ ទៅ ៥ សែន រ

-ទោសដាក់ពន្ធនាគារចាប់ពី ៦ ថ្ងៃ ទៅ ១ ខែ និងពិន័យពី ១ ម៉ឺន រ ទៅ ១ សែន រ

-ទោសដាក់ពន្ធនាគារចាប់ពី ១ ថ្ងៃ ទៅ ១ ខែ និងពិន័យពី ១ ពាន់ រ ទៅ ១ សែន រ

យោងតាមការបង្ហាញនេះ អាចឱ្យគេដឹងថា ទម្ងន់នៃទោសមធ្យមប្រែប្រួលដោយឈរលើភាពធ្ងន់ធ្ងរនៃអំពើប្រព្រឹត្ត។

-ចំពោះបទលហុ ទោសដែលអនុវត្តគឺៈ

-ទោសដាក់ពន្ធនាគារចាប់ពី ១ថ្ងៃ ទៅ ៦ថ្ងៃ និងពិន័យពី ១ សែន រ ទៅ ១០ លាន រ ( ម. ៦៥១)

-ទោសដាក់ពន្ធនាគារចាប់ពី ១ ថ្ងៃ ទៅ ៦ ថ្ងៃ និងពិន័យពី ១ ពាន់ រ ទៅ ១ សែន រ

-ពិន័យជាប្រាក់ពី ១ សែន រ ទៅ ១០ លាន រ ( ម. ៣០៥ បរិហារកេរ្តិ៍ ឬជេរប្រមាថជាសាធារណៈ)

-ពិន័យជាប្រាក់ពី ៥ ពាន់ រ ទៅ ៥ ម៉ឺន រ

-ពិន័យជាប្រាក់ពី ៥ ពាន់ រ ទៅ ១ ម៉ឺន រ

-សូមមើលមាត្រា ៨៨ ច្បាប់ចរាចរផ្លូវគោក

## **ខ.-មូលទោសអនុវត្តចំពោះនីតិបុគ្គល**

ដោយហេតុថាទោសដកហូតសេរីភាព វាមិនអាចអនុវត្តចំពោះនីតិបុគ្គលបាន ហេតុនេះគេជំនួយទោសដាក់ពន្ធនាគារដោយទោសពិន័យជាប្រាក់ និងបង្កើតទោសបន្ថែម ព្រមទាំងទោសបន្ថែមផ្សេងៗទៀតដែលជាសិទ្ធិអំណាចរបស់ចៅក្រម។ អាស្រ័យហេតុនេះ ក្រមព្រហ្មទណ្ឌសម្រេចអំពី ទោសជាយថាប្រភេទដែលត្រូវរងដោយនីតិបុគ្គល :

១.ទោសពិន័យក្នុងឋានៈជាមូលទោស និង

២.ទោសបន្ថែមដែលចែងក្នុង មាត្រា ១៦៨ នៃក្រមនេះ (មាត្រា ១៦៧)។

ទោសពិន័យជាប្រាក់មានការប្រែប្រួលពីបទល្មើសមួយទៅបទល្មើសមួយ :

-ពិន័យជាប្រាក់ពី ១០០ លានរ ទៅ ៥០០ លាន រ ( ម. ៤០៩ សំអាត់ប្រាក់)

-ពិន័យជាប្រាក់ពី ៥០ លានរ ទៅ ៥០០ លាន រ

-ពិន័យជាប្រាក់ពី ២០ លានរ ទៅ ២០០ លាន រ

- ពិន័យជាប្រាក់ពី ១០ លានរ ទៅ ១០០ លាន រ
- ពិន័យជាប្រាក់ពី ៥ លានរ ទៅ ២០ លាន រ
-ពិន័យជាប្រាក់ពី ១ លានរ ទៅ ១០ លាន រ និង
- ពិន័យជាប្រាក់ពី ១ លានរ ទៅ ៥ លាន រ

តុលាការអាចប្រកាសទោសបន្ថែមលើលមូលទោស ដែលមានចែងក្នុងប្រភេទបទល្មើសនីមួយៗ។

## អនុកថាខណ្ឌទី ២ ទោសជំនួស

សូមអានផ្នែកទី ២ត្រង់ទោសជំនួសដែលចៅក្រមប្រកាស។

## អនុកថាខណ្ឌទី ៣ ទោសបន្ថែម

ទោសបន្ថែមមានគោលដៅពង្រឹងការដាក់ទោស ជាពិសេសប្រភេទបទល្មើសមួយចំនួនអាចបង្ការ និង បង្ក្រាបដោយមានការតាំងបទបញ្ញារដ្ឋបាល ឬតុលាការ។ ចំពោះទោសបន្ថែម វាជាសិទ្ធិរបស់ចៅក្រមក្នុងការប្រកាស ឬមិនប្រកាសទោសបន្ថែមដូចមានការគូសបញ្ជាក់ដោយមាត្រា ៥៤ "ទោសបន្ថែមនឹងអាចប្រកាសទៅបាន លុះត្រាតែទោសនេះត្រូវបានចែងដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុដែលត្រូវចោទប្រកាន់។ ទោសបន្ថែមត្រូវប្រកាសជាកាតព្វកិច្ច ប្រសិនបើច្បាប់ចែងយ៉ាងជាក់លាក់"។

ទោសបន្ថែមមានពីរប្រភេទ គឺទោសបន្ថែមអនុវត្តចំពោះរូបវន្តបុគ្គល និងនិតិបុគ្គលទៅតាមប្រភេទនៃទោសបន្ថែមដែលមិនមានវិសសមភាពជាមួយនីតិបុគ្គល។

### ១..ទោសបន្ថែមអនុវត្តចំពោះរូបវន្តបុគ្គល

មាត្រា ៥៣ បានកំណត់យកគោលការណ៍រួមនៃប្រភេទទោសបន្ថែម "ទោសបន្ថែមរួម មាន :

**១**.ការដកសិទ្ធិខ្លះជាពលរដ្ឋ

**២**.ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណាដែលបទល្មើសនោះបានប្រព្រឹត្ត នៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ

**៣**.ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ

**៤**.ការព្យួរលិខិតបើកបរ

**៥**.ការហាមឃាត់ចំពោះការស្នាក់នៅ

**៦**.ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**៧**.ការហាមឃាត់ចំពោះការចូល និងស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះទណ្ឌិតដែលជាជនបរទេស

**៨**.ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស

**៩**.ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស

**១០**.ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស

**១១**.ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុដែលលំអទីកន្លែងដែល បទល្មើសត្រូវបានប្រព្រឹត្ត

**១២**.ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត

**១៣**.ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

**១៤**.ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ

**១៥**.ការបិទគ្រឹះស្ថានដែលប្រើប្រាស់ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស

**១៦**.ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅ ក្នុងគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន

**១៧**.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស

**១៨**.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន

**១៩**.ការផ្សាយសេចក្តីសម្រេចផ្តន្ទា ទោសតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

បទប្បញ្ញត្តិដោយឡែកអាចបង្កើតទោសបន្ថែមផ្សេងៗទៀត។

សេចក្តីលំអិតអំពីទោសទាំងនោះ មានចែងក្នុងមាត្រា ៥៣ ខាងលើ :

## ក..ការប៉ះពាល់ដល់សិទ្ធិពលរដ្ឋ និងសេរីភាពសេដ្ឋកិច្ច

*.សិទ្ធិពលរដ្ឋដែលអាចដកបាន..* "សិទ្ធិពលរដ្ឋដែលអាចដកបានដូចមានចែងក្នុងចំណុច ១ នៃមាត្រា ៥៣ នៃក្រមនេះ រួមមាន :

១.សិទ្ធិបោះឆ្នោត

២.សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត

៣_សិទ្ធិបំពេញការងារជាមន្ត្រី ក្របខ័ណ្ឌមុខងារសាធារណៈ ៤_សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជាអាណត្តិគាហក របស់តុលាការ

៥_សិទ្ធិទទួលនិងពាក់គ្រឿងឥស្សរិយយសទាំងអស់

៦_សិទ្ធិធ្វើជាសាក្សីដែលទទួលសម្បថនៅមុខតុលាការ។

ទោសទាំងអស់ខាងលើនេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន" (មាត្រា ៥៥)។

*_សេរីភាពខាងសេដ្ឋកិច្ច*_ការប៉ះពាល់ដល់សេរីភាពសេដ្ឋកិច្ចរួមមាន :

**_ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ :** "ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ មិនអនុវត្តទៅលើការបំពេញអាណត្តិ ដែលជ្រើសតាំង ដោយការបោះឆ្នោតជាសាធារណៈ ឬការទទួលខុសត្រូវខាងសហជីពទេ។ ការហាមឃាត់នេះ មិនអាច អនុវត្តចំពោះបទល្មើសរំលោភលើច្បាប់ស្តីពីរបបសារព័ត៌មានទេ។ ទោសនេះអាចជាស្ថាពរ ឬក៏ជាបណ្តោះ អាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន។ តុលាការត្រូវបញ្ជាក់មុខរបរដែលត្រូវហាមឃាត"(មាត្រា ៥៦) ។

**_ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ** អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើននាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោល ក្នុងលទ្ធកម្មសាធារណៈទាំងឡាយដែលរៀបចំដោយ : ១_រដ្ឋ ២_រដ្ឋបាលថ្នាក់ក្រោមជាតិ ៣_គ្រឹះស្ថានសាធារណៈ ៤_សហគ្រាសដែលទទួលសម្បទាន ពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋ ឬដោយរដ្ឋបាល ថ្នាក់ក្រោមជាតិ"(មាត្រា ៦៥)។

**_ការបិទគ្រឹះស្ថាន :** ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង។ ទោសបិទគ្រឹះស្ថាននេះអាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ឆ្នាំ យ៉ាងច្រើន"(មាត្រា ៦៦)។

**_ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន**ដែលបើកចំហសម្រាប់សាធារណជន ឬដែលត្រូវប្រើប្រាស់ដោយសាធារណជន អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន"(មាត្រា ៦៧)។

### ខ_ការប៉ះពាល់ដល់ទ្រព្យសម្បត្តិ

*ការដកហូតទ្រព្យសម្បត្តិ:*

**_ការរឹបអូស :** ការរឹបអូសអាចធ្វើទៅលើវត្ថុដូចតទៅ : ១_ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលសម្រាប់ប្រព្រឹត្តបទល្មើស។ ២_វត្ថុ ឬមូល_

និធិដែលជាកម្មវត្ថុនៃបទល្មើស។ ៣.ផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពី បទល្មើស។ ៤..ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុ នៅក្នុងទីកន្លែងដែល បទល្មើសបានប្រព្រឹត្ត។ ប៉ុន្តែ ការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់សិទ្ធិរបស់តតិយជន(ម. ៦២)។

**-ការចាត់ចែងទ្រព្យសម្បត្តិរឹបអូស** : "កាលបើការរឹបអូសបានក្លាយទៅជាស្ថាពរ ទ្រព្យសម្បត្តិរឹបអូសក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែមានបទប្បញ្ញត្តិដោយឡែកដែលចែងអំពីការប្រគល់ផ្សេងពីនេះ។ រដ្ឋអាចលក់ ឬបំផ្លាញទ្រព្យរឹបអូស តាមនីតិវិធីស្តីពីការលក់ទ្រព្យសម្បត្តិរដ្ឋ"(មាត្រា ៦៣) ។

*-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស :*

**-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស :** "ទោសបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅកន្លែងដែលចង្អុលបង្ហាញដោយតុលាការ និងក្នុងរយៈពេលមួយដែលកំណត់ដោយតុលាការ។ ការបិទផ្សាយមិនអាចលើសពី ២ខែ ទេ ។ ការបិទផ្សាយអាច ធ្វើទាំងស្រុង ឬតាមសម្រង់ ឬតាមនិទ្ទេសធម្មតា។ សោហ៊ុយបិទផ្សាយ គឺជាបន្ទុករបស់ទណ្ឌិត។

ក្នុងករណីមានការបំបាត់ចោល ការលាក់បំបាំង ឬការហែកចោលសេចក្តីប្រកាសនេះ ត្រូវតែធ្វើការបិទផ្សាយជាថ្មី។ ការបិទផ្សាយនេះ ត្រូវចេញសោហ៊ុយដោយអ្នកបំបាត់ចោល លាក់បំបាំង ឬអ្នកហែកចោលសេចក្តីប្រកាសនេះ" (មាត្រា ៦៨)។ ការផ្សាយនេះអាចធ្វើឡើងតាម :

១.**សារព័ត៌មានសរសេរ** "តាមបែបបទ និងក្នុងចិរវេលាកំណត់ដោយតុលាការ សោហ៊ុយក្នុងការចុះផ្សាយជាបន្ទុករបស់ទណ្ឌិត។ ក្នុងករណីមិនគោរពតាម ទណ្ឌិតអាចត្រូវបង្ខំដល់រូបកាយ។ បើតុលាការបានបង្គាប់ការផ្សព្វផ្សាយសេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការផ្សព្វផ្សាយនេះបានទេ" (មាត្រា៦៩)

២.**តាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍** "តាមបែបបទដែលកំណត់ដោយតុលាការ។ ការផ្សាយនេះ មិនអាចលើសពី ៨ថ្ងៃទេ។ ការផ្សាយអាចផ្សាយទាំងស្រុងតាមសម្រង់ ឬតាមនិទ្ទេស" (ម.៧០)។

**គ..ការរឹតបន្តឹងសេរីភាពដទៃទៀត**

**-ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ**មិនត្រូវលើសពី ៥ ឆ្នាំ ទេ" (មាត្រា ៥៧)។

**-ការព្យួរលិខិតបើកបរ** : "ទោសព្យួរលិខិតបើកបរមិនត្រូវលើសពី ៥ ឆ្នាំទេ។ ទណ្ឌិតត្រូវប្រគល់លិខិតបើកបររបស់ខ្លួន ទៅក្រឡាបញ្ជីតុលាការ។ លិខិតបើកបរត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌"(មាត្រា ៥៨) ។

**-ការហាមឃាត់ចំពោះការស្នាក់នៅកន្លែងមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា** (មាត្រា ៥៩)[៣៧]

[៣៧] វាមានលក្ខណៈប្រហាក់ប្រហែលទៅនឹង ការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចាប់ពីម.២២៣ ដល់ម. ២៣០។

"ទោសហាមឃាត់ការស្នាក់នៅគឺជាការហាមឃាត់ដល់ទណ្ឌិតចំពោះការមានមុខនៅកន្លែងខ្លះ លើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ទោសនេះមិនអាចលើស ពី ១០ ឆ្នាំ ចំពោះបទឧក្រិដ្ឋ និង ០៥ ឆ្នាំ ចំពោះបទមជ្ឈិម។ តុលាការកំណត់បញ្ជីនៃកន្លែងដែលហាមឃាត់ និងកំណត់ថិរវេលានៃការហាមឃាត់។ ការហាមឃាត់ការស្នាក់ នៅរួមមានវិធានការតាមដាន។

ទណ្ឌិតត្រូវតែ :

១.ចូលបង្ហាញខ្លួនតាមដីកាកោះរបស់អាជ្ញាធរតុលាការ ឬរដ្ឋបាលដែលតុលាការបានចាត់តាំង ។

២.ចូលបង្ហាញខ្លួនឱ្យបានទៀងទាត់តាមការកំណត់នៅស្នាក់ការនគរបាល ឬកងរាជអាវុធហត្ថ តាមការចាត់តាំងរបស់តុលាការ។

តុលាការត្រូវកំណត់បែបបទនៃវិធានការតាមដាន ។

សេចក្តីសម្រេចរបស់តុលាការត្រូវជូនដំណឹងដោយព្រះរាជអាជ្ញាដល់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ" ។

**-ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា** មិនត្រូវលើសពី ៥ ឆ្នាំ។ ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ។ លិខិតឆ្លងដែននេះ ត្រូវរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ទណ្ឌិតមិនអាចសុំលិខិតឆ្លងដែនបានទេ ក្នុងរយៈពេល ដែលកំពុង ទទួលទោសនោះ"(មាត្រា ៦០) ។

**-ការហាមឃាត់ចំពោះការចូល និងស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដល់ទណ្ឌិតដែលជាជនបរទេស** អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន ។ ការហាមឃាត់នេះនាំឱ្យមានការបណ្តេញទណ្ឌិតឱ្យចេញដោយពេញច្បាប់នៅពេលបញ្ចប់ទោសដាក់ពន្ធនាគារ(មាត្រា ៦១)។

**-ការហាមឃាត់ចំពោះការកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ** អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន។ ការហាមឃាត់នេះ ត្រូវអនុវត្តទៅលើអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវ គ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា(មាត្រា ៦៤)។

**គ.ពេលនៃការអនុវត្តទោសបន្ថែម**

ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ នៃមាត្រា ៥៣ នៃក្រមនេះ ត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ ។

**២..ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

ទោសបន្ថែមដែលចែងក្នុងមាត្រា ១៦៨ អនុវត្តចំពោះនីតិបុគ្គលរួមមាន

"១.ការរំលាយចោល។

២-ការដាក់ឱ្យនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ ។

៣-ការហាមឃាត់ចំពោះការអនុវត្តសកម្មភាពមួយ ឬច្រើន ។

៤-ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ ។

៥-ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃ ។

៦-ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន ក្រៅពីឧបករណ៍អាចជួញដូរបានដែលកំណត់ ដោយធនាគារ ។

៧-ការហាមឃាត់ចំពោះការប្រើបណ្ណទូទាត់ ។

៨-ការបិទគ្រឹះស្ថានដែលប្រើសម្រាប់ធ្វើការរៀបចំ ឬប្រព្រឹត្តបទល្មើស ។

៩-ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហដល់សាធារណជន ឬដែលបានប្រើប្រាស់ ដោយសាធារណជន។

១០-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅ សម្រាប់ប្រព្រឹត្តបទល្មើស។

១១-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

១២-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

១៣-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែល បទល្មើសបានប្រព្រឹត្ត ។

១៤-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន សរសេរ ឬការផ្សាយ តាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍"។

**លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម**-"ទោសបន្ថែមអាចនឹងប្រកាសបាន ដោយតុលាការប្រសិនបើទោសនោះ ត្រូវបានចែងយ៉ាងជាក់លាក់ចំពោះបទល្មើសដែលចោទប្រកាន់"(មាត្រា ១៦៩)។

**ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល**-"សេចក្តីសម្រេចដែលបង្គាប់ឱ្យរំលាយនីតិបុគ្គល នាំឱ្យមានការ បញ្ជូន នីតិបុគ្គល នេះទៅតុលាការមានសមត្ថកិច្ច ដើម្បីធ្វើការជម្រះបញ្ជី"(មាត្រា ១៧០)។

**ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ**-"ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ មិនអាចលើស ពី ៥ឆ្នាំ ទេ។ សេចក្តីសម្រេចដាក់ការត្រួតពិនិត្យតាមដានរបស់តុលាការនាំឱ្យមានការចាត់តាំងអាណត្តិគាហកតុលាការដែលតុលាការបញ្ជាក់បេសកកម្ម។ ជារៀងរាល់ ៦ខែ យ៉ាងតិច អាណត្តិគាហកតុលាការធ្វើរបាយការណ៍ ជូនព្រះរាជអាជ្ញាអំពីដំណើរការនៃបេសកកម្មរបស់ខ្លួន។ ក្រោយពីបានឃើញរបាយការណ៍របស់អាណត្តិគាហកតុលាការ ព្រះរាជអាជ្ញាអាចប្តឹងទៅតុលាការដែលបានប្រកាសឱ្យធ្វើការដាក់ក្រោមការតាមដានរបស់តុលាការ។ តុលាការអាចប្រកាសនូវទោសថ្មីមួយ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់យោបល់របស់ តំណាងអយ្យការ អាណត្តិគាហកតុលាការ និងជាយថាហេតុ មេធាវីរបស់ នីតិបុគ្គល នោះ"(មាត្រា ១៧១)។

**ការហាមឃាត់ចំពោះការធ្វើសកម្មភាព** អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់ចិរវេលា ៥ ឆ្នាំ យ៉ាងច្រើន។ តុលាការបញ្ជាក់អំពីសកម្មភាពដែលត្រូវហាមឃាត់ (មាត្រា ១៧២)។

**ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ**នាំឱ្យមានការហាមឃាត់ចំពោះការចូលរួមដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងគ្រប់លទ្ធកម្មសាធារណៈដែលរៀបចំដោយ : ១.រដ្ឋ ២.រដ្ឋបាលថ្នាក់ក្រោមជាតិ ៣.គ្រឹះស្ថានសាធារណៈ ៤.សហគ្រាសដែលទទួលសម្បទានពីរដ្ឋឬពីរដ្ឋបាលថ្នាក់ក្រោមជាតិ ឬដែលត្រួតពិនិត្យដោយរដ្ឋ ឬដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោសនេះ អាចជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់ចិរវេលាមួយមិនលើស ពី ៥ ឆ្នាំ (មាត្រា ១៧៣)។

**ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ** អាចជាស្ថាពរ ឬជាបណ្តោះអាសន្នស ម្រាប់រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន។ ការហាមឃាត់នេះ នាំឱ្យមានការហាមឃាត់ដល់នីតិបុគ្គលចំពោះការអំពាវនាវ ដើម្បីឱ្យដាក់ឧបករណ៍អាចជួញដូរបានរបស់ខ្លួនទៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬក្រុមហ៊ុនមូលបត្រ។ ការហាមឃាត់នេះនាំឱ្យមានការហាមឃាត់ចំពោះការផ្សព្វផ្សាយជាសាធារណៈដែរ (មាត្រា ១៧៤)។

**ការហាមឃាត់ចំពោះការចេញឧបករណ៍អាចជួញដូរបាន** អាចជាស្ថាពរ ឬជាបណ្តោះអាសន្នសម្រាប់រយៈ ពេល ៥ ឆ្នាំ យ៉ាងច្រើន(មាត្រា ១៧៥) ។ ចំពោះការហាមឃាត់ប្រើប្រាស់ បណ្ណទូទាត់ក៏ដូចគ្នាដែរ។

**ការបិទគ្រឹះស្ថាន**.."ទោសបិទគ្រឹះស្ថាន នាំឱ្យមានការហាមឃាត់ចំពោះការប្រព្រឹត្តនៅក្នុងគ្រឹះស្ថាននេះនូវសកម្មភាពដែលបទល្មើសបានកើតឡើងនៅក្នុងឱកាសដែលធ្វើសកម្មភាពនេះ។ ទោសនេះ អាចជាស្ថាពរ ឬជាបណ្តោះ អាសន្នសម្រាប់ រយៈពេល ៥ ឆ្នាំ យ៉ាងច្រើន"(មាត្រា ១៧៦) ។

**ការហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថាន**ដែលបើកចំហដល់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជនអាចជាស្ថាពរ ឬជាបណ្តោះអាសន្នក្នុងរយៈពេល ៥ឆ្នាំ យ៉ាងច្រើន(មាត្រា ១៧៧)។

**ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស**.."កាលបើការរឹបអូសក្លាយជាស្ថាពរ វត្ថុរឹបអូសក្លាយជាកម្មសិទ្ធិរបស់រដ្ឋ លើកលែងតែបទប្បញ្ញត្តិដោយឡែកបានចែងអំពីការប្រគល់ផ្សេងទៀត។ រដ្ឋអាចលក់ ឬបំផ្លាញចោលវត្ថុរឹបអូស នៅក្នុងទម្រង់ដែលមានចែងសម្រាប់ការលក់ទ្រព្យសម្បត្តិរបស់រដ្ឋ។ ច្បាប់អាចចែងអំពីការបំផ្លាញចោលនូវវត្ថុខ្លះផងដែរ។ កាលបើវត្ថុរឹបអូសមិនត្រូវបានចាប់យកទេ ហើយនិងមិនអាចប្រគល់ឱ្យបានទេនោះ ទណ្ឌិតត្រូវចេញសងតម្លៃនៃវត្ថុរឹបអូសនេះ។ តម្លៃនេះ ត្រូវបានកំណត់ដោយតុលាការ។ វិធានការដើម្បីប្រមូល ប្រាក់នេះត្រូវធ្វើឡើងដូចក្នុងរឿងបង្ខំដល់រូបកាយដែរ"(មាត្រា ១៧៨)។

**ការរឹបអូស និងសិទ្ធិតតិយជន**.."ការរឹបអូសអាចធ្វើទៅលើវត្ថុដូចខាងក្រោមនេះ : ១.ឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទ.ល្មើស ២.វត្ថុ ឬ មូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ៣.ផលទុន ឬទ្រព្យសម្បត្តិ ដែលជាផលកើតចេញពី

បទល្មើស ៤-ឧបភោគភណ្ឌ សម្ភារៈ និងចលនវត្ថុនៅទីកន្លែងដែលបទល្មើសបានកើតឡើង។ ក៏ប៉ុន្តែ ការរឹបអូសមិនអាចត្រូវប្រកាសបានទេ ប្រសិនបើការរឹបអូសនោះប៉ះពាល់ដល់សិទ្ធិរបស់តតិយជន"(មាត្រា ១៧៩)[៣៨]។

**ការបិទផ្សាយសេចក្តីសម្រេច**-"ការបិទផ្សាយសេចក្តីសម្រេច ត្រូវអនុវត្តនៅទីកន្លែងដែលចង្អុលប្រាប់ដោយតុលាការ និងសម្រាប់រយៈពេលមួយដែលកំណត់ឡើងដោយតុលាការ។ ការបិទផ្សាយមិនអាចលើសពី ២ ខែ។ ការបិទផ្សាយអាចទាំង ស្រុងតាមសម្រង់ ឬតាមនិទ្ទេសធម្មតា។ សោហ៊ុយនៃការបិទផ្សាយជាបន្ទុករបស់នីតិបុគ្គល ដែលត្រូវផ្តន្ទាទោស។ ក្នុងករណីដែល ដកបំបាត់ចេញ លាក់បំបាំង ឬហែកចោលសេចក្តីប្រកាស បិទផ្សាយនោះត្រូវ ធ្វើការបិទផ្សាយជាថ្មីម្តងទៀត។ សោហ៊ុយនៃការបិទផ្សាយនេះត្រូវចេញដោយជនល្មើសដែលជាអ្នកដកបំបាត់ចោល លាក់បំបាំង ឬហែកចោល"(មាត្រា ១៨០)។

**ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍**-"ទោសផ្សាយសេចក្តីសម្រេចតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ត្រូវអនុវត្តតាមបែបបទដែលកំណត់ឡើងដោយតុលាការ។ ការផ្សាយនេះ មិនអាចលើសពី ៨ ថ្ងៃ។ ការផ្សាយនេះ អាចផ្សាយទាំងស្រុង តាមសម្រង់ ឬតាមនិទ្ទេស។ សោហ៊ុយនៃការផ្សាយជាបន្ទុករបស់នីតិបុគ្គលដែលត្រូវផ្តន្ទាទោស។ ទោសផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការត្រូវចុះផ្សាយក្នុងសារព័ត៌មានសរសេរ តាមបែបបទ និងក្នុងថិរវេលាដែលកំណត់ដោយតុលាការ។ សោហ៊ុយក្នុងការចុះផ្សាយ ជាបន្ទុករបស់នីតិបុគ្គល។ បើតុលាការបានបង្គាប់ ការផ្សព្វផ្សាយ សេចក្តីសម្រេច សារព័ត៌មានមិនអាចបដិសេធការ ចុះផ្សាយនេះបានទេ"(មាត្រា ១៨១)។

## កថាខណ្ឌទី ៣ ទោសអនុវត្តចំពោះអនីតិជន

ចំពោះអនីតិជន អ្នកនីតិប្បញ្ញត្តិបានគិតគូរជាពិសេស ហើយទោសអនុវត្តចំពោះអនីតិជនមានចែងចាប់ពីមាត្រា ១៦០ ដល់មាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌ។

អនីតិជនទទួលអត្ថប្រយោជននីត្យានុកូល ជាច្រើនដូចជា :

-**ទី ១** អនីតិជនដែល ប្រព្រឹត្តបទល្មើស "ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ" (មាត្រា ៣៩)។ ប៉ុន្តែ តុលាការអាចដាក់ទោសអនីតិជន អាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈ ឬបុគ្គលិកលក្ខណៈអនីតិជនតម្រូវ។

[៣៨] ក្រមនីតិវិធីព្រហ្មទណ្ឌ : ការចាប់យកវត្ថុតាងអនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ (មាត្រា ៩២) ដោយចៅក្រមស៊ើបសួរ (មាត្រា ១៦០) ការប្រគល់វត្ថុឱ្យទៅម្ចាស់ដើមវិញ (មាត្រា ១៦១ និងមាត្រា ២៤៨) ដីការបស់ចៅក្រមស៊ើបសួរបដិសេធប្រគល់វត្ថុចាប់យកឱ្យទៅម្ចាស់ដើមវិញ អាចប្តឹងឧទ្ធរណ៍បាន (មាត្រា ២៦៩)។

**-ទី ២** កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ ថ្ងៃ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក៏ប៉ុន្តែ ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមាន អានុភាពបន្ថយអតិបរមា នៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង ៥ ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជា បទឧក្រិដ្ឋដដែល។

**-ទី ៣ ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស.-** ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោសអនុវត្តលើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូច តទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមក នៅត្រឹម១ ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ ឆ្នាំ និងតិចជាង ១០ ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម៦ ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ ឆ្នាំ និងតិចជាង ៥ ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ ថ្ងៃ និងតិចជាង ២ ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម១ ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

**-ទី ៤ បទប្បញ្ញត្តិនៃការមិនរាងចាល**មិនអនុវត្តទៅលើអនីតិជនទេ ។

**-ទី ៥** នៅក្នុងករណីដែលតុលាការសម្រេចព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះ ប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤.ជួសជុលព្យសនកម្មដែលបណ្តាលមកអំពីបទល្មើស ទៅតាមធនធាន របស់ខ្លួន ។

៥.បង្ហាញភស្តុតាងបញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធាន របស់ខ្លួន បន្ទាប់ពីការផ្តន្ទាទោស ។

៦.មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧.មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨.មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជន-រងគ្រោះ នៃបទល្មើស ។

៩.មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ[៣៩] ។

**.ទី ៦ ទោសជំនួស.**.ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ ឆ្នាំ ប៉ុន្តែ ចិរវេលានៃការងារមិនអាចលើសពី ១០០ ម៉ោង។ ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**.ទី ៧ ទោសបន្ថែម.**.មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១.ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស។

២.ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។

៣.ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

៤.ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

៥.ការហាមឃាត់ចំពោះការកាន់កាប់ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

[៣៩] អ្វីដែលគួរឱ្យកត់សំគាល់នោះ គឺ មានតែយោធិន កងរាជអាវុធហត្ថ នគរបាល និងបុគ្គលដែលទទួលបានការអនុញ្ញាតពីក្រសួងមហាផ្ទៃប៉ុណ្ណោះ ទើបមានសិទ្ធិកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។ ចុះបុគ្គលទាំងនេះ អាចនៅជាអនីតិជន ហើយច្បាប់អនុញ្ញាតឱ្យកាន់កាប់ ឬយកតាមខ្លួន នូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវដែរ ឬទេ ?

# ផ្នែកទី ២ ទោសដែលកំណត់ដោយចៅក្រម

**អំណាចចៅក្រមក្នុងការប្រកាសទោស..**រដ្ឋធម្មនុញ្ញ បានផ្តល់អំណាចផ្តាច់មុខឱ្យចៅក្រម(អាសនៈ) ក្នុងការប្រកាសថាជនណាម្នាក់មានពិរុទ្ធ("ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ-មាត្រា ៣៨ កថាខណ្ឌទី ៧")។ បទប្បញ្ញត្តិនេះត្រូវបានបញ្ជាក់បន្ថែមដោយមាត្រា ៦ នៃក្រមព្រហ្មទណ្ឌ ថា "គ្មានទោសណាមួយដែលអាចត្រូវយកទៅអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការ"។ ក៏ប៉ុន្តែ អំណាចនេះត្រូវបានបទប្បញ្ញត្តិដទៃទៀតកំណត់ព្រំដែន និងកំណត់អំពីបែបបទនៃការអនុវត្តអំណាចនេះ។ ព្រំដែននៃអំណាចរបស់ចៅក្រមមានពីរយ៉ាង គឺទី ១ ចៅក្រមត្រូវគោរពគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងនៃទោស ពោលគឺ ចៅក្រមគ្រាន់តែជាអ្នកអនុវត្តច្បាប់ ហើយមានតែទោសដែលច្បាប់កំណត់ជាមុនតែប៉ុណ្ណោះ ទើបចៅក្រមអាចប្រកាសបាន (នីត្យានុកូលភាពនៃទោស)។ ព្រំដែននៃអំណាចរបស់ចៅក្រមទី ២ គឺចៅក្រមមានសេរីភាពក្នុងការប្រកាសទោស ដែលនៅចន្លោះអប្បរមា និងអតិបរមា មានន័យថា ចៅក្រមពុំអាចទៅមុខ ឬថយក្រោយហួសក្រឹតនេះទេ។ ក្រៅពីនេះ ប្រភេទ និងរបបនៃទោសជាឆន្ទានុសិទ្ធិរបស់ចៅក្រម ក្នុងលក្ខខណ្ឌដែលចៅក្រមយល់ឃើញថាប្រភេទនៃទោស និងរបបនៃទោសនោះស័ក្តិសមនឹងទណ្ឌិត(ទណ្ឌិតនឹងកែប្រែក្លាយជាពលរដ្ឋដ៏ល្អរបស់សង្គមក្រោយពេលអនុវត្តទោសនោះចប់សព្វគ្រប់)។ ក្រមព្រហ្មទណ្ឌបានកំណត់អំពីរបបនៃការប្រកាសទោសដ៏ទូលំទូលាយមួយដែលបង្ហាញសិទ្ធិអំណាចដ៏ធំធេងរបស់ចៅក្រមក្នុងការប្រកាសទោស។

**គោលការណ៍ឯកត្តកម្មនៃទោស និងអំណាចរបស់ចៅក្រមក្នុងការប្រកាសទោស..**"តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈនៃជនជាប់ចោទ សភាពផ្លូវចិត្ត ធនធាន និងបន្ទុក មូលហេតុព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ជាអាទិ៍ ចំពោះជនរងគ្រោះ"(មាត្រា ៩៦)។ ទាំងនេះ ជាគន្លឹះសម្រាប់ចៅក្រមពិចារណាកំណត់ទោសឱ្យត្រូវតាមជនល្មើសម្នាក់ៗ ពោលគឺបើជនល្មើសច្រើននាក់បានប្រព្រឹត្តបទល្មើស អាចមានទោសផ្សេងគ្នា ទៅស្ថានភាពផ្ទាល់ខ្លួនរបស់ជនល្មើសម្នាក់ៗ។ ការកំណត់ទោសឱ្យត្រូវស្ថានភាពបុគ្គលដែលជាជនល្មើសនេះ គេហៅថា "គោលការណ៍ឯកត្តកម្មនៃទោស"។

## អនុផ្នែកទី ១ របបនៃទោសដែលចៅក្រមប្រកាស

នៅក្នុងព្រំដែនដែលអនុញ្ញាតដោយច្បាប់ ចៅក្រមមានអំណាចប្រកាសទោស និងកំណត់អំពីរបបគតិយុត្តនៃទោសដែលប្រកាសនោះ ដោយយោងទៅតាមកាលៈទោសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទ។ ក្រមព្រហ្មទណ្ឌ បានផ្តល់អំណាចយ៉ាងទូលំទូលាយឱ្យចៅក្រមក្នុងការសម្រេចប្រកាសមូលៈទោស ទោសជំនួស ការព្យួរទោស ការព្យួរទោសសាកល្បង ការផ្អាកការប្រកាសទោស ផ្តល់ឱ្យជនល្មើស នូវការអនុវត្តទោសក្នុងទម្រង់ជារបបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ និងទោសបន្ថែមដែលក្នុងករណីមួយចំនួន ជាកាតព្វកិច្ច។

### កថាខណ្ឌទី ១ ការប្រកាសមូលទោស និងទោសបន្ថែម

**ការប្រកាសមូលទោស.**.-មានចែងក្នុងមាត្រា ៩៧ ដែលគួសបញ្ជាក់ពីពាក្យ "និង"។ នៅក្នុងគ្រប់ករណី ដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និង ពិន័យផង តុលាការអាចប្រកាស :

-ទោសដាក់ពន្ធនាគារ និងទោសពិន័យជាមួយគ្នា ឬ

-ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ ឬ

-ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ ។

កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយឬច្រើន ទោសបន្ថែមនេះ ត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ នៃក្រមនេះចេញ"(មាត្រា ៩៩)។ តុលាការអាចសម្រេច ជំនួសមូលទោសដោយទោសបន្ថែមមួយឬច្រើន នៅក្នុងករណីណាមួយដូចខាងក្រោម :

១-កាលណា ជនជាប់ចោទទទួល ទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់

២-កាលណាជនជាប់ចោទ ទទួលទោស ដាក់ពន្ធនាគារដែលអតិបរមា ស្មើ ឬតិចជាង ៣ ឆ្នាំ(មាត្រា ១០០)។

## កថាខណ្ឌទី ២ ទោសជំនួស : ទោសការងារសហគមន៍ និងការស្តីបន្ទោស

"ទោសការងារសហគមន៍ជំនួសឱ្យមូលទោស។ តុលាការដែលប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ។ ការស្តីបន្ទោសជំនួសឱ្យមូលទោស។ តុលាការដែលប្រកាសការស្តីបន្ទោស មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានទេ និងកាលណាតុលាការសម្រេច ជំនួសមូលទោសដោយទោសបន្ថែមមួយ ឬច្រើន តុលាការមិនអាចប្រកាស ទោសដាក់ពន្ធនាគារ ឬទោសពិន័យ ជាប្រាក់បានទេ"។

**ទោសការងារសហគមន៍.**.."កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលអតិបរមា តិចជាង ឬស្មើនឹង ៣ ឆ្នាំ តុលាការអាចប្រកាសទោសការងារសហគមន៍។ ការងារសហគមន៍ គឺជាកាតព្វកិច្ចត្រូវបំពេញក្នុង ចិរវេលាចន្លោះពី ៣០ ម៉ោង ទៅ ២០០ ម៉ោង នូវការងារគ្មានកម្រៃ ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬដល់អង្គការមិនមែនរដ្ឋាភិបាល ទៅតាមការកំណត់របស់ចៅក្រម។ ការងារសហគមន៍ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ ហើយនិងការងាររបស់ស្ត្រី ។

ការងារសហគមន៍អាចត្រួតគ្នាបានជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ ។

រដ្ឋត្រូវតែចេញសោហ៊ុយជួសជុលការខូចខាតដែលបង្កដល់អ្នកដទៃដោយទណ្ឌិតនៅក្នុងពេលដែលកំពុង អនុវត្តការងារសហគមន៍ ។ រដ្ឋត្រូវធ្វើឧបាទេសកម្មដោយពេញច្បាប់ ទៅក្នុងសិទ្ធិជនរងគ្រោះ។

**ទោសការងារសហគមន៍នឹងអាចប្រកាសបាន** លុះត្រាតែជនជាប់ចោទមាន វត្តមាននៅពេលសវនាការ ហើយយល់ព្រមធ្វើការងារនេះ[៤០]។ តុលាការនៅមុនពេល ប្រកាសសាលក្រម ឬសាលដីកា ត្រូវប្រាប់ជនជាប់ចោទ ថាសាមីខ្លួនមានសិទ្ធិប្រកែកមិនព្រមធ្វើការងារនេះ។ ចម្លើយរបស់ជនជាប់ចោទ ត្រូវតែមានចុះនៅក្នុងសាលក្រម ឬ សាលដីកា (មាត្រា ១០១) ។

**ទោសការងារសហគមន៍អនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៦ ឆ្នាំ.**.. ទោសនេះ មិនអាចលើសពី ១០០ ម៉ោងទេ ហើយទោសប្រភេទនេះ ត្រូវតែមានលក្ខណៈជាការបណ្តុះបណ្តាល និងការស្តារនីតិសម្បទាក្នុងការចូល មករួមរស់ក្នុងសង្គមវិញ(មាត្រា ១៦២)។

[៤០] សិទ្ធិមនុស្ស និងការងារដោយបង្ខំ។

**ការស្តីបន្ទោស**..“កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមា តិចជាង ឬស្មើនឹង ៣ ឆ្នាំ តុលាការអាចប្រកាសស្តីបន្ទោស ប្រសិនបើមានគ្រប់លក្ខខណ្ឌ ទាំងបីដូចតទៅនេះ :

-ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបានបញ្ចប់

-ការខូចខាតត្រូវបានជួសជុលរួចហើយ និង

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ”(មាត្រា ៧៦)។

## កថាខណ្ឌទី ៣ ការព្យួរទោស

ការព្យួរទោស ជាការបង្គាប់របស់តុលាការដែលមានអានុភាពផ្អាការអនុវត្តមូលទោស(មាត្រា ១០៤) និងឈានទៅរកការលុបទោសចោលទាំងស្រុង(មាត្រា ១១១ មាត្រា ១១៦ និង មាត្រា ១២៣) ក្នុងករណីគ្មានការដកហូតការព្យួរទោសទេ។ ការព្យួរទោសអាចប្រព្រឹត្ត ទៅក្រោមរូបភាពជា ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង(ភាពខុសគ្នាស្ថិតត្រង់អត្ថិភាពនៃលក្ខខណ្ឌ)។

### ក.-ការព្យួរទោសធម្មតា

**លក្ខខណ្ឌបឋមនៃការព្យួរទោស**..ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការព្យួរទោស ត្រូវគិតតែអំពីការផ្តន្ទាទោស ជាស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ (មាត្រា ១០៥)។

**លក្ខខណ្ឌគ្រឹះ**..គេសង្កេតឃើញថា លក្ខខណ្ឌនៃការព្យួរមានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើសចោទប្រកាន់ ថាតើជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ពោលគឺច្បាប់ដាក់លក្ខខណ្ឌលើ អត្ថិភាពនៃការផ្តន្ទាទោសពីមុន និងកំណត់អំពីទោសដែលអនុញ្ញាតឱ្យចៅក្រមអាចព្យួរបាន។

-*រយៈពេលនៃការផ្តន្ទាទោសស្ថាពរពីមុន ឬអតីតភាព* : ១.ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម បើ ៥ឆ្នាំ មុនមានការផ្តន្ទាទោសជាស្ថាពរ និង ២.ក្នុងករណីចោទប្រកាន់ពីបទលហុ បើ ១ឆ្នាំ មុនមានការផ្តន្ទាទោសជាស្ថាពរ នោះចៅក្រមពុំអាចសម្រេចព្យួរទោសបានទេ។ រយៈពេលនេះ ចាប់គិតពីថ្ងៃ ដែលសេចក្តីសម្រេចផ្តន្ទាទោសពីមុនចូលជាស្ថាពរ។ ម្យ៉ាងទៀត ប្រសិនបើមានការផ្តន្ទាទោសស្ថាពរ តែរយៈពេល ៥ឆ្នាំ ឬ ១ឆ្នាំ បានកន្លងហួស ទើបមានការប្រព្រឹត្តបទល្មើសចោទប្រកាន់ ជនល្មើសនៅតែអាចទទួលបានអត្ថប្រយោជន៍នេះដែរ។

-*ទោសដែលអាចព្យួរបាន* គឺទោសដាក់ពន្ធនាគារប្រកាស តិចជាង ឬស្មើនឹង ៥ ឆ្នាំ និងទោសពិន័យជាប្រាក់(បទឧក្រិដ្ឋ និងបទមជ្ឈិម) ហើយទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់(បទលហុ)។ ចំពោះបទឧក្រិដ្ឋ និងបទមជ្ឈិម តុលាការអាចប្រកាសព្យួរតែមួយផ្នែកនៃមូលទោស ដោយបញ្ជាក់ពីថិរវេលា និងចំនួនទឹកប្រាក់ពិន័យ ដែលព្យួរ(អាចព្យួរមួយផ្នែក ឬទាំងស្រុង)។

-*ការដកហូតការព្យួរទោស:* កាលណាមានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀត ក្នុងរយៈពេល ៥ ឆ្នាំ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម និងក្នុងរយៈពេល ១ ឆ្នាំ ពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ បន្ទាប់ពីមានការផ្តន្ទាទោសពីមុនទៅតាមករណីនីមួយៗ ការព្យួរទោសធម្មតានេះត្រូវដកហូតដោយពេញច្បាប់ ហើយទោសទី ១ ត្រូវអនុវត្តដោយមិន អាចស្រូបចូលជាមួយទោស ទី ២ ឡើយ។ គម្លាតរយៈពេល ៥ ឆ្នាំ ចំពោះការផ្តន្ទាទោសលើកទី ១ ពី បទឧក្រិដ្ឋ ឬ បទមជ្ឈិម ហើយ ១ឆ្នាំ ចំពោះបទលហុ ត្រូវគិតតាំងពីថ្ងៃសេចក្តីសម្រេចផ្តន្ទាទោសពីមុនបានចូលជាស្ថាពរ។ តែតុលាការអាចប្រកាសពីភាពមិនអាចដកហូត បានចំពោះការព្យួរទោសពីមុន ដោយបញ្ជាក់ហេតុផលជាពិសេស។

-*ការទុកជាអសារបង់ការផ្តន្ទាទោស.*-ក្នុងករណីដែលគ្មានការផ្តន្ទាទោសថ្មីជាស្ថាពរទេ ក្នុងរយៈពេល ៥ ឆ្នាំ ពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬ ១ ឆ្នាំ ពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរ លើកទី ១ ទេ នោះត្រូវទុកជាអាសារបង់ការផ្តន្ទាទោសដែលចៅក្រមប្រកាសព្យួរចំពោះបទលហុ ហើយចំពោះការផ្តន្ទាទោសពី បទបឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវទុកជាអាសារបង់ការផ្តន្ទាទោសទាំងស្រុង ទោះបីជាមានការព្យួរមួយផ្នែកក៏ដោយ។ មានន័យថាទោស មិនអាចយកមកអនុវត្តបានទៀតឡើយ។

## ខ.-ការព្យួរទោសសាកល្បង

"ការព្យួរទោសសាកល្បងមានអានុភាពដាក់ឱ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង(មាត្រា ១១៧ កថាខណ្ឌទី ២)។ រយៈពេលសាកល្បងដែលចៅក្រមកំណត់មិនអាចតិចជាង ១ ឆ្នាំ និងមិនអាចលើសពី ៣ ឆ្នាំ ទេ(មាត្រា ១១៨)។ ក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវស្ថិតក្រោមការត្រួតពិនិត្យតាមដាន និងអនុវត្តកាតព្វកិច្ចដែលកំណត់ក្នុងសេចក្តីសម្រេចតុលាការ។

**លក្ខខណ្ឌ**.-"តុលាការអាចសម្រេចព្យួរសាកល្បងនូវទោសដែលបានសម្រេចដាក់ពន្ធនាគារ ដែលមានរយៈ ពេលពី ៦ ខែ ទៅ ៥ ឆ្នាំ"(ម.១១៧ កថាខណ្ឌទី ១)។

**វិធានការត្រួតពិនិត្យ**.-គោលដៅនៃវិធានការនេះ គឺដើម្បីស្តារនីតិសម្បទាជនល្មើសឡើងវិញ ជា-ពិសេស វិធានការនេះជំរុញឱ្យទណ្ឌិតមានស្មារតីប្រុងប្រយ័ត្នមិនត្រូវប្រព្រឹត្តបទល្មើសថ្មីទៀត មិនត្រឹមតែក្នុងអំឡុងពេលនៃការសាកល្បងទេ តែនាពេលអនាគតវែងឆ្ងាយ។

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិត មានដូចតទៅ :

*១*-ទណ្ឌិតត្រូវតែគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ

*២*-ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើល របស់បុគ្គលដែលព្រះរាជអាជ្ញា បានប្រគល់អំណាចឱ្យ

*៣*-ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែល ព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ

*៤*-ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន

*៥*-ទណ្ឌិតត្រូវជូនដំណឹងដល់ ព្រះរាជអាជ្ញា អំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន

៦-ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា មុនពេលធ្វើដំណើរទៅបរទេស(មាត្រា ១១៩) ។

កាតព្វកិច្ចដោយឡែកដែលអាចតម្រូវទៅលើទណ្ឌិតមានដូចតទៅ :

*១*-បំពេញសកម្មភាពខាងវិជ្ជាជីវៈ

*២*-ទទួលការបង្ហាត់បង្រៀន ឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ

*៣*-រស់នៅក្នុងកន្លែងណាមួយជាកំណត់

*៤*-ទទួលឱ្យពេទ្យធ្វើ ការពិនិត្យ ឬការព្យាបាល

*៥*-បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ

*៦*-ធ្វើការជួសជុលការខូចខាត ដែលបណ្តាលមកពីបទល្មើស តាមលទ្ធភាពនៃ ធនធានរបស់ខ្លួន

*៧*-បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋ បន្ទាប់ពី ការផ្តន្ទាទោសតាមលទ្ធភាពធនធានរបស់ខ្លួន

*៨*-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ ឬសង្គមដែលអនុញ្ញាត ឬសម្រួល ដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់

*៩*-មិនត្រូវមានមុខនៅ ទីកន្លែងខ្លះ។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីទីកន្លែង ដែលហាមឃាត់

*១០*-មិនត្រូវសេពគប់បនល្បែង

*១១*-មិនត្រូវសេពគប់គ្រឿងភេសជ្ជៈស្រវឹង

*១២*-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេស ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីបុគ្គលដែលមិនត្រូវ សេពគប់ជាមួយ

*១៣*-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការត្រូវថែងអំពីកាតព្វកិច្ចដោយឡែក ដែលតម្រូវទៅលើទណ្ឌិត (មាត្រា ១២០)។ ក្នុងករណីចាំបាច់ និងយោងតាមបណ្តឹងរបស់ព្រះរាជអាជ្ញា តុលាការអាចកែប្រែកាតព្វកិច្ចដោយឡែក ដែលតម្រូវលើទណ្ឌិតបាន។

ការដកហូតការព្យួរទោស អាចប្រព្រឹត្តក្នុងករណី ករណីមានការបំពានកាតព្វកិច្ចដោយឡែក ឬ វិធានការត្រួតពិនិត្យ ឬការប្រព្រឹត្តបទល្មើសថ្មី ក្នុងកំឡុងពេលសាកល្បង។ ក្នុងករណីនេះ តុលាការ សម្រេចពីទំហំនៃការដក ហូតទោសសាកល្បង (មួយផ្នែក ឬទាំងស្រុង) ហើយលើកយកទោសមកអនុវត្ត។ ប្រសិនបើ ក្នុងរយៈពេល សាកល្បងពុំមានសេចក្ដីសម្រេចដកហូតទេ នោះទណ្ឌិតរួចផុតពីការអនុវត្តទោស ដែលបានប្រកាសប្រឆាំងនឹងខ្លួន។

**អនីតិជន.**-ក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកមួយចំនួនប៉ុណ្ណោះ ដែលអាចអនុវត្តចំពោះអនីតិជន(មាត្រា ១៦៥) គឺ :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល។

៤-ជួសជុលព្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្ដុតាងបញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធាន របស់ខ្លួន បន្ទាប់ពីការផ្ដន្ទាទោស។

៦-មិនត្រូវបង្ហាញមុខនៅកន្លែងខ្លះ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬ ជនរងគ្រោះនៃបទល្មើស។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**គោរពការសិក្សា ជាការគោរពគេរម៉ឺនឆ្នាំ។**

## កថាខណ្ឌទី ៤ ការផ្អាកការប្រកាសទោស

តុលាការក្នុងលក្ខខណ្ឌមួយចំនួនអាចសម្រេចផ្អាការប្រកាសទោស។ លក្ខខណ្ឌទាំងនោះមានចែងក្នុងមាត្រា ១២៤ នៃក្រមព្រហ្មទណ្ឌ "ក្នុងករណីចោទប្រកាន់ពីបទមជ្ឈិម តុលាការក្រោយពីបានប្រកាសថាជនជាប់ចោទមានពិរុទ្ធ អាចផ្អាកការប្រកាសទោស ប្រសិនបើលក្ខខណ្ឌដូចតទៅនេះ ត្រូវបានបំពេញ :

-ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ឈប់[៤១]

-ជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់នៅក្នុងសង្គមវិញ និង

-ជនជាប់ចោទសុំរយៈពេលដើម្បីជួសជុលការខូចខាត"។

ការផ្អាកការប្រកាសទោសអាចត្រូវបង្គាប់បាន លុះត្រាតែជនជាប់ចោទមានវត្តមានក្នុងសវនាការ។ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការសម្រេចទោស និងគំលាតរវាងការផ្អាក និងការសម្រេចអំពីទោសមិនអាចលើសពី ១ ឆ្នាំ ទេ។ ការសម្រេចអំពីទោសប្រព្រឹត្តទៅនាពេលសវនាការពិនិត្យរឿងដែលបង្អង់។ តុលាការអាចសម្រេចមិនប្រកាសទោសនោះបាន បើការផ្តន្ទាទោសលែងមានប្រយោជន៍ទៀតហើយ (ជនល្មើសកែខ្លួន ជាឱ ជាអាទិ៍....)។

## កថាខណ្ឌទី ៥ របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ

ក្នុងលក្ខខណ្ឌដែលច្បាប់បានអនុញ្ញាតនិងលក្ខខណ្ឌនីត្យាកូលត្រូវបានបំពេញ ចៅក្រមអាចអនុញ្ញាតឱ្យពិរុទ្ធជនទទួលបាននូវរបបពិសេសមួយនៃការអនុវត្តទោស គឺរបបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគ។

[៤១] បទល្មើសដែលប្រព្រឹត្តជាប្រភេទបទមជ្ឈិមស្រាល ហើយក្រោយពេលប្រព្រឹត្តគឺភាពច្របូកច្របល់ ដែលបង្កឡើងដោយបទល្មើសត្រូវបានបញ្ចប់ភ្លាមៗ។

**១-របបពាក់កណ្ដាលសេរីភាព**

របបនេះ អនុវត្តកាលណាលក្ខខណ្ឌមួយចំនួនត្រូវបានបំពេញ ហើយអាចដកហូតវិញក្នុងករណីមួយចំនួន។

ក.-លក្ខខណ្ឌ

យោងតាមមាត្រា ១២៧ នៃក្រមព្រហ្មទណ្ឌ "កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារ តិចជាង ឬ ស្មើនឹង ៦ ខែ តុលាការអាចសម្រេចថា ទោសត្រូវអនុវត្តក្រោមរបបពាក់កណ្ដាលសេរីភាព" មូលហេតុដែលនាំឱ្យទណ្ឌិតទទួលបានអត្ថប្រយោជន៍នេះ គឺ "ដើម្បីអនុញ្ញាតឱ្យទណ្ឌិតអាចបំពេញសកម្មភាពវិជ្ជាជីវៈ ទទួលការសិក្សា ឬការបណ្ដុះបណ្ដាល ឬការពិនិត្យព្យាបាលជំងឺ ឬជួយឧបត្ថម្ភដល់សេចក្ដីត្រូវការរបស់គ្រួសារ"។ ទណ្ឌិតត្រូវធ្វើការ គូសបញ្ជាក់ពីមូលហេតុដូចខាងលើនេះ ដើម្បីស្នើសុំឱ្យចៅក្រមផ្ដល់មកឱ្យខ្លួននូវរបបអនុវត្តទោសនេះ។

ទណ្ឌិតដែលស្ថិតនៅក្រោមរបបពាក់កណ្ដាលសេរីភាព ត្រូវបានអនុញ្ញាតឱ្យចាកចេញពីពន្ធនាគារក្នុងរយៈពេលជាកំណត់។ តុលាការកំណត់នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីថ្ងៃ និងម៉ោងដែលទណ្ឌិតត្រូវបាន អនុញ្ញាតឱ្យអវត្តមាននៅក្នុងពន្ធនាគារ(មាត្រា ១២៨)។ រយៈពេលនៃពាក់កណ្ដាលសេរីភាព(រយៈពេលអនុញ្ញាតឱ្យទណ្ឌិតចាក ចេញពីពន្ធនាគារ)ត្រូវគិតបញ្ចូលទៅក្នុងថិរវេលា នៃទោសដែលកំពុងអនុវត្ត(មាត្រា ១២៩)។

ខ-ការដកហូតរបបពាក់កណ្ដាលសេរីភាព

ទណ្ឌិតដែលអនុញ្ញាត់ឱ្យចាកចេញពីពន្ធនាគារ មានកាតព្វកិច្ចត្រូវចូលមកពន្ធនាគារវិញ ទៅតាមពេលវេលាកំណត់ បើពុំនោះទេ "ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់មកពន្ធនាគារវិញនៅពេលផុតកំណត់រយៈពេលនៃពាក់កណ្ដាលសេរីភាព"។ ម្យ៉ាងទៀត នៅគ្រប់ពេលតុលា-ការ អាចរៀបចំរយៈពេល នៃពាក់កណ្ដាលសេរីភាព ឬក៏លុបចោលនូវរបបពាក់កណ្ដាលសេរីភាពតាមបណ្ដឹងរបស់ព្រះរាជអាជ្ញា។ តុលាការ ត្រូវបានទទួលដំណឹងនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ការមិនគោរពរបបនេះ បណ្ដាលឱ្យ មានការដកហូតរបបពាក់កណ្ដាលសេរីភាព។

**២-ការបែងចែកទោសជាប្រភាគ**

ទណ្ឌិតក្នុងពន្ធធនាគារនៅក្នុងរយៈពេលខ្លះ ហើយពេលខ្លះនៅក្រៅ ដោយផលប្រយោជន៍នៃទណ្ឌិតគ្រួសារ ឬសង្គម។ តុលាការអាចផ្ដល់ឱ្យទណ្ឌិតក្នុងករណីដែលច្បាប់អនុញ្ញាត ហើយអាចដកហូតវិញ បើល្មើសនឹងការកំណត់។

ក.-លក្ខខណ្ឌនៃការបែងចែកទោសជាប្រភាគ

កាលណាតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើនឹង ១ ឆ្នាំ តុលាការអាចសម្រេចថា ទោសនោះត្រូវអនុវត្តជាប្រភាគ ដោយមូលហេតុ ធ្ងន់ធ្ងរដែលមានលក្ខណៈជាគ្រួសារ ជាវេជ្ជសាស្ត្រ ជាវិជ្ជាជីវៈ ឬជាសង្គម។ តាមន័យនេះ មានតែបទលហុ និងបទមជ្ឈិមតែប៉ុណ្ណោះដែលទណ្ឌិតអាចទទួលបានអត្ថប្រយោជន៍នេះ។

ខ.-បែបបទនៃការបែងចែកទោសជាប្រភាគ

ប្រភាគនៃទោសនីមួយៗ មិនត្រូវតិចជាង ១ ខែ ទេ។ ថិរវេលាសរុបនៃការអនុវត្តទោសមិនអាចលើសពី ២ ឆ្នាំ ទេ ដោយរាប់បញ្ចូលទាំងការផ្អាកការ អនុវត្តទោស ។

តុលាការកំណត់ក្នុងសេចក្ដីសម្រេចរបស់ខ្លួនអំពីបែបបទនៃការបែងចែកទោស ជាប្រភាគ ។

គ.-អំណាចកែប្រែ និងដកហូតសេចក្ដីសម្រេចនេះ

ការកែប្រែរបបនៃការបែងចែកទោសជាប្រភាគនៅគ្រប់ពេលវេលា តុលាការអាចរៀបចំបែបបទនៃការបែងចែកទោសជាប្រភាគ ឬលុបចោលរបបនៃការបែងចែកទោសជាប្រភាគ តាមបណ្ដឹងរបស់ព្រះរាជ-អាជ្ញា ។

តុលាការត្រូវបានទទួលបណ្ដឹងនៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រម នីតិវិធីព្រហ្មទណ្ឌ ។

**ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិត**.-"ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យចាប់ និងឃុំខ្លួនទណ្ឌិតដែលមិនវិលត្រឡប់ មកពន្ធនាគារវិញ នៅពេលផុតកំណត់រយៈពេលនៃការផ្អាកការអនុវត្តទោស"( មាត្រា ១៣៥)។

**គោរពការសិក្សា ឱ្យតំលៃជីវិតខ**

## អនុផ្នែកទី ២ ការប្រកាសទោស

ក្រៅពីលក្ខខណ្ឌដែលបានកំណត់ខាងលើ ចៅក្រមដែលប្រកាសទោស ក៏ត្រូវគិតគូរផងដែរថាតើមានបទល្មើសតែមួយ ឬ ច្រើនត្រូវបានប្រព្រឹត្ត។

### កថាខណ្ឌទី ១ ទោសដែលប្រកាសក្នុងករណីមានការប្រព្រឹត្តបទល្មើសតែមួយ

យោងតាមស្ថានភាពនៃការប្រព្រឹត្តបទល្មើស ច្បាប់ផ្តល់ស្ថានសម្រាលទោស( បន្ថែមទម្ងន់អតិបរមានៃទោសដាក់ពន្ធនាគារ) ហើយក៏គិតគូរពីស្ថានទម្ងន់ទោស(បន្ថយអប្បរមានៃទោសដាក់ពន្ធនាគារ)។

**ក. ស្ថានសម្រាលទោស**

ក្រមព្រហ្មទណ្ឌ គ្រាន់តែកំណត់ពីអំណាចរបស់ចៅក្រមក្នុងការផ្តល់ស្ថានសម្រាលទោស និងលក្ខខណ្ឌទទួលបានប្រយោជន៍នីត្យនុកូលនេះ តែមិនបានកំណត់អំពីករណីណាខ្លះដែលជនល្មើសអាចទទួលបានស្ថានសម្រាលទេ។ នីតិនិពន្ធបានទុកឱ្យចៅក្រមជាអ្នកសម្រេច ដោយគ្រាន់តែផ្តល់ក្របខណ្ឌគតិយុត្តមួយដ៏ទូលំទូលាយគឺ "កាលណាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ តុលាការអាចសម្រេចឱ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោស។ ស្ថានសម្រាលទោសអាចត្រូវផ្តល់ឱ្យជនជាប់ចោទ បានដែរ ទោះបីជាជននោះ ត្រូវបានប្រកាសថាស្ថិតនៅក្នុងភាពមិនរាងចាលក៏ដោយ(មាត្រា ៩៣) ។ ចំពោះការលើកលែងទោស (ខាងលើ)។

**កាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈនៃជនជាប់ចោទតម្រូវ.** យុត្តិសាស្ត្របារាំងបានឱ្យដឹងថាចៅក្រមបានទទួលស្គាល់ស្ថានសម្រាលទោសក្នុងករណី ជាទូទៅគឺការប្រព្រឹត្តអំពើយុត្តិការដែលមិនបំពេញបានគ្រប់លក្ខខណ្ឌនីត្យានុកូល ហើយក៏អាចកើតមានដោយសារ : អាយុនៃជនល្មើស ស្ថានភាពផ្ទាល់ខ្លួន ស្ថានភាពវិជ្ជាជីវៈ ភាពស្រវឹង ឬស្ថានភាពសុខភាពរបស់ជនល្មើស ការស្តាយក្រោយរបស់ជនល្មើស អសីលធម៌របស់ជនរងគ្រោះ។ ចៅក្រមលើកយកមកពិចារណាទាំងកត្តាខាងក្រៅ កត្តាខាងក្នុងនៃជនល្មើស ស្ថានភាពក្រោយពេល មុនពេល ឬក្នុងពេលប្រព្រឹត្តបទល្មើស។ លទ្ធិបារាំងតិះតៀនថា ចៅក្រមមាន

សេរីភាពពេញលេញក្នុងការផ្តល់ស្ថានសម្រាលទោស ដែលស្ថិតនៅជាអំណាចរបស់ខ្លួន ហើយគេតែងបារម្ភថាចៅក្រមអាចប្រើអំណាចនេះដោយបំពាន។ លើសពីនេះ គេសង្កេតឃើញមានប្រយោជន៍ពីរយ៉ាង គឺ ទី១.អនុញ្ញាតឱ្យចៅក្រមដាក់ទោសទៅតាមស្ថានភាពជាក់ ដើម្បីចៀសវាងការអនុវត្តច្បាប់ដោយអយុត្តិធម៌ និងមិនតឹងរ៉ឹង និង ទី ២.ស្ថានសម្រាលទោសនេះ ជាមធ្យោបាយមួយអនុញ្ញាតឱ្យ ចៅក្រមធ្វើឯកត្តកម្មនៃទោសដែលបញ្ញត្តិនីត្យានុកូលពុំអាចចែងបានសព្វគ្រប់ទេ។

**អានុភាពនៃស្ថានសម្រាលទោស.**.កាលណាតុលាការផ្តល់ឱ្យជនជាប់ចោទ នូវស្ថានសម្រាលទោស អប្បបរមា នៃមូលទោសចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដូចខាងក្រោម (មាត្រា ៩៤):

*១.*ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ ឆ្នាំ អប្បបរមានៃទោសនេះត្រូវបន្ថយ មកត្រឹម ២ឆ្នាំ

*២.*ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៥ ឆ្នាំ ហើយតិចជាង ១០ ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ ឆ្នាំ

*៣.*ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ ឆ្នាំ ហើយ តិចជាង ៥ ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ៦ ខែ

*៤.*ប្រសិនបើអប្បបរមានៃទោសដាក់ ពន្ធនាគារស្មើ ឬលើសពី ៦ ថ្ងៃ ហើយតិចជាង ២ ឆ្នាំ អប្បបរមានៃទោសនេះ ត្រូវបន្ថយមកត្រឹម ១ ថ្ងៃ

*៥.*អប្បបរមានៃ ទោសពិន័យ ត្រូវបន្ថយមកត្រឹមពាក់កណ្តាល។

**ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស.**.កាលណាបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចៅក្រមដែលផ្តល់ស្ថានសម្រាលទោស អាចប្រកាសទោសដាក់ពន្ធនាគារ ក្នុងចន្លោះ រវាង ១៥ ឆ្នាំ និង ៣០ ឆ្នាំ(មាត្រា ៩៥) ។

## ខ..ស្ថានទម្ងន់ទោស

ក្រមព្រហ្មទណ្ឌបានកំណត់ជាបញ្ជីយ៉ាងច្បាស់លាស់អំពីស្ថានទម្ងន់ទោសដែលរួមមាន:

**ក្រុមមានការចាត់តាំង** គឺជាការប្រមូលផ្តុំដែលបានបង្កើតឡើង ឬជាសន្និដ្ឋិភាពដែលបានធ្វើឡើងដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន (មាត្រា ៧៧) ។

**ការគិតទុកជាមុន** គឺជាគម្រោងដែលបង្កើតឡើងមុនសកម្មភាព ប្រព្រឹត្ត បទល្មើស(មាត្រា ៧៨)។

**ការពួនស្ទាក់**គឺជាអំពើឃ្លាំចាំជនរងគ្រោះនៅទីកន្លែងណាមួយ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តបទល្មើស(មាត្រា ៨២)។

**ការកាប់គាស់ទម្លុះទម្លាយ**គឺជាអំពើបង្ខំធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញគ្រឿង បិទទ្វារ ឬរបង ទោះបីមានប្រភេទយ៉ាងណាក៏ដោយ។ ត្រូវចាត់ទុកដូចជាការកាប់គាស់ទម្លុះទម្លាយ : ១.ការប្រើប្រាស់កូនសោក្លែង ២.ការប្រើប្រាស់កូនសោដែលបានមកដោយឧបាយកលទុច្ចរិត ៣.ការប្រើប្រាស់គ្រប់ឧបករណ៍ ដើម្បីធ្វើឱ្យគ្រឿងបិទដំណើរការដោយគ្មាន ការបង្ខំ ខូចខាត ឬបំផ្លិចបំផ្លាញទេ(មាត្រា ៧៩) ។

**ការផ្លោះរបងចូល.**-ការផ្លោះរបងចូល គឺជាអំពើចូលទៅក្នុងទីកន្លែងណាមួយដោយឆ្លងរបង ឬដោយចូលតាមទ្វារ ឬបង្អួច ដែលមិនមែនសម្រាប់ធ្វើជាផ្លូវចូលទេ(មាត្រា ៨០)។

**អាវុធនិងវត្ថុដែលត្រូវបានចាត់ទុកដូចអាវុធ.**-អាវុធ គឺជាវត្ថុទាំងអស់ដែលធ្វើឡើងដើម្បីសម្លាប់ ឬធ្វើឱ្យមានរបួស។ ត្រូវបានចាត់ទុកដូចជាអាវុធ វត្ថុដទៃទៀត ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្សនៅក្នុងករណី ដូចតទៅ : ១.វត្ថុត្រូវបានប្រើប្រាស់សម្រាប់សម្លាប់ ធ្វើឱ្យរបួស ឬគំរាមកំហែង ២.វត្ថុមានទីដៅសម្រាប់សម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង។ ការប្រើប្រាស់សត្វដើម្បីសម្លាប់ ធ្វើឱ្យមានរបួស ឬគំរាមកំហែង ត្រូវចាត់ទុក ដូចបានប្រើប្រាស់អាវុធដែរ(មាត្រា ៨១)។

គេសង្កេតឃើញថាបទប្បញ្ញត្តិខាងលើនេះ មិនបានបញ្ញត្តអំពីទោសដែលត្រូវអនុវត្តនោះទេ មានតែការមិនរាងចាលដែលជាស្ថានទម្ងន់ទោសមានភ្ជាប់ទណ្ឌកម្ម។

## កថាខណ្ឌទី ២ ទោសដែលតុលាការប្រកាសក្នុងករណីមានការប្រព្រឹត្តបទល្មើសច្រើន

បទល្មើសសំដៅលើ បទល្មើសដែលអាចប្រព្រឹត្តដោយបុគ្គលតែម្នាក់ ឬច្រើននាក់។

### ក.-បទល្មើសត្រួតគ្នា

មាត្រា ១៣៦ នៃក្រមព្រហ្មទណ្ឌ បានកំណត់ថា "មានបទល្មើសត្រួតគ្នាកើតឡើង កាលបើបទល្មើសមួយត្រូវបានប្រព្រឹត្តដោយបុគ្គលម្នាក់ មុនពេលដែលបុគ្គលនេះត្រូវបាន*ផ្តន្ទាទោសជាស្ថាពរ*ចំពោះបទល្មើសមួយផ្សេងទៀត"។ កាលណាមានបទល្មើសត្រួតគ្នា វិធានការពីរយ៉ាងត្រូវបានបញ្ញត្ត ១.ការចោទប្រកាន់ និង ២.ការគិតគូរថាគួរបូកទោស ត្រួតទោស ឬស្រូបទោស។ សូមប្រៀបធៀបជាមួយការមិនរាងចាល(មាត្រា ៨៣ ដល់មាត្រា ៩២ ជាពិសេសមាត្រា ៨៤)។

១-ការចោទប្រកាន់

ការចោទប្រកាន់អាចប្រព្រឹត្តទៅតាមរូបភាពពីរយ៉ាងគឺ ព្រះរាជអាជ្ញាអាចសម្រេចធ្វើការចោទប្រកាន់តែមួយរួមគ្នា ឬដាច់ដោយឡែកពីគ្នា។

-**ការចោទប្រកាន់តែមួយ**.-កាលបើនៅក្នុងពេលចោទប្រកាន់តែមួយ ជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសនីមួយៗអាចត្រូវប្រកាសឡើង។ ប៉ុន្តែ កាលបើទោសត្រូវទទួលមានច្រើន ហើយមានប្រភេទដូចគ្នា *តុលាការត្រូវប្រកាសទោសតែមួយនៃប្រភេទនេះ នៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ*[៤២]។ ទោសនីមួយៗ ដែលប្រកាសត្រូវចាត់ទុកថា**ជាទោសរួម**ចំពោះបទល្មើសដែលត្រួតគ្នានៅក្នុង ព្រំដែននៃអតិបរមាស្របច្បាប់អនុវត្តទៅលើបទល្មើសនីមួយៗ(មាត្រា ១៣៧)។

-**ការចោទប្រកាន់ដាច់ពីគ្នា**.-នៅក្នុងពេលចោទប្រកាន់ដាច់ពីគ្នា កាលបើជនជាប់ចោទ ត្រូវបានរកឃើញថាមានពិរុទ្ធពីបទល្មើសច្រើន ទោសដែលត្រូវប្រកាស*ត្រូវអនុវត្តត្រួតគ្នានៅក្នុងព្រំដែននៃអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ*។ ប៉ុន្តែ តុលាការចុងក្រោយដែលត្រូវសម្រេចអាចប្រកាសឱ្យអនុវត្ត ទោសស្រូបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា។ ការស្រូបទោសនេះ អាចអនុវត្តតាមមាត្រា ៥០១ ក្រមនីតិវិធីព្រហ្មទណ្ឌ[៤៣]។

ដើម្បីអនុវត្តមាត្រានេះ នៅក្នុងករណីទោសដែលច្បាប់កំណត់ ជាទោសដាក់ពន្ធនាគារមួយជីវិតអតិបរមាស្របច្បាប់ដែលខ្ពស់ជាងគេ ត្រូវបានកំណត់ដាក់ពន្ធនាគារត្រឹម ៣០ ឆ្នាំ ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតទេ។ ការព្យួរទោសទាំងមូល ឬមួយផ្នែកនៃទោសដែលប្រកាសចំពោះបទល្មើស ដែលត្រួតគ្នានេះ មិនអាចជាឧបសគ្គដល់ការអនុវត្តទោស នៃប្រភេទដូចគ្នាដែលគ្មានការព្យួរទោសទេ (មាត្រា១៣៨)។

២-វិធានការកំណត់ទោសដែលត្រូវយកទៅអនុវត្ត : បូកទោស ឬស្រូបទោស

នៅពេលមានបទល្មើសត្រួតគ្នា[៤៤] វិធាននៃការកំណត់ទោសមានចំនួនបី **ទី១.**វិធានបូកទោស (cumul matériel des peines) គឺបូកទោសដែលផ្តន្ទាចំពោះបទល្មើសនីមួយៗចូលគ្នា ដែលប្រព័ន្ធនេះមិនសូវមានការអនុវត្តទេ ព្រោះវាមិនអាចអនុញ្ញាតឱ្យអនុវត្តទោសដាក់ពន្ធនាគារអស់មួយជីវិតជាន់គ្នាទេ **ទី២.**វិធានត្រួតទោស (cumul juridique des peines) ជាវិធានមួយដែលអនុញ្ញាតឱ្យផ្តន្ទាទោសដែលធ្ងន់ជាងគេ ក្នុងចំណោមបទល្មើសដែលបានប្រព្រឹត្ត ហើយតំលើងទោសឱ្យធ្ងន់ទៅតាមចំនួនបទល្មើស និងស្ថានទម្ងន់ទោសនៃ

[៤២] ក្នុងន័យនេះ ចៅក្រមមានជម្រើសពីរយ៉ាង គឺ **ស្រូបទោស** និង**បូកទោស**ក្នុងព្រំដែននៃអតិបរមានៃទោសនៃបទល្មើសធ្ងន់ជាងគេ។

[៤៣] ពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ត្រូវលើកនៅមុខតុលាការដែលបានសម្រេចចុងក្រោយគេ។ តុលាការនេះទទួលបណ្តឹងតាមពាក្យប្តឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ។ តុលាការសម្រេចក្នុងពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ ។

[44] Le concours réel des infractions et le principe de non-cumul des peines.

**បទល្មើសផ្សេងទៀត និង ទី៣**-វិធានស្រូបទោស ជាវិធាននៃការមិនបូកទោសបញ្ចូលគ្នា ហើយយកតែទោសណាមួយដែលធ្ងន់ជាងគេមកអនុវត្ត។

គេសង្កេតឃើញថាប្រភេទទាំងបីនេះត្រូវបានក្រមព្រហ្មទណ្ឌអនុម័តយក ១-បូកទោសអនុវត្តក្នុងករណីមួយចំនួន ដូចជារួមមានការមិនរាងចាល បទល្មើសលួចរត់ចេញពីពន្ធនាគារ[៤៥] (មាត្រា ១៤១ ក្នុងករណីផ្តន្ទាទោសពីបទរត់ចេញពីពន្ធនាគារ ទោសដែលប្រកាសពីបទនេះត្រូវបូកជាមួយនឹងទោសដែលប្រកាសឡើងចំពោះបទល្មើសដែលនាំឱ្យ មានការឃុំខ្លួនជននោះ ដោយមិនអាចមានការស្រូបចូលគ្នា។) និងទោសពិន័យជាប្រាក់(មាត្រា ១៤០ : ជាបដិប្បញ្ញត្តិទៅនឹងបទប្បញ្ញត្តិមុន ការពិន័យដែលបានប្រកាសឡើង ចំពោះបទលហុច្រើននោះត្រូវបូកបញ្ចូលគ្នា ហើយត្រូវបូកផងដែរ ជាមួយទោសពិន័យ ដែលប្រកាសឡើង ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម) ២-ត្រួតទោស មានចែងក្នុងមាត្រា ១៣៧ និង ៣-ស្រូបទោសក្នុងករណីមានពិរុទ្ធពីបទល្មើសច្រើនហើយមានប្រភេទដូចគ្នាដែលស្ថិតក្នុងការចោទប្រកាន់ដាច់ពីគ្នា តុលាការអាចប្រកាសទោសឱ្យស្រូបបញ្ចូលគ្នាទាំងមូល ឬមួយផ្នែកនៃទោសដែលមានប្រភេទដូចគ្នា។

**ករណីដោយឡែក : អានុភាពនៃការការលើកលែងទោស និងការបន្ធូរបន្ថយទោសលើការស្រូបទោស.**-កាលបើទោសជាកម្មវត្ថុនៃវិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដូចមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែគិតគូរអំពីទោសដែលជាលទ្ធផលនៃការលើកលែងទោស និងបន្ធូរបន្ថយទោស ដើម្បីអនុវត្តវិធានស្តីពីការស្រូបបញ្ចូលគ្នានៃទោស។ ចិរវេលានៃការបន្ធូរបន្ថយទោសត្រូវរាប់បញ្ចូលទៅក្នុងចិរវេលានៃទោសទៅថ្ងៃមុខ ក្រោយការស្រូបទោស។

[៤៥] មាត្រា ៥៦០ "ការលួចរត់ គឺជាអំពើរបស់ជនជាប់ឃុំដែលលួចរត់ចេញពីការឃុំខ្លួន តាមគ្រប់មធ្យោបាយ។ ការលួចរត់ចេញពីទីឃុំឃាំងត្រូវចាត់ទុកថាគ្រប់លក្ខណៈដែរ ទោះបីជាមធ្យោបាយខាងលើនេះ ជាអំពើរបស់តតិយជនក៏ដោយ។ ត្រូវចាត់ទុកថាជាជនជាប់ឃុំគឺ : ១-បុគ្គលដែលគេឃាត់ខ្លួនទុក ២-បុគ្គលដែលគេហៀប នឹងនាំទៅបង្ហាញខ្លួន ឬកំពុងតែនាំទៅបង្ហាញខ្លួនដល់អាជ្ញាធរតុលាការក្រោយពីការឃាត់ខ្លួន ឬដោយអនុវត្តដីកានាំខ្លួន ឬឱ្យចាប់ខ្លួន ៣-បុគ្គលដែលបានទទួល លិខិតឱ្យដំណឹងពីដីកាឱ្យឃុំ ឬឱ្យចាប់ខ្លួន ៤-បុគ្គលដែលអនុវត្តទោសដាក់ពន្ធនាគារ ឬដែលត្រូវគេចាប់ខ្លួនដើម្បីអនុវត្តទោសនេះ ៥-បុគ្គលដែលត្រូវគេឃុំខ្លួននៅ ក្នុងក្របខ័ណ្ឌនៃនីតិវិធីបត្យាប័ន ៦-ជនដែលស្ថិតក្នុងរបបពាក់កណ្តាលសេរីភាពតាមបញ្ញត្តិនៃម,១២៧ (លក្ខខណ្ឌនៃរបបពាក់កណ្តាលសេរីភាព) នៃក្រមនេះ"។ មាត្រា ៥៦២ "ត្រូវចាត់ទុកថាជាអំពើលួចរត់ និងត្រូវផ្តន្ទាទោសដូចគ្នា : ១-អំពើរបស់ជនជាប់ឃុំដែលត្រូវបានដាក់នៅក្នុងគ្រឹះស្ថានសុខាភិបាល ឬមន្ទីរពេទ្យ ឬទីកន្លែងផ្សេងទៀត ដូចជាតុលាការអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ជាអាទិ៍ ដែលគេចខ្លួនចេញពីការតាមឃ្លាំមើល ២-អំពើរបស់ទណ្ឌិតដែលបានទទួលរបបពាក់កណ្តាលសេរីភាព របបព្យួរទោស ឬរបបបែងជាប្រភាគនៃទោស ឬនៃការអនុញ្ញាតឱ្យចេញក្រៅពន្ធនាគារ ហើយមិនវិលត្រឡប់មកពន្ធនាគារវិញ នៅពេលផុតរយៈកាលនៃសេរីភាព"។

## ខ. ការមិនរាងចាល

១-និយមន័យ

ការមិនរាងចាលជាស្ថានភាពនៃជនម្នាក់ក្រោយពេលផ្តន្ទាទោសជាស្ថាពរ ហើយបានប្រព្រឹត្តបទ-ល្មើសជាថ្មី ដែលលក្ខខណ្ឌមានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើស ក្នុង ៤ ករណីដូចខាងក្រោម :

១-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋថ្មីទៀតនៅក្នុងរយៈពេល ១០ ឆ្នាំ។

២-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទឧក្រិដ្ឋ បុគ្គលនោះបានប្រព្រឹត្ត បទមជ្ឈិមក្នុងរយៈពេល ៥ ឆ្នាំ ។

៣-កាលបើបុគ្គលណាម្នាក់ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ដោយត្រូវជាប់ពន្ធនាគារ ស្មើ ឬលើសពី ៣ ឆ្នាំ បុគ្គលនោះបានប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងរយៈពេល ៥ ឆ្នាំ ។

៤-កាលបើបុគ្គលណាម្នាក់ ដែលត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម បុគ្គលនោះបានប្រព្រឹត្ត *បទមជ្ឈិមដដែល*នៅក្នុងរយៈពេល ៥ ឆ្នាំ ។

រយៈពេល ១០ ឆ្នាំ និង ៥ ឆ្នាំ ចាប់ផ្តើមគិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសចំពោះបទល្មើសទី ១ ចូល ជាស្ថាពរ(មាត្រា ៨៤) ។

**សេចក្តីសម្រេចត្រូវបានចាត់ទុកថាជាស្ថាពរ** កាលណាសេចក្តីសម្រេចនេះ មិនអាចមានផ្លូវតវ៉ាបានទៀតឡើយ។ ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល ត្រូវគិតគូរតែលើការផ្តន្ទាទោសស្ថាពរខាងបណ្តឹងអាជ្ញាប៉ុណ្ណោះ(មាត្រា ៩១)។ ភស្តុតាងនៃការមិនរាងជាបញ្ហាលំបាកមួយដែលគេគួរតែពិចារណា។ "ការមិនរាងចាលអាចត្រូវកត់ត្រាទុក ទោះបីទោសដែលកើតចេញពីការផ្តន្ទាទោសនោះត្រូវផុតអាជ្ញាយុកាលក៏ដោយ។ ការមិនរាងចាល មិនអាចត្រូវកត់ត្រាទុកទេ បើទោសដែលកើតចេញពីការផ្តន្ទាទោសស្ថាពរនោះ ត្រូវបានលើកលែងដោយអនុលោមតាមមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជា-ណាចក្រកម្ពុជា(មាត្រា ៩២)។

២-ទោសត្រូវរងក្នុងករណីមិនរាងចាល

ការមិនរាងចាលមានអានុភាព នាំឱ្យមានការបន្ថែមទម្ងន់ អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិម(មាត្រា ៨៣)។ ព្រះរាជអាជ្ញាទទួលបន្ទុកក្នុងការទាមទារឱ្យតុលាការអនុវត្តស្ថានទម្ងន់ទោស។ មានន័យថា ការមិនរាងចាលអាចជាមូលហេតុនៃការបន្ថែមទម្ងន់ទោសបាន "ប្រសិនបើមានចែងយ៉ាងជាក់លាក់នៅក្នុងលិខិតចោទប្រកាន់"(មាត្រា ៩០)។

-ការមិនរាងចាលក្នុងបទឧក្រិដ្ឋ(មាត្រា ៨៥):"... អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មី ត្រូវទម្ងន់តាមខ្នាតដូចតទៅ :

១.ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋថ្មី មិនលើស ពី ២០ឆ្នាំ ទេ អតិបរមានេះត្រូវទ្វេឡើង

២.ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះ បទឧក្រិដ្ឋ ថ្មីនេះ មានរយៈពេល ៣០ ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត"។

-ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសពីបទឧក្រិដ្ឋ(មាត្រា ៨៦):អតិបរមាត្រូវទ្វេដង។

-ការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសពីបទមជ្ឈិម(មាត្រា ៨៧): "កាលបើបុគ្គលណាម្នាក់ត្រូវបានផ្តន្ទាទោសជាស្ថាពររួចហើយពីបទមជ្ឈិម ដាក់ពន្ធនាគារស្មើ ឬលើសពី ៣ ឆ្នាំ បុគ្គលនេះបានប្រព្រឹត្តបទឧក្រិដ្ឋ នៅក្នុងរយៈពេល ៥ ឆ្នាំ ទោសដែលត្រូវផ្តន្ទាទោសលើបទឧក្រិដ្ឋនេះ ត្រូវទម្ងន់ទៅតាមខ្នាតដូចតទៅ :

១.ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមិនលើសពី ២០ ឆ្នាំ ទេ អតិបរមានេះ ត្រូវទ្វេឡើង

២.ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទឧក្រិដ្ឋមានរយៈពេល ៣០ ឆ្នាំ អតិបរមានៃទោស គឺដាក់ ពន្ធនាគារអស់មួយជីវិត"។

-ការមិនរាងចាលក្នុងបទមជ្ឈិមបន្ទាប់ពីការផ្តន្ទាទោសពីបទមជ្ឈិម(មាត្រា ៨៨):" ...អតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទមជ្ឈិមថ្មីត្រូវទ្វេឡើង ។

ក្នុងន័យដើម្បីធានាការដាក់ទោសចំពោះកំហុសធ្ងន់ធ្ងរ គេបានធ្វើការប្រដូចបទល្មើស "ដើម្បីអនុវត្តបទប្បញ្ញត្តិស្តីពីការមិនរាងចាល បទលួច បទរំលោភលើទំនុកចិត្ត និងបទឆបោក ត្រូវចាត់ទុកថាជាបទល្មើសដូចគ្នាដដែល។ បទល្មើសទទួលផលចោរកម្មត្រូវប្រដូចជាបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិ ដែលទទួលលាក់បំបាំង។ បទសំអាតប្រាក់ត្រូវប្រដូចជាបទល្មើសដែលការសំអាតប្រាក់នេះបានសម្រេច"(មាត្រា ៨៩)។

**គោរពការសិក្សា មានអនាគតភ្លឺស្វាង រុងរឿង។**

# ផ្នែកទី ៣ ការអនុវត្តទោស

**គោលការណ៍.**.."គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការទេ"(មាត្រា ៦)។

**ការគិតថិរវេលានៃការអនុវត្តទោស.**..ទោសដាក់ពន្ធនាគារ ១ ថ្ងៃ ត្រូវគិត ២៤ ម៉ោង។ ទោសដាក់ពន្ធនាគារ ១ ខែ ត្រូវគិត ៣០ ថ្ងៃ។ ទោសដាក់ពន្ធនាគារលើសពី ១ ខែ ត្រូវគិតតាម ចំនួនថ្ងៃជាក់ស្តែងដែលមាននៅក្នុងខែនោះ។ ទោសដាក់ពន្ធនាគារ ១ ឆ្នាំ ត្រូវគិត ១២ ខែ"(មាត្រា ៥០២-១ ក្រមនីតិវិធីព្រហ្មទណ្ឌ)។ "ទណ្ឌិតដែលបានអនុវត្ត ទោសរបស់ខ្លួនហើយ ត្រូវដោះលែងនៅក្នុងចន្លោះពី ម៉ោង ៦ ព្រឹក ដល់ម៉ោង ១៨"(មាត្រា ៥០២-២ ក្រមនីតិវិធីព្រហ្មទណ្ឌ)។ ម្យ៉ាងវិញទៀត "ថិរវេលានៃការ ឃុំខ្លួនបណ្តោះអាសន្នត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដែលបានប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរងបន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា"(មាត្រា ៥០៣ ក្រមនីតិវិធីព្រហ្មទណ្ឌ)។

## កថាខណ្ឌទី ១ មូលហេតុទូទៅដែលមានផលប៉ះពាល់ដល់ការអនុវត្តទោស

ជាគោលការណ៍ទោសដែលតុលាការប្រកាសប្រឆាំងទណ្ឌិតមានអានុភាពអនុវត្ត។ តែមានមូល-ហេតុមួយចំនួនអាចប៉ះពាល់ដល់ការអនុវត្តទោសទាំងនេះ។

### ក..អាជ្ញាយុកាលនៃទោស

អាជ្ញាយុកាលជាកំឡុងពេលមួយដែលផុតពេលនោះអានុភាពនៃទោស ដែលតុលាការបានប្រកាសប្រឆាំងនឹងទណ្ឌិតត្រូវបាត់បង់។ មានន័យថា "នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ"(មាត្រា ១៤២)។ ក៏ប៉ុន្តែ ដើម្បីការពារប្រយោជន៍រួម ច្បាប់កំណត់ពីភាពមិនអាចផុតរលត់អាជ្ញា-យុកាលនៃទោសអនុវត្តចំពោះបទឧក្រិដ្ឋមួយចំនួន : ទោសដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋសង្គ្រាម(មាត្រា ៩ ក្រមនីតិវិធីព្រហាទណ្ឌ) និងអំពើភេរវកម្ម(មាត្រា ៩

ច្បាប់ស្តីពីការប្រឆាំងអំពើភេរវកម្ម) មិនអាចផុតរលត់អាជ្ញាយុកាលទេ។ ក្រៅពីបទល្មើសខាងលើ ច្បាប់ពិសេសអាចកំណត់អំពីការមិនអាចផុតរលត់អាជ្ញាយុកាលនៃទោសចំពោះបទល្មើសផ្សេងទៀត(មាត្រា ១៤៣)។

ទោសដែលប្រកាសពីបទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ ឆ្នាំ ពីបទមជ្ឈិម មានអាជ្ញាយុកាល ៥ ឆ្នាំ និងពីបទលហុមានអាជ្ញាយុកាល ១ ឆ្នាំ(មាត្រា ១៤៤)។ ចំណុចចាប់ផ្តើមនៃចិរវេលា ២០ ឆ្នាំ ៥ ឆ្នាំ និង ១ ឆ្នាំ ចាប់គិតពីថ្ងៃដែលសេចក្តីសម្រេចផ្តន្ទាទោសបានក្លាយទៅជាស្ថាពរ។

## ខ. ការអនុគ្រោះទោស

ការអនុគ្រោះទោសដែលជាព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រ ដូចមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ អាចអនុវត្តលើកទោសទាំងស្រុង(ការលើកលែងទោស) ឬលើកទោសមួយផ្នែក(ការបន្ធូរបន្ថយទោស)។

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬដោយការលើកលែងទោស អនុលោមតាមមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាលើក លែងឱ្យទណ្ឌិតរួចផុតពីការអនុវត្តទោសក្នុងទំហំដែលអនុគ្រោះនោះ(មាត្រា ១៤៧)។

ការអនុគ្រោះទោសមិនមែន ជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនៃព្រះរាជក្រឹត្យ ដែលពាក់ព័ន្ធនឹងការអនុគ្រោះទោសនោះ (មាត្រា ១៤៨)។

អនុលោមតាមក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០-មិថុនា-១៩៨៨ ការលើកលែងទោស ឬការបន្ធូរបន្ថយទោសអាចធ្វើឡើងពីរដងក្នុងមួយឆ្នាំ គឺ ក្នុងឱកាសបុណ្យ ៧ មករា និងបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ តែតាមព្រះរាជសារចុះថ្ងៃទី ១៥-វិច្ឆិកា-១៩៩៣ បានផ្លាស់ប្តូរទៅធ្វើនៅក្នុងឱកាសព្រះរាជពិធីបុណ្យតាំងតុ និងបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។ ចំណែកឯតាមការអនុវត្តសព្វថ្ងៃ ក្នុងមួយឆ្នាំ មានការបន្ធូរបន្ថយទោស ឬការលើកលែងទោស ចំនួនបីដង អនុវត្តនៅ ក្នុងឱកាសបុណ្យពិសាខបូជា បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ និងបុណ្យចំរើនព្រះជន្មព្រះមហាក្សត្រ។

### ១-លក្ខខណ្ឌ

អនុលោមតាមក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០-មិថុនា-១៩៨៨ ទណ្ឌិតដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម មានសិទ្ធិទទួលបានការបន្ធូរបន្ថយទោស ឬការលើកលែងទោស(មាត្រា ១ មាត្រា ២ និងមាត្រា ៣) :

*១.១ ការលើកលែងទោស*

-បានអនុវត្តទោសក្នុងពន្ធនាគារ ចំនួន មួយភាគបី ឬ បាន ១៥ ឆ្នាំ ក្នុងករណីការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះការលើកលែងទោស។

-ទណ្ឌិតមិនស្ថិតក្នុងករណីមិនរាងចាល(មាត្រា ៥)

-បានភ្ញាក់រលឹកខិតខំលុតដំកែប្រែខ្លួនបានល្អ និងប្តេជ្ញាខិតខំរៀនសូត្រអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ

-បានយកចិត្តទុកដាក់បំពេញការងារពលកម្មយ៉ាងសកម្ម ទៀងទាត់ មានឥទ្ធិពលល្អ និងជាគំរូល្អដល់ទណ្ឌិតដទៃទៀត និង

-បានគោរពប្រតិបត្តិយ៉ាងហ្មត់ចត់ ត្រឹមត្រូវ តាមរបបបទបញ្ជាផ្ទៃក្នុងពន្ធនាគារ។

*១.២ ការបន្ធូរបន្ថយទោស*

-បានអនុវត្តទោសក្នុងពន្ធនាគារចំនួនពីរភាគបី ឬបាន ៧ឆ្នាំ ក្នុងករណីការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត

-បានភ្ញាក់រលឹកខិតខំលុតដំកែប្រែខ្លួនបានល្អ និងប្តេជ្ញាខិតខំរៀនសូត្រអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ

-បានយកចិត្តទុកដាក់បំពេញការងារពលកម្មយ៉ាងសកម្ម ទៀងទាត់ មានឥទ្ធិពលល្អ និងជាគំរូល្អដល់ទណ្ឌិតដទៃទៀត និង

-បានគោរពប្រតិបត្តិយ៉ាងហ្មត់ចត់ ត្រឹមត្រូវ តាមរបបបទបញ្ជាផ្ទៃក្នុងពន្ធនាគារ។

***លិខិតលេខ ២៨២ រប.៦១៦០.៩៤ របស់ក្រសួងយុត្តិធម៌*** ចុះថ្ងៃទី ២៤-កុម្ភៈ-១៩៩៤ បានណែនាំការអនុវត្តព្រះរាជសារចុះថ្ងៃទី ១១-វិច្ឆិកា-១៩៩៣ ថា ការសុំលើកលែងទោស ឬបន្ថយទោសឱ្យទណ្ឌិត ទាំងពីរភេទ អាចប្រព្រឹត្តទៅចំពោះទណ្ឌិតដែលត្រូវតុលាការផ្តន្ទាទោសមិនធ្ងន់ធ្ងរ ហើយកែប្រែខ្លួនបានល្អនៅក្នុងពន្ធនាគារ។ ចំណែកទណ្ឌិតដែលត្រូវតុលាការផ្តន្ទាទោសធ្ងន់ធ្ងរ គប្បីស្នើសុំត្រឹមការបន្ថយទោស។

**ចិរវេលានៃការបន្ធូរបន្ថយទោស.**-ក្រឹត្យលេខ ២៨ ក្រ ខាងលើមិនបានចែងអំពីទំហំនៃការលើកលែងទោសទេ ហើយបើតាមការអនុវត្តជាក់ស្តែង គឺការលើកលែងទោសធ្វើឡើងចំពោះទោសដាក់ពន្ធ-នាគារ ទាំងអស់ដែលចៅក្រមប្រកាសប្រឆាំងនឹងទណ្ឌិត។

ចិរវេលានៃការបន្ធូរបន្ថយទោស ត្រូវអនុលោមតាមការកំណត់ដូចខាងក្រោម :

-ទោសកំណត់ពី ១ ឆ្នាំ ទៅដល់ក្រោម ១០ ឆ្នាំ អាចបន្ធូរបន្ថយបាន ៦ ខែ

- ទោសកំណត់ពី ១០ ឆ្នាំ ទៅដល់ក្រោម ១៥ ឆ្នាំ អាចបន្ធូរបន្ថយបាន ៩ ខែ

- ទោសកំណត់ពី ១៨ ឆ្នាំ ទៅដល់ក្រោម ២០ ឆ្នាំ[៨៦] អាចបន្ធូរបន្ថយបាន ១២ ខែ

- ទោសដាក់ពន្ធនាគារអស់មួយជីវិត អាចបន្ធូរបន្ថយលើកទី ១ មកនៅ ២០ ឆ្នាំ។

[៨៦] យោងតាមក្រមព្រហ្មទណ្ឌ គឺខ្ពាតពី ១៥ ឆ្នាំ ទៅ ៣០ ឆ្នាំ។

ក្រៅពីនេះ ទណ្ឌិតអាចទទួលការបន្ធូរបន្ថយទោសច្រើនដងបាន ក្នុងលក្ខខណ្ឌដែលទណ្ឌិតនោះអនុវត្តទោសទាំងអស់បានពាក់កណ្ដាលនៃទោសដែលតុលាការបានប្រកាស។ ចំពោះទណ្ឌិតដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ដែលទទួលអត្ថប្រយោជន៍គឺបន្ថយលើកទី ១ មកនៅត្រឹម ២០ ឆ្នាំ នៅតែអាចទទួលការបន្ធូរបន្ថយទោសទៀតបាន តែមិនត្រូវឱ្យការអនុវត្តទោសសរុបក្នុងពន្ធនាគារ ក្រោម ១៥ ឆ្នាំ ទេ (មាត្រា ៤ នៃក្រឹត្យលេខ ២៨ ក្រ ខាងលើ)។

២-នីតិវិធី

ជាទូទៅ ប្រធានពន្ធនាគារជាអ្នកទទួលបន្ទុកតាមដាន និងកត់ត្រាអំពីកិរិយាមាយាទរបស់ទណ្ឌិតម្នាក់ៗ ហើយក្នុងករណីដែលទណ្ឌិតរូបណាបំពេញលក្ខខណ្ឌនីត្យានុកូល ហើយមានសិទ្ធិទទួលបាន ការអនុគ្រោះទោស ប្រធានពន្ធនាគារត្រូវស្នើសុំទៅព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត នាទីកន្លែងពន្ធនាគារស្ថិតនៅ។ ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី ខេត្ត ត្រូវបញ្ជូនសំណើនេះទៅប្រធានតុលាការ ហើយប្រធានតុលាការត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌។ នាយកដ្ឋានកិច្ចការព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ត្រូវពិនិត្យ និងលើកយោបល់ជូនរដ្ឋមន្ត្រី ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវលើកសំណើនោះជូននាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេច។ មុននឹងលើកសំណើថ្វាយព្រះមហាក្សត្រ នាយករដ្ឋមន្ត្រីត្រូវទទួលយោបល់ពីក្រុមប្រឹក្សាអ្នកច្បាប់។

ជាទូទៅនីតិវិធីនៃការអនុគ្រោះទោសត្រូវធ្វើតាមរយៈ ប្រធានពន្ធនាគារ។ ក៏ប៉ុន្តែ តាមការអនុវត្តជាក់ស្ដែងការលើកលែងក៏អាចត្រូវបានធ្វើ *១-ដោយក្រុមគ្រួសារទណ្ឌិត ឬដោយទណ្ឌិតខ្លួនឯងដែរ* ករណីដូចជា ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៣/២៨៧ ចុះថ្ងៃទី ១៨ កញ្ញា ២០០៣ ស្ដីពីការលើកលែងទោសឱ្យទណ្ឌិត ពីររូប ដែលត្រូវបានផ្ដន្ទាទោសតាមអំណាចសាលក្រមលេខ ៦១ "ង" ចុះថ្ងៃទី ០២-១៥ កញ្ញា ២០០៣ របស់តុលាការក្រុងភ្នំពេញ *២-ដោយនាយករដ្ឋមន្ត្រី*ដែលស្នើសុំឱ្យមានការលើកលែងទោសទណ្ឌិតដោយមិនចាំបាច់គោរពលក្ខខណ្ឌនៃក្រឹត្យលេខ ២៨ ខាងលើដែរ។ ករណីនេះ កើតមានជាញឹកញាប់ ចំពោះឥស្សរៈជនល្បីៗ ឬអ្នកនយោបាយ។

***<u>កំណត់សំគាល់</u>*** :

ការលើកលែងទោស ដែលជាព្រះរាជសិទ្ធិរបស់ព្រះមហាក្សត្រមានអានុភាពចំពោះបុគ្គលដែលមានចែងក្នុងព្រះរាជក្រឹត្យប៉ុណ្ណោះ ដែលប្រការនេះវាខុសពីការលើកលែងទោសជាទូទៅ ដែលធ្វើឡើងដោយច្បាប់របស់សភា ហើយការលើកលែងទោសជាទូទៅមានអានុភាពសាកល ពោលគឺអនុវត្តចំពោះគ្រប់បុគ្គលទាំងអស់ដែលជាប់ពាក់ព័ន្ធ។

### គ. ការលើកលែងទោសជាទូទៅ

យោងតាមមាត្រា៩០ថ្មី (ពីរ) វាក្យខណ្ឌ ទី ៤ នៃរដ្ឋធម្មនុញ្ញ ការលើកលែងទោសជាទូទៅ ត្រូវធ្វើតាមរយៈច្បាប់របស់អង្គការនីតិប្បញ្ញត្តិ ហើយត្រូវកំណត់អំពីប្រភេទបទល្មើសដែលលើកលែង និងអំឡុងពេលច្បាស់លាស់។ ច្បាប់នេះ ត្រូវបានគេធ្វើឡើងតែក្នុងកាលៈទេសៈពិសេស ប៉ុណ្ណោះ។

ការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ថ្មី (ពីរ) វាក្យខណ្ឌ ទី ៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជាទូទៅ (មាត្រា ១៤៩)។ ទោសមិនអាចអនុវត្តបានទៀតទេ។ ទោសដែលកំពុងអនុវត្ត ត្រូវបានបញ្ចប់។

ប៉ុន្តែ ចំពោះប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តី ដែលបានបង់រួចហើយ មិនអាចទារសំណងពីរដ្ឋវិញបានទេ ។

**ការលើកលែងទោសជាទូទៅ និងការដកការព្យួរទោស** កាលបើការព្យួរទោសពីមុន ត្រូវបានដកហូត ដោយអានុភាពនៃការផ្តន្ទាទោសខាងក្រោយ ការលើកលែងទោសជាទូទៅចំពោះទោស ខាងក្រោយនេះ បង្កើតឡើង វិញនូវផលប្រយោជន៍នៃការព្យួរទោសដែលមានពីមុន។

លើកលែងតែច្បាប់បញ្ញត្តផ្សេងពីនេះ ការលើកលែងទោសជាទូទៅមិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលសំណងការជួសជុលនៃការខូចខាតឡើយ(មាត្រា ១៥១)។

**<u>កំណត់សំគាល់</u>** :

ការអនុគ្រោះដូចខាងបានបង្ហាញខាងលើ មានលក្ខខណ្ឌ នីតិវិធី និងគោលគំនិតស្រដៀងគ្នា ឬប្រហាក់ប្រហែលគ្នាទៅនឹងការដោះលែងដោយមានលក្ខខណ្ឌដូចមានចែងចាប់មាត្រា ៥១២ ដល់មាត្រា ៥២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**ដើមឈើរឹងមាំ គឺដើមឈើមធំ បែកមែកត្រួយឈើងត្រសៃ**
**ដើមឈើផ្តល់ផ្លែច្រើន និងឃ្មុំអង្វែង គឺដើមឈើធំ និងរឹងមាំខ**

## កថាខណ្ឌទី ២ ការអនុវត្តទោស និងការដោះលែងដោយមានលក្ខខណ្ឌ

ជាគោលការណ៍ ទណ្ឌិតត្រូវទទួលរងទោសក្នុងពន្ធនាគាររហូតដល់កាលកំណត់ (ក) តែក្នុងករណីមួយចំនួន ទណ្ឌិតអាចត្រូវបានដោះលែងឱ្យមានសេរីភាពមុនកាលកំណត់បាន (ខ)។

### ក.-ការអនុវត្តទោស

អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្ដីសម្រេចខាងបទព្រហ្មទណ្ឌ ហើយអយ្យការធ្វើការអនុវត្តទោស នៅពេលដែលសេចក្ដីសម្រេចតុលាការបានក្លាយជាស្ថាពរ ហើយរយៈពេលប្ដឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា អាចសុំកំលាំងសាធារណៈ ដើម្បីធានារ៉ាប់រងការអនុវត្តទោស។

ជាគោលការណ៍ ការអនុវត្តទោស និងការបង្ខំដល់រូបកាយត្រូវធ្វើតាមគំនិតផ្ដើមរបស់អយ្យការ ចំណែកឯការអនុវត្តទណ្ឌកម្មរដ្ឋប្បវេណីត្រូវតែធ្វើតាមគំនិតផ្ដើមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី(មាត្រា ៤៩៦)។ ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារ នៅក្រោមឱវាទរបស់អយ្យការ។ ប្រាក់ពិន័យ និងប្រាក់ពន្ធនីតិវិធីដែលប្រមូល ត្រូវបង់ចូលថវិការដ្ឋ។ គ្រប់សេចក្ដីសម្រេចផ្ដន្ទាទោសស្ថាពរមានតំលៃជាបញ្ជាឱ្យបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី។

ការលំបាកទាំងឡាយដែលទាក់ទងនឹងការអនុវត្តទោស ត្រូវតែលើកជូនតុលាការជាន់ដំបូង ឬតុលាការជាន់ខ្ពស់ ដែលបានសម្រេចផ្ដន្ទាទោសនោះ ដោះស្រាយ។ ក្នុងករណីនេះ តុលាការទទួលបណ្ដឹងតាមពាក្យប្ដឹងរបស់អយ្យការ ឬរបស់ភាគីពាក់ព័ន្ធ ហើយតុលាការសម្រេចនៅពេលសវនាការសាធារណៈក្រោយពីបានស្ដាប់អយ្យការ ភាគីពាក់ព័ន្ធ និងជាយថាហេតុមេធាវីរបស់ភាគីនេះ។ នៅក្នុងករណីនេះ ការអនុវត្តទោសអាចត្រូវបានព្យួរដោយតុលាការ។

ការអនុវត្តទោស ក្នុងពន្ធធនាគារមានចែងចាប់ពីមាត្រា ៥០២ ដល់ មាត្រា ៥១១ :

ក្រមនីតិវិធីព្រហ្មទណ្ឌ

**មាត្រា ៥០២.** – ការគណនាថិរវេលានៃការដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារក្នុង ១ (មួយ) ថ្ងៃ មានថិរវេលា ២៤ (ម្ភៃបួន) ម៉ោង ។

ទោសដាក់ពន្ធនាគារ ក្នុង ១ (មួយ) ខែ មានថិរវេលា ៣០ (សាមសិប) ថ្ងៃ ។

ទោសដាក់ពន្ធនាគារលើសពី ១ ខែ ត្រូវគិតតាមលេខរៀងនៃថ្ងៃក្នុងខែទី ១ ទៅលេខរៀងនៃថ្ងៃ ក្នុងខែមួយទៀត ។

ទណ្ឌិតដែលបានអនុវត្តទោសរបស់ខ្លួនរួចហើយ ត្រូវដោះលែងនៅក្នុងចន្លោះពីម៉ោង ៦ ព្រឹក ដល់ម៉ោង ១៨ ។

**មាត្រា ៥០៣. –** ការគិតបញ្ចូលថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានគិតបញ្ចូលទាំងស្រុងទៅក្នុងថិរវេលានៃទោសដែលបាន ប្រកាស ឬជាយថាហេតុនៃថិរវេលាសរុបនៃទោសដែលត្រូវទទួលរង បន្ទាប់ពីការស្រូបទោសបញ្ចូលគ្នា ។

**មាត្រា ៥០៤. –** ការរៀបចំពន្ធនាគារ

ការរៀបចំនិងរបបផ្ទៃក្នុងនៃពន្ធនាគារនិងមណ្ឌលឃុំខ្លួនត្រូវកំណត់ដោយប្រកាសរបស់ក្រសួងដែលគ្រប់គ្រងពន្ធនាគារ ។

ប្រកាសនេះកំណត់ផងដែរ អំពីលក្ខខណ្ឌនៃការបែងចែកទណ្ឌិតនៅតាមពន្ធនាគារ និងមណ្ឌលឃុំខ្លួននានា អំពីបែបបទអនុវត្តទោសដកហូតសេរីភាព និងអំពីរបបឃុំខ្លួន ។

*មាត្រា ១៦៦ នៃក្រមព្រហ្មទណ្ឌបានកំណត់អំពីលក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារថា "អនីតិជនដែលជាប់ពន្ធនាគារត្រូវឃុំខ្លួននៅកន្លែងពិសេសខណ្ឌដាច់ពីនីតិជន។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែក ជាឯកត្តបុគ្គលដែលដាក់ន្លែងសម្រាប់អប់រំ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ របបឃុំឃាំងត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ។"*

**មាត្រា ៥០៥. –** បញ្ជីជនជាប់ឃុំ

គ្រប់ពន្ធនាគារ និងមណ្ឌលឃុំខ្លួនទាំងអស់ ត្រូវមានបញ្ជីមួយដែលចុះនិទ្ទេសអំពី អត្តសញ្ញាណបុគ្គលឃុំខ្លួន កាលបរិច្ឆេទឃុំខ្លួន និងកាលបរិច្ឆេទដោះលែង។ បញ្ជីនេះត្រូវបានត្រួតពិនិត្យជារឿយៗដោយអយ្យការ។ ទំព័រនីមួយៗ ត្រូវតែចុះទិដ្ឋាការដោយអយ្យការ ។

គ្រប់ភ្នាក់ងារនៃរដ្ឋបាលពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវតែជូនបញ្ជីទៅចៅក្រមពិនិត្យមើលតាមការស្នើសុំ ព្រមទាំងបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមការ ប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ៥០៦. –** លិខិតឃុំខ្លួន

គ្មានភ្នាក់ងាររដ្ឋបាលពន្ធនាគារណាអាចទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មាន លិខិតចេញដោយអាជ្ញាធរតុលាការបានឡើយ ។

ភ្នាក់ងាររដ្ឋបាលពន្ធនាគារណាដែលបានទទួល និងឃុំខ្លួនបុគ្គលណាម្នាក់ដោយគ្មានលិខិតចេញដោយអាជ្ញាធរតុលាការទេ នោះត្រូវជាប់ពិរុទ្ធពីបទបង្ខាំងមនុស្សដោយខុសច្បាប់ ។

**មាត្រា ៥០៧. –** ការឃុំខ្លួនដោយខុសច្បាប់

គ្រប់ចៅក្រមទាំងអស់ដែលបានទទួលបណ្ដឹងស្ដីពីការឃុំខ្លួនបុគ្គលណាម្នាក់ដោយខុសច្បាប់ត្រូវធ្វើការផ្ទៀងផ្ទាត់ជាចាំបាច់ភ្លាម។

**មាត្រា ៥០៨. –** ការបង្ហាញខ្លួនជនជាប់ឃុំតាមការស្នើសុំ

គ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ត្រូវតែបង្ហាញខ្លួនជនជាប់ឃុំដល់ចៅក្រមតាមការស្នើសុំ ព្រម ទាំងដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ច តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

**មាត្រា ៥០៩. –** អធិការកិច្ចពន្ធនាគារ

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ប្រធានសភាស៊ើបសួរ និងចៅក្រម ស៊ើបសួរត្រូវធ្វើអធិការកិច្ចលើពន្ធនាគារជាប្រចាំ ។

**មាត្រា ៥១០.** – ការសន្ទនារបស់ជនជាប់ឃុំជាមួយនឹងមេធាវីរបស់ខ្លួន

ជនជាប់ឃុំត្រូវតែមានសិទ្ធិសន្ទនាជាសម្ងាត់ជាមួយនឹងមេធាវីរបស់ខ្លួន ។

**មាត្រា ៥១១.** – ការផ្ដល់ដំណឹងដល់ព្រះរាជអាជ្ញាក្នុងករណីមានឧប្បត្តិហេតុធ្ងន់ធ្ងរ

គ្រប់ឧប្បត្តិហេតុធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ ក្នុងមណ្ឌលឃុំខ្លួន ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ។

ក្នុងករណីដែលអ្នកទោសរត់ចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួន នោះព្រះរាជអាជ្ញាចេញបញ្ជា ស្វែងរកចាប់ខ្លួន និងចាត់វិធានការជាបន្ទាន់ ដើម្បីអនុវត្តបញ្ជាស្វែងរកចាប់ខ្លួន ដោយអនុលោមតាមបញ្ញត្តិដែលចែងក្នុងមាត្រា ១៩៦ (ដីកាបង្គាប់ឱ្យចាប់ខ្លួន) និងមាត្រាបន្តបន្ទាប់នៃក្រមនេះ ។

ច្បាប់បានកំណត់វិធានការពិសេសសម្រាប់អនុវត្តក្នុងករណីដែលទណ្ឌិត ឬបុគ្គលពាក់ពន្ធផ្សេងទៀត មិនព្រមបង់ធនទណ្ឌ អាចបណ្ដាលឱ្យមានការបង្ខំដល់រូបកាយដែលត្រូវបានគេស្គាល់ថា "ការបង្ខំដល់រូបកាយដើម្បីទារធនទណ្ឌ"[៤៧] ។

ការបង្ខំដល់រូបកាយដោយសារមិនបង់ធនទណ្ឌ[៤៨] យោងតាមច្បាប់ឆ្នាំ ១៩៩២ ត្រូវបានទទួលស្គាល់ដោយមាត្រា ៦៩ នៃក្រមព្រហ្មទណ្ឌ និងចាប់ពីមាត្រា ៥២៣ ដល់មាត្រា ៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ធនទណ្ឌ ជាប្រាក់ពិន័យ ប្រាក់ពន្ធ នៃនីតិវិធី និងប្រាក់សំណងនិងសំណងជំងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលសម្រេចដោយតុលាការព្រហ្មទណ្ឌ។ ក្នុងករណីដែលមិនមានលទ្ធភាព ឬរឹងទទឹងមិនព្រមបង់ត្រូវដាក់គុកបង្ខំដល់រូបកាយ។ ក្នុងន័យនេះ សេរីភាពដែលជាសិទ្ធិក្រៅបេតិកភណ្ឌ បានប្រែក្លាយជាសិទ្ធិ បេតិកភណ្ឌដែលអាចវាយតំលៃជាសាច់ប្រាក់បាន។

ក្នុងករណីមានការប្រជែង គ្នារវាងប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្តនោះ ប្រាក់សំណង និង ជម្ងឺចិត្តត្រូវមានអាទិភាពទទួលសងមុនគេ ។

"ការដាក់គុកបង្ខំដល់រូបកាយ គឺជាវិធានការបង្ខំទណ្ឌិតឱ្យសងធនទណ្ឌតែប៉ុណ្ណោះមិនមែនជាការកាត់កងឱ្យរួចពីធនទណ្ឌនោះទេ។ ទណ្ឌិតដែលបានទទួលការបង្ខំរូបកាយរួចហើយនោះ នៅតែជំពាក់ចំនួនទឹកប្រាក់ដែលត្រូវបង់ដដែល។ ប៉ុន្តែ ទណ្ឌិតនេះ មិនត្រូវទទួលរងការបង្ខំរូបកាយចំពោះបំណុលដដែលនេះទៀតទេ"(មាត្រា ៣ ច្បាប់ឆ្នាំ ១៩៩២ និង មាត្រា ៥៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ការបង្ខំដល់រូបកាយមិនចាំបាច់ប្រកាសដោយតុលាការទេ ត្រូវធ្វើដោយព្រះរាជអាជ្ញា[៤៩] (មាត្រា ៥២៤ មាត្រា ៥២៥ និង មាត្រា

[៤៧] **គង់ សំអុន** និង **លីវ សុវណ្ណា** *ការដាក់គុកបង្ខំដល់រូបកាយដើម្បីទារធនទណ្ឌគឺជាការរំលោភសិទ្ធិមនុស្ស* ព្រឹត្តិបត្រអ្នកច្បាប់ លេខ ០៦ មករា-មីនា ២០០៣ ។

[៤៨] ច្បាប់ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២ ស្ដីពី ការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ។

[៤៩] មាត្រា ៥ ច្បាប់ឆ្នាំ ១៩៩២ "ភាគីដើមបណ្ដឹង ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្ដឹងមកប្រធានតុលាការខេត្ត ក្រុង ខាងលំនៅរបស់ទណ្ឌិត ត្រូវចេញដីកាបង្គាប់បញ្ជា

៥៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ចំពោះ*ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី* អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញា[៥០] ហើយព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយ(មិនអាចតិចជាង ១០ ថ្ងៃទេ) ឱ្យបង់ដោយបញ្ជាក់អំពីវិបាកនៃការមិនបង់(បង្ខំដល់រូបកាយ)។ ចំណែកឯ*ប្រាក់សំណង និងជំងឺចិត្ត* ដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើឱ្យព្រះរាជអាជ្ញាបង្ខំដល់រូបកាយ ដោយបង្ហាញភស្តុតាងថា ខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬអចលនវត្ថុ ជាដើម។ ព្រះរាជអាជ្ញាអាចហៅដើមបណ្ដឹងរដ្ឋប្បវេណីឱ្យធ្វើនីតិវិធីថ្មី ដើម្បីសាកល្បងទារប្រាក់សំណង និងជម្ងឺចិត្តនេះ។ ក្នុងករណី**មិនព្រមបង់**[៥១] ត្រូវបង្ខំដល់រូបកាយ។ នីតិវិធីនៃការបង្ខំដល់រូបកាយ មានចែងពីមាត្រា ៥២៦ ដល់ ៥៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ចំពោះថិរវេលានៃការបង្ខំដល់រូបកាយ សូមអានមាត្រា ៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**រដ្ឋកម្ពុជា**

**រដ្ឋសភា** **ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

**ច្បាប់ស្តីពី**

**ការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ**

**មាត្រា ១.-**

ធនទណ្ឌ គឺប្រាក់ពិន័យ ប្រាក់សំណង ឬប្រាក់ជំងឺចិត្ត ។ របៀបទារធនទណ្ឌ គឺអាចទារប្រាក់ទាំង ៣មុខរួមគ្នា ឬទារ មួយមុខៗ តាមគ្រប់វិធីដែលច្បាប់អនុញ្ញាត និងតាមផ្លូវដាក់គុកបង្ខំដល់រូបកាយផងក៏បាន ។

ធនទណ្ឌនេះ ត្រូវទារតាមអំណាចនៃសម្រេចសាលក្រមរបស់តុលាការដែលមានលក្ខណៈជាស្ថាពរហើយ ។ ប្រាក់សំណង និងប្រាក់ជម្ងឺចិត្ត ត្រូវទារតាមបណ្តឹងរបស់ភាគីដើមបណ្តឹង ដែលតុលាការបានសំរេចសេចក្តី ។ ប្រាក់ពិន័យ ប្រាក់ សំណង ឬប្រាក់ជម្ងឺចិត្ត ដែលត្រូវបានទៅរដ្ឋ ត្រូវទារតាមបណ្តឹងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២.-**

ការទារប្រាក់ពិន័យផង ប្រាក់សំណងផង ប្រាក់ជម្ងឺចិត្តផង ពីទណ្ឌិតដែលមានធនធានមិនគ្រប់គ្រាន់ គេត្រូវទារប្រាក់សំណង ឬប្រាក់ជម្ងឺចិត្តមុនប្រាក់ពិន័យ ។

របៀបនៃការទារប្រាក់ពិន័យ ប្រាក់សំណង និងប្រាក់ជម្ងឺចិត្ត ត្រូវអនុវត្តដូចគ្នា និងរបៀបនៃការទារប្រាក់សំណង

ឱ្យយកទណ្ឌិត ទៅដាក់គុកបង្ខំដល់រូបកាយ ។ នៅពេលកំពុងអនុវត្តការដាក់គុកបង្ខំដល់រូបកាយនោះ ទណ្ឌិតបានសងធនទណ្ឌគ្រប់ចំនួនហើយ ប្រធានតុលាការត្រូវចេញដីកា បង្គាប់បញ្ជាអោយដោះលែងទណ្ឌិតនោះចេញពីពន្ធនាគារភ្លាម" ។

[៥០] ការប្រមូលប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធីត្រូវធ្វើដោយភ្នាក់ងាររតនាគារ នៅក្រោមឱវាទរបស់អយ្យការ ហើយត្រូវបង់ចូលថវិការដ្ឋ។

[៥១] មានប្រាក់ដែរ តែទណ្ឌិតមិនព្រមបង់ ឬទណ្ឌិតមិនមានលទ្ធភាពបង់ ?

ក្នុងរឿងរដ្ឋប្បវេណីដែរ លើកលែងតែវិធីដាក់គុកបង្ខំដល់រូបកាយ ។

**មាត្រា ៣.~**

ការដាក់គុកបង្ខំដល់រូបកាយគឺ ជាវិធានការបង្ខំទណ្ឌិតឱ្យសងធនទណ្ឌតែប៉ុណ្ណោះមិនមែនជាការកាត់កងឱ្យរួចពីធន ទណ្ឌនោះទេ ។

នៅពេលដែលទណ្ឌិតរួចផុតពីកំណត់កាលដាក់គុកបង្ខំដល់រូបកាយ ប្រាក់ដែលទណ្ឌិតមិនទាន់បានសងទាំងប៉ុន្មាន ត្រូវ នៅជំពាក់ទាំងអស់ដដែល ។ ប៉ុន្តែ មិនត្រូវយកទណ្ឌិតនេះទៅដាក់គុកបង្ខំដល់រូបកាយជាថ្មី ដើម្បីទារប្រាក់ជំពាក់ដដែល នេះទៀតទេ ។

**មាត្រា ៤.~**

ជនដែលច្បាប់រដ្ឋប្បវេណីឱ្យរួចផុតពីការដាក់គុកបង្ខំដល់រូបកាយនោះ មិនត្រូវបានរួចផុតពីការដាក់គុកបង្ខំដល់ រូបកាយក្នុងរឿងព្រហ្មទណ្ឌឡើយ ទោះបីជាប្រាក់ដែលជំពាក់នោះជាប្រាក់ពិន័យក្តី ប្រាក់សំណងក្តី ឬប្រាក់ជម្ងឺចិត្តក្តី ។

អនីតិជនអាយុតិចជាង ១៨ឆ្នាំ និងមនុស្សវិកលចរិតមិនត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារធនទណ្ឌនោះ ទេ។

នីតិជនមានអាយុចាប់ពី ១៨ឆ្នាំ ឡើងមានសតិជានាល្អ មានវិចារណប្បញ្ញា ស្គាល់ខុសស្គាល់ត្រូវ ទើបដាក់ គុកបង្ខំដល់រូបកាយ ដើម្បីទារធនទណ្ឌនោះ ។

**មាត្រា ៥.~**

ក្នុងរឿងព្រហ្មទណ្ឌ ការសុំឱ្យដាក់គុកបង្ខំដល់រូបកាយនេះ ឥតមានបង់ថ្លៃអ្វីទេ គឺថា បើមានភាគីដើមបណ្តឹង ឬ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្តឹងមក ប្រធានតុលាការខេត្ត ក្រុង ខាងលំនៅរបស់ទណ្ឌិត ត្រូវចេញដីកាបង្គាប់បញ្ជាឱ្យយក ទណ្ឌិតទៅដាក់គុកបង្ខំដល់រូបកាយដោយគ្មានឱ្យចេញថ្លៃ ឬឱ្យតម្កល់ប្រាក់ថ្លៃអាហារទេ ថ្វីបើមានប្រើសិទ្ធិរឹបអូសលក់ តាមផ្លូវច្បាប់នូវចលនវត្ថុ អចលនវត្ថុក៏ដោយ ។ ប្រធានតុលាការចេញដីកានេះ ដោយសំអាងទៅលើសម្រង់ សាលក្រមដែលមាន សេចក្តីសំរេចជាស្ថាពរ ។

ប៉ុន្តែ នៅពេលកំពុងអនុវត្តការដាក់គុកបង្ខំដល់រូបកាយនោះ ទណ្ឌិតបានសងធនទណ្ឌគ្រប់ចំនួនហើយ ប្រធាន-តុលាការត្រូវចេញដីកាបង្គាប់បញ្ជាអោយដោះលែងទណ្ឌិតនោះចេញពីពន្ធនាគារភ្លាម ។

**មាត្រា ៦.~**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចអនុញ្ញាតឱ្យបង្អង់អនុវត្តនូវការដាក់គុកបង្ខំដល់រូបកាយនោះបាន កាលបើទណ្ឌិត នោះមានសុខភាពមិនល្អគួរឱ្យបង្អង់ ហើយទណ្ឌិតក៏ឥតមានជាប់គុកពីបទល្មើសណាទៀតទេ ក្នុងពេលដែលឱ្យបង្អង់នេះ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងអនុញ្ញាតឱ្យបាន ក៏លុះណាតែមានភស្តុតាងច្បាស់លាស់ គឺសេចក្តីសន្និដ្ឋានរបស់ពេទ្យ ដែលពិនិត្យអាការរោគទណ្ឌិតនោះផងដែរ ។ សាមីជនអ្នកសុំអោយពេទ្យពិនិត្យនោះ ត្រូវបង់ប្រាក់ថ្លៃពិនិត្យនេះនៅ ការិយាល័យក្រឡាបញ្ជីនៃសាលាជំរះក្តីខាងលំនៅរបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចអនុញ្ញាតឱ្យបង្អង់យ៉ាងនេះបានតែក្នុងរយៈវេលាមួយខែគត់ ប៉ុន្តែ បើទណ្ឌិតបាន

សំបុត្រពេទ្យជាថ្មីទៀត ទណ្ឌិតអាចសុំឱ្យបង្អង់ម្តងមួយខែៗ បានជាដរាប ។ ការសុំបន្តម្តងៗ ទណ្ឌិតត្រូវមានសេចក្តីសន្និដ្ឋានរបស់ ពេទ្យជាថ្មីទៀតគ្រប់តែដងជាដាច់ខាត ។

**មាត្រា ៧.-**

របៀបដាក់គុកបង្ខំដល់រូបកាយ ត្រូវដាក់គុកមួយថ្ងៃក្នុងប្រាក់ជំពាក់ប្រាំរយរៀល "៥០០៛០០ ឬតិចជាងប្រាំរយរៀល"៥០០៛០០" ។ បើប្រាក់ជំពាក់នោះមានចំនួនច្រើនដល់ដប់ម៉ឺនរៀល"១០០.០០០៛០០" ការដាក់គុកនេះត្រូវគិតក្នុងមួយថ្ងៃប្រាំរយរៀល "៥០០៛០០"ៗ ដរាបអស់ប្រាក់ដប់ម៉ឺនរៀល"១០០.០០០៛០០" បើប្រាក់ជំពាក់នេះ លើសពីដប់ម៉ឺនរៀល"១០០.០០០៛០០" ទៅ ការនេះត្រូវគិតពីត្រឹមប្រាក់លើសនោះមួយពាន់រៀល"១.០០០៛០០" ក្នុងមួយថ្ងៃ ។ ប៉ុន្តែ ទោះបីប្រាក់ជំពាក់នោះមានចំនួនច្រើនយ៉ាងណាក៏ដោយក៏រយៈវេលាដែលត្រូវដាក់គុកទណ្ឌិតតែម្នាក់ឯងក្នុងរឿងតែមួយ ដោយសរុបទាំងអស់មិនត្រូវអោយលើសពី ពីរឆ្នាំទេ ។

**មាត្រា ៨.-**

បើទណ្ឌិតតែម្នាក់ ឬច្រើននាក់ជំពាក់ធនទណ្ឌ ព្រោះខ្លួនបានប្រព្រឹត្តបទល្មើសមួយបទ ឬច្រើនបទដែលត្រូវរួបរួមគ្នាសង ភាគីដើមបណ្តឹងតែម្នាក់ រយៈវេលានៃការដាក់គុកបង្ខំដល់រូបកាយ នោះត្រូវគិតដូចរបៀបខាងលើគ្រប់រូបទណ្ឌិតទាំងអស់ គឺបើគិតទៅឃើញ ២០ថ្ងៃ ត្រូវដាក់ ២០ថ្ងៃទាំងអស់គ្នា ។

បើទណ្ឌិតតែម្នាក់ ឬច្រើននាក់ជាចារីនៃបទល្មើសមួយបទ ឬច្រើនបទដែលត្រូវរួបរួមគ្នាបង់ធនទណ្ឌឱ្យភាគីដើមបណ្តឹងច្រើននាក់ រយៈពេលវេលាដាក់គុកបង្ខំដល់រូបកាយត្រូវបំបែកតាមចំនួនប្រាក់របស់ភាគីដើមបណ្តឹងម្នាក់ ៗ ឱ្យដាច់ពីគ្នា មិនត្រូវបូករួមសំណង ឬជម្ងឺចិត្តរបស់ភាគីទាំងអស់ចូលគ្នាជាចំនួនមួយនោះទេ ។

ក្នុងការដែលមានធនទណ្ឌខាងពិន័យផង ខាងជម្ងឺចិត្តផង ត្រូតគ្នាយ៉ាងនេះ រយៈវេលាដាក់គុក ត្រូវញែកប្រាក់ពិន័យ និង ប្រាក់ជម្ងឺចិត្តអោយដាច់ពីគ្នា ហើយគិតថ្ងៃដាក់គុកតាមពិន័យដោយខ្លួន តាមជម្ងឺចិត្តដោយខ្លួនកុំបូកប្រាក់ពិន័យ និង ប្រាក់ជម្ងឺចិត្តចូលគ្នាឡើយ ។

**មាត្រា ៩.-**

កាលបើទណ្ឌិតច្រើននាក់ ខ្លះចារី ខ្លះជាសហចារី ខ្លះជាអ្នកសមគំនិត ហើយត្រូវទណ្ឌកម្មឱ្យរួបរួមគ្នាសងជម្ងឺចិត្តនោះ រយៈវេលាដាក់គុកបង្ខំដល់រូបកាយត្រូវគិតទៅលើទណ្ឌិតម្នាក់ៗ នូវចំនួនថ្ងៃដាក់គុក ដូចជាទណ្ឌិតនោះត្រូវទោសតែម្នាក់ឯង គឺថា មិនត្រូវយកចំនួនប្រាក់នោះមករំលែកជាភាគចែកគ្នា ដាក់គុកតាមចំណែកសព្វខ្លួននោះបានទេ ។

រយៈវេលាដែលត្រូវដាក់គុកបង្ខំទារប្រាក់នេះទៀត ក៏មិនត្រូវបន្ថយបន្ថែមអ្វីឱ្យខុសអំពីរបៀបគិតថ្ងៃ ដូចបានពោលមកនោះទេ ។

ឯប្រាក់ពិន័យដែលតុលាការដាក់ទណ្ឌកម្មឱ្យម្នាក់ៗបង់នោះ មិនត្រូវយកចំនួនប្រាក់ពិន័យនោះបូកសរុបគ្នាបង់ទេ គឺត្រូវបង់តាមចំណែកសព្វខ្លួន ការដាក់គុកបង្ខំទារប្រាក់នោះទៀត ក៏ត្រូវដាក់គុកតាមចំណែក ប្រាក់ពិន័យសព្វខ្លួនដែរ ។

**មាត្រា ១០.-**

ជាគោលការណ៏ក្នុងរឿងព្រហ្មទណ្ឌ ដូចជាក្នុងរឿងរដ្ឋប្បវេណី ការទារធនទណ្ឌអាចនឹងធ្វើទៅបានលុះណាតែមាន រូបមន្តបង្គាប់ដែលបានកំណត់នៅក្នុងសាលក្រម ។

ក្នុងរឿងព្រហ្មទណ្ឌមិនចាំបាច់អោយមានបណ្តឹងពីភាគីដើមបណ្តឹងទេ តុលាការត្រូវតែសំរេចបង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារធនទណ្ឌ បើកូនបំណុលមិនព្រមសង ។

ក្នុងរឿងរដ្ឋប្បវេណី នៅពេលមុនសំរេចសេចក្តី ចាំបាច់ត្រូវតែមានបណ្តឹងពីភាគីដើមបណ្តឹង ទើបតុលាការឱ្យសំរេចដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ជំពាក់ កាលបើកូនបំណុលមិនព្រមសង ។ ក្នុងបទនេះ តុលាការមិនត្រូវបង្ខំ ឬណែនាំដល់កូនក្តីឱ្យប្តឹងសុំនោះទេ ។

**មាត្រា ១១.-**

ក្នុងសេចក្តីចម្លងសាលក្រម ឬសម្រង់សាលក្រមដែលត្រូវយកទៅអនុវត្តត្រូវតែមានរូបមន្តបង្គាប់ឱ្យអនុវត្តផងដាក់នៅខាងចុងសាលក្រម ឬសម្រង់សាលក្រមនេះ រូបមន្តបង្គាប់នោះមានដូចតទៅ :

"ប្រមុខរដ្ឋ នៃរដ្ឋកម្ពុជា បង្គាប់មកអ្នកអនុវត្តសាលក្រមឱ្យសំរេចតាមសាលក្រមនេះ និងឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ថ្នាក់ ជួយអនុវត្តសាលក្រមនេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់" ។

**មាត្រា ១២.-**

ជាគោលការណ៏សម្រង់សាលក្រមព្រហ្មទណ្ឌ ក្រឡាបញ្ជីត្រូវចារសំគាល់ពីអានុភាព នៃសាលក្រម ហើយស្រង់ចំនួនថ្ងៃដែលត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារធនទណ្ឌ និងស្រង់រូបមន្តដាក់នៅចុងសាលក្រមនោះផង ។ ក្នុងករណីមិន បានអនុវត្តតាមគោលការណ៏នោះទេ ក្រឡាបញ្ជីដែលចេញសម្រង់សាលក្រម ត្រូវទទួលទោសពិន័យជាប្រាក់ ប្រាំពាន់រៀល "៥.០០០៛០០" ។

រូបមន្តដែលត្រូវស្រង់ចូលមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ។

**មាត្រា ១៣.-**

កងកម្លាំងប្រដាប់អាវុធ នគរបាលប្រជាជន អង្គការរដ្ឋអំណាចមូលដ្ឋាន គ្រប់ថ្នាក់ ត្រូវជួយការងារអនុវត្តសាលក្រមឱ្យបានសំរេច កាលបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័តនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩២ នាសម័យប្រជុំលើកទី ២២ នីតិកាលទី ១ ។

ភ្នំពេញ.ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩២

ជ. រដ្ឋសភា

ប្រធាន

***<u>បញ្ជាក់</u>*** ច្បាប់នេះ ត្រូវបាននិរាករណ៏ដោយតុល្យភាព ដោយក្រមនីតិវិធីព្រហ្មទណ្ឌ។

តាមពិត ទាំងច្បាប់ឆ្នាំ ១៩៩២ ទាំងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ ជាបទបញ្ញត្តិដែលមិនផ្ទុយនឹងរដ្ឋធម្មនុញ្ញ តាមរយៈមាត្រា ១១ នៃកាតិកាសញ្ញាឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកំណត់ថា "... គ្មានជនណាម្នាក់ត្រូវគេចាប់ដាក់គុក ដោយសារតែខ្លួនមិនអនុវត្តកិច្ចសន្យាទេ" ដូចការអះអាងរបស់មេធាវីមួយចំនួន ទេ ព្រោះដែនអនុវត្តនៃមាត្រា ១១ នេះ គឺអនុវត្តចំពោះតែរឿងក្តីរដ្ឋប្បវេណី ឬ "កាតព្វកិច្ចកើតចេញពីកិច្ចសន្យា" ប៉ុណ្ណោះ។ អ្វីដែលគួរឱ្យកត់សំគាល់មួយទៀតគឺ ក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឱ្យព្រះរាជអាជ្ញាជាអ្នកដើរតួនាទី អនុវត្តការបង្ខំដល់រូបកាយ ដោយមិនចាំបាច់ឆ្លងកាត់ចៅក្រមទេ (អ្នកអនុវត្តទោស ?)។

<u>*សំណួរត្រិះរិះ:*</u>

តើការបង្ខំដល់រូបកាយ ត្រូវធ្វើនៅពេលណា ? ពេលទណ្ឌិតកំពុងអនុវត្តទោសក្នុងពន្ធនាគារ ហើយត្រូវបន្តដោយការបង្ខំដល់រូបកាយ ឬ ក៏ចាំពេលចាកចេញពីពន្ធនាគារសិន សុំអនុវត្តជាក្រោយ ?

### ខ. ការដោះលែងដោយមានលក្ខខណ្ឌ

ជាគោលការណ៍ការដោះលែងមិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើទណ្ឌិតមិនទាន់អនុវត្តទោស ចប់។ តែក្នុងករណីមួយចំនួន ទណ្ឌិតអាចត្រូវបានដោះលែងមុនពេលកំណត់បាន ក្នុងលក្ខខណ្ឌគ្រឹះដូចខាងក្រោម :

១.លក្ខខណ្ឌទាក់ទងនឹងគំនិតមារយាទ(មាត្រា ៥១២ ក្រមនីតិវិធីព្រហ្មទណ្ឌ[៥២]).-គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនេះបានបង្ហាញឱ្យ ឃើញថាខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។

២.លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចរាល់ហើយ(មាត្រា ៥១៣).-ការដោះលែងដោយមានលក្ខខណ្ឌអាចត្រូវផ្តល់ឱ្យដល់ទណ្ឌិតដែលទទួលរងទោសជាប់ពន្ធនាគារ :

- ចំនួនពាក់កណ្តាលនៃទោស ប្រសិនបើទោសនោះតិចជាង ឬស្មើ ១ ឆ្នាំ
- ចំនួនពីរភាគបីនៃទោស ក្នុងករណីផ្សេងទៀត។

ទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតបានទទួល ទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត ២០ ឆ្នាំ រួចមកហើយ។

៣.នីតិវិធី និងសេចក្តីសម្រេច

[៥២] មាត្រាបន្តបន្ទាប់ ក្នុងផ្នែក "ខ" នេះ ជាមាត្រា នៃក្រមនីតិវិធីព្រហ្មទណ្ឌ លើកលែងមានកំណត់ផ្សេងពីនេះ។

៣.១ អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ផ្តល់ការដោះលែងដោយមានលក្ខខណ្ឌ(មាត្រា ៥១៤): ការដោះលែងដោយមានលក្ខខណ្ឌ ត្រូវផ្តល់ឱ្យដោយប្រធានតុលាការជាន់ដំបូងនៃទីកន្លែងឃុំខ្លួន។ ប្រធានតុលាការនេះសម្រេច ក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិ ដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌ ។

គណៈកម្មការជាតិរួមមាន :

-សមាជិក ២រូប ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែល ១រូប ជាប្រធាន

-ប្រធានពន្ធនាគារ ឬតំណាង ជាសមាជិក។

៣.២ យោបល់របស់គណៈកម្មការជាតិ(មាត្រា ៥១៥): ក្រោយពីបានទទួលពាក្យសុំដោះលែង ដោយមានលក្ខខណ្ឌ ប្រធានតុលាការជាន់ដំបូងបញ្ជូនទៅគណៈកម្មការជាតិនូវ :

១.ពាក្យសុំ

២.សាលក្រម ឬ សាលដីកាផ្តន្ទាទោស

៣.ជាយថាហេតុសាលក្រម និងសាលដីកាទាំងឡាយ ប្រសិនបើទណ្ឌិតទទួលទោសច្រើន

៤.ព្រឹត្តិបត្រលេខ១ នៃបញ្ជី ថ្កោលទោស

៥.យោបល់ព្រះរាជអាជ្ញា និង

៦.គ្រប់លិខិតទាំងអស់ដែលមានប្រយោជន៍ ។

គណៈកម្មការជាតិបញ្ចេញយោបល់របស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត។ យោបល់នេះ ធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវផ្ញើជូនទៅប្រធានតុលាការជាន់ដំបូងភ្លាម ។

៣.៣ សេចក្តីសម្រេចទាក់ទងនឹងការដោះលែងដោយមានលក្ខខណ្ឌ(មាត្រា ៥១៦): ប្រធានតុលាការជាន់ដំបូងមិនត្រូវជាប់ជំពាក់នឹងយោបល់របស់គណៈកម្មការជាតិទេ។ ប្រធានតុលាការសម្រេចតាមដីកាដោយមានសំអាងហេតុ។ សេចក្តីសម្រេចរបស់ប្រធានតុលាការនេះ អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បាន ក្នុងរយៈពេល ៥ ថ្ងៃ។ បណ្តឹងតវ៉ានេះ អាចធ្វើបានដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញានៃ តុលាការសាមី តែប៉ុណ្ណោះ។ កាលណាប្រធានតុលាការជាន់ដំបូងបង្គាប់ឱ្យដោះលែងដោយមានលក្ខខណ្ឌ សេចក្តីសម្រេចនេះ គ្មានអានុភាពអនុវត្តទេ នៅក្នុងរយៈពេល ៥ថ្ងៃ។ ប្រសិនបើមានការតវ៉ា សេចក្តីសម្រេចនេះ គ្មានអានុភាពអនុវត្តទេ រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍។

ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាដោយមានសំអាងហេតុ និងមិនអាចតវ៉ាបានឡើយ។

៤.បែបបទនៃការអនុវត្តនិងលក្ខខណ្ឌនៃការដោះលែងដោយមានលក្ខខណ្ឌ(មាត្រា ៥១៧): សេចក្តីសម្រេចឱ្យដោះលែងដោយមានលក្ខខណ្ឌ ត្រូវកំណត់បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិត។ សេចក្តីសម្រេចនេះកំណត់រយៈពេលសាកល្បង ដែលមិនអាចលើសពីថិរវេលានៃទោស ដែលនៅសល់មិនទាន់បានទទួលរងឡើយ។ បែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅ

ក្នុងសង្គមវិញនៃទណ្ឌិតដែលដោះលែង ដោយមានលក្ខខណ្ឌត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តធម៌។ ប្រកាសនេះ អាចប្រគល់ឱ្យស្ថាប័ន សាធារណៈ ឬឯកជននូវការយកចិត្តទុកដាក់ធានារ៉ាប់រងលើការបញ្ចូលទណ្ឌិតទៅក្នុងសង្គមវិញ(ម.៥២២)។ ប្រសិនបើការដោះលែងដោយមានលក្ខខណ្ឌ មិនត្រូវបានដកហូតក្នុងរយៈពេលសាកល្បងទេ លុះផុតរយៈពេលសាកល្បង ការដោះលែងក្លាយទៅជាស្ថាពរ ក្នុងករណីនេះទោសត្រូវចាត់ទុកថាបានទទួល តាំងពីថ្ងៃដោះលែងដោយមាន លក្ខខណ្ឌមកម្ល៉េះ (មាត្រា ៥២១)។

**ការដកហូតសេចក្តីសម្រេច**(មាត្រា ៥១៨)._ក្នុងករណីមានការផ្តន្ទាទោសជាថ្មី ឬក្នុងករណីមិនគោរពលក្ខខណ្ឌដែលកំណត់ដោយដីកាទេ ប្រធានតុលាការជាន់ដំបូងអាចដកហូតសេចក្តីសម្រេចរបស់ខ្លួនវិញបាន។ ក្នុងករណី ដកហូតការដោះលែងដោយមានលក្ខខណ្ឌ ទណ្ឌិតត្រូវទទួលទោសរបស់ខ្លួនដែលនៅសេសសល់។ រយៈពេលសេសសល់ ត្រូវគិតចាប់ពីពេលដែលទណ្ឌិតបានទទួលសេចក្តីសម្រេចឱ្យដោះលែងដោយមានលក្ខខណ្ឌ។ ប្រសិនបើទណ្ឌិតត្រូវបានចាប់ខ្លួន រយៈពេលឃុំខ្លួនរហូតមកទល់នឹងសេចក្តីសម្រេចដកហូតការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវយកមកគិតក្នុងថិរវេលានៃទោសដែលនៅសេសសល់(មាត្រា ៥២០)។

**ការចាប់ខ្លួនទណ្ឌិតដែលត្រូវបានដោះលែង**._ក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការសាមី អាចបង្គាប់ឱ្យចាប់ខ្លួនទណ្ឌិតដែលបានដោះលែងនោះបាន។ ព្រះរាជអាជ្ញា ត្រូវជូនដំណឹងដល់ប្រធានតុលាការជាន់ដំបូងភ្លាម។

ការសិក្សាប្រៀននឹងការលូតលាស់របស់រុក្ខជាតិមួយដើម ។ តើចង់ងាយដួលរលំ ឬចង់រឹងមាំ ?

## ផ្នែកទី ៤ ការលុបលាងទោស និង កំណត់ត្រាការផ្តន្ទាទោសនិងការអនុវត្តទោស

ជាគោលការណ៍ គ្រប់ការផ្តន្ទាទោសព្រហ្មទណ្ឌ និងរដ្ឋប្បវេណី(ការប្រកាសក្ស័យធន និងការជម្រះបញ្ជីទ្រព្យសម្បត្តិ ឬការជម្រះបញ្ជីតាមផ្លូវតុលាការ) និងឧប្បត្តិហេតុជុំវិញការអនុវត្តទោស ការដោះលែងដោយមានលក្ខខណ្ឌ ការបង្ខំដល់រូបកាយ និងការផ្តល់នីតិសម្បទាឡើងវិញ ត្រូវកត់ត្រា ក្នុងលិខិតបញ្ជាក់មួយប្រភេទ ចេញដោយក្រសួងយុត្តិធម៌ ដែលត្រូវបានគេស្គាល់ថាជា "លិខិតថ្កោលទោស"។

ការលុបលាងទោស ឬបើតាមក្រមនីតិវិធីព្រហ្មទណ្ឌ "ការមាននីតិសម្បទាឡើងវិញ"(មាតិកាទី ៤ នៃគន្ថីទី ៨ ពីមាត្រា ៥៣៤ ដល់មាត្រា ៥៤០_ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ និងមាត្រា ៥៤១_បញ្ញត្តអំពីការមាននីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់) សំដៅដល់ការលាងទោសកំហុសទណ្ឌិតដែលត្រូវបានផ្តន្ទាទោសតាមសេចក្តីសម្រេចផ្តន្ទាទោសដែលបានចូលជាស្ថាពររួចហើយ ដើម្បីឱ្យក្លាយជាមនុស្សស្អាតស្អំ និងមានសិទ្ធិពលរដ្ឋពេញលេញឡើងវិញ។ មានន័យថា ក្រោយពេលអនុវត្តទោសក្នុងពន្ធនាគារចប់សព្វគ្រប់ និងក្នុងចិរវេលាមួយបានកន្លងហួស ទណ្ឌិតត្រូវទទួលបាននូវភាពជាមនុស្សស្អាតស្អំ និងមានសិទ្ធិពលរដ្ឋពេញលេញឡើងវិញ។ ការលុបលាងទោសនេះ ពុំមានអានុភាពដូច បណ្តឹងសើរើទេ ព្រោះទណ្ឌិតនៅតែជាប់ឈ្មោះថាបានប្រព្រឹត្តបទល្មើស ហើយនៅតែជាប់កំណត់ត្រាទោស ក្នុងបញ្ជីលិខិតថ្កោលទោស ដូចមានចែងយ៉ាងច្បាស់ក្នុងមាត្រា ៥៥២ ក្រមនីតិវិធីព្រហ្មទណ្ឌ ថា "ការផ្តល់នីតិសម្បទាឡើងវិញ លុបលាងទណ្ឌកម្មព្រហ្មទណ្ឌ។ ក៏ប៉ុន្តែ ទោសនេះនៅតែមានចុះនៅក្នុងបញ្ជីថ្កោលទោសដដែលដោយមានចុះនិទ្ទេសថា ត្រូវបាននីតិសម្បទាឡើងវិញ"។ ព្រោះក្នុងបណ្តឹងសើរើ តុលាការកំពូលផ្តល់ភាពស្អាតស្អំ ជូនទណ្ឌិតដែលត្រូវបានតុលាការ ផ្តន្ទាទោសដោយភាន់ច្រឡំ។

**មនុស្សខុសពីដើមឈើ ហើយការលូតលាស់ ដុះដាលនៃចំណោះក៏ខុសពីដើមឈើដែរ ។**

## កថាខណ្ឌទី ១ ការលុបលាងការផ្តន្ទាទោស ឬការផ្តល់នីតិសម្បទាឡើងវិញ

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ការលុបលាងទោសអាចធ្វើតាមផ្លូវតុលាការ ឬដោយពេញលក្ខណៈច្បាប់ ទៅតាមលក្ខខណ្ឌកំណត់។

### ក.-ការលុបលាងទោស ឬការផ្តល់នីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ នីតិសម្បទាត្រូវមានឡើងវិញ ដោយពេញលក្ខណៈច្បាប់ នៅក្នុងករណី ដូចតទៅ

-នៅពេលផុតរយៈពេល ៥ ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីដែលបុគ្គលនោះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពី ៥ ឆ្នាំ ទេ ឬក៏ផ្តន្ទាទោសពិន័យ។

-នៅពេលផុតរយៈពេល ១០ ឆ្នាំ គិតពីថ្ងៃអនុវត្តទោសរួចហើយ ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល ក្នុងករណីដែលបុគ្គលនោះ ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ៥ ឆ្នាំ។

### ខ.-ការលុបលាងទោស ឬការផ្តល់នីតិសម្បទាឡើងវិញដោយតុលាការ

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ក្រៅពីការលុបលាងទោសដោយពេញលក្ខណៈច្បាប់ ទណ្ឌិតក៏អាចស្នើសុំឱ្យតុលាការផ្តល់នូវភាពស្អាតស្អំ និងផ្តល់សិទ្ធិពលរដ្ឋឱ្យខ្លួនវិញ តាមរយៈបណ្តឹងសុំឱ្យផ្តល់នីតិ-សម្បទាឡើងវិញ ប្រសិនបើបំពេញលក្ខខណ្ឌនីត្យានុកូល ហើយត្រូវធ្វើទៅតាមនីតិវិធី កំណត់ដោយច្បាប់។

១-លក្ខខណ្ឌសារធាតុ ឬលក្ខខណ្ឌគ្រឹះ

លក្ខខណ្ឌរយៈពេល ទាក់ទងនឹងពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ.-ពាក្យសុំឱ្យមាននីតិ-សម្បទាឡើងវិញ អាចនឹងដាក់ជូនសភាព្រហ្មទណ្ឌពិនិត្យបាន លុះត្រាតែ ផុតរយៈពេលដូចតទៅ :

-៥ ឆ្នាំ ចំពោះបទឧក្រិដ្ឋ

-៣ ឆ្នាំ ចំពោះបទមជ្ឈិម

-១ ឆ្នាំ ចំពោះបទលហុ ។

រយៈពេលនេះចាប់ផ្តើមគិត :

-ពីការអនុវត្តទោសរួច

-ពីការអនុវត្តការបង្ខំដល់រូបកាយរួច នៅក្នុងករណីដែលមានចែងនៅក្នុងកថាខ័ណ្ឌ ទី២ មាត្រា ៥៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ការផ្តល់ភស្តុតាងចាំបាច់.-ទណ្ឌិតត្រូវជូនភស្តុតាងដែលបញ្ជាក់ថា ខ្លួនបានបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និងជម្ងឺចិត្តរួចហើយ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបានបោះបង់ ចោលមិនទារប្រាក់សំណង និងជម្ងឺចិត្តទេ ទណ្ឌិតត្រូវផ្តល់ការបញ្ជាក់អំពីការបោះបង់នេះ លើកលែងតែរកដើម-បណ្តឹងរដ្ឋប្បវេណីមិនឃើញ ។

ប្រសិនបើទណ្ឌិតត្រូវបានបង្ខំដល់រូបកាយ ការមិនបង់ប្រាក់ពិន័យ ប្រាក់ពន្ធនៃនីតិវិធី ឬប្រាក់សំណង និងជម្ងឺចិត្ត មិនមែនជាឧបសគ្គដល់ការឱ្យមាននីតិសម្បទាឡើងវិញទេ ប្រសិនបើទណ្ឌិតជូនភស្តុតាងថាខ្លួនស្ថិតក្នុងភាពអសាធនី ។

ប្រសិនបើអ្នកប្តឹងសុំត្រូវបានផ្តន្ទាទោសពីបទនិទ្ធនភាព សាមីខ្លួនត្រូវជូនភស្តុតាងដែលបញ្ជាក់ថា បានទូទាត់ប្រាក់បំណុលនៃការក្ស័យធនរួចហើយ ។ ប្រសិនបើម្ចាស់បំណុលបានបោះ បង់ចោលមិនឱ្យទូទាត់ប្រាក់បំណុលនេះទេ ទណ្ឌិតត្រូវផ្តល់ការបញ្ជាក់ពីការបោះបង់នេះ ។

## ២-លក្ខខណ្ឌនីតិវិធី

ការផ្តល់នីតិសម្បទាឡើងវិញ ជាសមត្ថកិច្ចរបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានការប្រកាសផ្តន្ទាទោសដោយតុលាការនៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍នេះ(មាត្រា ៥៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ)។

ទណ្ឌិតធ្វើពាក្យសុំឱ្យមានការផ្តល់នីតិសម្បទាឡើងវិញ ជូនទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។ ទណ្ឌិតត្រូវចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅតាំងពីពេលដែលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។

ព្រះរាជអាជ្ញាចាត់ធ្វើការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែង ដែលទណ្ឌិតធ្លាប់បានរស់នៅតាំងពីពេលខ្លួនត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ។

ព្រះរាជអាជ្ញាសុំឱ្យគេប្រគល់មកខ្លួននូវ :

-លិខិតចម្លងនៃសេចក្តីសម្រេចផ្តន្ទាទោស

-លិខិតជូនដំណឹងអំពីកាលបរិច្ឆេទនៃការអនុវត្តទោសរួចហើយ

-ព្រឹត្តិបត្រលេខ ១ នៃបញ្ជីថ្កោលទោស ។

ព្រះរាជអាជ្ញាបញ្ជូនសំណុំរឿង ដោយមានយោបល់ដែលមានសំអាងហេតុរបស់ខ្លួនភ្ជាប់ជាមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាប្តឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្តឹងសុំ និងដល់មេធាវី ។

តុលាការត្រូវសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់ទណ្ឌិត មេធាវី និង អគ្គព្រះរាជអាជ្ញា។

ក្នុងករណីដែលតុលាការបដិសេធពាក្យសុំ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀត មុនផុត រយៈពេល ២ ឆ្នាំ បានឡើយ ។

ប៉ុន្តែប្រសិនបើពាក្យសុំលើកទី ១ ត្រូវបានតុលាការបដិសេធមកពីមិនគោរពរយៈពេលដែលចែង នៅមាត្រា ៥៣៥ នៃក្រមក្រមនីតិវិធីព្រហ្មទណ្ឌ ពាក្យសុំថ្មីអាចធ្វើបានចាប់ពីផុតរយៈពេលនោះ ។

## កថាខណ្ឌទី ២ កំណត់ត្រាការផ្តន្ទាទោសនិងការអនុវត្តទោស : បញ្ជីថ្កោលទោស

បញ្ជីថ្កោលទោសត្រូវបានកាន់កាប់ដោយអង្គភាពមួយនៃក្រសួងយុត្តិធម៌ គឺការិយាល័យថ្កោលទោស ស្ថិតក្រោយនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ។ ការិយាល័យថ្កោលទោសចេញព្រឹត្តិបត្រថ្កោលទោស ឱ្យទៅ បុគ្គលដែលទាមទារ ត្រឹមត្រូវទៅតាមនីតិវិធីនៃច្បាប់ ដើម្បីយកទៅប្រើប្រាស់ និងជាបន្ទាល់អនុញ្ញាតឱ្យ អនុវត្តសិទ្ធិពលរដ្ឋ ឬសម្រាប់តុលាការ ឬអាជ្ញាធរពាក់ព័ន្ធបន្តអនុវត្តច្បាប់ចំពោះជនល្មើស។ ព្រឹត្តិបត្រថ្កោល ទោសជាសំរង់នៃនិទ្ទេសទាំងអស់ ឬមួយផ្នែកដែលមានចុះនៅក្នុង បញ្ជីថ្កោលទោសចំពោះបុគ្គលណាម្នាក់ ជាកំណត់(មាត្រា ៥៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ) ដោយរួមទាំងនីតិបុគ្គលផងដែរ[៥៣] ។

បច្ចុប្បន្ន ក្រុមហ៊ុន អង្គការមិនមែនរដ្ឋាភិបាល ស្ថានទូត និងជារឿងធម្មតាសម្រាប់អង្គភាពរដ្ឋ ... បាននឹងកំពុងជំរុញឱ្យមានការប្រើប្រាស់យ៉ាងទូលំទូលាយនូវព្រឹត្តិបត្រថ្កោលទោស ដោយដាក់ជាលក្ខខណ្ឌ បឋមក្នុងការអនុញ្ញាតឱ្យមានសិទ្ធិប្រឡងប្រជែងបញ្ចូលក្របខណ្ឌមន្ត្រីរាជការសាធារណៈ ឬការជ្រើសរើស ជាបុគ្គលបម្រើការងារ ដើម្បីចៀសវាងបញ្ហាទៅថ្ងៃក្រោយ។ ច្បាប់មួយចំនួនធំ ហាមឃាត់ជនដែលធ្លាប់ ត្រូវតុលាការផ្តន្ទាទោសជាស្ថាពរ មិនឱ្យប្រកបមុខរបរ ឬការងារឯកជន។

អ្វីដែលគួរឱ្យបារម្ភទាក់ទងនឹងព្រឹត្តិបត្រថ្កោលទោស គឺសច្ចភាពលិខិតដែលចេញឱ្យ ដោយសារតែ មូលហេតុពីរយ៉ាង។ ទី ១ ការខ្វះតម្លាភាព និងគណនេយ្យភាព ដែលមានប្រភពចេញពីកង្វះការចងក្រង សេចក្តីសម្រេចតុលាការព្រហ្មទណ្ឌ ជាប្រព័ន្ធ Database ហើយលិខិតចេញមកដោយការបើកមើលលើ

[៥៣] មាត្រា ៥៤៥ : បញ្ជីថ្កោលទោសត្រូវទទួលចុះសលាកបត្រទាំងឡាយដែលបញ្ជាក់ពីការផ្តន្ទាទោសគ្រប់ប្រភេទ ដោយតុលាការព្រហ្មទណ្ឌចំពោះនីតិបុគ្គល ។

ឯកសារសំណៅពិតជាមិនអាចគ្រប់ជ្រុងជ្រោយទេ។ ទី ២ មន្ទិលជុំវិញរយៈពេលចេញព្រឹត្តិបត្រដែលខ្លីតើភាពជឿជាក់យ៉ាងដែលយើងគួរតែមានលើព្រឹត្តិបត្រ បើគ្មានប្រព័ន្ធ Database ផង ? ហើយអំពើមិនប្រក្រតីក៏អាចកើតដោយសារអំពើពុករលួយផងដែរ។

ជាទូទៅ កម្ពុជាទទួលបន្ទុកកាន់កាប់តែជនជាតិខ្មែរទេ តែជនបរទេសដែលមករស់នៅ ឬបំពេញការងារនៅកម្ពុជា ក៏អាចស្នើសុំការិយាល័យថ្កោលទោសនៃក្រសួងយុត្តិធម៌ឱ្យចេញព្រឹត្តិបត្រថ្កោលទោសដើម្បីយកទៅប្រើប្រាស់បានផងដែរ។ មាត្រា ៥៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គូសបញ្ជាក់បន្ថែមថា បញ្ជីថ្កោលទោសក៏ទទួលផងដែរនូវសលាកបត្រដែលទាក់ទងនឹង :

-បុគ្គលដែលកើតនៅឯកបរទេស

-បុគ្គលដែលអត្តសញ្ញាណមិនអាចផ្ទៀងផ្ទាត់មើលបាន ឬដែលគួរឱ្យសង្ស័យ។ ក្នុងករណីនេះ ត្រូវចុះនិទ្ទេសពិសេសនៅក្នុងបញ្ជីថ្កោលទោសថាអត្តសញ្ញាណមិនអាចផ្ទៀងផ្ទាត់មើលបាន ឬដែលគួរឱ្យសង្ស័យ។

ដើម្បីសម្រេចគោលដៅនេះ ច្បាប់តម្រូវឱ្យ :

-ក្រឡាបញ្ជីតុលាការ ផ្ញើជូនអង្គភាពនៃក្រសួងយុត្តិធម៌ទទួលបន្ទុកចេញព្រឹត្តិបត្រថ្កោលទោស ក្រោមការត្រួតពិនិត្យរបស់ប្រធានតុលាការ នូវសលាកបត្រចំពោះសេចក្តីសម្រេចនីមួយៗដែលត្រូវចុះក្នុងបញ្ជីថ្កោលទោស។

-ប្រធានពន្ធនាគារជូនដំណឹងដល់អង្គភាពបញ្ជីថ្កោលទោសអំពីកាលបរិច្ឆេទនៃការអនុវត្តទោស ឬការបង្ខំដល់រូបកាយ រួចរាល់ហើយ។

-អង្គភាពរតនាគារជូនដំណឹងដល់អង្គភាពបញ្ជីថ្កោលទោសអំពីការបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនីតិវិធី

-អង្គភាពបញ្ជីថ្កោលទោសរ៉ាប់រងទទួលព័ត៌មានអំពីវិធានការលើកលែងទោស និងបន្ធូរបន្ថយទោសដែលប្រទានដោយព្រះមហាក្សត្រ និងសេចក្តីសម្រេចបណ្តេញជនបរទេស។

ចំពោះបុគ្គលដែលកើតនៅកម្ពុជា បញ្ជីថ្កោលទោសនេះ ទទួលសលាកបត្រដែលកត់ត្រា :

-គ្រប់ការផ្តន្ទាទោសចំពោះមុខ ការផ្តន្ទាទោសដែលទុកជាចំពោះមុខ និងការផ្តន្ទាទោស ដោយកំបាំងមុខទាំងអស់ដែលត្រូវបានប្រកាសដោយតុលាការព្រហ្មទណ្ឌកម្ពុជា

-ការផ្តន្ទាទោសដែលត្រូវបានប្រកាសដោយតុលាការបរទេស ហើយដែលអនុវត្តតាមកិច្ចព្រមព្រៀងអន្តរជាតិ ត្រូវបានជូនដំណឹងមកដល់អាជ្ញាធរកម្ពុជា

-វិធានការលើកលែងទោស និងបន្ធូរបន្ថយទោស ដែលប្រទានដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សេចក្តីសម្រេចក្នុងរឿងដោះលែងដោយមានលក្ខខណ្ឌ

-សេចក្តីសម្រេចស្តីពីការបង្ខំដល់រូបកាយ

-សាលក្រម ឬសាលដីកាដែលប្រកាសការក្ស័យធន

-សេចក្តីសម្រេចឱ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

-សេចក្តីសម្រេចបណ្តេញជនបរទេស ។

កាលណាទណ្ឌិតបានទទួលទោសពន្ធនាគារ ឬការបង្ខំដល់រូបកាយរួចរាល់ហើយ កាលបរិច្ឆេទនៃការអនុវត្តទោស ឬការបង្ខំដល់រូបកាយនេះ ត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីថ្កោលទោស។

កាលណាទណ្ឌិតបានបង់ប្រាក់ពិន័យ និងប្រាក់ពន្ធនៃនីតិវិធី កាលបរិច្ឆេទនៃការបង់ប្រាក់ នេះត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីថ្កោលទោស ។

កាលណាការផ្តន្ទាទោសណាមួយត្រូវបានទទួលនីតិសម្បទាជាថ្មីដោយពេញលក្ខណៈច្បាប់ នោះនិទ្ទេសនេះត្រូវចុះនៅក្នុងបញ្ជីថ្កោលទោស។

ត្រូវដកចេញពីបញ្ជីថ្កោលទោស :

-ការផ្តន្ទាទោសដែលសម្រេចដោយកំបាំងមុខ កាលណាការផ្តន្ទាទោសនេះត្រូវទុកជាអសារបង់បន្ទាប់ពីមានបណ្តឹងទាស់

-ការផ្តន្ទាទោសដែលត្រូវបានលុបលាងដោយការលើកលែងទោសជាទូទៅ

-ការផ្តន្ទាទោសដែលកើតមកដោយការភន្តច្រឡំអត្តសញ្ញាណ

-ការផ្តន្ទាទោសដែលត្រូវបានចាត់ទុកជាអសារបង់ដោយនីតិវិធីនៃបណ្តឹងសើរើ។

ព្រឹត្តិបត្រថ្កោលទោសមានបីប្រភេទ :

<u>*ទី ១.ព្រឹត្តិបត្រលេខ ១*</u> នៃបញ្ជីថ្កោលទោស រួមមាននិទ្ទេសទាំងអស់ដែលចុះនៅក្នុងបញ្ជីថ្កោល ទោសបុគ្គលនីមួយៗ ។ ព្រឹត្តិបត្រលេខ ១ អាចចេញឱ្យដល់អាជ្ញាធរតុលាការតែប៉ុណ្ណោះ។

<u>*ទី ២. ព្រឹត្តិបត្រលេខ ២*</u> មាននិទ្ទេសទាំងអស់ដែលចុះនៅក្នុងព្រឹត្តិបត្រលេខ ១ លើកលែងតែ :

-ការផ្តន្ទាទោស ដែលត្រូវបានលុបបំបាត់ដោយការផ្តល់នីតិសម្បទាឡើងវិញតាម ផ្លូវតុលាការ ឬ ដោយពេញលក្ខណៈច្បាប់

-ការផ្តន្ទាទោសព្យួរដោយគ្មានការដកហូត

-សាលក្រម ឬសាលដីកាដែលប្រកាសការក្ស័យធនក្នុងករណីទទួលបាននីតិសម្បទាឡើងវិញ។

ព្រឹត្តិបត្រលេខ ២ ត្រូវចេញឱ្យដល់ :

-អាជ្ញាធរតុលាការ

-អាជ្ញាធរយោធាដែលទទួលពាក្យសុំចូលបំរើក្នុងកងទ័ព

-ភ្នាក់ងារដែលកាន់បញ្ជីពាណិជ្ជកម្ម

ព្រឹត្តប័ត្រលេខ ២ នេះក៏អាចត្រូវចេញឱ្យដល់អភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋផងដែរ :

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋបានទទួលពាក្យសុំធ្វើការងាររដ្ឋ

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋ បានទទួលពាក្យស្នើស្តីពីការងារសាធារណៈ ឬ អាបណសញ្ញា(លទ្ធកម្ម)សាធារណៈ

-កាលណាអភិបាលខេត្ត ក្រុង និងអង្គភាពរដ្ឋបានទទួលពាក្យសុំបើកគ្រឹះស្ថានដែល ត្រូវតែមានការអនុញ្ញាត

-នៅក្នុងក្របខ័ណ្ឌនៃនីតិវិធីខាងវិន័យ ។

*ទី ៣-ព្រឹត្តិបត្រលេខ ៣* មានចុះតែការផ្តន្ទាទោសជាប់ពន្ធនាគារដោយគ្មានការព្យួរទោស ដែលប្រកាសទៅលើបុគ្គលណាមួយពីបទឧក្រិដ្ឋ ឬបទមជ្ឈិមប៉ុណ្ណោះ។ ប៉ុន្តែ ការផ្តន្ទាទោសដែលបានទទួលនីតិសម្បទាឡើងវិញហើយ គ្មានចុះក្នុងព្រឹត្តិបត្រលេខ ៣ ទេ ។

ព្រឹត្តិបត្រលេខ ៣ ត្រូវចេញឱ្យដល់សាមីជនដែលពាក់ព័ន្ធ ។ ក្នុងករណីណាក៏ដោយ ព្រឹត្តិបត្រលេខ ៣ មិនត្រូវចេញឱ្យដល់តតិយជនទេ ។

**ការកែតម្រូវបញ្ជីថ្កោលទោស.**-កាលណាបុគ្គលណាមួយត្រូវបានផ្តន្ទាទោស ដោយមានការខុសអត្តសញ្ញាណ អយ្យការត្រូវតែសុំឱ្យធ្វើការកែតម្រូវបញ្ជីថ្កោលទោសភ្លាម។

"មើលសត្វកណ្តៀរកពូនដី
មើលសត្វបក្សីក្រងសំបុក
មើលឃ្មុំជាដើមសាងក្តីសុខ
ព្យាយាមសំរុកបានសម្រេច។
ទឹកស្រក់តក់ៗទំលុះថ្ម
រលកតៗថ្មសិកដាច់
កាន់ការងារអ្វីត្រូវប្តូរផ្តាច់
ផលល្អសម្រេចព្រោះព្យាយាម។"

ដោយធម្មាចារ្យ **ប៊ុត សាវង្ស**

# ចប់

# ឯកសារពិគ្រោះ


១-បណ្ឌិត ហ៊ែល ចំរើន *មរតកយុត្តិធមិខ្មែរ* ឆ្នាំ ២០០៩-២០១០

២-សន្និសីទស្ដីពីសេចក្ដីព្រាងក្រមព្រហ្មទណ្ឌរៀបចំដោយរដ្ឋសភាកាលពីថ្ងៃទី ២៣ កញ្ញា ២០០៩ (គន្លឹទី ១ បទប្បញ្ញាត្តិទូទៅ)

៣-សន្និសីទបើកឱ្យប្រកាសផ្សាយក្រមព្រហ្មទណ្ឌនៅសណ្ឋាគារ Intercontinental នាថ្ងៃទី ១០ មីនា ២០១០

៤-ឯកសារបណ្ដុះបណ្ដាលក្រមព្រហ្មទណ្ឌរបស់ក្រសួងយុត្តិធមិ និងក្រមពិភាក្សាព្រហ្មទណ្ឌ

៥-សៀវភៅនីតិព្រហ្មទណ្ឌរបស់លោក ហ្សង់រ៉ូ រ៉ាកេន

៦-ក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០ និងអត្ថបទច្បាប់ទាក់នឹងវិស័យព្រហ្មទណ្ឌ

៧-សៀវភៅ *វិធីសាស្ត្រគតិយុត្ត-នីតិកម្ពុជា*- បោះពុម្ពផ្សាយដោយសមាគមដើម្បីច្បាប់ខ្មែរ ឆ្នាំ ២០០៦។

៨-សៀវភៅនីតិព្រហ្មទណ្ឌទូទៅរបស់លោក សេង នាង បោះពុម្ពផ្សាយដោយសាកលវិទ្យាល័យបៀលប្រាយ

9-Jean Pradel, *Droit pénal général*, éd. CUJAS, 2004-2005

10-Frédéric Desportes et François Le Gunehec, *Le nouveau droit pénal, T.1 Droit pénal général*, 7e éd. Economica, 2009

11-Jean-Claude Soyer, *Droit pénal et procédure pénal*, 14e éd. LGDJ, 1999

12-Michel Bonnieu et Elisabeth Catta, *Aspects techniques de la codification : l'expérience du nouveau code pénal et du nouveau code de procédure pénale cambodgiens*, ក្នុងឱកាសនៃ សន្និសីទបើកឱ្យប្រកាសផ្សាយក្រមព្រហ្មទណ្ឌនៅសណ្ឋាគារ Intercontinental នាថ្ងៃទី ១០ មីនា ២០១០

13-Thomas W. Simon, *Law and philosophy. An introduction with readings*, McGraw-Hill ed., chapter 6: Rights and chapter 8: Responsibility and Punishment (Criminal law).

14-Les Fiches de TD Droit pénal général, URDSE, Pôle de coopération française, chargé par SE Veng

15-Les sites de légifrance et de la Cour de cassation française, Chambre criminelle.